

## សុខាភិយាចនគាថា

ពុទ្ធំសុមាលី ទិបទុត្តមោ តមោ
ហន្ត្វាន ពោធេសិធ បឡូដំ ភដំ
មគ្គគ្គសេលម្ហិ សុខុដ្ឋិតោ ឋិតោ
សោ មំ ចិរំ បាតុ សុខំ សទា សទា ។

| | |
|---|---|
| ព្រះពុទ្ធដូចអាទិត្យ | ឧត្តមពិតជាងពួកជន |
| កំចាត់នូវមោហន្ធ | ហើយចេញចាកសព្វកិលេស ។ |
| ទ្រង់ឋិតនៅលើភ្នំ | ដ៏ឧត្តមមគ្គវិសេស |
| ដាស់សត្វជាប់កិលេស | ឲ្យភ្លឺថៃសក្នុងលោកា ។ |
| សូមទ្រង់ប្រោសគ្រប់គ្រង | យើងខ្ញុំផងរាល់វេលា |
| ឲ្យបានសុខគ្រប់គ្នា | អស់កាលយូរអង្វែងទៅ ។ |

សម្រាប់ជាធម្មទាន

បែបរៀនភាសាបាលី ភាគទី ៥

ព.ស. ២៥៥៩

ប្រាក់ ឃុន

# បែបរៀនភាសាបាលី

## ភាគទី ៥

### វិធីទំនើបសម្រាប់រៀន និង បង្រៀនភាសាបាលី
### នៅកំរិតពុទ្ធិកបឋមសិក្សា

រៀបរៀងដោយ


ខ្ញុំព្រះករុណា អាត្មាភាព

**ធម្មបាលោ ប្រាក់ ឃុន**



កំណែលម្អជាថ្មី

ព.ស. ២៥៥៩ គ.ស. ២០១៥



# ធម្មបាលោ ប្រាក់ ឃុន

## ព្រះជន្មាយុ ៨៩ ឆ្នាំ

## កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

# បែបរៀនភាសាបាលី

## ភាគទី ៥

### វិធីធំនើបសម្រាប់រៀន និងបង្រៀនភាសាបាលី

### នៅក៏រិតពុទ្ធិកបឋមសិក្សា

រៀបរៀងដោយ

ធម្មបាលោ ព្រាក់ ឃុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

បានពិនិត្យផ្ទៀងផ្ទាត់សាជាថ្មី

នៅវត្តព្រះគន្លក្មុជ ខេត្តបាត់ដំបង

ព.ស. ២៥៥៩ គ.ស. ២០១៥

ឈ្មោះសៀវភៅ : បែបរៀនភាសាបាលី ភាគទី ៥

រៀបរៀងដោយ : ធម្មបាលោ ប្រាក់ យុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

ផ្នែកអក្ខរាវិរុទ្ធ

ភិក្ខុ ញាណកោសល បណ្ឌិត យ៉ន សេងយៀត

ព្រះសាកលវិទ្យាធិការរង ព.ស.ស ភ្នំពេញ

ភិក្ខុ ចន្ទវរធម្មោ ហ៊ឺ ជីតៅ : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ ជោតបញ្ញោ ជឹម សុវណ្ណជា : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ យសបាលោ ជ័យ សុហុន : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ នាគទីបោ នាគ ទី : សមណសិស្ស

ផ្នែកកុំព្យូទ័រ

វជិរបញ្ញោ គូ សុភាព វត្តនិគ្រោធវ័ន (ហៅ គល់ទទឹង)

កោវិទោ ឡោះ សុទៀត

បោះពុម្ពលើកទី២ : ព.ស. ២៥៥៩ គ.ស. ២០១៥

# កំណែលម្អជាថ្មី

សៀវភៅ បែបរៀនភាសាបាលី ភាគទី ១ ដល់ភាគទី ៥ និងបាលីវេយ្យាករណ៍ ១ ក្បាល ដែលជាស្នាដៃរបស់ខ្ញុំព្រះករុណា អាត្មាភាព **ឆម្មចារោ ប្រាក់ ឃុន** កំពុងតែចរាចរ ទៅក្នុងប្រទេសនិងក្រៅប្រទេស អមដំណើរដោយសម្លេងបង្រៀនវេយ្យាករណ៍ និងប្រែធម្មបទ - មង្គល - វិសុទ្ធិមគ្គ - នៅក្នុងខ្សែអាត់ និង ឌិសផង ដើម្បីឲ្យសិក្ខាកាមជាប់ចិត្តជិតអារម្មណ៍ ខំសិក្សារៀនសូត្រភាសាបាលីតរៀងទៅ ។

ដើម្បីសម្រួលដល់ការចង់ចេះដឹងភាសាបាលី របស់ព្រះសង្ឃ គ្រហស្ថ និងដើម្បីរក្សាវប្បធម៌មរតអក្សរសាស្ត្រខ្មែរ ឲ្យគង់វង្សនិងរីកចំរើនតរៀងទៅ ។

ខ្ញុំព្រះករុណា អាត្មាភាព និងព្រះសង្ឃវត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង ជួយឧបត្ថម្ភ ព្រមទាំងសមណនិស្សិត សិស្សនៅខេត្ត ក្រុងដទៃទៀត ជួយឧបត្ថម្ភ **កំណែលម្អជាថ្មី** ធ្វើឲ្យ

"បែបរៀនភាសាបាលី" ឲ្យមានភាពសុក្រឹត្យប្រសិទ្ធភាពពិតប្រាកដជាមូលដ្ឋាន នៃវប្បធម៌ព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ រុងរឿង ស្ថិតស្ថេរចេរកាលយូរអង្វែងតរៀងទៅ ។

សូមថ្លែងអំណរគុណយ៉ាងប្រសើរបំផុត ចំពោះសាស្ត្រាចារ្យ វិនយាចារ្យ ធម្មាចារ្យ និស្សិត សិស្ស ដែលបានជួយឧបត្ថម្ភតាមសមត្ថភាពគ្រប់ព្រះអង្គ ជួយផ្តល់យោបល់ និងជួយកែតម្រូវ ដើម្បីធ្វើឲ្យសៀវភៅនេះ រឹងរឹតតែល្អប្រសើរឡើងទៀត ។

សូមអនុមោទនាយកផលានិសង្សនៃមហាធម្មទាន បានសម្រេចមគ្គ ផល ដល់ព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

វត្តព្រះគន្ធកុដិ ថ្ងៃ ១២ រោច ខែ ភទ្របទ ព.ស. ២៥៥៩ / គ.ស. ២០១៥

**អ្នករៀបរៀង**

**ធម្មបាលោ ប្រាក់ ឃុន**

# បុព្វកថា

នាងខ្ញុំមានសេចក្តីរីករាយ ចំពោះការសរសេរបុព្វកថានេះ ។ គឺឯកឧត្តម ឈន អៀម, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធសាសនបណ្ឌិត្យ, ដែលបានប្រាប់អោយនាងខ្ញុំដឹងមុនគេ ចំពោះហេតុដែលថា ការរៀនភាសាបាលីនៅកម្ពុជា ត្រូវបានប្រព្រឹត្តទៅតាមការរៀនសូត្រចាំមាត់, ហើយដោយហេតុនេះ ត្រូវការយ៉ាងបន្ទាន់អោយមានការផ្លាស់ប្តូរក្នុងវិធីបង្រៀន ។ ការនិយាយប្រាប់នេះ បានកន្លងទៅពីរឆ្នាំហើយ តាំងពីពេលដែលនាងខ្ញុំកំពុងធ្វើការជាមួយអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជាម្ល៉េះ ។

ក្រោយពេលនាងខ្ញុំបានមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ នាដើមឆ្នាំ ១៩៩៦, ឯកឧត្តម ដោក ណារិន, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធិកសិក្សា បានធ្វើសំណូមពរអោយនាងខ្ញុំជួយឧបត្ថម្ភថវិកាដល់កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីសម្រាប់គ្រូបង្រៀនភាសាបាលី ជិត ២៥០ នាក់ ដែលមិនធ្លាប់បានទទួលការបណ្តុះបណ្តាលដ៏សមស្រប ។ នាងខ្ញុំបានឆ្លៀតយកឱកាសនោះ ពិនិត្យមើលសៀវភៅវេយ្យាករណ៍បាលីដែលមានស្រាប់ ហើយសរសេរជាភាសាខ្មែរ ។ ឯកឧត្តម ដោក ណារិន ក៏បានប្រាប់អោយនាងខ្ញុំដឹងផងដែរ អំពីសំណៅមេរៀនភាសាបាលីបែបថ្មីមួយ រៀបរៀងឡើងដោយលោក ប្រាក់ ឃុន ដែលមិនទាន់បានបោះពុម្ពផ្សាយនៅឡើយ ។ នៅក្នុងសំណៅនោះ នាងខ្ញុំបានមើលឃើញមានសក្តានុពល ដែលអាចនាំទៅកាន់ការធ្វើអោយមេរៀនភាសាបាលីបានត្រឹមត្រូវ ប្រកបដោយវិធីបង្រៀនទំនើប ។ នាងខ្ញុំ បានអង្គុយប្រជុំជាមួយលោក ប្រាក់ ឃុន និងក្រុមគ្រូបង្រៀនបាលីមកពីក្រសួងធម្មការ និងសាសនា និងមកពីពុទ្ធសាសនបណ្ឌិត្យ, ហើយបានណែនាំ

អស់លោកទាំងនោះ អំពីវិធីទំនើបបង្រៀនភាសាដល់អ្នករៀនដំបូង តាមរយៈការ ការតែងជាឃ្លាប្រយោគ . ដ៏ជាទិដ្ឋភាពមួយដែលខ្វះនៅក្នុងមេរៀនភាសាបាលី បច្ចុប្បន្ន ក្នុងប្រទេសកម្ពុជា ។ នេះគឺជាវិធីដែលព្រះតេជព្រះគុណ សាស្ត្រាចារ្យ អ.ប. ពុទ្ធទត្តៈ មហានាយកត្ថេរ នៃប្រទេសស្រីលង្កា ធ្លាប់បានប្រើនៅក្នុងសៀវភៅ « The New Pali Course » ( វិជ្ជាសិក្សាភាសាបាលី បែបថ្មី ) បោះពុម្ពផ្សាយ ជាភាសាអង់គ្លេស ក្នុងឆ្នាំ ១៩៣៧ ដែលនាងខ្ញុំធ្លាប់បានសិក្សា និងធ្លាប់បានបង្រៀន នៅក្នុងប្រទេសស្រីលង្កា និងនៅក្នុងប្រទេសអង់គ្លេសផងដែរ ។

បាលី ឬ មាគធី, ដូចដែលគេធ្លាប់ហៅពីកាលនោះ, គឺជាភាសាដែល ព្រះពុទ្ធតែងបានប្រើសម្រាប់ទេសនា នៅក្នុងសតវត្សទី ៦ មុនគ្រិស្តសករាជ នៅក្នុង ប្រទេសស្រីលង្កា ។ ចាប់តាំងពីពេលនោះមក អដ្ឋកថាព្រះត្រៃបិដកជាច្រើន, អត្ថបទស្តីពីទស្សនវិជ្ជាពុទ្ធសាសនាជាច្រើន, ក៏ដូចជាអត្ថបទផ្លូវលោកទាំងឡាយ ផងដែរ ត្រូវបានគេសរសេរជាភាសាបាលី នៅក្នុងប្រទេសឥណ្ឌា និងនៅក្នុង ប្រទេសកាន់ពុទ្ធសាសនាថេរវាទ ដូចជា ស្រីលង្កា, ភូមា, សៀម, និងកម្ពុជា ។ ជាងនេះទៀត កាលណាបព្វជិតទាំងឡាយមកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ បាន និមន្តទៅកាន់ប្រទេសកាន់ពុទ្ធសាសនាថេរវាទមួយទៀត កាលពីអតីតកាល, ភាសា បាលី គឺជាភាសាអន្តរជាតិ ដែលបព្វជិតទាំងនោះបានប្រើ សម្រាប់ប្រាស្រ័យឆ្លើយ ឆ្លងគ្នា ។ ថ្វីបើភាសាបាលិ មិនត្រូវបានប្រជាជននិយាយក៏ដោយ, ក៏ភាសានេះ នៅតែ ជាភាសារួមរហូតមកដល់សព្វថ្ងៃនៅឡើយ, ដែលតាមរយៈភាសានេះ បព្វជិតពុទ្ធ. សាសនិកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ តែងប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ជា ឧទាហរណ៍ បព្វជិតមកពីស្រីលង្កា, កាលណាលោកនិមន្តទៅកាន់ប្រទេសថៃ, តែង សន្ទនាជាមួយបព្វជិតថៃ ជាភាសាបាលិ ។ ដោយហេតុនេះ ការរៀនភាសាបាលី តាម រយៈការតែងជាឃ្លា . ប្រយោគ ជួយសម្រួលដល់ការសន្ទនា, បន្ថែមទៅលើការយល់

អត្ថបទជាភាសាបាលិ ពីបុរាណកាលទៀតផង ។

សៀវភៅ « វិជ្ជាសិក្សាភាសាបាលិ » នេះ គឺជាតម្រុយមួយ នៅក្នុងប្រទេសកម្ពុជា ពីព្រោះ នេះគឺជាការខិតខំមួយជាលើកដំបូង ដើម្បីបង្រៀនបាលិដល់អ្នករៀនដំបូង តាមរយៈការតែងជាឃ្លា-ប្រយោគ ។ នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក ប្រាក់ ឃុន និងចំពោះក្រុមគ្រូបង្រៀនបាលិដែលបានធ្វើការយ៉ាងនឿយហត់ ដើម្បីបង្កើតឡើងនូវសៀវភៅនេះ, ព្រមទាំងអំណរគុណចំពោះសម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម, អគ្គាធិការនៃពុទ្ធិក-សិក្សា, ចំពោះព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ , នាយកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, និងចំពោះសម្តេចព្រះធម្មលិខិត លាស់ ឡាយ ព្រះចៅអធិការវត្តសន្សំកុសល, ទីក្រុងភ្នំពេញ, ដែលបានពិនិត្យយ៉ាងល្អិតល្អន់នូវសំណៅចុងក្រោយ ។ នៅទីអវសាន, នាងខ្ញុំ សូមថ្លែងអំណរគុណ លោក ឱម ខែម, នាយកពុទ្ធសាសន-បណ្ឌិត្យ ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ធ្វើអោយសៀវភៅនេះ សម្រេចបោះពុម្ពបាន ។

បណ្ឌិត *ហេម៉ា គូណាតិលកេ*

ពុទ្ធសាសនបណ្ឌិត្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ : 672 / 96 ក.ធ.ស

# លិខិតបង្គាប់ការ

មន្ត្រីរាជការ នៃក្រសួងធម្មការ និង សាសនា ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានចាត់តាំងឱ្យទៅពិនិត្យ និងសម្រេចបោះពុម្ពសៀវភៅសិក្សា « បាលីវេយ្យាករណ៍ » ជាមួយលោកស្រីបណ្ឌិត ហេម៉ា នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៩៦ វេលាម៉ោង ៨ ព្រឹក តទៅ រហូតដល់ចប់ជាស្ថាពរ ។

១. លោក រស់ សាវេន

២. លោក នួច ជីម

៣. លោក ប្រាក់ ឃុន

៤. លោក ម៉ែន ប្រាង

៥. លោក អាំ ធន

៦. លោក អ៊ឹង សុវណ្ណ

៧. លោក ជិត ជន

មន្ត្រីរាជការ ដូចមានរាយនាមខាងលើ ត្រូវអនុវត្តភារកិច្ចរៀងៗខ្លួនឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៩៩៦

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ះរៀន-វណ្ណាវ៉ៃ

# និវេទនកថា

គណៈកម្មការឯកទេសភាសាបាលី បានត្រួតពិនិត្យសំណៅ « បាលិវេយ្យាករណ៍ ភាគទី ១ » របស់លោក ប្រាក់ ឃុន គ្រូពុទ្ធិកបឋមសិក្សា វត្តពោធិវាល ខេត្តបាត់ដំបង ជាពីរលើក នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ :

. លើកទី ១ នៅខែកញ្ញា ឆ្នាំ ១៩៩៦ ។ គណៈកម្មការបានពិនិត្យ និងសម្រេចឱ្យកាត់បន្ថយត្រង់អន្លើខ្លះ ខាងផ្នែកមេរៀនវេយ្យាករណ៍ ទុកសម្រាប់សៀវភៅ ភាគទី ២ ហើយបានសុំឱ្យលោក ប្រាក់ ឃុន រៀបរៀង កែសម្រួល និងបំពេញបន្ថែមផ្នែកលំហាត់មួយចំនួនទៀត ។ បន្ទាប់មក អង្គប្រជុំបានសម្រេចដូរឈ្មោះ « បាលិវេយ្យាករណ៍ ភាគទី ១ » នេះទៅជា « បែបរៀនភាសាបាលិ » វិញ ដើម្បីឱ្យស្របទៅនឹងមេរៀន និងលំហាត់ ក្នុងសៀវភៅនេះ ។

. លើកទី ២ នៅដើមឆ្នាំ ១៩៩៧ ។ គណៈកម្មការបានពិនិត្យឃើញថា សៀវភៅ «បែបរៀនភាសាបាលិ ភាគទី ១ » ដែលបានរៀបរៀង កែសម្រួលឡើងវិញនេះ មានលក្ខណៈសមស្របតាមវិធីទំនើបសម្រាប់រៀន និងបង្រៀនភាសាបាលិ នៅពុទ្ធិកបឋមសិក្សា នាពេលបច្ចុប្បន្ននេះ ។

គណៈកម្មការឯកទេសភាសាបាលី បានធ្វើសំណូមពរឱ្យគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា ដាក់បញ្ចូលសៀវភៅ បែបរៀនភាសាបាលិនេះ ក្នុងពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី » ក្នុងព្រះរាជាណាចក្រកម្ពុជា តទៅ ។

ភ្នំពេញ, ថ្ងៃ ១៣ ខែមករា ឆ្នាំ ១៩៩៧

ជ. គណៈកម្មការឯកទេសភាសាបាលី

ម៉ែន ប្រាជ

# សេចក្ដីដកស្រង់កំណត់ហេតុ
# របស់គណៈកម្មការអភិឌ្ឍន៍ពុទ្ធិកសិក្សា

បន្ទាប់ពីគណៈកម្មការឯកទេសភាសាបាលី បានពិនិត្យសំណៅ « *បែបរៀនភាសាបាលី ភាគទី ១* » ដែលរៀបរៀងឡើងដោយលោក ប្រាក់ ឃុន រួចមក គណៈកម្មការអភិឌ្ឍន៍ពុទ្ធិកសិក្សានៃក្រសួងធម្មការ និងសាសនា បានប្រជុំគ្នាត្រួតពិនិត្យយ៉ាងម៉ត់ចត់នូវសំណៅ បែបរៀនភាសាបាលី ភាគទិ ១ នេះ នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ។ គណៈកម្មការយល់ឃើញថា :

. មេរៀនសង្ខេប លំហាត់តែង និងបំពេញពាក្យជាឃ្លា . ប្រយោគ ក្នុងសៀវភៅនេះ មានលក្ខណៈឆ្លើយតបតាមសំណូមពរ របស់សិស្សនិងគ្រូនៃសាលាពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួចចង់បានជាយូរមកហើយ ។

. សៀវភៅនេះ ជាជំហានដំបូង ស្របតាមទិសដៅនៃការអភិវឌ្ឍន៍ពុទ្ធិក-សិក្សា នៅក្នុងប្រទេសកម្ពុជា នាបច្ចុប្បន្ន ។

. សៀវភៅនេះ ស្របតាមសង្វាក់នៃការសិក្សាផ្នែកភាសាអន្តរជាតិផងដែរ ។

គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា បានសម្រេចបញ្ចូលសៀវភៅ *បែបរៀនភាសាបាលី* នេះ ក្នុងពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី កម្រិតពុទ្ធិកបឋមសិក្សា ឆ្នាំទី ១ » តទៅ ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ជ. គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

**ដោក ណារិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា

លេខ ៣៧ / ៩៧ ក.ធ.ស

ភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

## សេចក្តីសម្រេច

ស្តីពីការបោះពុម្ពសៀវភៅបែបរៀនភាសាបាលីភាគ ।

---

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣,
- បានឃើញព្រះរាជក្រម លេខ នស.រកម. ០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា,
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៧,

## សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបោះពុម្ពសៀវភៅ បែបរៀនភាសាបាលីភាគ ។ ។

ប្រការ ២ : សៀវភៅបែបរៀនភាសាបាលីភាគ ។ ត្រូវបោះពុម្ពខ្នាត ទំហំ ១៤ x ២០,៥ ។

ប្រការ ៣ : អនុអញ្ញាតឱ្យបោះពុម្ពលើកទី ។ ចំនួន ៣.៥០០ ក្បាល ។

ប្រការ ៤ : វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ អគ្គនាយកដ្ឋានពុទ្ធិកសិក្សា មានភារកិច្ចអនុវត្តឱ្យបានសម្រេចលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចម្លងជូន :

- ក្រសួងសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ឯកសារ

ព្រៀង-ភណ្ណារ័ត្ន

# អារម្ភកថា

បុព្វហេតុដែលនាំឲ្យកើតសៀវភៅនេះឡើងនៅថ្ងៃពុធ ៣ រោច ខែផល្គុន ឆ្នាំ ឆ្លូវ ឯកស័ក ពុទ្ធសករាជ ២៥៥៣ ត្រូវនឹងថ្ងៃទី ៣ ខែមីនា គ.ស. ២០១០ ។ ខ្ញុំព្រះករុណាខ្ញុំបាទបានទទួលភារៈអំពីសមណៈសិស្សជាច្រើន ដែលនិយាយថាខ្ញុំបានតែងសៀវភៅច្រើនបែប មានបែបរៀនភាសាបាលីភាគ ១ ភាគ ២ ភាគ ៣ ដល់ភាគ ៤ និងវេយ្យាករណ៍បាលី ១ ដូច្នោះមិនទាន់ឃើញ " បែបប្រែភាសាបាលី " នៅឡើយ តែវិធីប្រែបាលីដែលនិពន្ធដោយ **ឃុនស៊ីសុវត្ថិ យូអ៊ុន** បានតែងរួចហើយ ប៉ុន្តែ លោកចង់ឲ្យខ្ញុំបានរៀបរៀង ឲ្យបានពិស្តារជាងនេះទៀត ទើបខ្ញុំខំយកអស់សមត្ថភាពដើម្បីរៀបរៀងឲ្យបានជាបែបរៀនប្រែជាភាសាបាលីនេះឡើង ដោយបានយក វិធីប្រែបាលីជាន់មុនមកជាគោលអាង ហើយផ្សេផ្សំជាមួយនឹង បទពិសោធន៍របស់ខ្ញុំដែលបានបង្រៀនព្រះសង្ឃអស់ ១៨ ឆ្នាំហើយ ។ ពេលនេះខ្ញុំមានអាយុ ៨៣ ឆ្នាំបរិបូរហើយឈានចូល ៨៤ ឆ្នាំ បង្ហាត់ព្រះសង្ឃមិនកើត

ដោយមានជំងឺលើសឈាម សព្វថ្ងៃចិញ្ចឹមជីវិតក្នុងផ្ទះកូន នៅភូមិដំណាក់ល្ហុង ឃុំ វត្តគ ស្រុកបាណន់ ខេត្ត បាត់ដំបង ទើបខ្ញុំឆ្លៀតឱកាសដែល ទើបនឹងងើបអំពីជំងឺនោះ បានគួរសមហើយ ក៏រៀបរៀងជា សៀវភៅនេះឡើង តែបើមានកំហុសឆ្គងត្រង់កន្លែងណា សូមបណ្ឌិត ផ្នែកខាងភាសាបាលី មេត្តាជួយកែតម្រូវឲ្យទានផង ព្រោះកំហុសតែងមានដល់អ្នកធ្វើ ទោះតិចឬច្រើនមិន ដែលខានទេ ។ ដូច្នេះ ខ្ញុំសូមឧទ្ទិសកុសលពីការតែង សៀវភៅនេះ ជូនដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបីតាជីដូនជីតាញាតកាទាំង ៧ សន្តាន គ្រូឧបជ្ឈាយាចារ្យ ក្នុងសង្សារវដ្តរបស់ខ្ញុំសូមទទួលឥដ្ឋមនុញ្ញផល ហើយបានដល់នូវព្រះនិព្វាន កុំបីអាក់ខានឡើយ ។ម្យ៉ាងទៀត សូមឧទ្ទិសកុសលនេះ ជូនដល់សិក្ខាកាមទាំងឡាយ ដែលមានប្រាថ្នាត្រូវការរៀនភាសាបាលីដើម្បីបន្តវេនពីរូបខ្ញុំ **ប្រាក់ ឃុន** ឲ្យបានឋិតថេរចេរកាលតទៅ ព្រោះថា ភាសាព្រះពុទ្ធ និងភាសាខ្មែររបស់យើង ក៏បានប្រើភាសាបាលីនេះដែរ ។ ដូច្នេះសូម

អនុមោទនាយកកុសលផលបុណ្យ ដែលកើតអំពីការបង្រៀន និងការតែងជាដើមនេះ សូមមាន ប្រាជ្ញា អាចកាប់ឆ្ការនូវកងកិលេស ជានិរាវិសេស ឲ្យបានសម្រេច ព្រះនិព្វានគ្រប់ព្រះអង្គគ្រប់គ្នាទៅហោង ។

# មាតិកា

**ឈ្មោះអត្ថបទ** **ទំព័រ**

១. បែបរៀនប្រែភាសាបាលី ..........................................១
២. ការប្រែតាមសព្ទចែកជាពីរគឺ ..................................២
៣. ការប្រែតាមអត្ថ .....................................................៨
៤. ការប្រែភាសាបាលី .................................................៨
៥. វាចកៈ ៥ យ៉ាង ........................................................៩
៦. ការកត់សំគាល់វាចកៈ .............................................១០
៧. កិរិយាកិតកៈឃុំគ្រងពាក្យ ......................................១១
៨. វិធីរកបទប្រធាន .....................................................១២
៩. គោលនៃការប្រែបាលីមាន ៩ យ៉ាង .........................១៩
១០. អាលបន ...............................................................២០
១១. និបាត ..................................................................២៤
១២. កាលសត្តមី ..........................................................២៤
១៣. ប្រធាន ................................................................៣១
១៤. លក្ខណៈរបស់បទដែលធ្វើប្រធានបាន ................៣១

១៥. បែបពិនិត្យរកបទប្រធាន ....................................២៣
១៦. ឈ្មោះប្រធានក្នុងប្រយោគ ..................................៣៣
១៧. អនុកិរិយា និង ប្រយោគជ្រែក ............................៣៥
១៨. អថ , ឯរំ .........................................................៤៣
១៩. បទពង្រីកអនុកិរិយា និង ប្រយោគជ្រែក ................៥០
២០. មហាកិរិយា ........................................................៥២
២១. បទពង្រីកមហាកិរិយា .........................................៥៥
២២. ប្រយោគមានលក្ខណៈ ៤ ប្រភេទ .......................៧០
២៣. ប្រយោគធម្មតា ..................................................៧០
២៤. ប្រយោគមានលេខក្រៅ លេខក្នុង .......................៧២
២៥. ប្រយោគមានតែលេខក្នុង ..................................៧៣
២៦. ប្រយោគមានទម្រង់ជាវាចកៈផ្សេងៗ....................៧៤
២៧. គោលនៃការប្រែរូបមាន ៨ យ៉ាង ........................៧៥
២៨. បែបរៀនយោគសព្វនាម ...................................១០៦
២៩. ការប្រែភាវស័ព្ទមាន ៤ យ៉ាង ............................១១២
៣០. បែបរៀនប្រែវិកតិកត្តា ....................................១១៨

៣១. បែបរៀនប្រើប្រយោគឧបមា ..........................១២៧
៣២. ការប្រើប្រយោគឧបមាមាន ៣ យ៉ាង ...............១២៨
៣៣. ប្រយោគឧបមាជាវាក្យាង្ស ..............................១៣៤
៣៤. នាមវាក្យាង្ស ..................................................១៣៤
៣៥. គុណវាក្យាង្ស ..................................................១៣៥
៣៦. ឧបមាវាក្យាង្សមាន ៣ យ៉ាង ...........................១៣៦
៣៧. ឧបមាលិង្គត្ថ: ................................................១៣៦
៣៨. ឧបមាវិសេសន: ...............................................១៣៨
៣៩. ឧបមាវិកតិកត្តា ...............................................១៤០
៤១. ប្រយោគបការ: និង កិរិយាវិសេសន: ...............១៤៦
៤២. ប្រយោគពិសេស ...............................................១៥២
៤៣. សម្ពន្ធ ..........................................................១៥៨
៤៤. ប្រយោគកិរិយាបរាមាស ..................................១៦២
៤៥. សព្វនាមជាបុំលិង្គ .........................................១៦២
៤៦. ប្រយោគត្រូវបន្ថែម .........................................១៦៦
៤៧. ការយោគប្រធាន, ការថែមប្រធាន,
ការឡើងប្រធាន ..............................................១៧៧

៤៨. សក្កា មានលក្ខណៈ ៤ យ៉ាង គឺ .........................១៨៤
៤៩. ការប្រែ អលំ ....................................................១៨៦
៥០. ការប្រែ លព្ភា ..................................................១៨៩
៥១. ការប្រែ សម្ភាវនៈ ..............................................១៩១
៥២. ការប្រែ វិសេសលាភី .........................................១៩៣
៥៣. ការប្រែ ឥត្ថម្ភូត ...............................................១៩៥
៥៤. ការប្រែ បគេវ ...................................................១៩៧
៥៥. ឥតិ សព្ទ .........................................................១៩៨
៥៦. គោលប្រែអដ្ឋកថា ..........................................២០៣
៥៧. វិធីសង្កេតគោលប្រែអដ្ឋកថា ............................២០៩
៥៨. វិធីប្រែអដ្ឋកថាពិសេស ....................................២២៤
៥៩. ការប្រែដោយអត្ថ គួរមានគោលដូច្នេះ ...............២២៨

# បែបរៀនប្រែភាសាបាលី

បែបរៀនប្រែភាសាបាលី បានដល់ការប្រែតាមសព្ទគឺ នាមសព្ទ កិរិយាសព្ទ និងអព្យយសព្ទ ។ ការប្រែតាមអត្ថ គឺប្រែយកសេចក្ដីខ្មែរ ។ ការប្រែតាមសព្ទ បានដល់ នាមសព្ទ គឺនាមនាម គុណនាម និងសព្វនាម ដែលត្រូវប្រកបដោយ លិង្គ វចនៈ និង វិភត្តិ ។ កិរិយាសព្ទ គឺកិរិយាអាខ្យាត និង កិរិយាកិតកៈ, អព្យយសព្ទ គឺឧបសគ្គ និបាត និងបច្ច័យ ។ សិក្ខាកាមគប្បីចាំពាក្យប្រែរបស់សព្ទទាំងអស់ ព្រមទាំង អាយតនិបាត និងកិរិយានុគ្រោះឲ្យបានស្ទាត់ជំនាញ ទើបប្រែបាន ។

## I. ការប្រែតាមសព្ទចែកជាពីរគឺ

ក/ ប្រែប្រថប់សព្ទ : កាលបើសព្ទនោះគេបានដឹងគ្រប់គ្នាដូចជា **ពុទ្ធស្ស សាវកា** ប្រែថា សាវ័កទាំងឡាយរបស់ព្រះពុទ្ធ ។ ពាក្យថា ពុទ្ធក្ដី សាវ័កក្ដី ជាការប្រែ ប្រថប់សព្ទដែលគេធ្លាប់ស្គាល់គ្រប់គ្នាមកហើយអាចស្ដាប់បាន ។

ស្រះ " េ "(**អេ**) ក្នុងបាលី ខ្មែរអានថា " **ែ** "(**អែ**) :

| **បាលី** | ប្រែថា | អានថា |
|---|---|---|
| **ហេតុ** | ហេតុ | ហែត |
| **ខេត្តំ** | ខេត្ត | ខែត |
| **ខេមំ** | ក្សេម | ក្សែម |
| **សេវតិ** | សេព | សែព |
| **សង្ខេបោ** | សង្ខេប | សង្ខែប |
| **វិសេសោ** | វិសេស | វិសែស |
| **មហាថេរោ** | មហាថេរ | មហាថែរ |
| **អនុថេរោ** | អនុថេរ | អនុថែរ |
| **សាមណេរោ** | សាមណេរ | សាមណែរ |
| **ចេតិយំ** | ចេតិយ | ចែដី |
| **សេសវត្ថុ** | វត្ថុសេសសល់ | វត្ថុសែសសល់ |

| | | |
|---|---|---|
| **ឯករជ្ជំ**<br>**ឯកឧត្តមោ**<br>**ឯកទេសោ**<br>**បច្ចេកពុទ្ធោ** | ឯករាជ្យ<br>ឯកឧត្តម<br>ឯកទេស<br>ព្រះបច្ចេកពុទ្ធ | អែក:រាច<br>អែកអ៊ុតដំ<br>អែក:ទេស<br>ប៉ាច់ចែក:ពុទ្ធ |

ភាសាបាលីមិនមានប្រើសញ្ញាបន្តក់ " ' " ទេ :

| **បាលី** | ប្រែថា | អានថា |
|---|---|---|
| **ជនោ**<br>**ជនបទោ**<br>**ទុក្កដំ**<br>**សុគតោ**<br>**ទុគ្គតោ**<br>**បណ្ឌិតោ**<br>**នាយកោ** | រីជន<br>ជនបទ<br>ទុក្កដ<br>សុគត<br>ទុគ៌ត<br>បណ្ឌិត<br>នាយក | ជន់<br>ជន់ន:បត់<br>ទុកកត់<br>សុគត់<br>ទុរ:គត់<br>បរ:ពត់<br>នាយក់ |

| | | |
|---|---|---|
| **នាយកដ្ឋានំ**<br>**មិគសិរ**<br>**ទឹកខិរៈ** | នាយកដ្ឋាន<br>មិគសិរ<br>ទឹកក្សិរ | នាយៈកាត់ថាន<br>មិគៈសេរ<br>ទឹកក្សេរ |

បាលីជា " **ត** " ខ្មែរអាន " ដ "

| **បាលី** | ប្រែថា | អានថា |
|---|---|---|
| **ជាតកោ** | ជាតក | ជាដក់ |
| **វេស្សន្តរោ** | ព្រះវេស្សន្តរ | វេសសន់ដរ |
| **ឧត្តមោ** | ឧត្តម | អ៊ុតដំ |
| **ឧត្តរោ** | ឧត្តរ | អ៊ុតដរ |
| **មាតា** | មាតា | មាតដា |
| **បកតិ** | ប្រក្រតី | ប្រក្រដី |
| **សេនាបតិ** | សេនាបតី | សេណា ប៉ៈដី |
| **សីលវតី** | សីលវតី | សីឡៈវ៉ៈដី |

| | | |
|---|---|---|
| **បទុមវតី** | បទុមវតី | បទុមៈវៈដី |
| **សន្តានំ** | សន្តាន | សន់ដាន |
| **សន្តោសំ** | សន្តោស | សន់ដោស |
| **អន្តរធានំ** | អន្តរធាន | អន់ដរៈធាន |
| **ទូរសន្តោ** | ទូរសព្ទ | ទូរៈសាប់ |
| **ទូរទស្សនំ** | ទូរទស្សន៍ | ទូរៈទស់ |
| **មត្តកំ** | មរតក | មៈរៈដក់ |
| ផូរផង់ (ខ្មែរ) | កុំអានផូរៈផង់ | ផូផង់ |

បាលីជា “ **ប៉** ” ខ្មែរអាន “ ប ” :

| **បាលី** | ប្រែថា | អានថា |
|---|---|---|
| **បុញ្ញំ** | បុណ្យ | បុណ្យ |
| **បាបំ** | បាប | បាប |
| **បុគ្គលោ** | បុគ្គល | បុកគល់ |

| | | |
|---|---|---|
| **បំសុកូលំ** | បង្សុកូល | ប៉ាំងសុកូល |
| **បរមំ** | បរម | បរ៉ម "កុំថា ប៉ាក់" |
| **បរមសុខំ** | បរមសុខ | បរ៉ម ម៉ៈសុខ |
| **បរមត្ថំ** | បរមត្ថ | បរ៉ៈម៉ាត់"កុំថា ប៉ាក់" |
| **បរមត្ថបារមី** | បរមត្ថបារមី | បរ៉ៈម៉ាត់ថៈបារៈម៉ី |
| **បរិកម្មំ** | បរិកម្ម | បរិកាំ |
| **បរិក្ខារោ** | បរិក្ខារ | បរ៉ិកខា |
| **បរិច្ចាគោ** | បរិច្ចាគ | បរ៉ិចចាក |
| **បរិច្ឆេទោ** | បរិច្ឆេទ | បរ៉ិចឆែត |
| **បរិវារោ** | បរិវារ | បរ៉ិវ៉ា |

ខ/ ប្រែតាមមូលសព្ទ : គឺសព្ទដើមចេញមកពីធាតុ បច្ច័យ និងសាធនៈ ក៏ប្រែចេញជាភាសាខ្មែរតាមនោះទៅ ដូចជា **ពុទ្ធស្ស សាវកា** ប្រែថា អ្នកស្ដាប់ទាំងឡាយ របស់លោកអ្នកត្រាស់ដឹង ។ អ្នកប្រែតាមមូលសព្ទបានល្អ គឺអ្នក

មានសមត្ថភាព អាចកំណត់ចាំធាតុបច្ច័យវិភត្តិបាន ច្បាស់លាស់ ។

| **បាលី** | ប្រែប្រចប់សព្ទ | ប្រែតាមមូលសព្ទ |
|---|---|---|
| **សត្តោ** | វីសត្វ | អ្នកជាប់នៅក្នុងអារម្មណ៍ |
| **ភិក្ខុ** | វីភិក្ខុ | អ្នកសុំដោយប្រក្រតី |
| **សត្ថា** | វីព្រះសាស្តា | អ្នកប្រៀនប្រដៅ |
| **បុគ្គលោ** | វីបុគ្គល | អ្នកទៅកាន់នរក |
| **សាមណេរោ** | វីសាមណេរ | កូនចៅនៃអ្នកស្ងប់ |
| **ធម្មោ** | វីព្រះធម៌ | សភាវៈទ្រទ្រង់សត្វ |
| **អត្តា** | វីខ្លួន, អាត្មា | អ្នកស៊ីនូវសុខ និង ទុក្ខ |
| **ឧបជ្ឈាយោ** | វីឧបជ្ឈាយ៍ | អ្នកមើលទោសតូចធំ |
| **អាចរិយោ** | វីអាចារ្យ | អ្នកដែលសិស្សគួរបម្រើ |
| **សមាធិ** | វីសមាធិ | ការតម្កល់ចិត្តទុកល្អ |
| **ឧបាសកោ** | វីឧបាសក | អ្នកអង្គុយជិតព្រះរតនត្រ័យ |
| **វិនយោ** | វីវិន័យ | ឧបាយជាគ្រឿងណែនាំ |

| | | |
|---|---|---|
| **លោភោ** | វីលោភៈ | កិលេសជាហេតុចង់បាន |
| **ទោសោ** | វីទោសៈ | កិលេសជាហេតុប្រទូស្ត |
| **មោហោ** | វីមោហៈ | កិលេសជាហេតុវង្វេង |
| **រោគោ** | វីរាគៈ | កិលេសជាហេតុត្រេកអរ |
| | ។ល។ | |

## II. ការប្រែតាមអត្ថ

ការប្រែតាមអត្ថ គឺការប្រែសំដៅយកសេចក្ដីជាការសំខាន់ មិនសំដៅយកបច្ច័យ វិភត្តិជាគោលសំខាន់ទេ ដូចជា **សាមណេរា តិស្សំ សាលាយំ ភត្តានិ ភុញ្ជន្តិ** ប្រែថា : ពួកសាមណេរកំពុងឆាន់ភត្តក្នុងសាលានោះ។

## ការប្រែភាសាបាលី

មុននឹងលើកសព្ទឡើងប្រែ សិក្ខាកាមត្រូវពិនិត្យឲ្យដឹងច្បាស់ថា ប្រយោគកត្តុវាចកៈ ឬប្រយោគកម្មវាចកៈ ជាដើមសិន នៅត្រង់កិរិយាឃុំគ្រងពាក្យ បានដល់ កិរិយាដែលរៀង

ខាងចុងបំផុតនៃប្រយោគ សិក្ខាកាមគប្បីមើលសារឡើងវិញនូវ កិរិយាអាខ្យាត និងកិរិយាកិតក: ដែលរៀបរាប់ពីវាចក: ទាំង ៥ ឲ្យបានច្បាស់លាស់ ដូចមានសេចក្ដីសង្ខេបតទៅនេះ ៖

## វាចក:

**វាចក:** គឺកិរិយាសព្ទសម្រាប់ប្រាប់ដល់បទប្រធាន កំណត់ឲ្យដឹងថាប្រធាន ជាកត្តាអ្នកធ្វើ ឬវុត្តកម្ម តួកម្មដែលគេត្រូវធ្វើ ។

## វាចក: ៥ យ៉ាង គឺ

១. **កត្តុវាចក:** កិរិយាសព្ទប្រាប់កត្តា "អ្នកធ្វើខ្លួនឯង" ឡើងជាប្រធាន។

២. **កម្មវាចក:** កិរិយាសព្ទប្រាប់កម្មតួអំពើ ធ្វើជាប្រធាន ។

៣. **ភាវវាចក:** កិរិយាសព្ទប្រាប់ភាព គឺមិនប្រាប់កត្តា ឬ កម្មឡើយ ។

៤. **ហេតុកត្តុវាចកៈ** កិរិយាសព្ទប្រាប់ហេតុកត្តា គឺអ្នកប្រើគេឲ្យធ្វើជាប្រធាន ។

៥. **ហេតុកម្មវាចកៈ** កិរិយាសព្ទប្រាប់នូវអំពើហៅវុត្តកម្ម ដែលគេត្រូវប្រើឲ្យអ្នកដទៃទៀត ធ្វើឡើងជាបទប្រធាន ។

## **ការកត់សំគាល់វាចកៈ**

សិក្ខាកាមអាចស្គាល់វាចកៈទាំង ៥ បានច្បាស់លាស់ដោយសារបច្ច័យ ជា គ្រឿងសំគាល់ដូច្នេះ ។

១. កិរិយាអាខ្យាត ប្រកបដោយបច្ច័យ ១៥ ប្រចាំ ពួកធាតុទាំង ៨ ដូចជា **ភវតិ**, **គច្ឆតិ**, **សេតិ**, **ហោតិ**, ។ល។ **ចោរេតិ**, **ចោរយតិ**, **មន្តយីសុ** កិរិយានេះជាកត្តុវាចកៈ ។

២. កិរិយាអាខ្យាតជាសកម្មធាតុ ប្រកបដោយ **យ**-បច្ច័យ ឬចុះ **ឥ**-អាគម និង **យ**-បច្ច័យ ដូចជា **បច្ចតេ**, **លព្ភតេ**, **ករិយតេ**, **គហិយតេ** កិរិយានេះជាកម្មវាចកៈ។

៣. កិរិយាអាខ្យាតជាអកម្មធាតុ ប្រកបដោយ **យ**-

បច្ច័យ ចុះ **តេ**-វត្តមានាវិភត្តិ អត្តនោបទប៉ុណ្ណោះ ជាភាវវាចកៈ កន្លែងខ្លះចុះ **ឥ**-អាគមផង ក៏នៅតែភាវវាចកៈ ដែរ ។

៤. កិរិយាអាខ្យាតប្រកបដោយ **ណេ**, **ណយ**, **ណាបេ**, **ណាបយ** បច្ច័យដូចជា **សារេតិ**, **ចោរាបេតិ**, **អាហារាបយតិ** ជាហេតុកត្តុវាចកៈ។

៥. កិរិយាអាខ្យាតប្រកប ដោយ **ណាបេ** + **ឥ** + **យ** ទាំងសកម្មធាតុ ទាំងអកម្មធាតុដូចជា **បាចាបិយតេ**, **ភារាបិយតេ**, **មារាបិយតេ** ហេតុកម្មវាចកៈ ។

## កិរិយាកិតកៈឃុំគ្រងពាក្យ

១. ធាតុដែលប្រកបដោយ **ត**, **តព្វ**, **អនីយ**-បច្ច័យ មានលិង្គវចនៈ វិភត្តិស្មើគ្នា នឹងបទប្រធាន។

២. មិនមានកិរិយាអាខ្យាតនៅក្នុងសេចក្ដីនោះទេ ។

៣. កិរិយាកិតកៈនោះមិនជាប់ជាបទសមាស ដូចជា **កតបុញ្ញោ ទិន្នភារោ ទិដ្ឋបុញ្ញោ កតភារោ** ។ល។ បើជាប់សមាសធ្វើកិរិយាមិនកើតទេ។

៩. មានគោលកំណត់កិរិយាកិតកៈជាវាចកៈដូច្នេះ

ក. **ត**-បច្ច័យចុះខាងក្រោយអកម្មធាតុ ដូចជា **គតោ**, **មតោ**, **ខុត្តោ**, **ឋិតោ**, **ឧបេតោ** (ល) ដោយច្រើនជា កត្តុវាចកៈ បើជាឯកវចនៈ នបុំសកលិង្គ ប្រើជាភាវវាចកៈបាន ។

ខ. **ត**-បច្ច័យចុះខាងក្រោយសកម្មធាតុ ធ្វើកម្មវាចកៈ កត្តុវាចកៈបាន ។ **លភតិ** រមែងបាន, អ្នកណាបាន ? **បុរិសោ** ឬ **គរុ** ឬ **មុនិ** ឬ **វិញ្ញូ** មិនគិតលិង្គ វិភត្តិ ការន្តអ្វីទេ ឲ្យតែបឋមបុរសឯកវចនៈ ដាក់ **កញ្ញា** ក៏បាន **នារី** ក៏បាន **កុលំ** ក៏បាន **លភតិ** ឯកវចនៈបានតែឯកវចនៈដែរ ដាក់ថា **សេដ្ឋី** រីសេដ្ឋី **លភតិ** រមែងបាន **បុត្តំ** នូវកូន,។ **គរុ** រីគ្រូ **លភតិ** រមែងបាន **សិស្សេ** នូវសិស្សទាំងឡាយ ។ **ជញ្ញា** មកពី **ញា**-ធាតុផ្លាស់ជា "**ជា**" **នា**-បច្ច័យ និង **ឯយ្យ**-សត្តមីផ្លាស់ទៅជា **ជញ្ញា** តែម្តង ប្រែថា : គប្បីដឹង, ត្រូវដឹង, គួរដឹង ។

## ១. វិធីរកបទប្រធាន

ដូចជា **លភតិ** "រមែងបាន" **ឯយ្យ**-ផ្លាស់ជាមួយនឹង

**ញ្ញា** ធាតុទៅជា **ជញ្ញា** តើ **ឯយ្យ** វចនៈអ្វី ? ឯកវចនៈ បើអញ្ចឹង នាមឲ្យតែបឋមបុរស ការន្តអ្វី លិង្គអ្វី ក៏ដោយឲ្យតែ ឯកវចនៈ ដូចជា **ឯយ្យ** ប្រែបានហើយ, ដាក់ **ឥត្ថី** ក៏បាន វិស្រីគប្បីចេះនូវធម៌ ។ **ចោរេតិ** លួច បើអ្នកណាចេះលួច អ្នកហ្នឹងគេ ហៅថា ចោរ ។ **ករឹសុ** មកពី **ករ**-ធាតុ **ឱ**-បច្ច័យ **ករ**-ធាតុ វានៅក្នុងពួក **តន**-ធាតុចុះ **ឱ**-បច្ច័យទៅជា **ករោ** និង **ឧំ** ផ្លាស់ជា **ឥំសុ** គឺលុប **ឱ** ចេញ ចុះ **ឥំសុ** នេះមកវិញ លុបស្រៈរបស់បច្ច័យចោល ហើយដាក់ស្រៈរបស់វិភត្តិវិញ វិភត្តិ ណាដែលជាតួអក្សរដូច **តិ**, **អន្តិ**, **សិ**, **ថ**, **មិ**, **ម**, គេទុកបច្ច័យ ។ តែបើកាលណាវិភត្តិជាស្រៈដូចជា **ឯយ្យ**, **ឯយ្យុំ**, **ឯយ្យាសិ**, **ឯយ្យាថ**, **ឯយ្យាមិ**, **ឯយ្យាម**, **ឦ**, **ឧំ**, **ឱ**, **ឥំ** កាលណាចុះបច្ច័យ មានស្រៈដូចគ្នា គេត្រូវលុបស្រៈរបស់បច្ច័យ ហើយទុកស្រៈរបស់វិភត្តិដើម្បីស្រួលរកប្រធាន ដូចជា **ករឹសុ** < **ឧំ** ជា **ឥំសុ** ហើយបើទុក **ឱ** ផង **ឥំសុ** ផងថា មិនកើតទេ ត្រូវលុប **ឱ** ចេញ **ករឹសុ** ធ្វើហើយ, អ្នកណាធ្វើ អ្នកនោះត្រូវជាពហុវចនៈ ព្រោះ **ឧំ** ជាពហុវចនៈ , ឯបទប្រធានការន្តអ្វីក៏ដោយលិង្គអ្វីក៏ដោយ ឲ្យតែពហុវចនៈក្នុងបឋមាវិភត្តិ, **ជនា** វិជន

ទាំងឡាយ **ករីសុ** ធ្វើហើយ **ទានំ** នូវ ទានក៏ត្រូវ ។ **អគមាសិ** បានទៅហើយ, តើ **សិ** អ្វី ? ពិចារណា ទៀត **សិ**-វត្តមានាវិភត្តិ ឬ ? បើវត្តមានាវិភត្តិមាន **អ**-អាគម ទេ ?

បើមាន **អ**-អាគម **អគមាសិ** មិនមែនវត្តមានាវិភត្តិទេ គឺ **សិ** មកអំពី **ស**-អាគម **ឦ**-អជ្ជត្តនី រស្សៈជា **ឥ** បានជាមាន **អ**-អាគមនៅខាងដើម, អជ្ជត្តនីអាចចុះអាគមបាន **អ**, **ស**, **ឞ** និគ្គហិតក៏អាចចុះបានទៀតប៉ុន្តែមិនសូវមានប្រើទេ **អ** នឹងជាអ្វី ? **ឦ** រស្សៈជា **ឥ** ជាបឋមបុរស ឯកវចនៈ បើបទប្រធានឲ្យតែឯកវចនៈធ្វើបទប្រធានបានហើយ **សមណោ** រីសមណៈ **អគមាសិ** បាននិមន្តទៅហើយ **អារាមំ** កាន់វត្ត ។

បើ **សុណោតិ** "ស្តាប់" **តិ**-វត្តមានាវិភត្តិ បឋមបុរស ឯកវចនៈ ទាល់តែស្គាល់ អញ្ចឹងបានរកប្រធានកើត អ្នកណាស្តាប់ ? អ្នកហ្នឹងបានតែឯកវចនៈ **ឧបាសកោ** រីឧបាសក **សុណាតិ** ស្តាប់ **ធម្មំ** នូវធម៌ ។

**អញ្ញាសិ** មកពី **អា + ញា**-ធាតុ ហើយក្នុងពេលនេះអត់ **នា**-បច្ច័យទេ បើ **នា**-បច្ច័យ **ជានាសិ**, ប៉ុន្តែ **អញ្ញាសិ**

មិនចុះ **នា**-បច្ច័យទេ ហើយបើអត់ចុះ **នា**, បច្ច័យអ្វីវិញ ? ថា **អ**-បច្ច័យក៏បាន ព្រោះ **អ**-បច្ច័យ ត្រូវតែលុប **អ** ចេញ វត្តមានាវិភត្តិ ឡើងអ្វី ? **ត្វំ** បើ **ស**-អាគម **ឡ្យ**-អជ្ជត្តនី បទប្រធានថាយ៉ាងណា ? **បុរិសោ បុគ្គលោ សាមណេរោ ភិក្ខុ ភិក្ខុនី កញ្ញា** បានទាំងអស់ឲ្យតែបឋមបុរសបានច្រើនណាស់ ។ **គច្ឆ** ចូរទៅ **គច្ឆ** វិភត្តិអ្វី ? ឲ្យតែរកវិភត្តិឃើញរកប្រធានឃើញ បើមិនស្គាល់វិភត្តិរកប្រធានមិនឃើញទេ ។ **គច្ឆ** មកពី **គម**-ធាតុផ្លាស់ជា **គច្ឆ** + **អ** បច្ច័យ + **ហិ** បញ្ចមីវិភត្តិ កាលណាទុក **ហិ** ត្រូវតែ **គច្ឆាហិ** កាលណាបើលុប **ហិ** ចេញ ត្រូវតែរស្សៈ ចុះបើរស្សៈស្រាប់ហើយមិនបាច់រស្សៈទៀតទេ បទប្រធានត្រូវឡើងអ្វី ? **សិ ហិ** ជាអ្វី បុរស ? មជ្ឈិមបុរិស បទប្រធាន ឯកវចនៈ ឬ ពហុវចនៈ ? ឯកវចនៈ អញ្ជើងឡើង **ត្វំ** **ត្វំ** រីអ្នកក៏បាន **ត្វំ** រីនាងក៏បាន **ត្វំ** រីឯង, រីវា **គច្ឆ** ចូរទៅចុះ។

**បាបុណិស្សាមិ** < **ប** + **អប** + **ឧណា**-បច្ច័យ, **ប** បូកនិង **អប** ប្រែថា ដល់, ទាន់, លុះ, **ឧណា**-បច្ច័យនៅពួកអ្វី ? **ឧណា** ហ្នឹងពួក **សុ**-ធាតុ ហើយចុះ **ឥ**-អាគមមកទៅជា **បា-បុណិស្សាមិ** , **ស្សាមិ** ជាវិភត្តិអ្វី ? **ស្សាមិ** ជាភវិស្សន្តិវិភត្តិ,

បុរសអ្វី ? ឧត្តមបុរស, វចនៈអ្វី ? ឯកវចនៈ, បទប្រធានមានតែមួយគឺ **អហំ**, **អហំ** វីខ្ញុំ **ចាបុណិស្សាមិ** នឹងដល់ **អរហត្តំ** នូវព្រះអរហត្ត ។ **អកាសិ** បានធ្វើហើយ, **វទ** ចូរពោល, **បច្ចតិ** តែងចម្អិន, **លភតេ** តែងបាន, **ករិយតេ** ធ្វើ, **គយ្ហតេ** កាន់យក, **គុយ្ហតេ** លាក់, **សុណាតិ** រមែងស្តាប់, **ភិន្ទិយតេ** តែងបំបែក ឬ ទម្លាយ, **មុច្ចតេ** តែងរួច, **ការេតិ** ឲ្យធ្វើ, **ភាវេតិ** ឲ្យច្រើន គឺចម្រើន, **ខមាបេសិ** ឲ្យអត់ទោសហើយ, **អាហរាបេសិ** ឲ្យនាំមកហើយ ។ សូមមើលត្រង់នេះសិន **ករិយតេ លព្ភតេ គយ្ហតេ** សុទ្ធតែ **យ**-បច្ច័យ តែបើផ្លាស់ **យ** ដូចជា **លភ** និង **យ** ទៅ **លព្ភ** អញ្ចឹង អត់ចុះ **ឥ**-អាគមទេ **គហ** ចុះ **យ** មក, **យ** វាជិះ **ហ** ដូច **គយ្ហតេ** បើផ្លាស់ដូច្នេះ មិនមាន **ឥ**-អាគមទេ ។ **ករិយតេ** អត់ផ្លាស់ត្រូវចុះ **ឥ**-អាគម ដូច្នេះប្រយោគហ្នឹងមើលធាតុ **បច្ចតិ** អាចប្រើ **តិ** បរស្សបទ ក៏បាន **លព្ភតេ គយ្ហតេ ករិយតេ ខុយ្ហតេ** ចុះក្នុងវាចកៈអ្វី ? **សូយតេ ភិន្ទិយតេ មុច្ចតេ** ចាត់ជា ប្រយោគអ្វី ? **យ** មាន **ឥ** ក៏មាន អត់ **ឥ** ក៏មានហើយចុះ សុទ្ធតែអត្តនោបទ ចាត់ជា ប្រយោគអ្វី ? បើរកវាចកៈមិនឃើញ រកប្រធានក៏មិនឃើញ ដែរ ។

បច្ច័យហ្នឹងវាប្រកបកម្មវាចកៈ បើកម្មវាចកៈ អ្នកណាប្រធាន ? ប្រធានវាឈ្មោះ អ្វី ? ឈ្មោះកម្ម តួកម្ម, ដូចជាពាក្យថា **បចតិ** ចម្អិន, ចម្អិនអ្វី ? ចម្អិនបាយ, បាយឡើងប្រធាន ចម្អិនបបរៗ ឡើងប្រធាន ចម្អិនគោៗ ឡើងប្រធាន ។ **លភតិ** តែងបាន បានអ្វី ? បានប្រពន្ធៗ ឡើងប្រធាន, បានកូនៗ ឡើងប្រធាន បានអ្នកណា អ្នកហ្នឹងជាប្រធាន អញ្ចឹងហៅថា តួកម្មហើយ ។ **ភរិយា** រីប្រពន្ធ ឥឡូវយក **លភតិ** មួយមកចុះ, អ្នកណាបាន អ្នកហ្នឹងជាតតិយាវិភត្តិប្រែថា គឺ ឬដែល, ថា **មយា** គឺខ្ញុំ **លភតិ** តែងបាន។ **ករិយតេ** ធ្វើ, ធ្វើសាលា, **សាលា** រីសាលា, អ្នកណាធ្វើ ជាងឈើ **វឌ្ឍកិនា** គឺជាងឈើ **ករិយតេ** តែងធ្វើ, **គយ្ហតេ** តែងកាន់យក, កាន់យកអ្វី ? កាន់បាត្រ **បត្តោ** រី បាត្រ **បព្វជិតេន** គឺបព្វជិត **គយ្ហតេ** តែងកាន់យក ។ **សូយតេ** ស្តាប់, ស្តាប់អ្វី ? ស្តាប់ធម៌ ធម៌ៗ ឡើងប្រធាន, ស្តាប់វិន័យៗ ឡើងប្រធាន អ្នកស្តាប់ជាតតិយាវិភត្តិ, **ភិន្ទិយតេ** បំបែក ទម្លាយ ទម្លាយអ្វី ? ទម្លាយរបងៗ ឡើងប្រធាន ទម្លាយទ្វារៗ ឡើងប្រធាន ។ អ្នកទម្លាយជាតតិយាវិភត្តិ ។ **មុច្ចតេ** រួច អ្នកណារួច ? រួចអំពីអ្វី ? **ការេតិ** តែងឲ្យធ្វើ, **ការាបេតិ** ឲ្យ

ចម្រើន, **ខមាបេសិ** ឲ្យអត់ទោសហើយ, **អាហរាបេតិ** ឲ្យនាំមក ។ **ការេតិ** ចុះ **ណេ**-បច្ច័យ **ខមាបេសិ** ចុះ **ណាបេ**-បច្ច័យ **អាហរាបេតិ**, **ណាបេ**-បច្ច័យទៀត បើអញ្ចឹងវាចកៈអ្វី ? **ហេតុ-កត្តុវាចកៈ**ៗ ត្រូវមានគ្នាប៉ុន្មាននាក់ ? យ៉ាងតិច ៣ នាក់ ប៉ុន្តែ បំពេញឲ្យច្រើនមក គ្រប់ចំនួន ៤ នាក់ ។ **ការេតិ** អ្នកណាធ្វើប្រធាន ? គឺអ្នកប្រើគេ **ភិក្ខុ** រីភិក្ខុ **សាមណេរេ** ញុំាងសាមណេរទាំងឡាយ **ការេតិ** ឲ្យធ្វើ ធ្វើអ្វី ? **កម្មំ** នូវការងារ **ទណ្ឌកម្មំ** នូវទណ្ឌកម្ម ។ **ឧបជ្ឈាយោ** រីឧបជ្ឈាយ៍ **សិស្សេ** ញុំាងសិស្សទាំងឡាយ **ការេតិ** ឲ្យធ្វើ ធ្វើអ្វី ? **កុដឹ** នូវកុដិ ។ **ខមាបេសិ** ជាអកម្មធាតុ បើអកម្មធាតុឡើង អ្នកណាញុំាងអ្នកណាឲ្យអត់ទោសហើយ **ខមាបេសិ**, **ស**-អាគម **ឡ**-អជ្ជត្តនីវស្សេៈជា **ឥ** អាចថាហើយ បើមិន ប្រែថា ហើយគឺ **សិ** វត្តមានាវិភត្តិ, **ខមាបេសិ** តែបើ ប្រែថា ហើយ គឺអជ្ជត្តនីវិភត្តិ ... **អាហរាបេសិ** ក៏អញ្ចឹងដែរ ឲ្យនាំមកហើយ, តែហើយ គឺ **ស**-អាគម **ឡ**-អជ្ជត្តនី បទប្រធាន ត្រូវតែ បឋមបុរស **ឧបជ្ឈា-យោ** រីឧបជ្ឈាយ៍ **មំ** ញុំាងខ្ញុំព្រះករុណា **អាហរាបេសិ** ឲ្យនាំមកហើយ, នាំអ្វី ? ដាក់តួកម្មមកទៀត ប៉ុន្តែ អ្នកប្រើជាបទ

ប្រធានជា **ហេតុកត្តុវាចក:** អ្នកណាប្រើគេ អ្នកហ្នឹងធ្វើប្រធានហើយ ។ **គតោ** ទៅហើយ **មតោ** ស្លាប់ ហើយ **លទ្ធោ** បានហើយ **ទិដ្ឋោ** ឃើញហើយ ។

## គោលនៃការប្រែបាលីមាន ៩ យ៉ាងគឺ

**១. អាលបន, ២. និបាតផ្ដើមសេចក្ដី, ៣. កាលត្ថសត្តមី, ៤. បទប្រធាន, ៥. បទពង្រីកប្រធាន, ៦. អនុកិរិយា និងប្រយោគវែ្រក, ៧. បទពង្រីក អនុកិរិយា និង បទពង្រីក-កិរិយាវែ្រក, ៨. មហាកិរិយា (កិរិយាឃុំគ្រងប្រយោគ), ៩. បទពង្រីក មហាកិរិយា ។**

ក្នុងប្រយោគដែលមានគោលទាំង ៩ យ៉ាងនេះ ការប្រែគួរកាន់យកបទតាមលំដាប់ តែបើខ្វះគោលណាមួយ ការប្រែត្រូវរំលងបទនោះចេញទៅដរាបដល់ ចប់ប្រយោគ ដូចជា **ឥទ្ធំ បស្ស នដបុត្ត ឧគ្គសេន មហព្វល** ប្រែថា **ឧគ្គសេន** ម្នាលឧគ្គសេន (ពេលអានឲ្យថា ឧគ្គសែន) **នដបុត្ត** ជាកូនអ្នករបាំ **មហព្វល** មានកម្លាំងច្រើន **ឥទ្ធំ** អញ្ជើញ **បស្ស** សូមមើលចុះ ។

## ១. អាលបន

សេចក្ដីអធិប្បាយ **អាលបនៈ** ពាក្យសម្រាប់ហៅរកគ្នា ហៅថា **អាលបនៈ** មាន ២ យ៉ាងគឺ :

**១. អាលបននាម** បានដល់ បទនាមដែលសម្រេចមកពី អាលបនវិភត្តិ ដូចជា **បុរិស, ភិក្ខវេ, ភន្តេ** ជាដើម ។

**២. អាលបននិបាត** បានដល់ និបាតសព្ទ ដូចជា **យគ្ឃេ ភន្តេ, ភណេ, អាវុសោ** ជាដើម ។ ក្នុងប្រយោគមួយមានអាលបនៈច្រើនបទត្រូវប្រែ អាលបននាមមុន ដូច **អម្ភោ កុមារកា ឯស សាលិកបោតកោ តំ គណ្ហាថ** ប្រែថា **កុមារកា** នៃកុមារទាំងឡាយ **អម្ភោ** វើយ **សាលិកបោត្តកោ** រីកូនសត្វសាលិកា **ឯសោ** នោះ **តុម្ហេ** រីឯងទាំងឡាយ **គណ្ហាថ** ចូរចាប់ **តំ** នូវវា ។

## លំហាត់ប្រែ

**១. អម្ភោ សាមណេរ សទ្ធាធិការោ ហុហឹ គតោ** ប្រែថា **សាមណេរ** ម្នាលសាមណេរ **អម្ភោ** ដ៏ចម្រើន **សទ្ធាធិការោ**

រីសង្ឃាធិការ (គឺលោកជាធំក្នុងសង្ឃ អធិការរបស់សង្ឃ) **គតោ** និមន្តទៅហើយ **កុហឹ** ក្នុងទីណា ។

**២. អាវុសោ មោគ្គល្លាន ទាយកានំ ធម្មំ ទេសេហិ** ប្រែថា **មោគ្គល្លាន** (ជាអាលបននាម) ម្នាលមោគ្គល្លាន **អាវុសោ** ដ៏មានអាយុ **ត្វំ** រីលោក **ទេសេហិ** សូមសម្ដែង **ធម្មំ** នូវធម៌ **ទាយកានំ** (**ទាយកានំ** ២ វិភត្តិ គឺ ចតុត្ថី និង ឆដ្ឋី) ដល់ទាយកទាំងឡាយ ។ **ឥធ ភន្តេ គាមទារិកា រុក្ខំ អារុហន្តិ** ប្រែថា **ភន្តេ** បពិត្រលោកដ៏ចម្រើន **គាមទារកា** រីក្មេងអ្នកស្រុកទាំងឡាយ **ឥធ គាមេ** ក្នុងស្រុកនេះ **អារុហន្តិ** តែងឡើង **រុក្ខំ** កាន់ដើមឈើ ។ **៦៥ សាមណេរា លេខ្ខុនា បហរិត្វា បាតេថ** ប្រែថា **សាមណេរា** ជាបទប្រធានកើតទេ ? មិនបានទេ, **សាមណេរា** មានប៉ុន្មានវិភត្តិ ? ដូច **បុរិសា** មានប៉ុន្មានវិភត្តិ ? ៣ វិភត្តិ ប៉ុន្តែពេលនេះយក **អាលបនះ** ហើយ ព្រោះធ្វើប្រធានមិនកើត **ថ** នោះ មានពួកម៉ាកវា អ្នកណាពួកម៉ាករបស់ **ថ** គឺ **តុម្ហេ** របស់ **ថ**, **សាមណេរា** កុំធ្វើប្រធាន, ធ្វើអាលបនៈថា **សាមណេរា** ម្នាលសាមណេរទាំងឡាយ **តុម្ហេ**

វីលោកទាំងឡាយ **ឯថ** ចូរមក ។ **ធាតេថ** ឡើង **តុម្ហេ** ទៀត ហើយ ចុះបើកុំឡើងបានទេ ? មិនបានទេ ពីព្រោះអ្វី ? ប្រយោគខុសគ្នា **ឯថ សាមណេរា** មួយប្រយោគ, **លេឌ្ឌុនា បហរិត្វា ធាតេថ** និងមួយប្រយោគទៀត **ឯថ** ជាប្រយោគ-កត្តុវាចកៈ **ធាតេថ** ជាប្រយោគអ្វី ? ជាហេតុកត្តុវាចកៈ បទប្រធានត្រូវតែឡើងទាំងពីរ បើប្រយោគត្រូវគ្នា កត្តុវាចកៈដូចគ្នា ឬ ហេតុកត្តុដូចគ្នា បទប្រធានឡើងតែមួយ ក៏បាន តែនេះប្រយោគខុសគ្នា ត្រូវប្រធានមួយម្នាក់ហើយ **តុម្ហេ** វីលោកទាំងឡាយ **ឯថ** ចូរមក **តុម្ហេ** វីលោកទាំងឡាយ **បហរិត្វា** ប្រហារហើយ ឬ គ្រវែងហើយ **លេឌ្ឌុនា** ដោយដុំដី **ធាតេថ** ចូរញ៉ាំងវាឲ្យធ្លាក់ចុះ (ចូរញ៉ាំងជាហេតុកត្តុ...) ។ បើអញ្ចឹង **តុម្ហេ** ខាងដើមជា **សយកត្តា** ក្នុង **ឯថ**, **តុម្ហេ** ខាងចុង ជា **ហេតុកត្តា** ក្នុង **ធាតេថ** ដូច្នេះ ដាច់ខាតត្រូវឡើងទាំងពីរ ។

**៣. ន គច្ឆាមិ ភន្តេ អហំ គាមំ** ប្រែថា **ភន្តេ** បពិត្រ-លោកដ៏ចម្រើន **អហំ** វីខ្ញុំ **ន គច្ឆាមិ** មិនទៅ **គាមំ** កាន់ស្រុកទេ ។

៤. **ភន្តេ មយំ ពាលា ន ភវេយ្យាម** ប្រែថា **ភន្តេ** បពិត្រលោកដ៏ចម្រើន **មយំ** វីខ្ញុំព្រះករុណាទាំងឡាយ **ពាលា ន ភវេយ្យាម** មិនគប្បីជាមនុស្សល្ងង់ខ្លៅទេ ។

៥. **អាវុសោ ឯថ បិណ្ឌាយ ចរិតុំ បវិសិស្សាម** ប្រែថា **អាវុសោ** ម្នាលលោកដ៏មានអាយុ **តុម្ហេ** វីលោក **ឯថ** ចូរមក **មយំ** វីយើងទាំងឡាយ **បវិសិស្សាម** នឹងចូលទៅ **ចរិតុំ** ដើម្បីត្រាច់ទៅ **បិណ្ឌាយ** ដើម្បីបិណ្ឌបាត ។

៦. **ត្វំ អម្ភោ បុរិស បិណ្ឌំ លភមានោ តំ ភុញ្ជាហិ** ប្រែថា **បុរិស** នែបុរស **អម្ភោ** ដ៏ចម្រើន **ត្វំ** វីលោក **លភមានោ** កាលបាន **បិណ្ឌំ** នូវដុំបាយ **ភុញ្ជាហិ** ចូរឆាន់ **តំ បិណ្ឌំ** នូវដុំបាយនោះចុះ ។

៧. **អម្ហាកម្បន** កាត់បទថា **អម្ហាកំ** + **បន** = **អម្ហាកម្បន ពុទ្ធោ លោកេ ឧប្បន្នោ ហោតិ** ប្រែថា **បន** ក៏ **ពុទ្ធោ** វីព្រះពុទ្ធ **អម្ហាកំ** នៃយើងទាំងឡាយ **លោកេ ឧប្បន្នោ ហោតិ** ជាព្រះអង្គទ្រង់កើតឡើងហើយក្នុងលោក ។ **អហំ ភន្តេ ធានេន គោគំ លភាមិ** ប្រែថា **ភន្តេ** បពិត្រលោកដ៏ចម្រើន **អហំ** វីខ្ញុំ

**លភាមិ** តែងបាន **ភោគំ** នូវភោគ **ទានេន** ដោយការឲ្យ (ឲ្យអ្វី ? ឲ្យទាន) ។ លំហាត់ប៉ុណ្ណេះ សមគួរហើយ បទខាងលើនេះ សិក្ខាកាមត្រូវឆ្លើយឲ្យត្រឹមត្រូវថា បទទាំងអស់នេះមកពី **លិង្គ ការន្ត វិភត្តិ** អ្វី ? ត្រូវប្រែដូចម្តេច ? ឬសម្រេចមកពីធាតុបច្ច័យអ្វី ? វិភត្តិអ្វី ? ឈ្មោះវាចកៈអ្វី ?

## ២. និបាត

សំដៅយកនិបាតផ្តើមសេចក្តី គឺ **ហិ**, **ច**, **បន**, **តុ**, **អបិ ច**, **អថវា**, និបាតប្រាប់សេចក្តីបានឮ **កិរ**, **ខលុ**, **សុទំ**, និបាតប្រាប់បរិកប្ប **អថ**, **យទិ**, **ចេ**, **សចេ**, **ឧទាហុ**, **អាទូ**, ប្រាប់សេចក្តីទទួល **អាម** ជាដើម ដូចជា **តាត មហល្លកស្ស ហិ អត្តនោ ហត្ថបាទាបិ អនស្សវា ហោន្តិ** ប្រែថា **តាត** នែប្អូន **ហិ** ព្រោះថា **ហត្ថបាទាបិ** សូម្បីរីដៃនិងជើងទាំងឡាយ **អត្តនោ** នៃខ្លួន **មហល្លកស្ស** របស់បុគ្គលចាស់ **អនស្សវា ហោន្តិ** ជាអវយវៈមិនស្តាប់បង្គាប់ ។

## ៣. កាលសត្តមី

សព្ទប្រាប់ពេលវេលាមាន ៣ យ៉ាងគឺ :

១/ បទនាមសព្ទប្រាប់ពេលប្រកបដោយទុតិយាវិភត្តិ **ឯកំ ទិវសំ**, **ឯកទិវសំ**, **ឯកំ សមយំ ទិវសំ** ក្នុងថ្ងៃ **ឯកំ** មួយ , **ឯកទិវសំ** ក្នុងថ្ងៃមួយ, **សមយំ** ក្នុងសម័យ **ឯកំ** មួយ, គេអត់ពន្យល់ ប្រែទេ ប៉ុន្តែខ្ញុំព្រះករុណាពន្យល់ ។

តតិយាវិភត្តិ **តេន សមយេន**, **ឯកេន សមយេន**, **សមយេន** ក្នុងសម័យ **តេន** នោះ, **សមយេន** ក្នុងសម័យ **ឯកេន** មួយ ។

សត្តមីវិភត្តិ **ឯកស្មឹ សមយេ**, **វេលាយំ**, **រត្តោ** ... **សមយេ** ក្នុងសម័យ **ឯកស្មឹ** មួយ, **វេលាយំ** ក្នុងពេល ឬ ក្នុងវេលា, **ទិវា** ក្នុងវេលាថ្ងៃ (ជានិបាត) តែ **រត្តោ** ជានាម **រត្តិយំ រត្យំ រត្តោ** ក្នុងរាត្រី ក្នុងពេលយប់ ។

២/ និបាតប្រាប់កាល ... **អថ**, **បាតោ**, **ទិវា**, **សាយំ**, **សុវេ**, **ហីយ្យោ** ជាដើម ។

៣/ សព្វនាមប្រកបដោយ **ទា**, **ទានិ**, **រហិ**, **ធុនា**, **ទាចនំ**, **ជ្ជ**, **ជ្ជុ** ដូចជា **យទា**, **តទា**, **ឥទានិ**, **អជ្ជ** ជាដើម, **យ** និង

**ទា**, **យ** ហ្នឹងជាសព្វនាម ហើយបូកនឹង **ទា**-បច្ច័យ **យទា** ក្នុងកាលណា **តទា** ក្នុងកាលនោះ **ឥម** សព្វលុប **ម** ចេញទៅផ្សំនឹង **ទានិ** ទៅជា **ឥទានិ** ប្រែថា ក្នុងកាលនេះ ក្នុងកាលឥឡូវនេះ ដូចជា **អជ្ជ** មកពី **ឥម** ផ្លាស់ជា **អ** បូកនឹង **ជ្ជ**-បច្ច័យ ទៅជា **អជ្ជ** អញ្ចឹងជាដើម ។

## លំហាត់ប្រែ

**១/ ឧបោសថទិវសេ បន អាវុសោ អគ្គី ជាលេយ្យាថ**

ប្រែថា **អាវុសោ** គោលទី ១, និបាតផ្ដើមសេចក្ដីទី ២, កាលសត្តមីទី ៣, បទប្រធានទី ៤, **ទិវសេ** អការន្តបុំលិង្គ បំបែកដូច **បុរិស** អញ្ចឹង ជាប់សមាសប៉ុន្មានក៏ដោយឲ្យតែ **ទិវសេ** នៅចុងហើយ ពួកនោះទៅជា **អ**-ការន្តបុំលិង្គ ទាំងអស់ហើយ ។ **លិង្គ** អ្វីក៏ដោយ សព្វចុងបំផុតជា **អ**-ការន្ត បុំលិង្គ បំបែកដូច **បុរិស** ។ **បន** ជានិបាតផ្ដើមសេចក្ដី **អាវុសោ** ជា **អាលបននិបាត** ហើយបទប្រធាននៅឯណា ? អត់មានត្រូវថែម, **ឯយ្យាថ** បទប្រធានថា យ៉ាងម៉េច ?

**១. អាវុសោ** ម្នាលលោកដ៏មានអាយុទាំងឡាយ ព្រោះ

**អាវុសោ** ហ្នឹងមិនមាន វចនៈទេ មិនមានលិង្គ មិនមានការន្តទេ, **អាវុសោ** ម្នាលលោកដ៏មានអាយុទាំងឡាយ **មន** ចុះ **ឧបោសថទិវសេ** ក្នុងថ្ងៃឧបោសថ **តុម្ហេ** រីលោកទាំងឡាយ **ជាលេយ្យាថ** គប្បីដុត **អគ្គឹ** នូវភ្លើង ។ តែម្យ៉ាងទៀត លោកថាបុគ្គលតែម្នាក់ ប៉ុន្តែយើងនិយាយដោយ ការគោរពត្រូវឡើងពហុវចនៈ ប៉ុន្តែមិនបាច់ថាទាំងឡាយទេ, ភាសាជិតយើងនេះគេថាតែពហុវចនៈ ប្រែថា "ទាំងឡាយ, ហើយ" ប៉ុន្តែខ្មែរថា បើលោកធំ ដូចជាសម្តែងអាបត្តិជាមួយនឹងលោកចាស់ មិនថាទាំងឡាយទេ ព្រោះតែលោកប្រើដោយគោរពដូចជា **បស្សថ ភន្តេ តំ អាបត្តិំ** ។

២. **ឯកទិវសំ ហិ ភន្តេ ឯកោ ភិក្ខុ អរញ្ញេ កម្មំ ទិវសំ កត្វា សាយំ បច្ឆាគច្ឆតិ** ប្រែថា **ភន្តេ** បពិត្រលោកដ៏ចម្រើន **ហិ** មែនពិត **ឯកទិវសំ** ក្នុងថ្ងៃមួយ **ភិក្ខុ** រីភិក្ខុ **ឯកោ** មួយអង្គ **កត្វា** ធ្វើហើយ **កម្មំ** នូវការងារ **អរញ្ញេ** ក្នុងព្រៃ **ទិវសំ** អស់មួយថ្ងៃ **បច្ឆាគច្ឆតិ** តែងវិលមក **សាយំ** ក្នុងវេលាល្ងាច ។

៣. **ហរេ ខុជ្ជេ មម តំ ភារណំ ទទេហិ** ប្រែថា **ខុជ្ជេ**

នៃមេគម **ហរេ** ចង្រៃ **តំ** រីហេង **វទេហិ** ចូរប្រាប់ **ការណំ** នូវហេតុ **តំ** នោះ **មម** ដល់អញ ។ **តេនហិ ភិក្ខវេ សុណាថ** ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **តេនហិ** បើដូច្នោះ (អត់មានកាលសត្តមីទេ) **តុម្ហេ** រីលោកទាំងឡាយ **សុណាថ** ចូរស្តាប់ចុះ ។

**៤. សចេ សាមណេរា សីលំ សមាទយិត្វា សុគតឹ បាបុណេយ្យាថ** ប្រែថា **សាមណេរា** ម្នាលសាមណេរទាំងឡាយ **សចេ** ថាបើ **តុម្ហេ** រីលោកទាំងឡាយ **សមាទិយិត្វា** សមាទានហើយ **សីលំ** នូវសីល **បាបុណេយ្យាថ** គប្បីដល់ **សុគតឹ** នូវសុគតិ ។

**៥. ហន្ទ មយំ ពុទ្ធស្ស ភគវតោ បុព្វភាគនមការំ ករោមសេ** (មិនមានអាលបនៈទេ) និបាត មានគឺ **ហន្ទ** (កាលៈគួសត្តមីមិនមានទេ) ប្រធានមានគឺ **មយំ** ត្រូវនឹង **ករោម** ឯណោះ **សេ** ជា **និបាត** មិនមែននិបាតផ្តើមសេចក្តីទេ និបាតគ្រាន់តែបំពេញពាក្យជា **បូរណនិបាត** ប្រែថា **ហន្ទ** ថ្វីបើ **មយំ** រីយើងទាំងឡាយ **ករោមសេ** តែងធ្វើ **បុព្វភាគនមការំ**

នូវការនមស្សការជាចំណែកខាងដើម **ភគវតោ** ចំពោះព្រះមានព្រះភាគ **ពុទ្ធស្ស** ជាព្រះពុទ្ធ (មួយប្រែចេញ **អាយតនិបាត**) បន្ទាប់មកប្រែថា ជាព្រះពុទ្ធ ។

៦. **អយំ មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ** (**តិ** បឋមបុរស ឯកវចនៈ) **អយំ រុក្ខោ** រីឈើនេះ **ទេវតាយ មហេសក្ខាយ បរិគ្គហិតោ ភវិស្សតិ** នឹងជាឈើគឺទេវតាមានស័ក្តិធំហ្នួងហែងហើយ, ប្រែក្នុងពេលនេះ ទៅជាតតិយាវិភត្តិ ព្រោះ **បរិគ្គហិតោ ភវិស្សតិ** កាត់បទថា **បរិ**-បុព្វបទ + **គហ**-ធាតុ + **ឥ**-អាគម + **ត**-បច្ច័យ ហើយទៅជា **វិភត្តិកត្តា** និង **ភវិស្សតិ** ។

៧. **អក្ខីនិ មេ អាវុសោ បរិហីនានិ** (**បរិហីនានិ ត**-បច្ច័យ ផ្លាស់ជា **ឦន** ទៅជា **បរិហីនំ** ដូច **អក្ខីនិ បរិហីនានិ**) ប្រែថា **អាវុសោ** ម្នាលលោកអ្នកមានអាយុទាំងឡាយ **អក្ខីនិ** រីភ្នែកទាំងឡាយ **មេ** របស់ខ្ញុំ **បរិហីនានិ** សាបសូន្យហើយ (សាបសូន្យអស់ហើយអញ្ចឹងក៏បាន) ។ **តេនហិ ភន្តេ គច្ឆថ ភន្តេ** បពិត្រលោកដ៏ចម្រើនទាំងឡាយ **តេនហិ** បើដូច្នោះ

**ភិក្ខវេ** រីលោកទាំងឡាយ **គច្ឆថ** ចូរទៅចុះ។

**៨. ឥទានិ ភន្តេ កឹ ភត្តព្វំ** (បើ **ភត្តព្វំ** កិរិយាជាសកម្មធាតុ ត្រូវប្រើជាកម្មវាចកៈ បើអកម្មធាតុ ប្រើជាភាវវាចកៈ) **ភន្តេ** បពិត្រលោកដ៏ចម្រើន **ឥទានិ** ក្នុងកាលឥឡូវនេះ **កឹ ភម្មំ** រីអំពើដូចម្តេច **មយា** គឺខ្ញុំព្រះករុណា **ភត្តព្វំ** គប្បីធ្វើ ។

**៩. មហារាជ មម ឥមស្មឹ ទេវលោកេ មាតាបិតរោ វា ភាតិកភគិនិយោ វា នត្ថិ** ប្រែថា **មហារាជ** បពិត្រមហារាជ **មាតាបិតរោ វា** រីមាតានិងបិតាទាំងឡាយក្តី **ភាតិកភគិ-និយោ វា** រីបងប្អូនប្រុសនិងបងប្អូនស្រីទាំងឡាយក្តី **មម** របស់ខ្ញុំ **នត្ថិ** មិនមាន **ទេវលោកេ** ក្នុងទេវលោក **ឥមស្មឹ** នេះ ។ គេប្រែក្រោយកិរិយា ព្រោះ **ទេវលោកេ** ជាកន្លែងនៅ សម្ពន្ធចូលនឹង **នត្ថិ**ៗ ជានិបាតាខ្យាតបទ មិនមែនជាកិរិយាអាខ្យាតទេ និបាតកិរិយាជាកត្តុវាចកៈ ។

ក្នុងប្រយោគមួយណាមានកាលសត្តមីដូចម្តេច ? សូមពន្យល់ផង ។

## ៤. ប្រធាន

បន្ទាប់ពី **អាលបនៈ និបាត** និង **ការលក្ខសត្តមី** មកសិក្សាកាម ត្រូវប្រែបទប្រធាន ។ ប្រធានគឺជាអ្នកធំជាម្ចាស់របស់កិរិយាក្នុងប្រយោគ ។

## លក្ខណៈរបស់បទដែលធ្វើប្រធានបានគឺ

**១. បទនាមនាម** ឬ **បុរិសសព្វនាម ត**-សព្ទ **តុម្ហ**-សព្ទ **អម្ហ**-សព្ទ ដូចជា **បុរិសោ** វីបុរស **ឥត្ថី** វីស្ត្រី **អហំ** វីខ្ញុំ **ត្វំ** វីឯង ។ល។

**២. បទសង្ខ្យាប្រភេទនាមនាម** ដូចជា **ភិក្ខូនំ សតំ** វីរយនៃភិក្ខុទាំងឡាយ **ទ្វេ សហស្សានិ** វីពាន់ទាំងឡាយពីរ ។ល។

**៣. បទសមាស** ប្រភេទនាមនាម ដូចជា **មហាថេរោ រាជបុត្តោ** ។ល។

**៤. បទតទ្ធិត** ប្រភេទនាមនាម **សាមណេរា សាមញ្ញំ សហាយតា** ។ល។

៥. **បទនាមកិតកៈ** ដែលប្រើជានាមនាម ដូចជា **ទាយកោ សាវកោ សមាធិ រាគោ ករណំ គមនំ** ។ល។

៦. **បទកិរិយាកិតកៈ** ខ្លះ ដែលប្រើជានាមនាម ដូចជា **ពុទ្ធោ ជីវិតំ ខាទនីយំ គន្តព្វំ** ។ល។

និបាតខ្លះដែលចុះក្នុងអត្ថបឋមាវិភត្តិ ដូចជា **អលំ** រី ល្មមហើយ **តថា** រីយ៉ាងនោះ **ឯវំ** រីយ៉ាងនេះ **អជ្ជ** រីថ្ងៃនេះ **សាធុ** រីល្អហើយ **សក្កា** រីកិរិយាគឺគេអាច ។

៧. **សត្តមីបច្ចត្ត សយកត្តា** បទនាមនាមប្រកប សត្តមីវិភត្តិ ប្រើជាប្រធាន បានខ្លះដូចជា **អសុកគាមគមន-ដ្ឋានេ** រីទីជាទីទៅកាន់ស្រុកឯណោះអំពីស្រុកនោះ (ធម្មបទ ភាគ៣) ។ល។

## បែបពិនិត្យរកបទប្រធាន

ក្នុងការស្វែងរកប្រធាន សិក្ខាកាមត្រូវពិនិត្យមើល កិរិយាប្រចាំប្រយោគដូច្នេះ :

១. បើកិរិយាអាខ្យាត បទប្រធាន និង កិរិយាអាខ្យាត ដាច់ខាតត្រូវមានវចនៈ និង **បុរិស** ដូចគ្នា សូម្បីក្នុងប្រយោគនោះ មិនរៀងទុកប្រធានក៏ដោយ ត្រូវតែ បន្ថែមមកឲ្យមានវចនៈ **បុរិស** ស្របគ្នា ដូចជា **ឯហិ ភិក្ខុ** (**ភិក្ខុ** រីលោក) **ភិក្ខុ** ចូរពោល **ឯហិ** យ៉ាងនេះ ។

២. បើកិរិយាកិតកៈ **ត**, **តព្វ**, **អនីយ**-បច្ច័យ បទប្រធាន និង កិរិយា ត្រូវមាន លិង្គ វចនៈ និង វិភត្តិ ដូចគ្នា ។ ក្នុងករណីប្រយោគនោះ មានបទនាមនាមដែលអាចធ្វើ ប្រធានបានមានពីរគឺ ជាសាធារណនាម ១ ជាអសាធារណនាម ១ ឲ្យប្រែ សាធារណនាម ជាប្រធានមុនទើបប្រែ អសាធារណនាម ជាបទវិសេសនៈក្រោយ ដូចជា **អថខោ កោកាលិកោ ភិក្ខុ** (ប្រែ) **អថខោ** គ្រានោះឯង **ភិក្ខុ** រីភិក្ខុ **កោកាលិកោ** ឈ្មោះកោកាលិក ។

## ឈ្មោះប្រធានក្នុងប្រយោគ

**១. កត្តុវាចកៈ** ប្រធានឈ្មោះ **សយកត្តា** ជាអ្នកបញ្ជាក់កិរិយាដោយខ្លួនឯង ប្រកបដោយបឋមាវិភត្តិ អ្នកណាធ្វើខ្លួន

ឯង អ្នកហ្នឹងជា **សយកត្តា** ប្រកបដោយបឋមាវិភត្តិ ។

**២. កម្មវាចក:** ប្រធានឈ្មោះ **វុត្តកម្ម** ជាតួកម្មដែលគេត្រូវធ្វើប្រកបដោយ បឋមាវិភត្តិ ។

**៣. ភាវវាចក:** ប្រធានឈ្មោះ **អនភិហិតកត្តា** ប្រកបដោយតតិយាវិភត្តិ ប្រែថា គឺ ... ។

**៤. វីរិយេន បុរិសេន ធនានិ លព្ភន្តេ** ប្រែថា **ធនានិ** រីទ្រព្យទាំងឡាយ **បុរិសេន** គឺបុរស **វីរិយេន** មានសេចក្តីព្យាយាម **លព្ភន្តេ** តែងបាន **ធនានិ** ជាពហុវចន: ត្រូវគ្នានឹង **លព្ភន្តេ** បើជា **ធនំ** វិញ ត្រូវតែ **លព្ភតេ** ។

**៥. អាចរិយោ អត្តនោ សិស្សេ ធម្មំ សាវេតិ** ប្រែថា **អាចរិយោ** រីអាចារ្យ **សិស្សេ** ញ៉ាំងសិស្សទាំងឡាយ **អត្តនោ** របស់ខ្លួន **សាវេតិ** ឲ្យស្តាប់ **ធម្មំ** នូវធម៌ ។

**៦. អម្ហាកំ អាវុសោ ពុទ្ធោ គោតមេន គោតមោ នាម ហោតិ** ប្រែថា **អាវុសោ** ម្នាលលោកដ៏មានអាយុទាំងឡាយ **ពុទ្ធោ** រីព្រះពុទ្ធ **អម្ហាកំ** របស់យើងទាំងឡាយ **គោតមេន**

**គោតមោ នាមហោតិ** ជាព្រះពុទ្ធទ្រង់ព្រះនាមថា **គោតម** ដោយគោត្រ ។

**៧. អញ្ញតរោ ភិក្ខុ គាមំ បិណ្ឌាយ បវិដ្ឋោ** ប្រែថា **ភិក្ខុ** រីភិក្ខុ **អញ្ញតរោ** មួយរូប **បវិដ្ឋោ** ចូលទៅហើយ **គាមំ** កាន់ស្រុក **បិណ្ឌាយ** ដើម្បីបិណ្ឌបាត ។

**៨. ឯស រុក្ខោ វាតេន បហដោ តស្ស បណ្ណានិ បតិតានិ** ប្រែថា (**បហដោ** ប្រហារ វាយ ជាកិរិយាកិតក: **ប**-បុព្វបទ + **ហរ** + **ត**-បច្ច័យ) **រុក្ខោ** រីឈើ **ឯសោ** នេះ **វាតេន** គឺខ្យល់ **បហដោ** ប្រហារហើយ **បណ្ណានិ** រីស្លឹកទាំងឡាយ **តស្ស** របស់វា **បតិតានិ** ជ្រុះចុះហើយ ជាប្រយោគ **កត្តុវាចក:** ។

**៩. អវស្សំ មយា មរិតព្វំ, មយា** គឺយើង **មរិតព្វំ** គប្បីស្លាប់ **អវស្សំ** ដោយពិត ជាប្រយោគ **ភាវវាចក:** ។

## ៥. អនុកិរិយា និង ប្រយោគប្លែក

អនុកិរិយាគឺជាកិរិយាបន្ទាប់ កិរិយាតូច សំដៅយកកិរិយាកិតក:ទាំងឡាយកិរិយាដែលប្រកបដោយ **អន្ត** (**គវន្តុ**,

**តាទិ**) **តព្វ**, **អនីយ**, **មាន** និង **ត**-បច្ច័យ ទាំងអព្យយកិរិយា ដែលប្រកបដោយ **ត្វា**, **ត្វាន**, **តូន**-បច្ច័យ ។

**១/ បទកិរិយាកិតក:** ប្រកប **ត្យ**-បច្ច័យ ជាបឋមាវិភត្តិ មានលិង្គ វចន:ដូច ប្រធាន ប៉ុន្តែរៀងទុកនៅខាងមុខប្រធាន ហៅថា វិសេសន: និងប្រកបដោយវិភត្តិ ដទៃក្រៅអំពីបឋមាវិភត្តិ ក៏ចាត់ជាបទវិសេសន:ទាំងអស់ដូចជា **មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ** ប្រែថា "**បុញ្ញំ** រីបុណ្យ **មយា កតំ** ដែលខ្ញុំធ្វើហើយ **សាមិនា** គឺលោកម្ចាស់ **អនុមោទិតព្វំ** គប្បីត្រេកអរតាម" **កតំ** រៀងនៅមុខប្រធាន **បុញ្ញំ**, **កតំ** ជាវិសេសន:របស់ **បុញ្ញំ**ៗ វុត្តកម្មក្នុង **អនុមោទិតព្វំ**ៗ កិតបទ-កម្មវាចក: **មយា** អនភិហិតកត្តាក្នុង **កតំ** **សាមិនា** អនភិហិតកត្តាក្នុង **អនុមោទិតព្វំ** ។

**សេដ្ឋី ឥត្ថឹ គាមំ គច្ឆន្តឹ បស្សន្តោ តំ បក្កោសតិ** (**ប**-បុព្វបទ **កុស**-ធាតុ **អ**-បច្ច័យ) ប្រែថា **សេដ្ឋី** រីសេដ្ឋី **បស្ស-ន្តោ** កាលឃើញ **ឥត្ថឹ** នូវស្ត្រី **គច្ឆន្តឹ** កំពុងទៅ **គាមំ** កាន់ស្រុក **បក្កោសតិ** តែងហៅ **តំ** នូវវា (**តំ** នូវវា គឺប្រែ **ត**-សព្វ

ជាបុរិសសព្វនាម បើ **ត**-សព្ទក្នុងវិសេសនសព្វនាម ត្រូវថែម **តំ ឥត្ថី** នូវស្ត្រីនោះ) **គច្ឆន្តី** ជាវិសេសនៈរបស់ **ឥត្ថី**, បើរៀងទុកក្រៅអំពីបឋមាវិភត្តិ មានទុតិយាវិភត្តិជាដើមទៅ សុទ្ធតែជាវិសេសនៈទាំងអស់ គឺ **អន្ត**, **តវន្តុ**, **តាវី**, **ត**, **តព្វ**, **អនីយ**, **មាន**-បច្ច័យ ។ បើរៀងទុកខាងដើមប្រធាន ក្រៅអំពី បឋមា-វិភត្តិ ក៏ជាវិសេសនៈទាំងអស់ បើថាជាបឋមាវិភត្តិ ក៏ជាវិសេសនៈដែរ ។

បើមាន លិង្គ វចនៈ វិភត្តិ ដូចបទប្រធាន ប៉ុន្តែរៀងទុកខាងក្រោយប្រធាន ក្នុងប្រយោគមានកិរិយា អាខ្យាតឃុំគ្រងពាក្យ ហៅថា **អព្ភន្តរកិរិយា** ឬ **វិកតិកត្តា** ចំពោះតែ **ត**-បច្ច័យ ដូចជា **អាគន្ត្វា វាតបានឧម្មារេ ឋិតោបិ ន លភិស្សសិ** (ប្រែថា **ត្វំ** រីលោក **អាគន្ត្វា** មកហើយ **វាតបានឧម្មារេ ឋិតោបិ** សូម្បីឈរហើយលើធរណីនៃបង្អួចក៏ដោយ **នលភិស្សសិ** នឹងមិនបាន **មុខំ** នូវនំទេ) ។ **អាគន្ត្វា** ក្តី **ឋិតោ** ក្តី ចាត់ជា អនុកិរិយា ប៉ុន្តែមានឈ្មោះខុសគ្នា ។ **អាគន្ត្វា** បុព្វកាលកិរិយាក្នុង **ឋិតោ**ៗ នេះជា អព្ភន្តរកិរិយា ព្រោះកិរិយានៅខាងក្នុង, បើគ្មានអាខ្យាតទេ **ឋិតោ** អាចធ្វើធំបាន ប៉ុន្តែមានកិរិយាអាខ្យាត **ឋិតោ** ចាត់

ជាអព្ភន្តរកិរិយា ប្រែថាកិរិយាខាងក្នុងក្រៃពេក (**អតិ** និង **អន្តរ**) ។ **អយំ មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ អយំរុក្ខោ** រីឈើនេះ (រូបដោយអំណាចកិរិយា រូបថា) **មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ** នឹងជាឈើ គឺ ទេវតាមានស័ក្តិធំហ្វូងហែងហើយ ។ **ត**-បច្ច័យដែលរៀងទុកមុខប្រធាន ហៅថា វិសេសនៈដែលរៀងទុកខាងក្រោយប្រធាន ចាត់ជា **វិកតិកត្តា** វិញ ។

ខាងក្រោយប្រធាន ទៅជា **វិកតិកត្តា** ហៅថា **អព្ភន្តរ-កិរិយា** ឬ **វិកតិកត្តា** ចំពោះតែ **ត**-បច្ច័យ **ឋិតោ** ជា **អព្ភន្តរ-កិរិយា** ។ **ពុទ្ធំ សរណំ គតោស្មិ, ពុទ្ធំ សរណំ គតាស្មិ** បទប្រធានមានតែមួយគឺ **អហំ**, **គតោស្មិ** នេះជាបុំលិង្គ, **គតាស្មិ** ជាឥត្ថីលិង្គ, **អហំ** ទាំងពីរហ្នឹងខុសគ្នា **អហំ** ខាង **គតោស្មឹ** នេះជាបុំលិង្គ ប្រែថា **អហំ** រីខ្ញុំព្រះករុណា **គតោ អស្មិ** ជាអ្នក ដល់ហើយ **ពុទ្ធំ** នូវព្រះពុទ្ធ **សរណំ** ថាជាទីពឹងទីរលឹក, **អហំ** រីខ្ញុំម្ចាស់ **គតា អស្មិ** សូមជាស្ត្រីដល់ហើយ **ពុទ្ធំ** នូវព្រះពុទ្ធ **សរណំ** ថាជាទីពឹង ។

២/ បទកិរិយាដែលប្រកបដោយអព្យយ បច្ច័យៗ មានឈ្មោះ **បុព្វកាលកិរិយា** ជាដើម (សូមមើលក្នុងសម្ពន្ធមាលា)

ដែលមិនប្រែប្រួលតាមលិង្គ វចនៈ វិភត្តិទេ គឺ នៅដដែល ហៅថា **អព្យយ**-បច្ច័យ មានឈ្មោះដូចជា **សោ តតោ និក្ខមិត្វា អរញ្ញេ គាយិត្វា ធាវូនិ ឧទ្ធរន្តិយា ឯកិស្សា ឥត្ថិយា គីតំ សុត្វា សរេ និមិត្តំ គណ្ហិ** ប្រែថា **សោ សាមណេរោ** រី សាមណេរនោះ **សុត្វា** ឮហើយ **គីតំ** នូវចម្រៀង **ឥត្ថិយា** នៃស្ត្រី **ឯកិស្សា** ម្នាក់ (រូបដោយអំណាចប្រយោគមាត្រា រូបតាំងពី **តតោ** ថែម **គាមតោ** មក) **តតោគាមតោ និក្ខមិត្វា អរញ្ញេ គាយិត្វា ធាវូនិ ឧទ្ធរន្តិយា** (**អន្ត** ប្រែថា កាល) កាលចេញអំពីស្រុកនោះហើយច្រៀង រើឡើងនូវឧសទាំងឡាយក្នុងព្រៃ **គណ្ហិ** កាន់យកហើយ **និមិត្តំ** នូវនិមិត្ត **សរេ** ក្នុងសម្លេង (**ត្វា** មាន ៣ កន្លែង **និក្ខមិត្វា ១ គាយិត្វា ១ សុត្វា ១**, **និក្ខមិត្វា** ជាបុព្វកាលកិរិយាក្នុង **គាយិត្វា**ៗ អត់ប្រែថាហើយទេ (ព្រោះច្រៀងផងរើឧសផងជាសមានកាល) **គាយិត្វា** សមានកាលកិរិយាក្នុង **ឧធរន្តិយា**, **អរញ្ញេ** ជា **អាធារៈ** ក្នុង **ឧទ្ធរន្តិយា** ទាំងច្រៀង ទាំងរើឧសនៅក្នុងព្រៃ, **ធាវូនិ** អវុត្តកម្មក្នុង **ឧទ្ធរន្តិយា**ៗ ក្តី **ឯកិស្សា** ក្តី ជាវិសេសនៈរបស់ **ឥត្ថិយា**ៗ

ជាម្ចាស់ចំរៀង **សុត្វា** នេះ ជាបុព្វកាលកិរិយាក្នុង **គណ្ឋិ** (ពីព្រោះស្តាប់ ហើយបានចាប់យកនិមិត្តក្នុងសំឡេង) ប្រយោគជ្រែក បានសេចក្តីថា វាមិននៅម្នាក់ឯងទេ វាត្រូវជ្រែកគេ ហៅថា ប្រយោគជ្រែក សេចក្តីផ្សេងពីសេចក្តីដើម ជ្រែកចូលមកខាងក្នុង ឬ កណ្តាលប្រយោគធំ ហើយមានប្រធាន និងកិរិយារបស់ប្រយោគជ្រែកមានពីរយ៉ាងគឺ :

**១. ប្រយោគអនាទរៈ** ប្រធាន និងកិរិយារបស់ ប្រយោគនេះ ប្រកបដោយឆដ្ឋីវិភត្តិ ប្រែថា : "កាល, កាលបើ, កាលដែល" ដូចជា **សាមណេរា ឯកតោ ទូរទស្សនេ កីឡំ បស្សិត្វា អាចរិយស្ស អាគច្ឆតោ បលាយឹសុ** ប្រែថា **សាម-ណេរា** រីសាមណេរទាំងឡាយ **បស្សិត្វា** មើលហើយ **កីឡំ** នូវកីឡា **ទូរទស្សនេ** ក្នុងវត្ថុសម្រាប់មើលនូវរូបក្នុង ទីឆ្ងាយ (ជា **មជ្ឈេលោប** សមាសលុបរូបកណ្តាលចេញ) **ឯកតោ** ក្នុងទីជាមួយគ្នា **អាចរិយស្ស** កាលដែលអាចារ្យ **អាគច្ឆតោ** កាលមក **បលាយឹសុ** រត់ទៅហើយ ។ **អាចរិយស្ស** និង **អាគច្ឆតោ** ជាប្រយោគជ្រែកព្រោះ **អនាទរៈ** ត្រូវមាន

**អាចរិយស្ស** ជានាមប្រកបដោយឆដ្ឋីវិភត្តិ និង កិរិយាកិតកៈ ប្រកបដោយ **អន្ត**, **មាន**, **ត** ឆដ្ឋីវិភត្តិដូចគ្នា ហៅថា ប្រយោគ ជ្រែកអនាទរៈ ។

២. **ប្រយោគលក្ខណៈ** ប្រធាន និងកិរិយាប្រកបដោយ សត្តមីវិភត្តិដូចគ្នា ប្រែថា "នាកាល, កាលបើ" ដូចជា **ចោរា សេដ្ឋិស្ស គាមេ ឆិទ្ទំ គវេសន្តា បឋមមាសេ អតិក្កន្តេ ឱកា-សំ លភឹសុ** ប្រែថា **ចោរា** រីចោរទាំងឡាយ **គវេសន្តា** កាល ស្វែងរក **ឆទ្ទំ** នូវច្រកជាប្រហោង **គាមេ** ក្នុងស្រុក **សេដ្ឋិស្ស** របស់សេដ្ឋី **បឋមមាសេ** នាកាលខែជាដំបូង **អតិក្កន្តេ** (**អតិ**-បុព្វបទ + **កម**-ធាតុ + **ត**-បច្ច័យ ហើយផ្លាស់ **ម** ជា **ន** ជា **អតិ-ក្កន្ត** ដល់ **ស្មឹ** ជា **ឯ** ទៅជា **អតិក្កន្តេ**) កន្លងទៅហើយ **លភឹសុ** បានហើយ **ឱកាសំ** នូវឱកាស ។ កិរិយារបស់ប្រយោគ ជ្រែកប្រកបដោយ **អន្ត**, **មាន**, និង **ត**-បច្ច័យ មានលិង្គ វចនៈ វិភត្តិ ដូចប្រធានខ្លួនឯង ដែលប្រកបដោយ សត្តមីវិភត្តិដែរ ។ តែបើខ្វះនាមនាម ឬ ខ្វះកិរិយាត្រូវបន្ថែម មកឲ្យគ្រប់គ្រាន់ ទើបប្រើបាន ដូចជា **ឯកស្ស ទារកស្ស មាតា តស្ស វយប្បត្តស្ស** (**សមានស្ស**) **កាលមកាសិ** (**វយប្បត្តស្ស** នេះមិនអាចធ្វើ

កិរិយាបានទេ ព្រោះជាបទសមាស ត្រូវឡើង **សមានស្ស** ជាកិរិយារបស់ **ទារកស្ស**) ប្រែថា **មាតា** រីមាតា **ទារកស្ស** របស់ទារក **ឯកស្ស** ម្នាក់ **តស្ស ទារកស្ស** កាលដែលទារកនោះ **វយប្បត្តស្ស** ដែលដល់ហើយនូវវ័យ (**សមានស្ស** កាលមាន) **អកាសិ** បានធ្វើហើយ **កាលំ** នូវមរណកាល ។

បើមានតែនាម ខ្វះកិរិយា ថែមកិរិយា ។ តែកន្លែងខ្លះមានតែកិរិយា ខ្វះនាមទៅវិញ ត្រូវថែមឲ្យស្មើគ្នា ឲ្យបានពីរ គឺនាមជាប្រធាន ប៉ុន្តែប្រធានក្នុងទីនេះ មិនមែនជាបឋមាវិភត្តិទេ ។

**ត**-សព្ទមានពីរយ៉ាងគឺ **បុរិសសព្វនាម ១ វិសេសនសព្វនាម ១**, បើ **ត**-សព្ទ ប្រែថា "ព្រះអង្គ, លោក, អ្នក, នាង, គេ, គាត់, វា" ជាបុរិសសព្វនាម បើ **វយប្បត្តស្ស** ធ្វើកិរិយាមិនកើត ពីព្រោះវាចូលជាសមាសទៅហើយគ្រាន់តែ ប្រែជាវិសេសនៈ **ទារកស្ស** ត្រូវថែម **សមានស្ស** (**សមានស្ស** មកអំពី **អស**-ធាតុ + **មាន**-បច្ច័យ) ប្រែថា "កាលមាន" មិនដែលសមាសបទ ធ្វើជាកិរិយាកើតទេ ។ **ត** ប្រែថា "នោះ" ឈ្មោះ **វិសេសនសព្វនាម** ។

## **អថ , ឯវំ**

**អថ** បើសព្ទជាសេចក្ដីលេខក្នុង និង **ឯវំ**-សព្ទជាសេចក្ដីសំដៅដល់ហេតុ បុព្វាចារ្យ លោកឲ្យប្រែជាប្រយោគលក្ខណៈបានដោយបំពេញកិរិយាថា **សមានេ** ឬ **សន្តេ** ដូចជា **អថ កឹ ករិស្សសិ ព្រាហ្មណាតិ** ។ **ព្រាហ្មណា** + **ឥតិ** = **ព្រាហ្មណាតិ** ប្រែ **ព្រាហ្មណី** រីព្រាហ្មណី **ពុទ្ធិ** សួរហើយ **អថ** (ល) **ព្រាហ្មណ ឥតិ** ថាដូច្នេះ **ព្រាហ្មណ** បពិត្រព្រាហ្មណ៍ **អថ** នាកាលបការៈយ៉ាងនេះ (**សន្តេ** កាលមាន) **ត្វំ** រីលោក **ករិស្សសិ** នឹងធ្វើ **កឹ** ដូចម្ដេច ? មានកិរិយាខ្វះប្រធាន ដូចជា **វុត្តេ** (**វច**-ធាតុ ទៅជា **វុច** បូកនឹង **ត**-បច្ច័យ ទៅជា **វុត្ត** បំបែក **ស្មឹ** ជា **ឯ** **វុត្តេ** (**វចនេ** នាកាលពាក្យ...គឺ) **វុត្តេ** ពោលហើយ ។

តាមយោបល់របស់ខ្ញុំព្រះករុណា (**ប្រាក់ ឃុន**) គួររាប់បញ្ចូលប្រយោគ **ឥត្ថម្ភូត** ថាជាប្រយោគជ្រែកផង ដូចជា **មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា** (**ចិន្តេតិ វា**)

ព្រោះថា **មនសា** និង **បសន្នេន** ជាតតិយាវិភត្តិដូចគ្នា ប្រែថា **ចេ** ថាបើ **បុគ្គលោ** រីបុគ្គល **មនសា** មានចិត្ត **បសន្នេន** ជ្រះថ្លា ហើយ **ភាសតិ វា** ពោលក្តី **ករោតិ វា** ធ្វើក្តី (**ចិន្តេតិ វា** គិតក្តី) ពន្យល់ថា វាមាននាមនាម កិរិយាដូចគ្នានឹង **អនោនរៈ** ដែរ ប៉ុន្តែក្នុងច្បាប់ផ្សេងៗ ខ្ញុំព្រះករុណាមិនដែល ឃើញនិយាយ ប៉ុន្តែពេលប្រែ ធម្មបទ មាន ។

## លំហាត់ប្រែ

ចូរប្រែប្រយោគតទៅនេះ ហើយប្រាប់ក្បួនវេយ្យាករ-ណ៍ក្នុងនោះផង ប្រាប់ថា មួយណាមកពីសព្វប្រយោគណាជាដើម ។

**១**. **ទារកស្ស រុទតោ បិតា និក្ខមិ**, **និក្ខមិ** មកអំពី **និ**-បុព្វបទ + **កម**-ធាតុ (មិនមែន **ខម** ទេ) ប៉ុន្តែផ្លាស់ **កម** ទៅជា **ខម** អសទិសសំយោគដាក់ថា **និក្ខម**ៗ + **អ**-បច្ច័យ + **ឦ** អជ្ជត្តនី រស្សៈជា **ឥ** ទៅជា **និក្ខមិ**, **ទារកស្ស** វាគូគ្នានឹង **រុទតោ**ៗ ធាតុអ្វី ? បច្ច័យអ្វី ? មកពី **រុទ**-ធាតុ + **អន្ត**-បច្ច័យ

(ប៉ុន្តែបំបែកដូច **ភវន្ត** ៗ ទៅជា **ភវតោ ភវន្តស្ស**) **រុទតោ រុទន្តស្ស** បានពីរយ៉ាងហ្នឹង ប្រែថា **ទារកស្ស** កាលបើទារក **រុទតោ** កំពុងយំ **បិតា** វីបិតា (ប្រែថា កំពុង ឬ កាល) **និក្ខមិ** ចេញទៅហើយ (កន្លែងខ្លះ **បព្វជិ**) បើ **បព្វជិ** បួសហើយ ។

**២. ទារកេ រុទន្តស្មឹ មាតា ខីរំ បាយេតិ** ប្រែថា **ទារកេ** នាកាលទារក **រុទន្តស្មឹ** កំពុងយំ **មាតា** វីមាតា **បាយេតិ** តែងឲ្យបៅ **ខីរំ** នូវទឹកដោះស្រស់ ។

**៣. វេស្សន្តរស្ស បេក្ខតោ ជូជកោ ទារកេ នេតិ** (ជា **អន្ត**-បច្ច័យ ប្រែថា កាល ឬ កំពុង **ប**-បុព្វបទ + **ឥក្ខ**-ធាតុ ប្រែថា កំពុងមើល **វេស្សន្តរស្ស** ជាឆដ្ឋីវិភត្តិ) ប្រែថា : **វេស្សន្តរស្ស** នាកាលព្រះបាទវេស្សន្តរ **បេក្ខតោ** កំពុងមើល **ជូជកោ** វីជូជក **នេតិ** នាំទៅ **ទារកេ** នូវទារកទាំងឡាយ ។

**៤. មហាជនេ បេក្ខមានេ មច្ឆុ គិលានំ នេតិ** ប្រែថា **មហាជនេ** នាកាលមហាជន **បេក្ខមានេ** កំពុងសម្លឹងមើល

**មច្ចុ** រីសេចក្ដីស្លាប់ **នេតិ** តែងនាំទៅ **គិលានំ** នូវអ្នកជំងឺ ។

**៥. ពោធិសត្តេ ជាយមានេ មាតា បមោទតិ** ប្រែថា : **ពោធិសត្តេ** នាកាលព្រះពោធិសត្វ **ជាយមានេ** កាលកើតឡើង **មាតា** រីមាតា **បមោទតិ** តែងរីករាយ ។

**៦. ភិក្ខូសុ ភុត្តេសុ បុរិសោ បច្ចាគច្ឆតិ** (**ភុត្តេសុ** មកអំពី **ភុជ**-ធាតុ + **ត**-បច្ច័យ + **សុ**-សត្តមីវិភត្តិ ត្រូវគ្នានឹង **ភិក្ខូ-សុ** ប្រយោគជ្រែក និងជាប្រយោគលក្ខណៈ) ប្រែថា **ភិក្ខូសុ** កាលដែលភិក្ខុទាំងឡាយ **ភុត្តេសុ** ឆាន់រួចហើយ **បុរិសោ** រីបុរស **បច្ចាគច្ឆតិ** តែងត្រឡប់មកវិញ ។

**៧. ឯវំ វុត្តេ បុរិសោ បដិវចនំ ន ទេតិ** ប្រែថា **ឯវំ** (**វចនេ**) នាកាលពាក្យយ៉ាងនេះ (**តេ** គឺឯង, គឺអ្នក, គឺគេ) **វុត្តេ** ពោលហើយ (បើមានរឿងរ៉ាវ ប្រែថា "គឺនរណាទៅ" ឲ្យត្រូវនឹងសាច់រឿង ប៉ុន្តែកុំចោល " គឺ " ដាច់ខាតត្រូវដាក់ គឺ ព្រោះ **វុត្តេសុ** មកពី **វច**-ធាតុ + **ត**-បច្ច័យ ផ្លាស់ **វច** ជា **វុច**, **ច** ជា **ត** តម្រួតពីរ ទៅជា **វុត្ត**, **ស្មឹ** ជា **ឯ** ទៅជា **វុត្តេ** ឲ្យ

ត្រូវគ្នានឹង **ខចនេ**) ប្រែថា **ឯទំ** នាកាលហេតុយ៉ាងនេះ **ខុត្តេ** គឺនរណាទៅពោលហើយ **បុរិសោ** រីបុរស **នខេតិ** មិនឲ្យ **បដិខចនំ** នូវពាក្យតប ។

**៨**. **ឯទំ ខុច្ចមានោ ទារកោ បច្ចាគច្ឆតិ** (**ខុច្ចមានោ** មកពី **ខច**-ធាតុ + **យ**-បច្ច័យ ទៅជា **ខុច្ច** ហើយ **មាន**-បច្ច័យមួយទៀត ទៅជា **ខុច្ចមានោ**ៗ ជាវិសេសនៈរបស់ **ទារកោ** **ឯទំ** ជាកិរិយាវិសេសនៈរបស់ **ខុច្ចមានោ**) ប្រែថា **ទារកោ** រីទារក **ខុច្ចមានោ** គឺគេកាលពោល **ឯទំ** យ៉ាងនេះ (ចុះក្នុងកម្មវាចកៈថែម " គឺគេ " ព្រោះមាន **យ** + **មាន** បច្ច័យ) **អាគច្ឆតិ** តែងមក (រមែងមក ឬ មកទទេក៏បានដែរ ព្រោះ វត្តមានាវិភត្តិមិនចេញកិរិយានុគ្រោះក៏បាន) **ទារកោ** រីទារក **ខុច្ចមានោ** គឺគេកាលពោល **ឯទំ** យ៉ាងនេះ **បច្ចាគច្ឆតិ** តែងត្រឡប់មកវិញ ។

**៩**. **សចេ តុម្ហេ បុញ្ញំ ករេយ្យាថ តេសុ ភាលកតេសុ បុញ្ញេន សុគតឹ ចាបុណិស្សថ** (**ថ** ពីរដង) បើកាលណា វាចកៈត្រូវគ្នា ឡើងតែមួយក៏បាន ព្រោះ **ករេយ្យាថ** ក៏កត្តុវាចកៈ

**បាបុណិស្សថ** ក៏កត្តុវាចកៈ ហេតុអ្វីបានដឹងថា ជាកត្តុវាចកៈ ? ព្រោះអ្វី ? ព្រោះគេសម្គាល់ថា កត្តុវាចកៈមានបច្ច័យ ១៥ ប្រចាំពួកធាតុ **ករយ្យោថ** មកពី **ឯយ្យាថ** បរស្សបទ បានជាកត្តុវាចកៈ និង ហេតុកត្តុវាចកៈ ដូចជា **ករយ្យោថ** ក្តី **ស្សថ** ក្តី ក៏ជាបរស្សបទ ប្រើបានតែកត្តុវាចកៈ និង ហេតុកត្តុវាចកៈ **តុម្ហេ** តែមួយក៏បាន ព្រោះវាចកៈត្រូវគ្នា ។ ប្រែថា **សចេ** ប្រសិនបើ **តុម្ហេ** រីលោកទាំងឡាយ **ករយ្យោថ** គប្បីធ្វើ **បុញ្ញំ** នូវបុណ្យ **តេសុ តុម្ហេសុ** កាលបើអ្នកទាំងឡាយនោះ **កាលកតេសុ** ធ្វើហើយនូវមរណកាល (**កាលកតេសុ** ធ្វើកិរិយាមិនបានទេ ព្រោះវាជាប់សមាស ត្រូវថែមកិរិយាមក) **សមានេសុ** កាលមាន ឬ **សន្តេសុ** ក៏បាន ឬ **ហុន្តេសុ** ក៏ត្រូវទៀត (**ភូ, ហុ, ជន, អស** ប្រើបាន ប្រែថា : "មាន, កាលមាន" ) **បាបុណិស្សថ** នឹងដល់ **សុគតឹ** នូវសុគតិ **បុញ្ញេន** ដោយបុណ្យ ។

**១០. បុរិសេហិ អាគន្តុកានំ ភត្តំ ទីយតេ** (**ទីយតេ** ជាកម្មវាចកៈ ត្រូវតួកម្មឡើងប្រធានៗ ឈ្មោះ **វុត្តកម្ម**ៗ គឺ **ភត្តំ**)

**ភត្តំ** រីភត្ត **បុរិសេហិ** គឺបុរសទាំងឡាយ **ទីយតេ** ឲ្យ **អាគន្តុកានំ** ដល់ជនទាំងឡាយអ្នកទើបមកថ្មី ឬថាជនទាំងឡាយជាអាគន្តុកៈ ។

**១១. ឯវំ បសំសិយមានំ អាបជ្ជិត្វា ជីវិតបរិយោសានេ តាវតឹសភវនេ សក្កោ ទេវរាជា ហុត្វា និព្វត្តិ** ( **និ**-បុព្វបទ + **វត**-ធាតុ ផ្លាស់ **វត** ជា **ពត្ត អ**-បច្ច័យ + **ឦ** អជ្ជត្តនី វសេ្សៈជា **៨** ទៅជា **និព្វត្តិ** ជាប្រយោគកត្តុវាចកៈ **ត្វា** បច្ច័យជាអនុកិរិយាប្រែមុន **និព្វត្តិ**ៗ ជាបឋមបុរស ឯកវចនៈបទប្រធានឡើងបាន ឯកចនៈ ប្រែថា **បុរិសោ** រីបុរស **អាបជ្ជិត្វា** ដល់ហើយ **បសំសិយមានំ** នូវភាពនៃខ្លួនគឺគេគួរសរសើរ **ឯវំ** យ៉ាងនេះ **សក្កោ ទេវរាជា ហុត្វា** ជាទេវរាជឈ្មោះសក្ក **និព្វត្តិ** កើតហើយ **តាវតឹសភវនេ** ក្នុងភពឈ្មោះតាវតឹង្ស **ជីវិតបរិយោសានេ** ក្នុងកាលជាទីបំផុតនៃជីវិត ។ កាលសត្តមីប្រែក្រោយកិរិយាក៏បាន ឬ មុនបទប្រធាន អាចប្រែបានពីរបែប ។

**១២. សោ ភិក្ខុ ថេរស្ស ធម្មំ កថេត្វា បក្កន្តេសុ គន្ធាធម្មាសនេ និសីទិ** ( **និ**-បុព្វបទ + **សទ**-ធាតុ + **អ**-បច្ច័យ + **ឦ** អជ្ជត្តនី វសេ្សៈជា **៨**) ប្រយោគកត្តុវាចកៈ បទប្រធានជា

ឯកវចនៈ ព្រោះ **ឡ** ជាបឋមបុរស ឯកវចនៈ, **ថេរោ** ជាប្រយោគជ្រែកកណ្តាល **បក្កន្តោ** កិរិយារបស់ **ថេរោ** ប៉ុន្តែ **គហេត្វា** ជាបុព្វកាលកិរិយាក្នុង **បក្កន្តោ** មុននឹងជៀសចេញទៅសម្តែងធម៌ ហៅ **បុព្វកាល** ពេលប្រែប្រយោគជ្រែកប្រែថា **តិក្ខុ** វីភិក្ខុ **សោ** នោះ **ថេរោ** នាកាលព្រះថេរៈទាំងឡាយ (**ត្វា**-បច្ច័យ មាន " **ត** " នៅពីមុខ ចាត់ជាប្រយោគមាត្រា ត្រូវអានរូប **ត្វា**-បច្ច័យ ទាញ **ធម្មំ** ទៅផង) **ធម្មំ គហេត្វា បក្កន្តោ** (**ប**-បុព្វបទ + **កម**-ធាតុ + **ត**-បច្ច័យ," **ម** " នៅខាងចុង មាន " **ត** " នៅបន្ទាប់ផ្លាស់ " **ម** " ជា " **ន** " តម្រួត **បក្កន្តោ**) សម្តែងនូវធម៌ហើយគេចចេញ ទៅហើយ (បើ **អន្ត**-បច្ច័យ ទៅជា **បក្កមន្តោ**, **បក្កន្តោ** ជា **ត**-បច្ច័យ) **គន្ត្វា** និមន្តទៅហើយ **និសីទិ** គង់នៅហើយ **ធម្មាសនេ** លើគ្រែធម្មាសន៍ ។

## ៦. បទពង្រីកអនុកិរិយា និង ប្រយោគជ្រែក

បទពង្រីកអាចជា **នាមសព្ទ អព្យយសព្ទ សមាស តទ្ធិត កិតក:** ដែលប្រកប ដោយទុតិយាវិភត្តិ ដល់សត្តមីវិភត្តិ

ពួកណាមួយ ។ សិក្ខាកាមត្រូវប្រែបន្ទាប់ពីអនុកិរិយាជាលំដាប់តទៅ បើមានសេចក្ដីក្នុងឥតិសព្ទជាលេខក្នុង មានន័យទាក់ទង នឹងអនុកិរិយាក៏អាចប្រែរួបចូលគ្នា បានខ្លះ ដូចជា :

**ឯកស្មឹ ឃរេ ជនោ ភត្តំ ភត្វា ភរិយាយ កុទ្ធោ ហុត្វា គច្ឆ ទ្វារេ និសីទាតិ វត្វា ឯកំ គព្ភំ បវិសិត្វា ទណ្ឌំ គណ្ហិ ។**

សូម្បីបទ **នាមសព្ទ** ប្រកបដោយទុតិយាវិភត្តិ ប្រែមិនចេញពាក្យអាយតនិបាត ដែលសម្គន្ធថា កិរិយាវិសេសនៈ ដូចជា **សុខំ សយិត្វា** ដេកហើយសប្បាយ **មហារវំ រវិត្វា** ស្រែកហើយ ស្រែកខ្លាំង យ៉ាងនេះក៏ចាត់ថាជាបទពង្រីកអនុកិរិយា ដូចជា បទពង្រីកប្រយោគជ្រែកបានដែរ ។

**ជនោ** រីជន **ឃរេ** ក្នុងផ្ទះ **ឯកស្មឹ** មួយខ្នង (ជាដើម) **ភត្វា** ធ្វើហើយ **ភត្តំ** នូវភត្ត **កុទ្ធោ ហុត្វា** ជាអ្នកក្រោធហើយ **ភរិយា-យ** ចំពោះប្រពន្ធ **វត្វា** ពោលហើយ **គច្ឆ ទ្វារេ និសីទ ឥតិ** ថា (**គច្ឆ** ក្ដី **និសីទ** ក្ដី មកអំពី **ហិ** បញ្ចមីវិភត្តិ លុប **ហិ** ចេញត្រូវរស្សៈទៅជា **គច្ឆ** បទប្រធានឡើងតែមួយក៏បាន ពីព្រោះ

វាចកៈ ត្រូវគ្នា គឺកត្តុវាចកៈ ដូចគ្នា) ថា (វីនាង) ចូរទៅ ចូរអង្គុយជិតទ្វារដូច្នេះ **បវិសិត្វា** ចូលទៅហើយ **គព្ភំ** កាន់បន្ទប់ **ឯកំ** មួយ **គណ្ហិ** កាន់យកហើយ **ទណ្ហំ** នូវដំបង ។

## ៧. មហាកិរិយា

កាលបើសិក្ខាកាមប្រែអនុកិរិយា និងប្រយោគជ្រែកព្រមទាំងបទពង្រីកសេចក្ដីរួចហើយ គប្បីរកមើល **មហាកិរិយា** គឺជាកិរិយាឃុំគ្រងពាក្យជាតួសំខាន់ របស់សេចក្ដីនោះៗ មានដូចតទៅ :

(១) **កិរិយាអាខ្យាត** ទាំងអស់ត្រូវមាន វចនៈ បុរិសៈ ដូចគ្នានឹងប្រធាន (វៀរលែងតែ ភាវវាចកៈ ដែលកំណត់ ឲ្យប្រើតែ **តេ**-អត្តនោបទប៉ុណ្ណោះ) ដូចជា **សោ យាតិ**, **ត្វំ យាសិ**, **អហំ យាមិ** (ល) បឋមបុរិសៈឯកវចនៈ **ត**-សព្វ **សោ** បុំលិង្គ, ឥត្ថីលិង្គជា **សា**, នបុំសកលិង្គ **តំ យាតិ** កិរិយានៅតែ **តិ** ដដែល ក្រៅអំពី **ត**-សព្វ ប្រើសព្វណាក៏បានទាំងអស់ ឧទាហរណ៍ : **សេដ្ឋី គរុ វិញ្ញូ កញ្ញា នារី ឥត្ថី កុលំ ។ សិ** បាន

តែ **ត្វំ**, ខុសពី **ត្វំ**, **ថ**, បានតែ **តុម្ហេ**, **មិ** បានតែ **អហំ**, **ម** បាន តែ **មយំ** ។ ឧត្តមបុរិសៈ និងមជ្ឈិមបុរិសៈ បទប្រធាន មាន កំណត់ស្រេច ទោះបីគេដាក់ **ត្វំ** ក៏បាន មិនដាក់ **ត្វំ** ក៏បាន ។ **មិ** មិនបាច់ដាក់ **អហំ** ក៏បានដែរ តែប្រែត្រូវបញ្ចូលមកដូចជា **ពុទ្ធំ សរណំ គច្ឆាមិ ។**

(២) **កិរិយាកិតកៈ** ប្រកបដោយ **ត**, **អនីយ**, **តព្វ**-បច្ច័យ ប្រើបានក្នុងប្រយោគមិនមានកិរិយាអាខ្យាត ប៉ុន្តែត្រូវមាន លិង្គ វចនៈ វិភត្តិ ដូចបទប្រធានវៀរតែ **ភាវវាចកៈ** ដែល កំណត់ឲ្យប្រកបកិរិយាជានបុំសកលិង្គ ឯកវចនៈ ព្រោះភាវ-វាចកៈក្នុងកិរិយាអាខ្យាតបានតែ " **តេ** " អត្តនោបទឯកវចនៈ តែ ប៉ុណ្ណឹង ដល់ទៅកិរិយាកិតកៈ គឺត្រូវជា នបុំសកលិង្គឯកវចនៈ ប្រធានជា បុរិសៈ វចនៈអ្វីក៏បាន តែប្រកបដោយ តតិយាវិភត្តិ ដូចជា **អម្ហេហិ មរិតព្វំ ។ តុម្ហេហិ អប្បមត្តេហិ ភវិតព្វំ** ។

(៣) **ណ្យ**-បច្ច័យ នាមកិតកៈ ដូចជា **គារយ្ហា លព្ភា សក្កា**, **តេ ច ភិក្ខូ គារយ្ហា** ប្រែថា **ច** ក៏ **ភិក្ខូ** រីភិក្ខុទាំងឡាយ **តេ** គឺអ្នក **គារយ្ហា** គប្បីតិះដៀលបាន ។ **រញ្ញោ អាណា អភាតុំ**

**ន លព្ភា** ប្រែថា **អាណា** រីអាជ្ញា **រញ្ញោ** របស់ព្រះរាជា (**កេនចិ** គឺអ្នកណាមួយ) **ន លព្ភា** មិនគប្បីបាន **អករាតុំ** ដើម្បីមិនធ្វើបានទេ, បានសេចក្ដីថា អាជ្ញារបស់ព្រះរាជា (គឺនរណាក៏ដោយ) មិនគប្បីបានដើម្បីមិនធ្វើទេ គឺត្រូវតែធ្វើ ។

(៤) **ត្វា**-បច្ច័យ ក្នុងប្រយោគ កិរិយាប្រធានន័យនិបាតសព្ទខ្លះដូចជា **អលំ** ប្រែថា គួរ, **សក្កា** អាច, **លព្ភា** គប្បីបាន, **អត្ថិ** មាន ។

ក្នុងគម្ពីរវេយ្យាករណ៍បាលី ឈ្មោះកច្ចាយនៈថា **អត្ថិ សក្កា លព្ភា ឥច្ចេតេ បឋមាយំ** សព្ទនេះគឺជាបឋមាវិភត្តិ ។

សិក្ខាកាមគប្បីជ្រាបថា បើឃើញ **អត្ថិ នត្ថិ** មានបទប្រធានឯកវចនៈ គឺជាអាខ្យាតបទកត្តុវាចកៈ បើឃើញ **អត្ថិ នត្ថិ** មានប្រធានជាពហុវចនៈ គឺជានិបាត កិរិយាបទ កត្តុវាចកៈ ហេតុនេះ បានជាអាចរួមជាបទសមាសបាន ដូចជា **នត្ថិភូវោ អត្ថិភាវោ** ។

នៅក្នុងវិធីប្រែថា **ឥទានិ សូរិយាលោកស្ស អត្ថិភាវោ** ប្រែថា ភាវៈនៃពន្លឺ ព្រះអាទិត្យមាន មិនបាច់អុជប្រទីបក៏បាន

ដែរ តែបើអុជប្រទីបវិញថា ការអុជប្រទីបមាន ពីព្រោះ **សូរិយាលោកស្ស នត្ថិតាយ** ព្រោះភាវៈនៃពន្លឺព្រះអាទិត្យអត់មាន, **នត្ថិប្ឫវោ អត្ថិតាវោ** ។

ពួកនិបាតមិនមានធាតុបច្ច័យ គឺជាអព្យយសព្ទ អាចប្រើជាកិរិយាបានខ្លះ ប៉ុណ្ណោះ ។

## ៨. បទពង្រីកមហាកិរិយា

**បទនាមសព្ទ អព្យយសព្ទ សមាស តទ្ធិត កិតកៈ** ទាំងអស់ដែលប្រកបដោយ ទុតិយាវិភត្តិ ដល់សត្តមីវិភត្តិ និង ផ្នែកច្រើនទៀតដែលរៀងទុកខាងមុខកិរិយាធំ គប្បីជ្រាបថាជាបទទាក់ទងនឹងមហាកិរិយា ព្រោះកិរិយាធំភាគច្រើន គេរៀងទុកនៅក្រោយបំផុតដោយភាគច្រើន ប៉ុន្តែភាគតិចមានរៀងនៅដើមប្រយោគ ។ ក្នុងវិធី បែបរៀនភាសាបាលីភាគ ៤ ខ្ញុំព្រះករុណាដាក់ពន្យល់ថា ដូចម្ដេច ដែលត្រូវរៀង កិរិយាអាខ្យាតនៅខាងដើម ដូចម្ដេចដែលត្រូវរៀងកិរិយាអាខ្យាតនៅខាងចុង ប៉ុន្តែខាងដើមមានតិចណាស់

ដូចជាសួរគ្នាថា **បស្សសិ អាវុសោ ត្វំ អាបត្តិយោ**, **តវតុ សព្វមង្គលំ**, **តវតុ** កិរិយាអាខ្យាតនៅខាងដើម **សុណាតុ មេ ភន្តេ** ។ល។ បានសេចក្តីថា ឲ្យតែបទជានាមសព្ទ អព្យយ-សព្ទ សមាស តទ្ធិត កិតក: ដែលនៅខាងដើម គឺនៅមុនកិរិយាធំៗ មាន ២ យ៉ាង ក្រៅអំពីនោះ កិរិយាអាខ្យាតទាំងអស់ និងកិរិយាកិតក: ដែលប្រកបដោយ **ត**, **អនីយ**, និង **តព្វ**-បច្ច័យ ។

## លំហាត់ប្រែ

**១. យោ ពាលំ សេវតិ សោ វិនាសំ បាបុណាតិ** ប្រយោគហ្នឹងវាទាក់ទងគ្នា គេហៅថា **សន្ធរប្រយោគ** ប្រែតែមួយ ស្តាប់អត់កើត ត្រូវតែប្រែប្រយោគទាំងពីរឆ្លើយឆ្លងគ្នា បើ **យោ** ដាក់បុំលិង្គបានទាំងអស់ ឲ្យតែបុំលិង្គព្រោះ **យ** សព្ទក្នុងបុំលិង្គប្រែ **យោ បុរិសោ យោ មុនិ យោ សេដ្ឋី យោ គរុ យោ វិញ្ញូ យោ សត្ថា យោ បិតា យោ ជនោ** រីជនណា **សេវតិ** សេពគប់ **ពាលេ** នូវជនពាលទាំងឡាយ **សោ ជនោ** រីជន

នោះ **បាបុណាតិ** រមែងដល់ **វិនាសំ** នូវសេចក្ដីខូចខាត បើ **យោ** ដាក់ **ជនោ សោ** ត្រូវ **ជនោ** ដែរ, តែបើ **យោ** ដាក់ **បុរិសោ** ឬ **មនុស្សោ** ប្រយោគទាំងពីរធ្វើការរួមគ្នា ហៅប្រយោគ **យ**, **ត** ត្រូវប្រែឆ្លើយឆ្លងគ្នា ។

២. **សាវត្ថិយំ កិរ អញ្ញតរោ ភិក្ខុ អហិនា ឌដ្ឋោ កាលកតោ ហោតិ** ប្រែថា **កិរ** បានឮថា **ភិក្ខុ** រីភិក្ខុ **អញ្ញតរោ** មួយរូប **សាវត្ថិយំ** ក្នុងក្រុងសាវត្ថី **អហិនា** គឺពស់ **ឌដ្ឋោ** ខាំហើយ **កាលកតោហោតិ** ជាអ្នកធ្វើហើយនូវកាលៈ ។

**ថេរស្ស និទ្ទំ អនោក្កមន្តស្ស អក្ខិម្ហិ រោគោ ឧប្បជ្ជិ** មានប្រយោគជ្រែកនៅ ខាងដើមប្រយោគ (**ថេរស្ស និទ្ទំ អនោក្កមន្តស្ស** ប្រយោគឈ្មោះ **អនាទរៈ**) **ថេរស្ស** កាលដែលព្រះថេរៈ **អនោក្កមន្តស្ស** (បើ **អនោក្កន្តស្ស** ជា **ត**-បច្ច័យ ដល់ **អនោក្កមន្តស្ស** ជា **អន្ត**-បច្ច័យ) កាលមិន ឈានចុះ **និទ្ទំ** កាន់កិរិយាលក់ (កាន់និទ្រា) **រោគោ** រីរោគ **ឧប្បជ្ជិ** កើតឡើងហើយ **អក្ខិម្ហិ** ក្នុងភ្នែក ។

៣. **អគិលានេន ភិក្ខុនា ឯកោ អាវសថបិណ្ឌោ**

**ភុញ្ជិតព្វោ តតោ ចេ ឧត្តរឹ ភុញ្ជេយ្យ បាចិត្តិយំ** ប្រយោគនឹងទៅជាបីប្រយោគគឺ **អគិលានេន ភិក្ខុនា ឯកោ អាវសថបិណ្ឌោ ភុញ្ជិតព្វោ** មួយប្រយោគ **តតោ ចេ ឧត្តរឹ ភុញ្ជេយ្យ** មួយប្រយោគទៀត **បាចិត្តិយំ** មួយប្រយោគទៀត **អាវសថបិណ្ឌោ** រីដុំបាយជាទីនៅអាស្រ័យ **ឯកោ** មួយដុំ **ភិក្ខុនា** គឺភិក្ខុ **អគិលានេន** មិនឈឺ **ភុញ្ជិតព្វោ** គប្បីបរិភោគបាន **ចេ** ថាបើ **ភិក្ខុ** រីភិក្ខុ **ភុញ្ជេយ្យ** គប្បីឆាន់ **ឧត្តរឹ** ឲ្យក្រៃលែង **តតោ** ជាងនោះ **បាចិត្តយំ** រីអាបត្តិបាចិត្តយ **សិយា** គប្បីមាន ។

**៤. ចតុបញ្ញាសាយ ភិក្ខូនំ ចីវរានិ ទាយកេហិ ទិន្នានិ** (បទប្រធានគឺ **ចីវរានិ** ព្រោះកិរិយាសព្ទ **ទិន្នានិ** គឺកិរិយាកិតក: **ត**-បច្ច័យ **ត** ជា **ឥន្ន** បូកនឹង **ទា**-ធាតុ ទៅជា **ទិន្ន**) **ចីវរានិ** រីចីវរទាំងឡាយ **ទាយកេហិ** គឺទាយកទាំងឡាយ **ទិន្នានិ** ប្រគេនហើយ **ភិក្ខូនំ** ដល់ភិក្ខុទាំងឡាយ **ចតុបញ្ញាសាយ** ៥៤អង្គ, ប្រយោគនេះជាប្រយោគ **កម្មវាចក:** ។

**៥. តេវីសតិយា កុមារានំ អាចរិយោ គាមំ បវិដ្ឋោ ។**

**ប** + **វិស**-ធាតុ + **ត**-បច្ច័យ ទៅជា **បវិដ្ឋោ**, **អាចរិយោ** រីអាចារ្យ **កុមារានំ** នៃក្មេងទាំងឡាយ **តេវីសតិយា** ២៣ (ឲ្យតែមាន **ស** នៅខាងចុង ចុះ **អ** ទៅជា **សា** បំបែកដូច **កញ្ញា** ឥត្ថីលិង្គ ឯកវចនៈទាំងអស់, ខាងចុងមាន **តិ** (និង **ឡ្យ** ដូច **សេដ្ឋី**) ក៏បំបែកជា ឥត្ថីលិង្គ ហើយប្រើឯកវចនៈ ចូលនឹងនាមជាពហុវចនៈដូច **កុមារានំ** នៃក្មេងទាំងឡាយ **តេវីសតិយា** ២៣ នាក់, **បវិដ្ឋោ** ចូលទៅហើយ **គាមំ** កាន់ស្រុក ។

៦. **សេដ្ឋីនោ មាតា ពុទ្ធសាសនេ បសន្នា** ហៅថា ប្រយោគកត្តុវាចកៈ, **តាយ សទ្ធស្ស ទានំ ទិន្នំ** ប្រយោគ កម្មវាចកៈ, **វិធុរោ ភិក្ខុ ថេរំ ឧបសង្កមិត្វា តស្ស បុត្តោ តន្តេ អម្ហាកំ សត្ថាតិ បុច្ឆិ ។ សោ កបិលវត្ថុស្មឹ សុទ្ធោទនមហា-រាជស្ស អាវុសោតិ អាហ ។**

៧. **ឯកទិវសំ វិធុរោ ភិក្ខុ ថេរំ ឧបសង្កមិត្វា តស្ស បុត្តោ តន្តេ អម្ហាកំ សត្ថាតិ បុច្ឆិ ។ សោ កបិលវត្ថុស្មឹ សុទ្ធោ-ទនមហារាជស្ស អាវុសោតិ អាហ ។ ឯកទិវសំ** ក្នុងថ្ងៃមួយ **ភិក្ខុ** រីភិក្ខុ **វិធុរោ** ឈ្មោះវិធុរ **ឧបសង្កមិត្វា** ចូលទៅរកហើយ

**ថេរំ** នូវព្រះថេរ **បុច្ឆិ** សួរហើយ **កស្ស បុត្តោ** (ល) **សត្ថាឥតិ** ថាដូច្នេះ **ឥតិ** ជាអសាធារណនាម ប្រែមុន **ចិច្ចរោ**, **ឧបសង្ក-មិត្វា** ជាបុព្វកាលកិរិយាក្នុង **បុច្ឆិ**ៗ ជាអាខ្យាតបទ-កត្តុវាចក: ។ **ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន **បុត្តោ** រីកូន **កស្ស** របស់អ្នកណា **សត្ថា** ជាគ្រូ **អម្ហាកំ** នៃយើងទាំងឡាយ ប្រយោគនេះអត់មានកិរិយាទេ ឈ្មោះប្រយោគ **លិង្គត្ថ**, ចុះបើប្រែថែមវិញថា **ភន្តេ** បពិត្រព្រះថេរ:ដ៏ចម្រើន **បុត្តោ** រីរាជបុត្រ **កស្ស** នៃព្រះរាជាអង្គណា **សត្ថា ហោតិ** រមែងជាគ្រូ **អម្ហាកំ** នៃយើងទាំងឡាយ បើប្រែថែម **ហោតិ** មកទៅជាប្រយោគ **ចិកតិកត្តា កត្តុវាចក:** ។ **ថេរោ** រីព្រះថេរ **អាហ** ឆ្លើយហើយ **សោ** (ល) **អាវុសោ ឥតិ** ថាដូច្នេះ **អាវុសោ** ម្នាលលោកដ៏មានអាយុ **សោសត្ថា** រីព្រះសាស្តាអង្គនោះ **បុត្តោហោតិ** ព្រះអង្គជាព្រះរាជបុត្រ **សុទ្ធោទនមហារាជស្ស** នៃមហារាជព្រះនាម-សុទ្ធោទន: **កបិលវត្ថុស្មឹ** ក្នុងក្រុងកបិលពស្តុ ។

**សុជាតា បន ភាលំ កត្វា ឯកិស្សា គិរិកន្ទរាយ ពកសកុណិកា ហុត្វា និព្វត្តិ** ប្រែថា **បន** ក៏ **សុជាតា** រីនាងសុជាតា **កត្វា** ធ្វើហើយ **កាលំ** នូវមរណកាល **ពកសកុណិកា ហុត្វា** ជាកុកក្រេក **និព្វត្តិ** កើតហើយ **គិរិកន្ទរាយ** ក្នុងញកភ្នំ **ឯកិស្សា** មួយ, ជាមួយប្រយោគ ព្រោះ **និព្វត្តិ** នេះគឺជាកត្តុវាចកៈ ឯ **កត្វា** ជាបុព្វកាលកិរិយានៅក្នុង **និព្វត្តិ** និងជាអនុកិរិយា ។

## ការប្រែលំហាត់ចប់តែប៉ុណ្ណេះ ។

ក្នុងការប្រែបាលីនេះ ជាដំបូង លោកម្ចាស់នឹងប្រែប្រយោគណា ត្រូវមើលប្រយោគនោះឲ្យចប់ មួយប្រយោគដែលហៅថាមួយប្រយោគ គឺមួយសង្កាត់ពាក្យ ដែលអាចស្តាប់ សេចក្តីបាន មានកិរិយាធំនៅឈរខាងចុង គឺកិរិយាដែលមាននៅ ចុងបំផុតនោះ ភាគច្រើនជា កិរិយាអាខ្យាត ភាគតិចជាកិរិយាកិតកៈ មាន, **ត្វា**-បច្ច័យ មាន **សន្តា** មាននិបាត អាចធ្វើជាកិរិយាធំខ្លះ បានជាកិរិយា ប៉ុន្តែមានតិចតួចណាស់ ពិសេសគឺកិរិយាអាខ្យាតតែម្តង បើកិរិយាអាខ្យាត

ហើយ សូមប្រគេនថា តើកិរិយានោះជា បុរសអ្វី ? បឋម-បុរស មជ្ឈិមបុរស ឬ ឧត្តមបុរស បើដឹងបុរស ហើយ មើលវចនៈទៀត យល់វចនៈហើយ រាវរកប្រធាន ឲ្យស្គាល់ វាចកៈទៀត តើប្រយោគនោះប្រកបដោយបច្ច័យអ្វី បើបច្ច័យ តាំងពី **អ**, **ឥ**, **ណ្ហ**, **ឯ**, **យ**, **ណុ**, **ណា**, **ឧណា**, **នា**, **ប្ប**, **ណ្ហា**... **ឱ**, **យិរ**, **ណេ**, **ណយ**, ជា **កត្តុវាចកៈ** បើ **កត្តុវាចកៈ** បទប្រធានឈ្មោះ **សយកត្តា** គឺអ្នកធ្វើខ្លួនឯង ចុះបើប្រកបដោយ **យ**-បច្ច័យ **ឥ**-អាគម ហើយចុះ **តេ**-អត្តនោបទ ជាដើមប្រ-យោគនោះ ឈ្មោះប្រយោគកម្មហើយ សមាជិកក្នុងប្រយោគកត្តុវាចកៈមានតែពីរអ្នកក៏បាន គឺ **សោ យាតិ** ចុះបើថា ទៅណា ទៅកាន់ស្រុក **សោ គាមំ គច្ឆតិ** ។ តែប្រយោគកម្មវាចកៈដាច់ខាតបីនាក់, ពីរនាក់មិន អាចធ្វើការបានទេ ដូចជា **ទីយតេ** (ឲ្យ) **តេ**-អត្តនោបទ **យ**-បច្ច័យ បើឲ្យបាយ បាយឡើងប្រធាន, ឲ្យសំពត់ៗ ឡើងប្រធាន អញ្ចឹង ត្រូវមានប្រធានមួយ, អ្នកឲ្យមួយទៀត អ្នកណាឲ្យ អ្នកហ្នឹង ជាតតិយាវិភត្តិ បើគ្មានក៏ត្រូវតែថែម ត្រូវមានបីនាក់ តែខ្វះបីនាក់អត់ បាន

ដូចជាកិរិយា **កិតកៈ គច្ឆ, អនីយ**, ដូចគ្នា អញ្ចឹងមើលកិរិយាសិន ទើបបានរកប្រធាន ។ ឥឡូវនិយាយអំពី កម្មវាចកៈកិរិយា គឺ **ទីយតេ** កិរិយាអាខ្យាត, **ទិន្នំ** កិរិយាកិតកៈ តែបើ **ទីយតេ** បទប្រធាន ត្រូវតែ ឯកវចនៈ លិង្គអ្វីក៏ដោយ, តែបើ **ទិន្នំ** បទប្រធានបានតែ នបុំសកលិង្គ ខុសពីនបុំសកលិង្គអត់បាន ព្រោះ **ទិន្នំ** ជានបុំសកលិង្គឯកវចនៈ ចុះបើចង់ ជាបុំលិង្គបានទេ ? លោកថាបានទៅជា **ទិន្នោ** ឲ្យតែរបស់ណាដែលជាបុំលិង្គ, ចុះបើ **ទិន្នា** ឲ្យរបស់ដែលជា ឥត្ថីលិង្គ កិរិយាមិនមានលិង្គគឺ **ទីយតេ** ត្រូវដាក់ថា **វិហារោ** រីវត្ត **ទាយកេហិ** គឺទាយកទាំងឡាយ **ទីយតេ** តែងប្រគេន, កិរិយាអាខ្យាត មិនគិតលិង្គទេ **ចីវរំ** រីចីវរ **ទាយកេហិ** គឺទាយកទាំងឡាយ **ទីយតេ** តែងប្រគេន, ឬដាក់ **អាហារោ** ក៏បាន, **អាហារោ** រីអាហារ **បុរិសេហិ** គឺបុរសទាំងឡាយ (ឲ្យតែមាន "គឺ" លិង្គអ្វីក៏ដោយវចនៈអ្វីក៏ដោយ ដាច់ខាតត្រូវតែ "គឺ" ខានមិនបាន, កិរិយាកិតកៈគិតលិង្គ) **ទិន្នំ ចីវរំ ទុស្សំ** ឲ្យតែ នបុំសកលិង្គ ។ ចុះបើ **ទិន្នា** បទប្រធានបានតែ ឥត្ថីលិង្គ ដូច **រជ្ជុ** ខ្សែ ឬឲ្យសាលា ឲ្យកុដិ ។

តែបើកាលណា **ទិន្នោ** បាន តែបុំលិង្គទេ ឲ្យគោ ឲ្យសេះ ឲ្យដំរី **អគ្គោរោ** ផ្ទះ ដូចជា **ទិន្នោ អស្សោ** រីសេះ **បុរិសេន** គឺបុរស ឬ **ហត្ថី** រីដំរី **សេដ្ឋិនា** គឺសេដ្ឋី **ទិន្នោ** ឲ្យហើយ (**ហត្ថី** ក៏បុំលិង្គ ប៉ុន្តែបុំលិង្គជាបឋមាវិភត្តិ ឯកវចនៈ ដូច **ទិន្នោ** ទើបបាន, តែពហុវចនៈមិនបាន ព្រោះ **ទិន្នោ** ជាឯកវចនៈ និងតួកម្មឈ្មោះ **វុត្តកម្ម** ជាប្រធាន របស់ប្រយោគជា **កម្មវាចកៈ** និង **ហេតុកម្មវាចកៈ** ។ បើ កិរិយាកិតកៈវិញ ប្រកបដោយ **ណេ**, **ណយ**, **ណាបេ**, **ណាបយ**, ជាហេតុកម្មវាចកៈ, ហេតុកត្តុវាចកៈ មិនដែល ឃើញមានក្នុង **ត**-បច្ច័យ ។ ទី ១ បទអ្វី ? ទី ១ **អាលបនៈ**, ទី ២ **និបាត** ផ្ដើមសេចក្ដី, ទី ៣ **កាលសត្តមី** ប៉ុន្តែកាលសត្តមីនេះ ជួនកាលគេប្រើមុនប្រធាន ជួនកាលគេប្រើក្រោយកិរិយារបស់ប្រធានអាចបាន, ជួនកាលមានកាលសត្តមីច្រើនពេកគេប្រែ មុនប្រធានខ្លះទៅ ក្រោយប្រធានខ្លះទៅ, ។ ទី ៤ ប្រធានគឺ ប្រយោគ **កត្តុវាចកៈ កម្មវាចកៈ ហេតុកត្តុវាចកៈ ហេតុកម្មវាចកៈ** ប្រធានសុទ្ធតែបឋមាវិភត្តិ ប្លែកតែប្រយោគ ភាវវាចកៈ ប្រធានគឺតតិយាវិភត្តិវិញ

ប្រែថា " គឺ ", ទី ៥ បទ ពង្រីកប្រធានៗ មានមកហើយ ជួនណាវាមានគ្នាវា គឺ បទតុល្យ មាន វិភត្តិ លិង្គ វចនៈ ស្មើគ្នា ដូចជា **បណ្ឌិតោ ជនោ**, **ជនោ** រីជន **បណ្ឌិតោ** ជាបណ្ឌិត ឬ **សោ ភិក្ខុ**, **តេ ភិក្ខូ** ត្រង់ **តេ** ត្រង់ **បណ្ឌិតោ** ជាបទពង្រីករបស់ប្រធាន, ជួនកាលជាម្ចាស់ **បុត្តោ** រីកូន **អាចរិយស្ស** របស់លោកអាចារ្យ ជាឆដ្ឋីវិភត្តិ, ជួនកាលប្រែថាក្នុង ដូចជា **មនុស្សា** រីមនុស្សទាំងឡាយ **គាមេ** ក្នុងស្រុក ឬ **សេដ្ឋី** រីសេដ្ឋី **សាវត្ថិយំ** ក្នុងក្រុងសាវត្ថី ក៏ចាត់ជាបទពង្រីករបស់ប្រធានដែរ ឬ គេហៅ **បទតុល្យ** ដែលស្មើភាពគ្នា ប៉ុន្តែបទតុល្យបានតែ មានវចនៈ វិភត្តិ ស្មើគ្នា ដល់ទៅ ជាម្ចាស់របស់ ឬ ថាជាទីលំនៅ មិនហៅថា បទតុល្យទេ តែបើនិយាយពីបទពង្រីកប្រធាន វាមានច្រើនលើសបទតុល្យ កាលណាបើចប់ពង្រីកខាងបទតុល្យ បទពង្រីកប្រធានរួចហើយ ត្រូវរកមើលកិរិយាទៀត ។ កិរិយា មានកិរិយាធំ ដែលហៅថា កិរិយាអាខ្យាត, កិរិយាតូច សំដៅយកកិរិយាកិតកទាំងអស់ តាំងពី **អន្ត**, **តវន្តុ**, **តាវី**, **តព្វ**, **អនីយ**, **មាន**, **ត**, **ត្វា**, **ត្វាន**, **តូន**, ហៅថា

កិរិយាតូច ប៉ុន្តែកិរិយាតូចចែកជាពីរទៀត ចែកជា អព្ភន្តរកិរិ-យាៗ បានតែ **អន្ត**, **តវន្តុ**, **តាវី**, **តព្វ**, **អនីយ**, **មាន**, **ត**, ទាំង ៧ ហ្នឹងឯង ឈ្មោះថា **អព្ភន្តរកិរិយា** វាទាក់ទងជាមួយប្រធាន ឯ **ត្វា**, **ត្វាន**, **តូន**, ជាអព្យយកិរិយាសម្ពន្ធច្រើនយ៉ាង អនុកិរិយា គឺ កិរិយាតូច បានដល់ កិរិយាកិតកៈទាំងអស់ ទាំងព្យយកិរិយា ទាំងអព្យយកិរិយា មានឈ្មោះសម្ពន្ធ ៧, បច្ច័យខាងដើម មានឈ្មោះសម្ព័ន្ធតែអព្ភន្តរកិរិយា " កិរិយាក្នុង " , ប៉ុន្តែ **តវន្តុ**, **តាវី** មិនសូវមានប្រើទេ ច្រើនតែ **អន្ត**, **តព្វ**, **អនីយ**, **មាន**, និង **ត**, បន្ទាប់ពីកិរិយាតូចហ្នឹងទៅ មាន កិរិយាប្រយោគជ្រែក មួយទៀត ប្រយោគជ្រែកមានឈ្មោះ ២ យ៉ាងគឺ **អនាទរ** ដែលប្រកបដោយឆដ្ឋីវិភត្តិ និងសត្តមីវិភត្តិ ឈ្មោះ **លក្ខណៈ**, ប្រយោគអនាទរៈក្តី លក្ខណៈក្តី ត្រូវតែមាននាមប្រកប ដោយឆដ្ឋីវិភត្តិ និង សត្តមីវិភត្តិដូចគ្នានឹង កិរិយាកិតកៈ តែប្រយោគអនាទរៈ និង លក្ខណៈប្រើកិរិយា-កិតកៈ ឃើញប្រើតែ ៣ បច្ច័យទេគឺ **អន្ត**, **មាន**, **ត**, តែ **ឥត្ថម្ភូត** មួយនេះ គួររាប់បញ្ចូលក្នុងប្រយោគជ្រែកដែរ ពី

ព្រោះវាមានដំណើរស្រដៀងគ្នា តាមយោបល់របស់ខ្ញុំព្រះករុណា គួររាប់មួយហ្នឹងចូលទៀត ហើយប្រយោគនេះ បើសិនជាមានតែនាម ខ្វះកិរិយា ត្រូវថែមកិរិយា, បើមានតែកិរិយាខ្វះប្រធាន ប៉ុន្តែ ប្រធាននេះប្រកបដោយឆដ្ឋីវិភត្តិ និង សត្តមីវិភត្តិ ដូចពាក្យថា **អថ**ៗ លេខក្នុងឲ្យប្រែថា នាកាលបការៈយ៉ាងនេះ **សន្តេ** ថែមកិរិយា, តែកន្លែងខ្លះ **ទុត្តេ** ឃើញមានតែកិរិយាអត់ប្រធាន បើអត់ប្រធាន ត្រូវថែមប្រធានមក ភាគច្រើនថែម **វចនេ** ។ **វចនេ** នាកាលពាក្យ ហើយថែមគឺ ។ ខ្ញុំព្រះករុណាចូលចិត្តឲ្យមានលំហាត់ ព្រោះការបង្រៀនគ្មានលំហាត់នេះ ព្រះអង្គមិនអាចដឹងខ្លួនឯងថាចេះ ឬ មិនចេះបានទេ បានជាខ្ញុំព្រះករុណាខិតខំស្រាវជ្រាវរាវរក លំហាត់ផ្សេងៗ យកមកប្រគេន ។

បន្ទាប់ពីអនុកិរិយា និង ប្រយោគជ្រែកមក ដល់មាត្រាទី ៨ គឺមហាកិរិយាៗ ធំជាងគេក្នុងប្រយោគ ។ កិរិយាធំរាប់កិរិយាអាខ្យាតទាំងអស់ ប៉ុន្តែកិរិយាអាខ្យាត ក្នុង ភាវៈវាចកៈប្រើតែមួយទេ ប្រកបដោយ **តេ**-អត្តនោបទ វត្តមានា

វិភត្តិ បឋមបុរស ឯកវចនៈ ។ តែបើកិរិយាកិតកៈវិញ គឺប្រកបដោយ **អនីយ**, **តព្វ**, **ត**-បច្ច័យ បើភាវវាចកៈ ប្រកបដោយនបុំសកលិង្គ ឯកវចនៈប្រធានគឺជាតតិយាវិភត្តិ ប្រែថា " គឺ " ដោយភាគច្រើន, កិរិយាកិតកៈធ្វើលោកធំបាន កាលបើកិរិយាអាខ្យាតមិននៅ ។ បើគ្មានអាខ្យាតទើបប្រើ កិរិយា-កិតកៈជំនួសបានពេញទីគឺ **ត**, **តព្វ**, **អនីយ**, បានតែ បច្ច័យ ៣ ហ្នឹងទេ ហើយជូនកាលដោយពេលទៀត ។ **ត្វា**-បច្ច័យធ្វើលោកធំបាន ក្នុងប្រយោគកិរិយាបធានន័យ នឹងប្រគេននៅខាងមុខ មាននិបាតខ្លះទៀត បច្ច័យ **នាមកិតកៈ** តួខ្លះ ខ្ញុំព្រះករុណាឃើញ **ណ្យ**-បច្ច័យ និង **ខ**-បច្ច័យមួយទៀត ។ **ខ**-បច្ច័យ ដូចឧទាហរណ៍ថា **សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ** (**សុករំ** មកពី **សុ**-បុព្វបទ **ខ**-បច្ច័យ កាលណាបើ មាន **ឦសំ**, **ទុ**, **សុ**, ជាបុព្វបទ ត្រូវចុះ **ខ** បាន, **ខ** ចូលមក លុបចេញ តែទីបំផុតធាតុមិនលុបទេ **សុ** + **ករ**-ធាតុ + **ខ**-បច្ច័យ លុប **ខ**-បច្ច័យ នៅ **សុករ** បុំលិង្គ **សុករោ**, ឥត្ថីលិង្គ **សុករា** នបុំសកលិង្គ **សុករំ** ប្រែថា **សាធុ** រីអំពើល្អ **សាធុនា** គឺ

សប្បុរស **សុករំ** ធ្វើបានដោយងាយ ។ ប្រយោគ នេះជាប្រយោគ កម្មវាចកៈ ហើយប្រយោគមួយទៀតថា **សាធុ បាបេន ទុក្ករំ** ប្រែថា **សាធុ** រីអំពើល្អ **បាបេន** គឺ បុគ្គលបាប **ទុក្ករំ** ធ្វើបានដោយលំបាក ។ ឧទាហរណ៍ ក្នុងនាមកិតកៈតទៅខាងមុខ ។

**មាតា ពុទ្ធសាសនេ បសន្នា តាយ សង្ឃស្ស ទានំ ទិន្នំ** កិរិយាពីរ កិរិយាណា ខ្លះ ? **បសន្នា** ក៏ **ត**-បច្ច័យ **ទិន្នំ** ក៏ **ត**-បច្ច័យ ប៉ុន្តែ **បសន្នា** ជាឥត្ថីលិង្គ បទប្រធាន ត្រូវឥត្ថីលិង្គ ប្រែថា **មាតា** រីមាតា **សេដ្ឋិនោ** របស់សេដ្ឋី **បសន្នា** ជ្រះថ្លា ហើយ **ពុទ្ធសាសនេ** ក្នុងព្រះពុទ្ធសាសនា ។ **តាយ សង្ឃស្ស ទានំ ទិន្នំ** (**ទិន្នំ** ជានបុំសកលិង្គ បទប្រធានត្រូវតែនបុំសកលិង្គ គឺ **ទានំ**) **ទានំ** រីទាន **តាយមាតុយា** គឺមាតានោះ **ទិន្នំ** ប្រគេនហើយ **សង្ឃស្ស** ចំពោះសង្ឃ (ដល់ព្រះសង្ឃ) ប្រយោគពីរហ្នឹងមានវាចកៈខុសគ្នា **សេដ្ឋិនោ មាតា ពុទ្ធសាសនេ បសន្នា** ប្រយោគនេះជាប្រយោគ **កត្តុវាចកៈ** ។ **តាយ សង្ឃស្ស ទានំ ទិន្នំ** ប្រយោគនេះជាប្រយោគ **កម្មវាចកៈ** ។

## ប្រយោគមានលក្ខណៈ ៤ ប្រភេទគឺ

១. ប្រយោគធម្មតា
២. ប្រយោគមានលេខក្រៅលេខក្នុង
៣. ប្រយោគមានតែលេខក្នុង
៤. ប្រយោគមានទម្រង់ជាវាចកៈផ្សេងៗ

### ១. ប្រយោគធម្មតា

បានដល់ប្រយោគមួយ មានប្រធានមួយ ឬ ច្រើនបទ ដូចជា **សព្វីតិយោ វិវជ្ជន្តុ** (**សព្វីតិយោ** មកពី **សព្វ** + **ឦតិយោ** ពហុវចនៈ បានជាកិរិយាទៅជា **វិវជ្ជន្តុ** និងជាប្រធានមួយកិរិយាមួយ) **សព្វីតិយោ** ប្រែថា រីចង្រៃទាំងពួងទាំងឡាយ **វិវជ្ជន្តុ** ចូរជៀសវៀងចេញឆ្ងាយទៅ ។ **សព្វរោគោ វិនស្សតុ** ប្រែថា **សព្វរោគោ** រីរោគទាំងពួង **វិនស្សតុ** ចូរវិនាសបាត់ទៅ ។ **មា តេ ភវត្វន្តរាយោ** កាត់បទថា **ភវតុ** + **អន្តរាយោ** ប្រែថា **អន្តរាយោ** រីសេចក្តីអន្តរាយ **មាភវតុ** ចូរកុំមាន (**តេ** មកពី **ត**-សព្ទមានពីរវិភត្តិគឺ បឋមាវិភត្តិ និង ទុតិយាវិភត្តិ ពហុវចនៈ, **តេ** មកពី **តុម្ហ**-សព្ទ មានបីវិភត្តិទៀត ឥឡូវ **តេ**

នេះប្រែថា ដល់) **មាតវតុ** ចូរកុំមាន **តេ** ដល់លោក (**តេ** មក ពី **តុម្ហ**-សព្ទ មានបីវិភត្តិគឺ តតិយា ចតុត្ថី និង ឆដ្ឋី) ។

**សុខី ទីឃាយុកោ ភវ** (**ទីឃាយុកោ** មួយបទ **ភវ** មួយបទ ជាឯកវចនៈ មជ្ឈិមបុរស ត្រង់ពាក្យថា **ហិ** កាលណាបើទុក **ហិ** ត្រូវទីឃៈទៅជា **ភវាហិ** បើលុប **ហិ** ត្រូវតែរស្សៈទៅជា **ភវ** ប្រធានគឺ **ត្វំ**) **ត្វំ** រីអ្នក (ប្រយោគហ្នឹង ជាប្រយោគ **វិកតិកត្តា**) **សុខី ទីឃាយុកោ ភវ** (ត្រូវរូបៗ ដោយ អំណាច វិកតិកត្តា) **ភវ** ចូរជាអ្នក **សុខី** មានសេចក្តីសុខ **ទីឃាយុកោ** មានអាយុវែង នឹងជាកិរិយាមួយ ប្រធានមួយ ។ កិរិយា មួយ ប្រធានច្រើនដូចជា **សេដ្ឋី ច សេដ្ឋិភរិយា ច អារាមំ អគច្ឆីសុ** ប្រែថា **សេដ្ឋី ច** រីសេដ្ឋីផង **សេដ្ឋិភរិយា ច** រីភរិយា នៃសេដ្ឋីផង (បើពីរនាក់ឡើងទៅ កិរិយាដាច់ខាត ត្រូវតែពហុ វចនៈ) **អគច្ឆីសុ** បានទៅហើយ **អារាមំ** កាន់វត្ត កិរិយាជា ពហុវចនៈ ដាច់ខាត (ប្រធានតាំងពីពីរនាក់ឡើងទៅ កិរិយា ត្រូវផ្លាស់ជា ពហុវចនៈ) **ភិក្ខុ វា សាមណេរោ វា អារាមំ អគច្ឆិ** (ក្នុងទីនេះ **សាមណេរោ ច ភិក្ខុ ច អាបណំគច្ឆន្តិ**

ប្រែថា " ផង ", បើប្រើថា "ឬ" **ភិក្ខុ វា** រីភិក្ខុ ឬ **សាមណេរោ វា** ឬថារីសាមណេរ **អគច្ឆិ** បាននិមន្តទៅហើយ **អារាមំ** កាន់វត្ត (ប្រធានច្រើន មាន **វា**-សព្ទ កិរិយាតែមួយបាន ។ ឥឡូវប្រយោគមានបទប្រធានមួយ មានកិរិយាច្រើនបទបាន ប៉ុន្តែត្រូវមានវាចកៈ ដូចគ្នា ដូចជា **មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា** ប្រែថា **ចេ** ថាបើ **បុគ្គលោ** រីបុគ្គល **មនសា** មានចិត្ត **បសន្នេន** ជ្រះថ្លាហើយ **ភាសតិ វា** ពោលក្តី **ករោតិ វា** ធ្វើក្តី (**ចិន្តេតិ វា** គិតក្តី) ។

## ២. ប្រយោគមានលេខក្រៅ លេខក្នុង

បានដល់ប្រយោគចម្រុះគ្នាមាន **ឥតិ** ជាសញ្ញា ប្រាប់ថាជាសង្កាត់លេខក្នុង បទក្រៅអំពីនេះ ជាលេខក្រៅ ត្រូវប្រែមុនដូចជា **សោ ព្រាហ្មណោ អហំ ឥមំ ឋានំ គន្ត្វា បសន្នចិត្តោ អាគតោម្ហិ ឥតេ្តតិ អាហ** ។

**សោ ព្រាហ្មណោ** ... **អាហ** ជាប្រយោគលេខក្រៅ ។

**អហំ** ដល់ **ភន្តេ** ជាប្រយោគលេខក្នុង ព្រោះនៅក្នុងវង្វង់ **ឥតិ** ។

ម្យ៉ាងទៀត ប្រយោគមានលេខក្នុងច្រើនជាន់ អាចដឹងបានដោយ **ឥតិ**-សព្ទ មានច្រើនសង្កាត់ដែរ ដូចជា **សោ ព្រាហ្មណោ អហំ ឥមំ ឋានំ គន្ត្វា អយ្យោ តត្ថ វសតីតិ បសន្នចិត្តោ អាគតោម្ហិ ភន្តេតិ អាហ** ប្រែថា **ព្រាហ្មណោ** រីព្រាហ្មណ៍ **សោ** នោះ **អាហ** ពោលហើយ **អហំ ឥមំ** (ល) **ភន្តេ ឥតិ** ថាដូច្នេះ **ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន **អាហំ** រីខ្ញុំព្រះករុណា **គន្ត្វា** ទៅហើយ **ឋានំ** កាន់ទី **ឥមំ** នេះ **បសន្ន-ចិត្តោ** មានចិត្តជ្រះថ្លាហើយ **អយ្យោ តត្ថ វសតិ ឥតិ** ថារីលោកម្ចាស់ តែងគង់នៅក្នុងទីនោះដូច្នេះ **អាគតោអម្ហិ** ទើបជាអ្នកមកហើយ ។

## ៣. ប្រយោគមានតែលេខក្នុង

បានដល់ប្រយោគដែលមាន **ឥតិ** សព្ទនៅចុងបំផុតនៃប្រយោគ ដូចជា **ភោ តត្ថ វសតីតិ** (**វសតិ** + **ឥតិ** ដោយ

អំណាចសន្និយ៉ាងនេះ) ត្រូវតែបន្ថែមលេខក្រៅ ឡើងមកឲ្យសមគួរដល់ដំណើររឿងនោះៗ ។ បើប្រយោគលេខក្នុងមានអក្សរ **ត** ឬ **យ** ដូចជា **តោ**, **តំ**, **តុហិំ**, **យោ**, **យា**, **យំ**, **តត្ថ**, **យត្ថ**, ជាដើម ឬមាន **អត្ថិ នត្ថិ** នៅដើមប្រយោគ ត្រូវបំពេញលេខក្រៅថា **ពុច្ឆិតា** ឬ **ពុច្ឆិ ពុច្ឆីសុ** ។

ក្រៅអំពីលក្ខណៈដូចខាងលើ ត្រូវបំពេញ **វុត្តា** ឬ **អាហ** ជាដើមតាមគួរដល់ អត្ថន័យរបស់ប្រយោគ ។

## ៤. ប្រយោគមានទម្រង់ជាវាចកៈផ្សេងៗ

បានដល់ប្រយោគគ្រប់ប្រភេទក្នុងកិរិយាអាខ្យាត និងកិរិយាកិតកៈ ដូចបានចែងរួចហើយ នាមកិតកៈ ប្រើជាកិរិយាសព្ទបានខ្លះ ដូចបានចែងរួចហើយ ។

ការប្រែរូបក្នុងប្រយោគបាលីខ្លះ កាលបើយើងលើកបទមួយម្តងៗ មកប្រែ តែពុំបានសេចក្តីល្អ ជាពាក្យដែលគេពុំធ្លាប់និយាយសោះ ព្រោះហេតុដូច្នោះ សេចក្តីក្នុងប្រយោគនោះ គួរអានរូបបទតាមលក្ខណៈនៃការប្រែរូប ដូចមាន តទៅនេះ :

## គោលនៃការប្រែរួបមាន ៨ យ៉ាងគឺ

១. **តទ្ធិត:** អានរូបបទឆដ្ឋីវិភត្តិ

២. **តុំ**-បច្ច័យ អានរូបបទអព្យយកិរិយា ឬ អនភិហិត-កត្តា

៣. **និបាត** អានរូបបទនាម វិសេសនៈ និង កិរិយា

៤. **ប្រយោគមាត្រា** អានរូបបទអព្យយកិរិយា ឬ បទអនភិហិតកត្តា

៥. **ភាវសាធនៈ** អានរូបបទអព្យយកិរិយា ដែលតាំងនៅខាងមុខខ្លួន

៦. **វិកតិកត្តា** អានបទវិកតិកត្តាចូលក្នុងបទ កិរិយាដែល ជាធាតុ **ភូ**, **ហុ**, **អស**, **ជន**,

៧. **ភាវសព្ទ** អានរូបបទឆដ្ឋីវិភត្តិ

៨. **បទសមាស** អានរូបបទដែលចូលនឹងសព្ទមុខ ឬសព្ទក្រោយ ។

## អធិប្បាយ

**តទ្ធិត** គឺសព្ទដែលប្រកបបច្ច័យក្នុងភាវតទ្ធិតតួណាមួយ វេលាប្រែត្រូវអានរូបបទឆដ្ឋីវិភត្តិ ។

វេលាប្រែ ត្រូវអានរូបបទឆដ្ឋីវិភត្តិ ព្រមទាំងបទដទៃ ដែលទាក់ទងនឹងសព្ទ នោះរហូតដល់បច្ច័យ ដូចជា **អត្តនោ ធម្មេ បតិដ្ឋិតត្តំ** វិភាវៈនៃខ្លួនជាអ្នកតាំងនៅ ស៊ប់ហើយក្នុងធម៌ ។

ក្នុងវិធីនេះ ឲ្យអានរូបបទឆដ្ឋីវិភត្តិ ដែលត្រូវសម្ពន្ធចូលក្នុងភាវតទ្ធិត ។ សិក្ខាកាមគួរសង្កេត ដោយសម្ពន្ធដូចតទៅនេះ **អត្តនោ ភាវាទិ** សម្ពន្ធក្នុង **បតិដ្ឋិតត្តំ ធម្មេ អាធារៈ** ក្នុង **បតិដ្ឋិតត្តំ**ៗ លិង្គត្ថ បឋមា ។

ចំណែកឆដ្ឋីវិភត្តិ បើមានស្រាប់ជាការល្អ បើមិនមានទេ ក្នុងពេលប្រែត្រូវបំពេញមក ដូចជា **និសន្នតា** វិភាវៈ (នៃ...) ជាអ្នកអង្គុយហើយ ។ ពាក្យថា (នៃ...) ក្នុងវង្វង់ក្រចក នេះជាពាក្យប្រែ ឆដ្ឋីវិភត្តិដែល **ភាវតទ្ធិត** ហៅមក ។

**តុំ**-បច្ច័យ កិរិយាសព្ទប្រកបដោយ **តុំ**-បច្ច័យដែល ជា **តុមត្ថកត្តា** ក្តី ជា **តុមត្ថសម្បទាន** ក្តី ខ្លះមានបទដទៃចូលដោយផ្លូវសម្ពន្ធផង ខ្លះក៏គ្មាន ។ កាលបើមានបទ ដទៃចូល

ផង ទើបគួរអាន រូប គឺអានរូបបទអព្យយកិរិយា គឺកិរិយាសព្ទ ដែលប្រកបដោយបច្ច័យ **ត្វា**, **ត្វាន**, **តូន**, ប៉ុន្តែភាគច្រើន **ត្វា**-បច្ច័យ ឬ អនភិហិតកត្តាគឺ តតិយាវិភត្តិប្រែថា: " គឺ ឬ ដែល " ឬ បទអនភិហិតកត្តាចូលនឹង **តុំ**-បច្ច័យនោះ បើមាន បទដទៃសម្ពន្ធចូលក្នុងអព្យយកិរិយា ឬ ចូលក្នុងបទ អនភិហិតកត្តា ក៏ឲ្យអានរូបទៅផង ។

**តុមត្ថកត្តា** ដូចជា **ភី តយា ភតី កត្វាបិ យថាពលំ ទានំ ទាតុំ ន វដ្ដតិ, តយា ភតី កត្វាបិ ទាតុំ** រីកិរិយាគឺអ្នក សូម្បីធ្វើនូវការឈ្នួលហើយឲ្យ **ទានំ** នូវទាន **យថាពលំ** តាម កម្លាំង **ន វដ្ដតិ** មិនគួរ **ភី** ឬ ?

**និបាត** បានដល់និបាតដែលបង្គាប់បទនាម បទ វិសេសនៈ និង បទកិរិយា ឲ្យនៅក្នុងអំណាចខ្លួនប៉ុណ្ណោះ មិនសាធារណ៍ទូទៅគ្រប់និបាតទេ ។ និបាតដែល ប្រើអាន រូប ដោយច្រើននោះគឺ **អបិ**, **នាម**, **បិ**, **ឯវ**, **វិយ**, **ឥវ**, **វ**, **ច**, **វា**, សមុច្ច័យ ជាដើម ។ កាលបើពួកនិបាត ទាំងនេះណា

មួយតាំងនៅក្រោយបទ នាម វិសេសនៈ និង កិរិយាណា សិក្ខាកាមត្រូវអានរួបបទទាំងនោះ ព្រមទាំងបទដទៃដែលទាក់ទងគ្នា រហូតដល់និបាតដែលនៅខាងក្រោយបង្អស់ ដូចជា :

**អបិ នាម** ដូចជា **ឥធេវ មេ និបជ្ជិត្វា មរន្តស្សាបិ អបរាបរំ បវត្តេន្តស្សាបិ តយា សទ្ធឹ គមនំ នាម នត្ថិ** ប្រែថា **មេ** កាលអញ **ឥធ ឯវ និបជ្ជិត្វា មរន្តស្ស អបិ** ទុកជាកាលដេកស្លាប់ក្នុងទីនេះក៏ដោយ **ឥធ ឯវ និបជ្ជិត្វា អបរាបរំ បវត្តេន្តស្ស អបិ** ទុកជាកាលដេកបម្រះនៀលទៅមកៗ ក្នុងទីនេះក៏ដោយ **តយា សទ្ធឹ គមនំ នាម** ឈ្មោះថា រីកិរិយាទៅមួយអន្លើដោយអ្នក **នត្ថិ** មិនមាន ។

**បិ** ដូចជា **អាគន្ត្វា វាតបានទ្វារេ ឋិតោបិ ន លភិស្សសិ** ប្រែថា **ត្វំ** រីអ្នក **អាគន្ត្វា វាតបានទ្វារេ ឋិតោបិ** សូម្បីមកហើយឈរហើយត្រង់ធរណីនៃបង្អួច **ន លភិស្សសិ** នឹងមិនបាន (**ភត្តំ** នូវភត្ត) ។ **ឯវ** ដូចជា **ឥន្ទ្រិយេសុ គុត្តទ្វារា ភិក្ខូ ទេវានំ បិយា ឯវ ហោន្តិ** ប្រែថា **ភិក្ខូ** រីភិក្ខុទាំងឡាយ

**ឥន្ទ្រិយេសុ គុត្តទ្វារា** អ្នកមានទ្វាររក្សាហើយ ក្នុងឥន្ទ្រីយ៍ទាំងឡាយ **ទេវានំ បិយា ឯវ ហោន្តិ** រមែងជាទីស្រឡាញ់នៃទេវតា ទាំងឡាយដោយពិត ។

**វិយ** ដូចជា **សហ ភណ្ឌកេន ចោរំ ចូឡាយ គណ្ហន្តី វិយ មំ វិប្បការំ បាបេស្សតិ** ប្រែថា (**ឧបាសិកា** រីឧបាសិកា) **មំ** ញ៉ាំងអញ **បាបេស្សតិ** នឹងឲ្យដល់ **វិប្បការំ** នូវបការៈ ដ៏ប្លែក **សហ ភណ្ឌកេន ចោរំ ចូឡាយ គណ្ហន្តី** (**ឥត្ថី វិយ**) ដូចជា រីស្ត្រីកាល ចាប់នូវចោរត្រង់ផ្នួងសក់ព្រមទាំងទ្រព្យ ។

**វ** ដូចជា **សត្ថា គន្ធកុដិយំ និសិន្នោ វ** ប្រែថា **សត្ថា** រីព្រះសាស្តា **គន្ធកុដិយំ និសិន្នោ វ** គង់ហើយក្នុងគន្ធកុដិសោះ ។

**ច** ដូចជា **ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ខាទន្តិ អាវិលានិ ច បានិយានិ បិវាមិ** ប្រែថា (**ហត្ថី** រីដំរីទាំងឡាយ) **ឱភគ្គោភគ្គំ មេ សាខាភង្គំ ខាទន្តិ ច** រមែងទំពាស៊ី នូវមែកឈើបាក់ដែលអញបំបាក់ ចុះហើយផង (**អហំ** រីអញ) **អាវិលានិ បានិយានិ បិវាមិ ច** រមែងផឹកនូវទឹកទាំងឡាយ

ដ៏ល្អក់ផង ។

**វា** ដូចជា **ឥទានិ តុយ្ហំ វា មម ទស្សនំ មយ្ហំ វា តវ ទស្សនំ នត្ថិ** ប្រែថា **ឥទានិ** ឥឡូវនេះ **តុយ្ហំ មម ទស្សនំ វា** វីកិរិយាឃើញនូវអ្នករបស់ខ្ញុំ ឬ **មយ្ហំ តវ ទស្សនំ វា** ឬថា វីកិរិយាឃើញនូវខ្ញុំរបស់អ្នក **នត្ថិ** មិនមាន ។

**ប្រយោគមាត្រា** បទកិរិយាកិតកៈជាព្យយបច្ច័យ ៧ តួ គឺ **អន្ត**, **មាន**, **ត**, **តព្វ**, **អនីយ**, **តវន្តុ**, **តាវី**, ដែលជាបឋមាវិភត្តិ ជាសង្កាត់ៗ ក្នុងវង់អាខ្យាតហើយមានទាំង បទអនភិហិតកត្តា ឬ អព្យយកិរិយាដែលត្រូវសម្ព័ន្ធចូលផង រៀងទុកខាងមុខនៃបទកិរិយាកិតកៈនោះ លោកសន្មតឈ្មោះថា **ប្រយោគមាត្រា** ។ តែបើបទកិរិយាកិតកៈ ណាប្រកបបឋមាវិភត្តិ នៅក្នុងប្រយោគមិនមានកិរិយាអាខ្យាតឃុំគ្រងទេ បទកិរិយាកិតកៈនោះមិនឈ្មោះថាប្រយោគមាត្រាឡើយ ។ ក្នុងប្រយោគដូច្នេះ ហាមមិនឲ្យប្រែរួប ព្រោះបទកិរិយាកិតកនោះ ជាម្ចាស់របស់ប្រធាន ។ ឯបទកិរិយាកិតកៈ ប្រកបទុតិយាវិភត្តិជាដើមវិញ ដែលមានបទអនភិហិតកត្តា ឬ

អព្យយកិរិយារៀងទុកខាងមុខ សឹងបានឈ្មោះ ថាប្រយោគមាត្រា ទាំងអស់ ប្រកបទៅតាមវិភត្តិ បើប្រកបទុតិយាវិភត្តិជាទុតិយាមាត្រា តតិយាមាត្រារហូតដល់ប្រកបសត្តមីវិភត្តិជាសត្តមីមាត្រា ឲ្យតែមានបទអនភិហិតកត្តា ឬ អព្យយកិរិយារួមចូលជាមួយ នឹង **អន្ត**, **មាន**, **ត**, **តព្វ**, **អនីយ**, ប៉ុន្តែ **តវន្តុ**, **តាវី** មិនសូវ មានប្រើទេ ។

ឯការប្រែរូបនោះត្រូវអាស្រ័យកិរិយាកិតកៈ ជាប្រយោគមាត្រាដែលហៅរកបទអនភិហិតកត្តា ឬបទអព្យយកិរិយានោះចូលផង ទើបអានរូបបានដូចជា **សត្ថា បន តេន ហត្ថិនា ឧបដ្ឋិយមានោ សុខំ វសិ** ប្រែថា **បន** ក៏ **សត្ថា** រីព្រះសាស្តា **តេន ហត្ថិនា ឧបដ្ឋិយមានោ** គឺដំរីនោះកាលបម្រើ **វសិ** គង់នៅហើយ **សុខំ** ជាសុខ ។ បណ្តាបទទាំងឡាយ ក្នុងប្រយោគនេះ **ហត្ថិនា** ជាអនភិហិតកត្តាសម្ពន្ធចូលក្នុង **ឧបដ្ឋិយមានោ**ៗ ជាបទកិរិយាកិតកៈ ។

**វសិ** ជាបទអាខ្យាត ដែលជាម្ចាស់នៃបទប្រធានគឺ **សត្ថា** ។ ចូរសង្កេតសម្ពន្ធ ដូចតទៅនេះ **បន**-សព្វ វាក្យារម្ភៈ

**សត្ថា**, **សយកត្ថា** ក្នុង **វសិ**ៗ អាខ្យាតបទ-កត្តុវាចក:របស់ **សត្ថា** **តេន** វិសេសន:របស់ **ហត្ថិនា**ៗ អនភិហិតកត្តាក្នុង **ឧបដ្ឋិយមានោ**ៗ អព្ភន្តរកិរិយាវិសេសន:របស់ **សត្ថា**, **សុខំ** កិរិយាវិសេសន:ក្នុង **វសិ** ។ ឧទាហរណ៍ថា **សាបិ** (**ឥត្ថី**) **ថេរំ វន្ទិត្វា អត្តនា ទិន្នទានំ អាវជ្ជមានា និវត្តិ** ប្រែថា **អបិ** ចំណែកឯ **សា ឥត្ថី** រីស្រីនោះ **ថេរំ វន្ទិត្វា អាវជ្ជមានា** កាលថ្វាយបង្គំនូវព្រះថេរហើយរំពឹង **អត្តនា ទិន្នទានំ** នូវទានដែលខ្លួនប្រគេនហើយ **និវត្តិ** ត្រលប់វិញហើយ ។ បណ្តាបទទាំងឡាយក្នុងប្រយោគនេះ **វន្ទិត្វា** ជាបទកិរិយាប្រកបអព្យយបច្ច័យ ដែលត្រូវសម្ពន្ធចូលក្នុង **អាវជ្ជមានា**ៗ ជាបទកិរិយាកិតក: **និវត្តិ** ជាបទអាខ្យាតដែលជាម្ចាស់នៃបទប្រធានគឺ **ឥត្ថី**, ចំណែកបទ **អត្តនា ទិន្នទានំ** បានជាមិនអានរូបទៅផង ព្រោះជាប្រយោគមាត្រា គ្មានអំណាចដល់ទេ តែបើអានរូបទៅផងក៏គ្មានទាស់ដែរ ។ ចូរសង្កេតសម្ពន្ធដូចតទៅនេះ **អបិ**-សព្ទ បក្ខន្តរត្ថវាចក: **សា** វិសេសន:របស់ **ឥត្ថី**ៗ សយកត្តាក្នុង **និវត្តិ**ៗ អាខ្យាតបទ-កត្តុវាចក:របស់

**ឥត្ថី**, **ថេរំ** អវុត្តកម្មក្នុង **វន្ទិត្វា**ៗ បុព្វកាលកិរិយាក្នុង **អាវជ្ជមានា**, **អត្តនា** អនភិហិតកត្តាក្នុង **ឧិន្ន**, **ឧិន្នទានំ** អវុត្តកម្មក្នុង **អាវជ្ជមានា**ៗ អព្ភន្តរកិរិយាវិសេសនៈរបស់ **ឥត្ថី** ។ ឧទាហរណ៍ដែលលើកមក នេះជាប្រយោគមាត្រាប្រកបដោយបឋមាវិភត្តិ ។ ចំណែកប្រយោគមាត្រាដែល ប្រកបវិភត្តិដទៃមានទុតិយាវិភត្តិ ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

**ភាវសាធនៈ** សំគាល់យកសព្វនាមកិតកៈ ដែលសម្រេចមកពីរូបវិគ្គហៈជា **ភាវរូប** ។ បទភាវសាធនៈនេះកាលនាំទៅប្រើក្នុងសេចក្ដីទាំងពួង ខ្លះមានកិរិយាខាងមុខ ខ្លះក៏មិនមាន ។ បើមិនមានកិរិយាខាងមុខទេ មិនត្រូវប្រែរូបឡើយ បើមានទើបរូបបទកិរិយា និង បទដែលជាប់គ្នានោះទៅរហូតដល់បទភាវសាធនៈ, តែបទកិរិយាខាងមុខនោះត្រូវជាកិរិយាដែលប្រកបដោយអព្យយបច្ច័យ ទើបអាចអានរូបបាន ដូចជា **តុម្ហេសុ ចិត្តំ បសាទេត្វា សគ្គេ និព្វត្តនំ នាម** ឈ្មោះថាវីកិរិយាញ៉ាំងចិត្ត ឲ្យជ្រះថ្លាក្នុងព្រះអង្គហើយ កើតក្នុងឋានសួគ៌ **អត្ថិ** មាន ។ បទក្នុងប្រយោគនេះ **បសាទេត្វា**

ជាអព្យយកិរិយាសម្ពន្ធចូលក្នុង **និព្វត្តនំ** ដែលជា **ភាវសា-ធនៈ** ប៉ុន្តែ **តុម្ហេសុ** និង **ចិត្តំ** ទាក់ទងខាងផ្លូវសម្ពន្ធចូលក្នុង **បសាទេត្វា** ដូច្នេះត្រូវអានរូបចូលក្នុង **បសាទេត្វា** ចំណែកបទ **សត្តេ** រូបទៅដោយអំណាចនាមសព្ទបង្គាប់ សិក្ខាកាមគួរសម្ពន្ធមើលដូចតទៅនេះ **តុម្ហេសុ** អាធារៈក្នុង **បសាទេត្វា** **ចិត្តំ** ការិតកម្មក្នុង **បសាទេត្វា**ៗ បុព្វកាលកិរិយាក្នុង **និព្វត្តនំ**, **សត្តេ** វេសយិកាធារៈក្នុង **និព្វត្តនំ**ៗ សយកត្តាក្នុង **អត្ថិ**ៗ អាខ្យាតបទ-កត្តុវាចកៈក្នុង **និព្វត្តនំ**, **នាម**សព្ទ សញ្ញាជោតកៈក្នុង **និព្វត្តនំ**, **អត្ថិ** បើឃើញបទប្រធានជាឯកវចនៈ គឺអាខ្យាតបទ តែបើប្រធានជាពហុវចនៈ ជានិបាតាខ្យាតបទ ។ **នត្ថិ** ក៏អញ្ចឹងដែរ បើឯកវចនៈអាខ្យាតបទ **អស**-ធាតុ តែបើពហុវចនៈ ជានិបាតាខ្យាតបទ គឺជានិបាត ប៉ុន្តែប្រើដូចអាខ្យាត, ហើយបើមិនមែនជាអាខ្យាត អាចចូលជាបទសមាសបាន ឧទាហរណ៍ **នត្ថិប្ចយោ អត្ថិភាវោ** ។

**បទវិភត្តិកត្តា** បទគុណនាមក្តី បទនាមនាមដែលប្រើ

ដូចគុណនាមក្តី បទកិរិយាកិតកៈក្តី (វៀរអព្យយបច្ច័យចេញ) ដែលប្រកបដោយបច្ច័យទាំង ៧ នេះ ដែលសម្ពន្ធចូល នឹងកិរិយាជាធាតុ **ភូ ហុ អស ជន** ប្រែថា " ជា..." **ភូ**-ធាតុក្តី **អស** ក្តី **ជន** ក្តី ប្រែថា " ជា " មិនប្រែថា "មាន" ទេ ព្រោះធាតុទាំង ៤ ប្រែថា "កើត មាន ជា" ឥឡូវយកតែ " ជា " មួយទេ ហៅថា **វិភត្តិភត្តា** ។ បទនេះមានច្រើនក្តីតិចក្តីវេលាប្រែឲ្យលើកមកដាក់ខាងមុខកិរិយាវិញហើយ អានរួបចូលនឹងកិរិយាដែលប្រែថា " ជា " នោះ ដូចជា **តស្សេកបុត្តកោ អហោសិ បិយោ មនាបោ** ប្រែថា **ឯកបុត្តកោ** រីកូនតូចម្នាក់ **តស្ស បិយោ មនាបោ អហោសិ** បានជាកុមារជាទីស្រឡាញ់ ជាទីពេញចិត្តរបស់គាត់ហើយ ។ **បិយោ មនាបោ** រៀងខាងក្រោយលើកខាងក្រោយមកដាក់ខាងមុខវិញ, **ឯកបុត្តកោ** ប្រែថា "រី" យក **បិយោ មនាបោ** ទោះបីនៅ រៀងខាងណាក៏ដោយលើកយក មកដាក់ខាងមុខកិរិយាដែលប្រែថា " ជា..." ។

សម្ពន្ធ **ឯកបុត្តកោ** បកតិកត្តាក្នុង **អហោសិ**ៗ អាខ្យាតបទកត្តុវាចកៈរបស់ **ឯកបុត្តកោ**, **តស្ស** សាមិសម្ពន្ធក្នុង **បិយោ មនាបោ**ៗ វិកតិកត្តាក្នុង **អហោសិ** ។ មួយទៀតបើមានបទដទៃនៅខាងមុខ ដែលជាប់ដោយផ្លូវសម្ពន្ធ នឹងបទវិកតិកត្តានោះ ក៏ត្រូវតែអានរួបទៅជាមួយគ្នាដែរ ដូចជា **អយំ មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ**, **អយំ** (**វនប្បតិ** រីឈើជាម្ចាស់នៃព្រៃ) នេះ (ព្រៃនោះមានឈើនោះធំជាងគេជាម្ចាស់ព្រៃ) **មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ** (**ភវិស្សតិ** វិភត្តិ ប្រែថា "នឹង" **ភូ**-ធាតុប្រែថា "ជា" ) នឹង ជាដើមឈើគឺទេវតាមានស័ក្តិធំ កាន់កាប់ហើយ, **អយំ** វិសេសនៈរបស់ **វនប្បតិ**ៗ បកតិកត្តាក្នុង **ភវិស្សតិ**ៗ អាខ្យាតបទ-កត្តុវាចកៈរបស់ **វនប្បតិ**, **មហេសក្ខាយ** វិសេសនៈរបស់ **ទេវតាយ**ៗ អនភិហិតកត្តាក្នុង **បរិគ្គហិតោ**ៗ វិកតិកត្តាក្នុង **ភវិស្សតិ** ។

**ភាវ**-សព្ទចាត់ជាអង្គមួយ ឲ្យរួបបទឆដ្ឋីវិភត្តិដូចបច្ច័យ

ក្នុង **ភាវគន្ធិត** ដែរ តែ **ភាវ**-សព្ទនោះមាន អំណាចឲ្យអាន បទឆដ្ឋីវិភត្តិ ដូចជា **ននុ តេ បុត្តេន មដ្ឋកុណ្ឌលិនា មយិ មនំ បសាទេត្វា អត្តនោ សគ្គេ និព្វត្តភាវោ កថិតោ** ប្រែថា **អត្តនោ សគ្គេ និព្វត្តភាវោ** វិភាវៈនៃខ្លួនជាបុគ្គលកើតហើយក្នុងឋានសួគ៌ **មដ្ឋកុណ្ឌលិនា** គឺ **មដ្ឋកុណ្ឌលី បុត្តេន** ជាកូន **តេ** នៃអ្នក **មនំ** ញុំាងចិត្ត **បសាទេត្វា** ឲ្យជ្រះថ្លាហើយ **មយិ** ក្នុងតថាគត **កថិតោ** ប្រាប់ហើយ **ននុ** មិនមែនឬ ។ **ភាវ** សព្ទក្តី **ភាល** សព្ទក្តី **ភាម** សព្ទក្តី ដែលជាប់ជាបទសមាស ជាឥស្សរៈក្នុងការអានរូបបទឆដ្ឋីវិភត្តិ ។ ចូរសង្កេតសម្ពន្ធដូចតទៅ នេះ : **ននុសព្ទ បុច្ឆនត្ថ... អត្តនោ ភាវាទិ** សម្ពន្ធក្នុង **និព្វត្តភាវោ**, **សគ្គេ** វេសយិកាធារក្នុង **និព្វត្ត**, **និព្វត្តភាវោ** វុត្តកម្មក្នុង **កថិតោ**ៗ កិតបទ-កម្មវាចកៈរបស់ **និព្វត្តភាវោ**, **តេ** សាមិសម្ពន្ធក្នុង **បុត្តេន**ៗ វិសេសនៈរបស់ **មដ្ឋកុណ្ឌលិនា**ៗ អនភិហិតកត្តាក្នុង **កថិតោ**, **មយិ** អាធារក្នុង **បសាទេត្វា**ៗ បុព្វកាលកិរិយាក្នុង **កថិតោ** ។ អ្នកខ្លះបុព្វនេះ អានថា "ប៉ុបវៈ" ខុសទេ បើជើង ** វ** មិនថា វៈ ថា **ឬព្វ** ធ្វើអ្វី ? ត្រូវអានឲ្យដឹង

ថាកាលណាបើ **ព** នៅពីលើជាជើង **ព** ហើយមិនមែនជើង **វ** ទេ តែបើអក្សរលើមិនមែនជាអក្សរ **ព** គឺប្រាកដជាជើង **វ** ដូចជាស្វា ដូចជាឆ្វែលឆ្វៀល ដូចជា ខ្វាក្ដាមជាដើម អញ្ចឹង **ខ** ជើង **វ** > **ខ្វ**, តែបើ **ព** នៅពីលើជើង ដូចគ្នា (ដូចជាជើង **ត** និងជើង **ឌ**) កុំថា **ព** ជើង **វ** នោះខុសហើយ ។ ត្រូវថា **ព** ជើង **ព** ដូចជា **សព្វោ សព្វីតិយោ សព្វពុទ្ធា** ជាដើម ។

បទសមាសដែលមានបទដទៃចូលនឹងសព្ទមុខ ឬ សព្ទក្រោយ ទើបត្រូវអានរួបបទនោះទៅនឹងខ្លួនបាន ។

បទសមាសមានបទដទៃចូលនឹងសព្ទមុខ ឧទាហរណ៍ **សគ្គេ និព្វត្តភាវោ** ភាវៈ (នៃខ្លួន) ជាអ្នកកើតហើយក្នុង ឋានសួគ៌ ។

**អត្តនា ទិន្នទានំ** ទានដែលខ្លួនប្រគេនហើយ, **អត្តនា សហ គាមិនោ** អ្នកទៅមួយអន្លើដោយខ្លួន **សត្ថារំ ទដ្ឋុកាមោ** មានបំណងដើម្បីឃើញនូវព្រះសាស្ដា **សគ្គេ** ប្រែថា ឋានសួគ៌ តែភាវក្នុងឋានសួគ៌ ឬ កើតក្នុងឋានសួគ៌ ប្រែថា

"កើត" បើអញ្ជឹង **និព្វត្ត** បទមុខហើយ **ភាវោ** នេះជាបទ ក្រោយ អត់ចូលនឹងបទមុខ ព្រោះ **សគ្គេ** ត្រូវនឹងកើតៗ ក្នុង ឋានសួគ៌ មិនមែនចូលភាវៈក្នុងឋានសួគ៌ទេ, អញ្ចឹងហៅថា បទសមាសដែលមានបទដទៃចូលនឹងសព្ទមុខ **អត្តនា** ក្តី, **អត្តនា** ទាំងពីរហ្នឹង **អត្តនាទិន្ន** មួយ **អត្តនាសហ** មួយ មិន មែនទាន ដែលខ្លួនឲ្យទេ, **អត្តនា** អនភិហិតកត្តាក្នុង **ទិន្ន** ចូល ក្នុងសព្ទមុខហើយ, **អត្តនា** ខាងក្រោមចូលនឹង **សហ** "មួយ អន្លើដោយខ្លួន" មិនមែនទៅដោយខ្លួនទេ **សត្ថារំ** នូវព្រះសាស្តា មានបំណងឃើញនូវព្រះសាស្តា ថាមានបំណងឃើញៗ គឺ **ទដ្ឋុ** "ដើម្បីឃើញ" បើអញ្ចឹង **សត្ថារំ** ចូល **ទដ្ឋុ** ដូច្នេះ ឈ្មោះ ថាចូលនឹងសព្ទមុខ ។

បទសមាសមានបទដទៃចូលនឹងសព្ទក្រោយ ។

បទដទៃមិនសម្គាល់ថាជា ទុតិយា តតិយា ឬ សត្តមី ទេ អ្វីក៏ដោយឲ្យតែមានបទដទៃក្រៅអំពីសមាសហ្នឹង ដូច ជា **ទដ្ឋុកាមោ** បទដទៃវាចូល **សត្ថារំ** ជាទុតិយាវិភត្តិហើយ, **ទិន្នទានំ** មាន **អត្តនា**, **និព្វត្តភាវោ** មាន **សគ្គេ** ចូលមួយ

កំណាត់ មិនមែនចូលទាំងអស់ទេ ឥឡូវបទសមាសមានបទដទៃចូលនឹងសព្ទក្រោយដូចជា **និព្វុត្ត** មួយសព្ទ **តាទោ** មួយសព្ទ មួយណាសព្ទមុខគឺ **និព្វុត្ត**, សព្ទក្រោយ គឺ **តាទ តាទោ** ។

**តស្ស អន្តោគេហា** អំពីខាងក្នុងនៃផ្ទះរបស់គាត់ៗ និងខាងក្នុងឬ ? ផ្ទះហ្នឹងនៅខាងក្រោយ ឬខាងមុខ ថានៅខាងក្រោយ **អន្តោ** សព្ទមុខ, **គេហា** ជាសព្ទក្រោយ បើ អញ្ចឹងបទដទៃចូលនឹងសព្ទក្រោយ ។

**មយិ ចិត្តប្បសាទេន** ដោយការជ្រះថ្លានៃចិត្តក្នុងតថាគត **មយិ** ហ្នឹង មិនមែនក្នុងរបស់ចិត្តទេ មិនមែនចិត្តក្នុងតថាគតឯណា, សេចក្តីជ្រះថ្លាក្នុងតថាគត បើអញ្ចឹង **មយិ** សម្ពន្ធចូលសព្ទខាងក្រោយ គឺ **បសាទេន**, **វិហារមជ្ឈេ ឧបដ្ឋានសាលា** សាលាបម្រើក្នុងកណ្តាលនៃវត្ត **វិហារមជ្ឈេ** ចូលនឹងសព្ទក្រោយ ។

**សត្ថុ ធម្មទេសនា** ការសម្តែងនូវធម៌នៃព្រះសាស្តា បើ

**សត្ថុ** ម្ចាស់ទាំងអស់ មិនអាចរូបបានទេ ប៉ុន្តែការសម្តែងរបស់ព្រះសាស្តា (សម្តែងនូវធម៌) **សត្ថុ** ចូលក្នុង **ទេសនាៗ** ជាសព្ទខាងក្រោយ ។

បទសមាសមានបទដទៃ ចូលទាំងសព្ទមុខ ទាំងសព្ទក្រោយ មិនត្រូវអានរូប ទេ ។

**អត្តនោ ហត្ថបាទា** "ដៃនិងជើងទាំងឡាយនៃខ្លួន" ។

**មយ្ហំ មាតាបិតរោ** "មាតានិងបីតាទាំងឡាយនៃខ្ញុំ" ។

**សិស្សានំ អាចរិយុបជ្ឈាយា** "អាចារ្យ និង ឧបជ្ឈាយ៍ទាំងឡាយនៃសិស្សទាំងឡាយ" ទាំងអាចារ្យ ទាំងឧបជ្ឈាយ៍ទាំងមុខទាំងក្រោយ គឺជាម្ចាស់របស់សិស្ស ដូចជា :

**សក្កោ ភោ នុ ខោ មំ ឋានាចាវេតុកាមោតិ ឱលោកេន្តោ ទិព្វេន ចក្ខុនា ថេរំ អទ្ទស** ប្រែថា **សក្កោ** រីទេវរាជឈ្មោះសក្កៈ **ឱលោកេន្តោ** កាលរមឹលមើល **ភោ នុ ខោ មំ ឋានាចាវេតុកាមោ ឥតិ** (**ចិត្តនេន** ដោយកិរិយាគិត) ថាដូច្នេះ **អទ្ទស**

បានឃើញហើយ **ថេរំ** នូវព្រះថេរ **ចក្ខុនា** ដោយចក្ខុ **ទិព្វេន** ដ៏ជាទិព្វ ។ **កោ នុ ខោ** រីអ្នកណាហ្ន៎ **មំ ឋានា ចាវេតុកាមោ** មានបំណងដើម្បី ញ៉ាំងអញឲ្យរេកម្រើកចាកទី ។ សម្ពន្ធ **សក្កោ** សយកត្តា ក្នុង**អទ្ទស**ៗ អាខ្យាតបទកត្តុវាចកៈរបស់ **សក្កោ** ។

**កោ លិង្គត្ថបឋមា នុ ខោ និបាត** សមុហៈជាបុច្ឆនត្ថៈចុះក្នុងសេចក្តីថាសួរ, **មំ** ការិតកម្មក្នុង **ចាវេតុ**, **ឋានា** អបាទានក្នុង **ចាវេតុ**, **ចាវេតុកាមោ** វិសេសនរបស់ **កោ ឥតិ** សព្វអាការៈក្នុង **ឱលោកេន្តោ**ៗ អព្ភន្តរកិរិយាវិសេសនៈរបស់ **សក្កោ**, **ទិព្វេន** វិសេសនៈរបស់ **ចក្ខុនា**ៗ ករណៈក្នុង **អទ្ទស**, **ថេរំ** អវុត្តកម្មក្នុង **អទ្ទស** ។

**ខីណាសវានំ មរណចេតនា នាម នត្ថិ ភិក្ខវេ** ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **ខីណាសវានំ មរណចេតនា នាម** ឈ្មោះថារីចេតនាជាហេតុញ៉ាំងសត្វឲ្យស្លាប់របស់ ព្រះខីណាស្រពទាំងឡាយ **នត្ថិ** មិនមាន ។ សម្ពន្ធ **ភិក្ខវេ** អគារវាលបនៈ **ខីណាសវានំ** សាមិសម្ពន្ធក្នុង **មរណចេតនា**ៗ

សយកត្តាក្នុង **នត្ថិ** អាខ្យាតបទ-កត្តុវាចក:របស់ **មរណ-ចេតនា**, **នាម**សព្ទ សញ្ញាជោតក:ក្នុង **មរណចេតនា** ។

## លំហាត់ប្រែ

ចូរប្រែលោតប្រយោគខាងក្រោមនេះ មានវិធីដូចម្តេចដើម្បីឲ្យប្រែរូបបាន ហើយបើប្រែរូប តើដោយអំណាចនៃសព្ទអ្វី សូមពន្យល់។

**អថ នំ អស្សមបទំ នេត្វា សីលភេទំ អកត្វាវ អនុកម្បាយ បដិជគ្គិ** គ្រានោះ រីតាបសនោះ នាំទៅហើយនូវព្រះនាងទេវីនោះកាន់អាស្រមបទ មិនធ្វើហើយនូវ ការបែកធ្លាយនៃសីលសោះ ទំនុកបម្រុងហើយដោយសេចក្តីអនុគ្រោះ (ធ.ប.២) ។

**ន បន មំ បព្វាជេន្តិ** " ក៏ប៉ុន្តែ រីភិក្ខុទាំងឡាយ តែងមិនញុំាងខ្ញុំព្រះអង្គឲ្យបួស" (ធ.ប.៤) ។

**តស្ស ភគវតោ បាទមូលេ និប្បជ្ជិត្វា** "ក្រាបចុះហើយ

ក្នុងទីជិត នៃព្រះបាទ របស់ព្រះមានព្រះភាគអង្គនោះ″ (ធ.ប.១) ។

**តទា ចត្តារោ ភិក្ខូ ចត្តារោ ពិឡារា អហេសុំ** ″ភិក្ខុទាំងឡាយ បួនរូបក្នុងកាលនោះ បានជាឆ្មា ៤ តួហើយ (ក្នុងកាលនេះ″) (ធ.ប.៤) ។

**សា វេជ្ជេនាគន្ត្វា ភីទិសំ ភទ្ទេតិ បុដ្ឋា** ″ស្ត្រីនោះ ជាអ្នកគឺគ្រូពេទ្យមកហើយ សួរហើយថា ″ម្នាលនាងដ៏ចម្រើនរោគប្រាកដដូចម្ដេចទៅ″ ដូច្នេះ (ធ.ប.១)។

**សត្ថា គន្ធកុដិតោ និក្ខមិត្វា ទ្វិន្នំ គមនានំ អញ្ញតរេនគមនេន ធម្មសភំ គន្ត្វា** (បេ) ″ព្រះសាស្ដា ស្ដេចយាងចេញហើយអំពីព្រះគុន្ធកុដិ ស្ដេចទៅហើយកាន់ធម្មសភាបណ្ដាការទៅទាំងពីរយ៉ាងដោយការទៅមួយ″ (ធ.ប.៣) ។

**តស្សា វីហិប្បហរណកាលេ មុសលំ មុទ្ធំ បហរន្តំវិយ ឧប្បជ្ជតិ** ″អង្រែបីដូច ជាកំពុងប្រហារនូវក្បាល តែង

ប្រាកដដល់យក្ខិនីនោះ ក្នុងកាលជាទីបុកនូវស្រូវ" (ធ.ប.១) ។

**ភិក្ខុនា នាម ឯវំ ចិត្តវសិកេន ភវិតុំ ន វដ្ដតិ** "រីកិរិយាឈ្មោះថា គឺភិក្ខុជាអ្នកលុះទៅក្នុងអំណាចនៃចិត្ត យ៉ាងនេះ មិនសមគួរទេ" (ធ.ប.២) ។

**ភន្តេ អហំ មហល្លកកាលេ បព្វជិតោ គន្ថធុរំ បូរេតុំ ន សក្ខិស្សាមិ** "បពិត្រព្រះអង្គដ៏ចម្រើន រីខ្ញុំព្រះអង្គបួសហើយ ក្នុងកាលនៃខ្លួនជាមនុស្សចាស់ នឹងមិនអាច ដើម្បីបំពេញ នូវគន្ថធុរៈបានទេ" (ធ.ប.១) ។

**តានិ ញាណគ្គិនា ឈាបេត្វា អភព្វុប្បត្តិកានិ កាតុំ វដ្ដតិ** "រីកិរិយាញុំាងសំយោជនៈទាំងឡាយនោះ ឲ្យឆេះ ដោយភ្លើង គឺញាណហើយទើបធ្វើឲ្យជា ធម្មជាតិមានការ កើតឡើងមិនគួរ រមែងសមគួរ" (ធ.ប.២) ។

**តត្ថេវ តស្មិំ វូបសន្តេ អញ្ញត្ថ គន្តុំ វដ្ដតិ** "រីកិរិយា គឺ កាលអធិករណ៍នោះស្ងប់ហើយក្នុងទីនោះឯង ទៅក្នុងទីដទៃ

រមែងគួរ″ (ធ.ប.២) ។

**អត្តនោ បញ្ញានុរូបេន ឯកំ វា ទ្វេ វា និកាយេ សកលំ វា បន តេបិដកំ ពុទ្ធវចនំ ឧគ្គណ្ហិត្វា តស្ស ធារណំ** ‶រីកិរិយារៀនយកនូវនិកាយមួយឬ ឬថានូវនិកាយទាំងពីរ ឬក៏នូវព្រះពុទ្ធវចនៈ គឺព្រះត្រ័យបិដកទាំងអស់ ដោយសមគួរដល់ប្រាជ្ញារបស់ខ្លួន ហើយទ្រទ្រង់ទុកនូវព្រះពុទ្ធវចនៈនោះ″ (ធ.ប.១) ។

**ឥមំ ធម្មទេសនំ សត្ថា សាវត្ថិយំ វិហរន្តោ សបរិសំ ឱយេន អជ្ឈោត្ថរិត្វា មារិតំ វិឌូឌភំ អារព្ភ កថេសិ** ‶រីព្រះសាស្តាកាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវព្រះបាទវិឌូឌភៈ ប្រព្រឹត្តទៅមួយអន្លើដោយបរិស័ទ គឺទឹកជំនន់ ជន់លិចហើយ ឲ្យស្លាប់ហើយ ត្រាស់សម្តែងហើយ នូវព្រះធម៌ទេសនានេះ″ (ធ.ប.៣) ។

**សេដ្ឋី អត្តនា បាលិតំ វនប្បតឹ និស្សាយ លទ្ធត្តា តស្ស បាលោតិ នាមំ អកាសិ** ‶សេដ្ឋីបានធ្វើហើយនូវពាក្យថា ‶បាល″ ដូច្នេះឲ្យជាឈ្មោះដល់បុត្រ អ្នកកើតហើយ

មុននោះ ព្រោះភាវៈនៃបុត្រនោះ ជាអ្នកដែលខ្លួនអាស្រ័យនូវដើមឈើជាម្ចាស់ព្រៃដែលទេវតារក្សាហើយ ទើបបានហើយ” (ធ.ប.១) ។

**ឥមំ មយា មារេតុំ វា ហត្ថបាទេ វាស្ស ឆិន្ទិតុំ អក្ខីនិ វា ឧបាដេតុំ វដ្តតិ** ប្រែថា **ឥមំ មយា មារេតុំ វា** “វីកិរិយា គឺយើងញុំាងជាងឈើនេះឲ្យស្លាប់ឬ” **ហត្ថបាទេ អស្ស ឆិន្ទិតុំ វា** “ឬថាវីកិរិយាកាត់នូវដៃនិងជើងទាំងឡាយ របស់ជាងឈើនេះ” **អក្ខីនិ ឧប្បាទេតុំ វា** “ឬថាវីកិរិយា ឆ្កៀលចេញនូវភ្នែកទាំងឡាយ” **វដ្តតិ** ទើបគួរ (ធ.ប.៦) ។

**អតីតេ កិរាយស្មា មហាកប្បិនោ បទុមុត្តរពុទ្ធស្ស បាទមូលេ កតាភិនីហារោ សំសារេ សំសរន្តោ ពារាណសិតោ អវិទូរេ ឯកស្មឹ បេសក្ការគាមេ ជេដ្ឋកបេសការោ ហុត្វា និព្វត្តិ** ប្រែថា “**កិរ** បានឮថា **អតីតេ** ក្នុងកាលដែលកន្លងទៅហើយ **មហាកប្បិនោ** វីព្រះមហាកប្បិន **អាយស្មា** ដ៏មានអាយុ **បទុមុត្តរពុទ្ធស្ស បាទមូលេ កតាភិនីហារោ** មានអភិនីហារធ្វើទុកហើយ ក្នុងទីជិតនៃព្រះបាទរបស់ព្រះពុទ្ធ

ព្រះនាមបទុមុត្តរៈ **សំសរន្តោ** កាលអន្ទោលទៅ **សំសារេ** ក្នុងសង្សារ **វេជ្ជកបេសការោ ហុត្វា** ជានាយជាងតម្បាញធំបំផុត **និព្វត្តិ** កើតឡើងហើយ **បេសការគាមេ** ក្នុងស្រុកនៃជាងតម្បាញ **ឯកស្មឹ** មួយ **អវិទូរេ** ក្នុងទីជិត **ពារាណសិតោ** អំពីក្រុងពារាណសី" (ធ.ប.៤) ។

**បល្លលេ ឱតរិត្វា តត្ថ ចរិត្វា គច្ឆន្តោ រាជហំសោ វិយ កត្ថចិ អលគ្គោ យេវ មម បុត្តោ** ប្រែថា "**បុត្តោ** រីបុត្រ **មម** របស់យើង **កត្ថចិ អលគ្គោ ឯវ ហោតិ** ជាអ្នកមិនជាប់ជំពាក់ហើយក្នុងទីណាៗ **បល្លលេ ឱតរិត្វា តត្ថ ចរិត្វា គច្ឆន្តោ រាជហំសោ វិយ** បីដូចជារីរាជហង្ស កាលចុះលើភក់ហើយ ត្រាច់ទៅលើភក់នោះហើយហើរទៅ" (ធ.ប.៤) ។

**អជ្ជ មេ សុទិដ្ឋំ កត្វា អត្តានំ វន្ទិតុំ ទេហិ** ប្រែថា **អជ្ជ** ក្នុងថ្ងៃនេះ **ត្វំ** រីលោក **ទេហិ** ចូរឲ្យ **មេ សុទិដ្ឋំ អត្តានំ កត្វា វន្ទិតុំ** ដើម្បីធ្វើនូវខ្លួនឲ្យជាអ្នកគឺខ្ញុំឃើញល្អហើយ ថ្វាយបង្គំនូវខ្លួន (ធ.ប.៤) ។

**កឹ បន តេ សារីបុត្ត ឯវំ កតោបការំ ទុក្ខតោ មោចេតុំ ន វដ្ដតិ** ប្រែថា **សារីបុត្ត** ម្នាលសារីបុត្ត **បន** ក៏ **តេ ឯវំ កតោបការំ ទុក្ខតោ មោចេតុំ** រីកិរិយាគឺលោកញ៉ាំងព្រាហ្មណ៍អ្នកមានឧបការៈ ធ្វើហើយយ៉ាងនេះ ឲ្យរួចចាកទុក្ខ **ន វដ្ដតិ** តែងមិនគួរ **កឹ** ឬ ? (ធ.ប.៩) ។

**អន្នបានភេសជ្ជេសុ យោ យំ ឥច្ឆតិ តស្ស តំ យថិច្ឆិតមេវ សម្បជ្ជតិ** ប្រែថា **យោ ភិក្ខុ** រីភិក្ខុណា **ឥច្ឆតិ** តែងប្រាថ្នា **អន្នបានភេសជ្ជេសុ យំ វត្ថុំ** នូវបណ្តាបាយនិង ទឹកនិងភេសជ្ជៈទាំងឡាយ វត្ថុណា **តំ វត្ថុ** រីវត្ថុនោះ **សម្បជ្ជតិ** តែងដល់ព្រម **តស្ស ភិក្ខុនោ** ដល់ភិក្ខុនោះ **យថិច្ឆិតំ ឯវ** តាមសេចក្តីប្រាថ្នាមិនខាន (ធ.ប.១)។

**អត្តនោ បញ្ញានុរូបេន ឯកំ វា ទ្វេ វា និកាយេ ស-កលំ វា បន តេ បិដកំ ពុទ្ធវចនំ ឧគ្គណ្ហិត្វា តស្ស ធារណំ កថនំ វាចនំ** ប្រែថា **អត្តនោ បញ្ញានុរូបេន ឯកំ និកាយំ វា ទ្វេ និកាយេ វា សកលំ តេ បិដកំ ពុទ្ធវចនំ វា បន ឧគ្គណ្ហិត្វា តស្ស ធារណំ កថនំ វាចនំ** រីកិរិយា រៀនយកនូវ

និកាយមួយ ឬ ឬថានូវនិកាយទាំងពីរ ឬក៏នូវព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងមូលតាមសមគួរ ដល់ប្រាជ្ញា របស់ខ្លួនហើយ ទ្រទ្រង់ សំដែង បង្រៀន នូវពុទ្ធវចនៈនោះ (ធ.ប.១) ។

**តទា កិរ ចង្កមីហិ បាទស្ស អពោគករណភាវេន កតំ អត្តនោ ឧបការំ ញត្វា សព្វសេតស្ស ហត្ថិបោតកស្ស ទាយកោ ឯកចារិកោ ហត្ថី សារីបុត្តត្ថេរោ អហោសិ** ប្រែថា **កិរ** បានឮថា **ហត្ថី** រីដំរី **ឯកចារិកោ** អ្នកត្រាច់ទៅតែម្នាក់ឯង ជាប្រក្រតី **ចង្កមីហិ បាទស្ស អពោគករណភាវេន កតំ អត្តនោ ឧបការំ ញត្វា សព្វសេតស្ស ហត្ថិបោតកស្ស ទាយកោ** ជាអ្នកដឹងនូវឧបការៈ គឺជាងឈើទាំងឡាយធ្វើហើយដល់ខ្លួនដោយភាវ គឺការធ្វើនូវកិរិយាមិនមាននៃពោគដល់ជើង ឲ្យនូវកូននៃដំរី មានអវយវៈទាំងពួងសសុទ្ធ **តទា** ក្នុងកាលនោះ **ឥទានិ សារីបុត្តត្ថេរោ អហោសិ** បានជាព្រះសារីបុត្តក្នុងកាលឥឡូវនេះហើយ (ធ.ប.៤) ។

**ពន្ធុលកុមារោ សង្ឃិវេឡូ គហេត្វា មជ្ឈេ អយសលាកំ**

**បត្តិបិត្វា សដ្ឋិកលាបេ ឧស្សាបេត្វា ឋបិតេ មល្លរាជកុលេហិ ឥមេ កប្បេត្ថតិ ខុត្តេ អសីតិហត្ថំ អាកាសំ ឧល្លង្ឃិត្វា អសិនា កប្បេន្តោ អគមាសិ** ប្រែថា **ពន្ធុលោ** រីកុមារឈ្មោះ **ពន្ធុល ទចនេ** នាកាលពាក្យ) "**ពន្ធុលោ** រីកុមារឈ្មោះពន្ធុល **កប្បេត្** ចូរកាប់ **ឥមេ សដ្ឋិកលាបេ** នូវបាច់ ៦០ ទាំងឡាយនេះ" **ឥតិ** ដូច្នេះ (បើចង់ប្រែទម្លាយ លេខក្នុងថារូបឲ្យហើយក៏បាន) **ទចនេ** នាកាលពាក្យ **ពន្ធុលោ កប្បេត្ ឥមេ សដ្ឋិកលាបេ ឥតិ** ថារីពន្ធុលកុមារ ចូរកាប់នូវបាច់ ៦០ ទាំងឡាយនេះ ដូច្នេះ **មល្លរាជកុលេហិ** គឺត្រកូលនៃស្តេចមល្លទាំងឡាយ **ខុត្តេ** ពោលហើយ **ឧល្លង្ឃិត្វា** លោតឡើងហើយ **អាកាសំ** កាន់អាកាស **អសីតិហត្ថំ** មានហត្ថ ៨០ ជាប្រមាណ **កប្បេន្តោ** កាលទ្រង់កាត់ **សដ្ឋិកលាបេ** នូវបាច់ ៦០ ទាំងឡាយ **សដ្ឋិវេឡុ គហេត្វា មជ្ឈេ អយសលាកំ បត្តិបិត្វា ឧស្សាបេត្វា មល្លរាជកុលេហិ ឋបិតេ** ដែលត្រកូលនៃស្តេចមល្លទាំងឡាយ ទ្រង់កាន់យកនូវឫស្សីទាំង ៦០ ទ្រង់ដាក់ចុះហើយនូវស្នូលជាវិការៈនៃដែកក្នុងកណ្តាល ឲ្យលើកឡើងហើយ តាំងទុក

ហើយ **អសិនា** ដោយដាវ **អគមាសិ** បានស្តេចទៅហើយ (**ឋបិតេ** ជាកិរិយាកិតកៈ សម្រេចមកពី **ត**-បច្ច័យ ឲ្យទៅជាបទវិសេសនៈរបស់ **សង្ឃីកលាបេ**) (ធ.ប.៣) ។

**សោ អហិវាតរោគុប្បត្តិតោ បដ្ឋាយ សព្វំ តន្ទវតិយ-សេដ្ឋិនោ បវត្តឹ អាចិក្ខិត្វា តស្សា អត្តនោ ចេត្ថ ធីតុដ្ឋានេ ឋបិតភាវំ អារោចេសិ** ប្រែថា **សោ មិត្តកុដុម្ពិកោ** វិមិត្តកុដុម្ពិនោះ **អាចិក្ខិត្វា** ប្រាប់ហើយ **បវត្តឹ** នូវព័ត៌មាន **សព្វំ** ទាំងអស់ **តន្ទវតិយសេដ្ឋិនោ** របស់សេដ្ឋី ក្នុងក្រុងភទ្ទវតី **បដ្ឋាយ** ចាប់ដើម **អហិវាតរោគុប្បត្តិតោ** អំពីការកើតឡើងនៃអហិវាតរោគ **អារោចេសិ** ក្រាបទូលហើយ **តស្សា កុមារិកាយ អត្តនោ ជេដ្ឋធីតុដ្ឋានេ ឋបិតភាវំ** នូវភាវនៃនាងកុមារិកានោះជាអ្នកគឺខ្លួន តាំងទុក ហើយក្នុងតំណែងនៃធីតាច្បងបំផុតរបស់ខ្លួន (ធ.ប.២) ។

**សេដ្ឋី អត្តនា បាលិតំ វនប្បតឹ និស្សាយ លទ្ធត្តា តស្ស បាលោតិ នាមំ អកាសិ** ប្រែថា **សេដ្ឋី** វិសេដ្ឋី **អកាសិ** បានធ្វើហើយ **បាលោ ឥតិ វចនំ** នូវពាក្យថា "**បាល**" ដូច្នេះ

**នាមំ** ឲ្យជាឈ្មោះ **តស្សបុត្តស្ស** របស់កូននោះ **តស្សបុត្តស្ស អត្តនា បាលិតំ វនប្បតឹ និស្សាយ លទ្ធត្តា** ព្រោះភាវនៃបុត្ត នោះ ជាអ្នកគឺខ្លួនអាស្រ័យហើយ នូវឈើជាម្ចាស់នៃព្រៃ ដែលទេវតារក្សាហើយបានហើយ (ធ.ប.១)។

**សេដ្ឋិធីតាបិ តស្សាគន្ត្វា ទ្វារេ ឋិតភាវំ សុត្វា** ប្រែថា **សេដ្ឋិធីតាបិ** ឯវី ធីតានៃសេដ្ឋី **សុត្វា** ឮហើយ **តស្ស** (**ឃោសក-ស្ស**) **អាគន្ត្វា ទ្វារេ ឋិតភាវំ** នូវភាវៈ នៃឃោសកៈនោះជា អ្នកមកហើយឈរហើយជិតទ្វារ (ធ.ប.២) ។

**អនុសន្ធឹ ឃដេត្វា ធម្មំ ទេសេន្តោ ឥមំ គាថមាហ** ប្រែថា **សត្ថា** វីព្រះសាស្ដា **អនុសន្ធឹ ឃដេត្វា ធម្មំ ទេសេន្តោ** កាលទ្រង់តនូវអនុសន្ធិសម្ដែងនូវធម៌ **អាហ** ទ្រង់ត្រាស់ហើយ **គាថំ** នូវគាថា **ឥមំ** នេះ (ធ.ប.៤) ។

**អានាយ** នាំទៅហើយ **ថេរំ** នូវព្រះថេរ **យដ្ឋកោដិយា** ដោយចុងនៃឈើច្រត់ **គច្ឆន្តោ** កំពុងទៅ **សម្បាបុណិ** ដល់ ព្រមហើយ **អន្តរាមគ្គេ អដវិយំ សទ្ទដ្ឋនគរំ នាម ថេរេន**

**ឧបនិស្សាយ ខុជ្ជបុព្វគាមំ** នូវស្រុកដែលព្រះថេរធ្លាប់ចូលទៅអាស្រ័យនៅ ហើយឈ្មោះសង្កជ្ជនគរក្នុងដងព្រៃ ត្រង់ចន្លោះនៃផ្លូវ។

**ថេរេន** មានសេចក្តីសម្ព័ន្ធជាមួយនឹង **ខុជ្ជ** ជាចំណែករបស់ **ខុជ្ជបុព្វគាមំ**។

**អនុរុទ្ធត្ថេរោ អត្តនោ ញាតិឧបដ្ឋាកានំ ពហុភាវំ ញាបេតុកាមោ មញ្ញេ** ប្រែថា **អនុរុទ្ធត្ថេរោ** វព្រះថេរឈ្មោះអនុរុទ្ធ **អត្តនោ ញាតិឧបដ្ឋាកានំ ពហុភាវំ ញាបេតុកាមោ** (**ហោតិ**) **មញ្ញេ** ទំនងជាអ្នកមានប្រាថ្នា ដើម្បីញ៉ាំងជនទាំងឡាយ ឲ្យដឹងនូវភាវនៃញាតិ និងឧបដ្ឋាកទាំងឡាយរបស់ខ្លួនជាមនុស្សច្រើន (ធ.ប.៩) ។

ដើម្បីឲ្យស្ទាត់ជំនាញទាល់តែមានលំហាត់ដើម្បី សិក្ខាកាម យកទៅគិត ពិចារណាមើលហើយបើគិតទៅមិន ឃើញទេ **សុ ចិ បុ លិ**; **សុ**, ស្តាប់, **ចិ**. គិត, **បុ**. សាកសួរ, **លិ**. សរសេរទុក, អង្គបួនហ្នឹងហើយដែលធ្វើឲ្យចេះ បើមិនហ៊ានសាកសួរ មិនហ៊ានកត់ត្រាទុក ដោយប្រការដទៃទេ មិនអាចជាអ្នកប្រាជ្ញបានទេ បើអញ្ចឹង សូមប្រកបដោយសេចក្តី

ព្យាយាម ខ្ញុំព្រះករុណាក៏ខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីនឹងកែសម្រួល មេរៀនណាក៏ដោយ បើគ្មានលំហាត់មិនសូវមានគំនិតគិតគូរចង់ចេះចង់ដឹងទេ ទាល់តែមានលំហាត់ ធ្វើមិនកើត ទើបដឹងថា អាត្មាអញរៀនមិនទាន់ដល់ទេតើ បានជាធ្វើមិនកើត ដល់មិនបានធ្វើលំហាត់ អត់បានគិតគូរអ្វីសោះ បានជាខ្ញុំព្រះករុណាចូលចិត្តដាក់មេរៀនអី ហើយឲ្យមានលំហាត់ផង ទើបសមណៈជាសិក្ខាកាមមានសេចក្ដី ចង់ចេះចង់ដឹង សាកល្បងដោយសារលំហាត់ នឹងដឹងខ្លួនហើយថាអញទៅមិនរួច បានជាខ្ញុំព្រះករុណា ខំព្យាយាម ដើម្បីបង្រៀនអ្វីមួយឲ្យ មានលំហាត់ ទោះបីខុសត្រូវខ្លះ ក៏គ្រាន់បើជាងអត់ សូមព្រះគុណម្ចាស់ជាសមណសិស្សទាំងអស់ ខំយកព្រះទ័យទុកដាក់ហើយបានចេះដឹងច្រើន ខ្ញុំព្រះករុណាបានបុណ្យត្រង់ធម្មទាន ដែលព្រះទ្រង់ញាណ ប្រោសទេសនាថា **សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទានឈ្នះ ទានទាំងពួង ។

## បែបរៀនយោគសព្វនាម

វិសេសនសព្វនាមទាំងនិយមទាំងអនិយម ហៅថា **វិសេសនៈ** របស់នាមនាម វៀរលែងតែ **គឺ**-សព្ទដែល ប្រែថា "អ្នកណា" ប្រើជាកត្តាដូចនាមនាមប៉ុណ្ណោះ ។

ក្នុងប្រយោគ ដែលលោករៀងតែសព្វនាម មិនបាន រៀងនាមនាមទុកផងទេ វេលាប្រែ ត្រូវរកនាមនាមមកប្រកប ឲ្យត្រូវតាមលិង្គវចនៈ និងវិភត្តិរបស់វិសេសនសព្វនាម ហៅ ថា **យោគសព្វនាម** ។

ការយោគសព្វនាមនោះ មិនមែនយោគបានតាមចិត្ត ទេ ស្រេចហើយតែ សព្វនាមក្នុងស្រយោគនោះ សម្លឹងយក នាមនាម បែបណាដែលបាននិយាយរួច មកហើយ។

សិក្ខាកាមត្រូវពិចារណាថា វិសេសនៈសព្វនាមក្នុង ប្រ យោគនេះ តើដើម្បីសម្លឹងយកនាមនាមប្រភេទណា ? កាល បើដឹងច្បាស់ហើយ ទើបយកនាមនាម ប្រភេទនោះ ដូចជា **យោ យេ** បទទាំងពីរនេះ ជាបុំលិង្គឯកវចនៈបឋមាវិភត្តិ **យេ**

ជា បុំលិង្គពហុវចនៈបឋមាវិភត្តិ អាចយោគនាមនាម បានជា បុំលិង្គបឋមាវិភត្តិ ទៅតាម វចនៈដូចជា **យោ ជនោ**, **យោ មុនិ**, **យោ សេដ្ឋី**, **យោ គរុ**, **យេ ជនា**, **យេ មុនយោ**, **យេ សេដ្ឋិនោ**, **យេ គរូ** ជាដើម ដោយមិនគិតការន្តទេ ដូចជា **សត្ថា បន តេន ហត្ថិនា ឧបដ្ឋិយមានោ សុខំ វសិ ។ សោបិ គណ្ណំ បហាយ ផាសុវិហារត្ថាយ តំ វនសណ្ឌំ បាវិសិ** ។ **សោបិ** ត្រូវយក **ហត្ថី**, **សោ** និង **ហត្ថី** មានលិង្គវចនៈ វិភត្តិ ដូចគ្នា ផ្សេងតែការន្តអាចយោគចូលគ្នាបាន មិនខុសវិធី យោគសព្វនាមទេ ដូចប្រែថា **បន** ចំណែកខាង **សត្ថា** វីព្រះ សាស្តា **តេន ហត្ថិនា ឧបដ្ឋិយមានោ** កាលដែលដំរីនោះ បម្រើ **វសិ** ស្តេចគង់នៅហើយ **សុខំ** សប្បាយ ។ **សោបិ ហត្ថី** រីឯដំរីនោះ **បហាយ** លះបង់ហើយ **គណ្ណំ** នូវហ្វូង **បាវិសិ** ចូលទៅហើយ **វនសណ្ឌំ** កាន់ដងនៃព្រៃ **តំ** នោះ **ផាសុវិហារត្ថាយ** ដើម្បីប្រយោជន៍ដល់ការនៅសប្បាយ ។

ឧទាហរណ៍នេះ និយាយចំពោះបុំលិង្គបឋមាវិភត្តិ ឯកវចនៈប៉ុណ្ណោះ សូម្បី លិង្គវចនៈនិងវិភត្តិដទៃៗ សិក្ខាកាម

គប្បីផ្ទៀបគ្នាតាមន័យនេះចុះ ។ បើយោគឲ្យខុសលិង្គវចនៈ និង វិភត្តិ ដូចយោគថា **ឥមេ ឥត្ថី តា បុរិសា បរេ នារី** ខុស លិង្គ យ៉ាងនេះក្តី **ឥមេ ជនោ តេ ជនំ** ខុសវចនៈនិងវិភត្តិ យ៉ាងនេះក្តី ប្រើមិនបានឡើយ។

វិធីយោគសព្វនាមនៅមានច្រើនទៀត ។

ក) ក្នុងប្រយោគដើម មានសង្ខ្យាប្រាប់ចំនួននាមនាម ដល់មកប្រយោគក្រោយលោកច្រើនមិនសូវរៀងសង្ខ្យានោះ ទេរៀងទុកតែវិសេសនៈសព្វនាម។

កាលបើដូច្នេះ វេលាប្រែឲ្យបានសេចក្តីជាក់លាក់ល្អ គួរបំពេញសង្ខ្យាចំនួននោះមកប្រកបផង ទើបបានសេចក្តី ច្បាស់លាស់ ដូចជា **សេតព្យេនគរវាសិនោ ហិ ចុល្លកាឡោ មជ្ឈិមកាឡោ មហាកាឡោ ចាតិ តយោ ភាតរោ កុដុម្ពិកា ។ តេសុ ជេដ្ឋកនិដ្ឋា ទិសាសុ វិចរិត្វា បញ្ចហិ សកដសតេហិ ភណ្ឌំ អាហរន្តិ ។ តេសុ** ក្នុង សង្កាត់ក្រោយ ត្រូវយោគយក សង្ខ្យាក្នុងសង្កាត់មុន មកផងថា **តេសុ តីសុ កុដុម្ពិកេសុ** ។

ប្រែប្រយោគទាំងពីរសង្កាត់នោះថា **ហិ** សេចក្ដីពិស្ដារថា **កុដុម្ពិកា** រីកុដុម្ពិក៍ទាំងឡាយ **តយោ** បីនាក់ **ភាតរោ** ជាបងប្អូន **ឥតិ** គឺ**ចុល្លកាលោ ច** រីចុល្លកាល ១ **មជ្ឈិមកាលោ ច** រីមជ្ឈិមកាល ១ **មហាកាលោ ច** រីមហាកាល ១ **សេតព្យនគរវាសិនោ** មានកិរិយានៅក្នុង ក្រុងសេតព្យជាប្រក្រតី ។ **តេសុ តីសុ កុដុម្ពិកេសុ** បណ្ដា កុដុម្ពិក៍ទាំងបីនាក់នោះ **ជេដ្ឋកនិដ្ឋា** រីកុដុម្ពិក៍ជាបងបង្អស់និងកុដុម្ពិក៍ជាប្អូនពៅទាំងឡាយ **វិចរិត្វា** ត្រាច់ទៅហើយ ផ្សេងៗ **ទិសាសុ** ក្នុងទិសទាំងឡាយ **អាហរន្តិ** តែងនាំមក **ភណ្ឌំ** នូវរបស់ **សកដសតេហិ** ដោយរយនៃរទេះទាំងឡាយ **បញ្ចហិ** ប្រាំ ។

**តេសុ** ហ្នឹងឲ្យយោគទាំងសង្ខ្យាមកទៀត ដើម្បីឲ្យជាក់ច្បាស់បានជាថែម **តីសុ កុដុម្ពិកេសុ** ដើម្បីបញ្ជាក់ឲ្យ សេចក្ដីច្បាស់លាស់ ។

ខ) ក្នុងប្រយោគដើមប្រយោគខ្លះមាន **វា** ឬ **ច**, **ចិ**-សព្ទ ជាសមុច្ច័យ ឬ វិកប្បខ័ណ្ឌត្រង់ចន្លោះនៃបទនាម សម្រាប់

រូបរួម ឬញែកបទនាមឲ្យដាច់ចេញពីគ្នា ដល់មកប្រយោគក្រោយ **វា**, **ច**, **មិ**-សព្ទ ក្តីបទនាមនាមនោះៗ ក្តី ក៏បាត់អស់ទៅ ឯសេចក្តីគង់នៅជាប់ទាក់ទងគ្នា ព្រោះហេតុនោះ ទើបលោករៀងវិសេសនៈសព្ទនាមទុក សម្រាប់ឲ្យ យោគយកបទនាមនាមនោះៗ ព្រមទាំង **វា**, **ច**, **មិ**-សព្ទ ក្នុងវេលាដែលប្រែដូចជា **យេ ខោ កេចិ លោកេ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា អហំ តេសំ អញ្ញតរោ**; **តេសំ** បទក្រោយ **អហំ** ត្រូវយោគថា **តេសំ អរហន្តានំ វា អរហត្តមគ្គំ សមាបន្នានំ វា** ។ ប្រែទាំងពីរសង្កាត់ថា: **មុគ្គលា** រីបុគ្គលទាំងឡាយ **យេ ខោ កេចិ** ឯណានីមួយ **លោកេ** ក្នុងលោក **អរហន្តោ វា** ជាព្រះអរហន្តឬ **អរហត្តមគ្គំ សមាបន្នា វា** ឬជាអ្នកដល់ហើយនូវព្រះអរហត្តមគ្គ **តេសំ អរហន្តានំ វា អរហត្តមគ្គំ សមាបន្នានំ វា** បណ្តាបុគ្គលទាំងឡាយជាព្រះអរហន្ត ឬជាអ្នកដល់ហើយនូវអរហត្តមគ្គនោះ **អហំ** រីខ្ញុំ **អញ្ញតរោ** មួយរូបដែរ ។

**អញ្ញតរោ** ជា **និទ្ធារណីយៈ** គឺពាក្យដែលរើឡើងអំពី **តេសំ**, **តេសំ** មាន **អរហន្តានំ**, **អញ្ញតរោ** ត្រូវដាក់ **អរហា វា អរហត្តមគ្គំ សមាបន្នោ វា ហោមិ** ជាព្រះអរហន្ត ឬថាជាអ្នកដល់ហើយនូវអរហត្តមគ្គមួយរូបដែរ ។

## លំហាត់ប្រែ

**អថស្ស ភរិយាយ កុច្ឆិយំ គព្ភោ បតិដ្ឋាសិ។**

**អថស្ស ន ចិរស្សេវ ភរិយាយ គព្ភោ បតិដ្ឋាសិ សា គព្ភស្ស បតិដ្ឋិតភាវំ ញត្វា តស្ស អារោចេសិ ។**

**អន្តោបាឡិតេសុ ទ្វេសុ យោ យំ ឥច្ឆតិ តស្ស តំ យថិច្ឆិតមេវ សម្បជ្ជតិ ។**

**សេដ្ឋី អត្តនា បាលិតំ វនប្បតឹ និស្សាយ លទ្ធត្តា តស្ស បាលោតិ នាមំ អកាសិ ។**

**យោ តេសំ បច្ចយោ ហោតិ យំ និស្សាយ តេ តំ កម្មំ ករោន្តិ សោ ឧត្តោ មិត្តោ វា តេសំ បុព្វុត្តមោតិ វុច្ចតិ ។**

## មេរៀនប្រែភាវ-សព្ទ

## ការប្រែភាវសព្ទមាន ៤ យ៉ាងគឺ

១. សព្ទជានាមកិតក: ភាវសាធន: បើរួមជាបទ សមា-សនិងភាវសព្ទប្រែថា ភាវនៃកិរិយា...ដូចជា **គមនភាវោ** រីភាវនៃកិរិយាទៅ ។

២. សព្ទជាគុណនាមក្តី នាមប្រើជាគុណនាមក្តី បើរួមជាបទសមាសនិងភាវសព្ទ ប្រែថាភាវនៃ...ជា... ។ ដូចជា **រញ្ញោ មហន្តភាវោ** រីភាវ:នៃព្រះរាជាជាធំ, **បុរិសស្ស រាជភាវោ** រីភាវ:នៃបុរសជាព្រះរាជា ។

៣.សព្ទជាកិរិយាកិតក:ប្រកប **ត**-បច្ច័យបើរួមជា បទសមាស និងភាវសព្ទប្រែថា ភាវនៃ... ជាអ្នក... ដូចជា **ភិក្ខុនោ និសិន្នភាវោ** រីភាវ:នៃភិក្ខុជាអ្នកអង្គុយហើយ ។

៤. សព្ទជានាមនាមក្តី នាមកិតក:កត្តុសាធនក្តី បើរួមជាបទសមាសនិង ភាវសព្ទប្រែថាភាវនៃ... ដូចជា **សហាយ-ភាវោ** រីភាវ:នៃសម្លាញ់ **ឃាតកភាវោ** រីភាវ:នៃបុគ្គលអ្នក

សម្លាប់ ។ សូម្បីបទដែលប្រកបបច្ច័យ ក្នុងភាវតទ្ធិត ទាំងអស់ មាន **តា**-បច្ច័យជាដើម ក៏មានវិធីប្រែ ៤ យ៉ាងដូច **តាទ**-សព្ទ ដែលភ្ជាប់ជាបទសមាស ដែរ ។

## លំហាត់ប្រែ

**មគធរញ្ញោ រជ្ជេន និមន្តិយមានោ តំ បដិក្ខិបិត្វា សព្វញ្ញុតំ បត្វា** ប្រែថា **សត្ថា** រីព្រះសាស្ដា **មគធរញ្ញោ រជ្ជេន និមន្តយមានោ** គឺព្រះរាជាក្នុងដែនមគធៈកាលនិមន្តដោយភាវៈនៃព្រះរាជា **បដិក្ខិបិត្វា** ទ្រង់ហាមហើយ **តំ រជ្ជំ** នូវរាជ្យនោះ ឬថា (នូវភាវៈនៃព្រះរាជានោះ) **បត្វា** ទ្រង់ដល់ហើយ **សព្វញ្ញុតំ** នូវភាវៈនៃព្រះសព្វញ្ញូ ។ **រជ្ជំ** មកពី **រាជ** + **ណ្យ** បច្ច័យក្នុងភាវតទ្ធិត ហើយរាជនឹងប្រើជានាមនាម **សព្វញ្ញុតំ** នោះ សម្រេចមក **សព្វញ្ញុ** + **តា** បច្ច័យ ទុតិយាទៅជា **តំ** ឲ្យប្រើជានាមនាម ប្រែថាភាវៈនៃ... (ធ.ប.១) ។

**ចូឡបន្ថកោ សិនេហេន ពុទ្ធសាសនេ គិហិតាចំ ន បត្ថេតិ** ប្រែថា **ចូឡបន្ថកោ** រីចូឡបន្ថកៈ **ន បត្ថេតិ** តែងមិនប្រាថ្នា **គិហិតាចំ** នូវភាពជាគ្រហស្ថ **សិនេហេន** ដោយសេចក្ដីស្នេហា **ពុទ្ធសាសនេ** ក្នុងព្រះពុទ្ធសាសនា ។ **គិហិតាចំ** ជា

នាមនាម ប្រែថា ភាវៈនៃ... (ធ.ប.២) ។

**កាមគុណំ អារព្ភ ហសនភាវោ នាម ហីនោ ធម្មោ** ប្រែថា **កាមគុណំ អារព្ភ ហសនភាវោ នាម** ឈ្មោះថាវីភាវគឺកិរិយាសើចប្រារព្ធនូវកាមគុណ **ហីនោ ធម្មោ ហោតិ** រមែងជាធមិដ៏ថោកទាប ។

**អថស្ស អត្តនា សទ្ធឹ ឯកជ្ឈាសយតំ ញត្វា ឧប្បតិ-ស្សោ អាហ** (ធ.ប.១) ប្រែថា **អថ** គ្រានោះ **ឧប្បតិស្សោ** វីឧប្បតិស្ស **ញត្វា** ដឹងហើយ **អស្ស កោលិតស្ស អត្តនា សទ្ធឹ ឯកជ្ឈាសយតំ** នូវភាវៈនៃកោលិតៈនោះ ជាអ្នកមានអធ្យាស្រ័យតែមួយៗ អន្លើដោយខ្លួន **អាហ** ពោលហើយ (ប្រែភាវៈនៃ... ជា...) ។

**ឯចរូបំ អលភន្តស្ស ឯកចារិកភាវោ ច សេយ្យោ ឯចរូបំ សហាយំ អលភន្តស្ស បុគ្គលស្ស ឯកចារិកភាវោ ច** វីភាវនៃបុគ្គលជាអ្នកកាលមិនបាននូវ សម្លាញ់មានសភាពយ៉ាងនេះ ជាអ្នកត្រាច់ទៅម្នាក់ឯងជាប្រក្រតី **សេយ្យោ ហោតិ** ជាអាការប្រសើរបំផុត (ធ.ប.១) ។

**អថស្ស មម ចក្ខូនំ បរិហីនភាវំ អារោចេយ្យាថ** ប្រែថា **អថ** នាកាលបការៈយ៉ាងនោះ (**សន្តេ** កាលមាន) **តុម្ហេ** រីលោកទាំងឡាយ **អារោចេយ្យាថ** គប្បីប្រាប់ **មម ចក្ខូនំ បរិហីនភាវំ** នូវភាវៈនៃចក្ខុទាំងឡាយ របស់ខ្ញុំជាធម្មជាតសាបសូន្យហើយ **អស្ស កនិដ្ឋស្ស** ដល់ប្អូនពៅនោះ (ធ.ប.១) ។

**តាយ សញ្ញាយ អត្ថិភាវំ ជានិស្សាម** ប្រែថា **មយំ** រីយើងទាំងឡាយ **ជានិស្សាម** នឹងដឹង (**អម្ហាកំ**) **អត្ថិភាវំ** នូវភាវនៃយើងទាំងឡាយមាននៅ **សញ្ញាយ** ដោយសញ្ញា **តាយ** នោះ ។ បើចូលជាបទសមាសដូច្នេះ មិនមែនជាកិរិយាអាខ្យាតទេ គឺជានិបាតសព្ទ (ធ.ប.២) ។

**ភិក្ខូនំ អត្ថិភាវំ វា នត្ថិភាវំ វា ជានាហិ** (ធ.ប.២) ប្រែថា **ត្វំ** រីលោក **ជានាហិ** ចូរដឹង **ភិក្ខូនំ អត្ថិភាវំ វា** នូវភាវៈនៃភិក្ខុទាំងឡាយមាននៅ ឬ **ភិក្ខូនំ នត្ថិភាវំ វា** ឬថានូវភាវៈនៃភិក្ខុទាំងឡាយមិនមាននៅ ។ **អត្ថិ នត្ថិ** ជាសមាសដូច្នេះ គឺជានិបាតកិរិយាមិនមែនអាខ្យាតទេ ។ បើជាអាខ្យាតត្រូវមានបទប្រធានជាឯកវចនៈ តែម្យ៉ាង តែបទប្រធានជា

ពហុវចនៈ **អត្ថិ នត្ថិ** នោះ គឺជានិបាតកិរិយា អាចប្រធានជាពហុវចនៈបាន ឬ ចូលជាសមាស ជាប់នឹង បទដទៃបានដូចជា **នត្ថិបុត្តោ អត្ថិភាវោ** ជាដើម ។

បែបរៀនប្រែវិសេសនៈ បទវិសេសនៈ គឺបទសម្រាប់ពង្រីកសេចក្តីនៃនាមនាម ឬ បុរិសសព្វនាមឲ្យមាន សេចក្តីវិសេសប្លែកជាងធម្មតា ឯបទវិសេសនៈត្រូវ មានលិង្គវចនៈវិភត្តិដូចបទនាមនាមនោះ ឯវិភត្តិមានតាំងពីបឋមាវិភត្តិ រហូតដល់ អាលបនៈ ប៉ុន្តែបទវិសេសនៈ មិនអាចប្រែចេញ ពាក្យអាយតនិបាតទេ បទដែល អាចប្រើជាវិសេសនៈបាន គឺនាមនាមពួកខ្លះ ដូចជា **ថេរោ ភិក្ខុ** ភិក្ខុជាព្រះថេរៈ, បទគុណនាមដូចជា : **ឧច្ច** ខ្ពស់, **នីច** ទាប, **កាឡ** ខ្មៅ, **ឱទាត** ស ។ល។

បទនាមកិតកៈ ដូចជា **ទាយក** អ្នកឲ្យ, **លោកវិទូ** អ្នកដឹងច្បាស់នូវលោក, **អាយុទោ** អ្នកឲ្យនូវអាយុ, **នគរវាសី** អ្នកនៅក្នុងក្រុងដោយប្រក្រតីជាដើម ។ល។

កិរិយាកិតកៈ ដូចជា **លទ្ធ** បានហើយ, **នីត** នាំទៅ

ហើយ, **កត** ធ្វើហើយ, **មត** ស្លាប់ហើយ ។ល។ សមាសគុណ ដូចជា **ខីណាសវ** មានអាសវៈអស់ហើយ, **កតបុញ្ញ** មានបុណ្យធ្វើហើយ, **សុខប្បត្ត** ដល់ហើយនូវសេចក្តីសុខ ។ល។

តទ្ធិតគុណ ដូចជា **រាជគហិកៈ** អ្នកនៅក្នុងរាជគ្រឹះ, **កាយិកៈ** ប្រកបហើយដោយកាយ ។ល។ សង្ខ្យាគុណ ដូចជា **ចតុប្បញ្ញាសាយ ភិក្ខូនំ ទានំ ទេតិ** ។ សង្ខ្យានាម ដូចជា **បញ្ញាសតា** ជាដើម ។

វិសេសនសព្វនាម ទាំងនិយម ទាំងអនិយម ដូចជា **ឯតេ ភិក្ខូ យេ ច ពុទ្ធា** ។ល។ វិធីប្រែត្រូវ មានពាក្យអែប ជាមួយនឹងពាក្យនាមនាម ដូចជា នាមនាមជាម្ចាស់ត្រូវប្រែពាក្យអែបជាមួយនឹងវិសេសនៈ ជាអ្នក ឬ ទ្រង់ ឬ ព្រះអង្គ ជាដើម ដូចពាក្យថា **អធិបតិរាជា** "ស្តេចទ្រង់ជាធំក្រៃលែង" **មហទ្ធនោ សេដ្ឋី**, សេដ្ឋីលោកមានទ្រព្យច្រើន, បើជាឈ្មោះសត្វឲ្យប្រែថាជា ឬ ប្រែទទេៗ ដូចជា **ចណ្ឌោ សុនខោ** សត្វ

កាច, បើជាវិសេសនៈ របស់ទីឋានវត្ថុផ្សេងៗ ប្រែថា ដ៏, ដ៏ជា ឬដែលដូចជា **សីតំ ឋានំ** ទីដ៏ត្រជាក់, **សុន្ទរោ ធម្មោ** ធម៌ដែលល្អ ។ល។ បើប្រាប់ចំនួនត្រូវថែមពាក្យតាមសមគួរ ដូចពាក្យថា **ឯកា រជ្ជុ** ខ្សែមួយកន្ទុយ, **ឯកោ បទេសោ** ប្រទេសមួយស្រុក, **ឯកោ បោត្ថកោ** សៀវភៅមួយក្បាល, **ឯកោ ថម្ភោ** សរសរមួយដើម ។ល។

## មេរៀនប្រែវិកតិកត្តា

បទវិកតិកត្តា ពាក្យថា "**វិកតិ**" គឺជាបទអ្វី ? ប្រែថា ធ្វើឲ្យប្លែកៗ, កត្តា ប្រែថា អ្នកធ្វើ រួមគ្នាទៅជាវិកតិកត្តា "ធ្វើកត្តាឲ្យប្លែក" ឬ "ធ្វើអ្នកធ្វើឲ្យប្លែក" វិកតិកត្តា ត្រូវមាន អង្គ ៣ គឺ :

១. សព្ទប្រកបបឋមាវិភត្តិ ឬ តតិយាវិភត្តិ

២. កិរិយាសព្ទសម្រេចមកអំពីធាតុ ៤ គឺ : **ហុ**, **ភូ**, **អស**, **ជន**-ធាតុណាមួយក្នុងប្រយោគនោះ

៣. សព្ទពួកនោះ  គឺគុណនាម  នាមប្រើជាគុណ

កិរិយាកិតក: ប្រកបដោយ ព្យយ:បច្ច័យរៀងទុកនៅខាងមុខ ឬ ខាងក្រោយនៃកិរិយាសព្ទនោះ មិនមានបទដទៃរាំងក្នុងចន្លោះ កាលបើព្រមដោយអង្គ ៣ នោះ ទើបឈ្មោះថា ជាបទ **វិកតិកត្តា** ។

វិធីប្រែបទវិកតិកត្តានោះ ត្រូវទាញយកបទ បកតិកត្តាជាគោល ។ បើបទ បកតិកត្តាជាបុំលិង្គជាឥត្ថីលិង្គ ត្រូវប្រែបទវិកតិកត្តាឲ្យត្រូវតាមលិង្គ របស់បកតិកត្តា ដូច្នេះ :

១. ពួកមនុស្សបុំលិង្គ ប្រែថា "ជាអ្នក, ជាបុគ្គល, ជាបុរស" ឥត្ថីលិង្គ ប្រែថា "ជាអ្នក, ជាស្ត្រី" ។

២. ពួកធម៌បុំលិង្គ ប្រែថា "ជាធម៌, សភាវ" ឥត្ថីលិង្គ ប្រែថា "ជាធម្មជាតិ, ជា គុណជាតិ" នបុំសកលិង្គ ប្រែថា "ជាធម្មជាត, ជាគុណជាត" ។

**បុត្តោ ហិ មេ អសន្តាសី វីតតណ្ហោ មហាវីរិយោ មហាបញ្ញោ** (**ហោតិ**) ប្រែថា **ហិ** ក៏ **បុត្តោ** វីបុត្ត **មេ** របស់តថាគត **អសន្តាសី វីតតណ្ហោ មហាវីរិយោ មហាបញ្ញោ**

**ហោតិ** រមែងជាមនុស្សមានកិរិយាមិនតក់ស្លុតជាប្រក្រតី ជាអ្នកមានតណ្ហាទៅប្រាសហើយ ជាអ្នកមានវីរិយៈច្រើន ជាអ្នកមានប្រាជ្ញាច្រើន ។ **ភិក្ខុនា នាម រាធេន ឋិយ សុខេន ភវិតព្វំ** ប្រែថា **ភិក្ខុនា នាម** ដែលឈ្មោះថា គឺភិក្ខុ **រាធេន ឋិយ សុខេន ភវិតព្វំ** គប្បីជាអ្នកគឺគេប្រដៅងាយដូចជារាធ (ភិក្ខុ)។ **សា ទញ្ញា អហោសិ** ប្រែថា **សា** (**កុមារិកា** វីនាងកុមារិកា) នោះ **ទញ្ញា អហោសិ** បានជា ស្រីអាវហើយ ។ **អយំ មេ សហាយិកា ឥទានិ ពហុបការា ហោតិ** ប្រែថា **សហាយិកា** វីស្រីជាសម្លាញ់ **មេ** របស់អញ **អយំ** នេះ **ឥទានិ ពហុបការា ហោតិ** ជាអ្នកមានឧបការៈច្រើន ក្នុងកាល ឥឡូវនេះ ។ បើបទវិកតិកត្តាជានាមនាមជាលិង្គអ្វី ត្រូវទុកឲ្យគង់នៅតាមលិង្គដើម ដូចជា :

**អហោ ឧត អយំ ថេរោ មម ភរិយា ភវេយ្យ** ប្រែថា **អហោ ឧត** ឱហ្ន៎ **ថេរោ** វីព្រះថេរៈ **អយំ** នេះ **មម ភរិយា ភវេយ្យ** គប្បីជាភរិយារបស់អញ ។

**មហល្លកស្ស ហត្ថបាទាបិ អនស្សវា ហោន្តិ** ប្រែថា **មហល្លកស្ស ហត្ថបាទាបិ** សូម្បីវីដៃនិងជើងទាំងឡាយ នៃបុគ្គលចាស់ **អនស្សវា ហោន្តិ** ជាអវយវៈ មិនស្តាប់បង្គាប់ ។

**អង្គុលិយោ សោភណា ហោន្តិ** ប្រែថា **អង្គុលិយោ** រីម្រាមដៃទាំងឡាយ **សោភណា ហោន្តិ** ជាធម្មជាតិល្អ ។

**គត្តំ បូតិកំ ជាតំ** ប្រែថា **គត្តំ** រីខ្លួន **បូតិកំ ជាតំ** ជាធម្មជាតស្អុយ ។ **មុខំ សោភណំ** (**ហោតិ**) ប្រែថា **មុខំ** រីមុខ **សោភណំ ហោតិ** ជាធម្មជាតល្អ ។

**គាមោ សុន្ទរោ ហោតិ** ប្រែថា **គាមោ** រីស្រុក **សុន្ទរោ ហោតិ** ជាប្រទេសល្អ ។ **មនុស្សាវាសោ សបរិបន្ថោ ហោតិ** ប្រែថា **មនុស្សាវាសោ** រីប្រទេសជាទីនៅរបស់មនុស្ស **សបរិបន្ថោ ហោតិ** រមែងជាប្រទេសប្រព្រឹត្តទៅមួយអន្លើដោយអន្តរាយ ។

**នគរំ នាម អន្តោ សុវិភត្តំ ហោតិ វីថិចតុក្កសឡាដ-កសម្បន្នំ អន្តរាបណំ** ប្រែថា **នគរំ នាម** ធម្មតារីនគរ

**វីថិចតុក្កសង្ខាដកសម្បន្នំ អន្តរាបណំ អន្តោ សុចិតត្តំ ហោតិ** ជានគរដែលបរិបូរណ៌ហើយ ដោយថ្នល់បែកជាបួន និង ថ្នល់បែកជាបី មានរានផ្សារក្នុងចន្លោះ គឺ បុគ្គលចាត់ចែងល្អហើយក្នុងខាងក្នុង ។

## លំហាត់ប្រែ

**តស្ស តំ បិលោតិកខណ្ឌំ បរិមជ្ជិតស្ស កិលិដ្ឋំ អហោសិ ។ សេដ្ឋិនោ ធនំ អឌ្ឍំ ហោតិ ។ អដ្ឋិខ្ចិកោ មគ្គោ សេដ្ឋោ ឧត្តមោ (ហោតិ) ។ ចិត្តស្ស ទមថោ សាធុ (ហោតិ) ។ អកុសលា ធម្មា បន ឥធ លោកេ ច បរលោកេ ច មលមេវ ហោន្តិ ។ ឯតេសុ ចតូសុ យា ឯសា បញ្ញា នាម សា វ សេដ្ឋា ហោតិ ។ អវិជ្ជា បរមំ មលំ ហោតិ ។ សកលស្ស បន វដ្តទុក្ខស្ស បហានសំខាតំ អរហត្តមេវ ឥមស្មឹ លោកេ សុខំ នាម (ហោតិ) ។ មច្ឆេរំ ទទតោ មលំ (ហោតិ) អត្តទត្ថស្ស ចោសស្ស និច្ចំ សញ្ញតចារិនោ ។ ទេសនាវសានេ ចតុន្នំ បាណកោដីនំ ធម្មាភិសមយោ អហោសិ ។ យោ ហិ ឯវំ ករោតិ សោ លោកវជ្ជនោ នាម ហោតិ ។**

## តួវិភត្តិកត្តា

**កត្តា** ក្នុង **កត្តុវាចកៈ** ឈ្មោះថា **សយកត្តា**, ក្នុង

**ហេតុកត្តុវាចក:** ឈ្មោះថា **ហេតុកត្តា** ប្រកបដោយ បឋមាវិភត្តិ ដូច្នេះ តួ **វិកតិកត្តា** ត្រូវជា បឋមាវិភត្តិដែរ ដូចជា **រាជកុមារោ តំ នាសេតុកាមោ ហោតិ** ។ ប្រែថា **រាជកុមារោ** វព្រះរាជកុមារ **តំ នាសេតុកាមោ ហោតិ** ជាអ្នកប្រាថ្នាដើម្បីញ៉ាំងលោក ឲ្យវិនាស ។ **វេរញ្ជោ ព្រាហ្មណោ មារាវដ្ដនេន អាវដ្ដោ (ហុត្វា) ឯកទិវសំបិ សត្ថារំ អារព្ភ សតឹ ន ឧប្បាទេសិ** ប្រែថា **ព្រាហ្មណោ** វព្រាហ្មណ៍ **វេរញ្ជោ** ឈ្មោះវេរញ្ជៈ **មារាវដ្ដនេន អាវដ្ដោ ហុត្វា** ជាអ្នកគឺ គ្រឿងបង្វិលរបស់មារឲ្យវិលទូទៅហើយ **សត្ថារំ អារព្ភ សតឹ ន ឧប្បាទេសិ** មិនញ៉ាំងសតិប្រារព្ធ នូវព្រះសាស្តាឲ្យកើតឡើងហើយ **ឯកទិវសំបិ** សូម្បីក្នុងថ្ងៃមួយ ។

**កត្តា** ក្នុង **កម្មវាចក: ហេតុកម្មវាចក:** និង **ភាវ-វាចក:** ឈ្មោះថា **អនភិហិតកត្តា** ប្រកបដោយ តតិយាវិភត្តិ, តួ **វិកតិកត្តា** ត្រូវប្រកបដោយ តតិយាវិភត្តិដែរ ដូចជា **មជ្ឈិមវយេ អប្បមត្តេន ហុត្វា កុសលំ ភាតព្វំ** ប្រែថា **កុសលំ** វកុសល **បុគ្គលេន** គឺបុគ្គល **អប្បមត្តេន ហុត្វា** ជា

អ្នកមិនប្រមាទហើយ **ភាតព្វំ** គប្បីធ្វើ **មជ្ឈិមវយេ** ក្នុងមជ្ឈិមវ័យ ។

**សមានកេន នាម ព្យត្តេន ភវិតព្វំ** ប្រែថា **សមាន-បកេន** (**បុគ្គលេន**) **នាម** ឈ្មោះថាគឺបុគ្គលអ្នកបបួល **ព្យត្តេន ភវិតព្វំ** គប្បីជាអ្នកឈ្លាស ។ **មយា គហិនា ភវិតុំ វដ្ដតិ** ប្រែថា **មយា គិហិនា ភវិតុំ** រីកិរិយាគឺយើងជាគ្រហស្ថ **វដ្ដតិ** រមែងគួរ ។

**សោ តំ ខណញ្ញេវ តុណ្ហី ហុត្វា បុន គន្ត្វា ថេរេ អាភោសតិយេវ** ប្រែថា **សោ ឆន្នោ** រីព្រះឆន្នោះ **តំខណំ ឯវ តុណ្ហី ហុត្វា** ជាអ្នកនៅស្ងៀមក្នុងខណៈនោះឯង **គន្ត្វា** ទៅហើយ **ថេរេ អាភោសតិ ឯវ** តែងជេរនូវព្រះថេរទាំងឡាយមែនពិត ។

## បែបរៀនប្រែវិកតិកម្ម

បទវិកតិកម្មគឺបទអ្វី ? វិកតិ ប្រែថា "ធ្វើឲ្យប្លែក", កម្ម ប្រែថា "តួអំពើ" រួមសេចក្ដីថា "ធ្វើបទដែលគេត្រូវធ្វើឲ្យប្លែកៗ" បានដល់ធ្វើតួពង្រីកកម្មឲ្យប្លែកចាកភាពដើម មាន

សេចក្ដីថា វិកតិកត្តា គឺ វិកតិកត្តាជាតួពង្រីកបទកត្តាឲ្យប្លែក តែ វិកតិកម្មជាតួពង្រីកបទកម្មឲ្យប្លែក មានពីរយ៉ាងគឺ :

១. បទកម្ម ក្នុង កត្តុវាចក: ហេតុកត្តុវាចក: ប្រកប ដោយ ទុតិយាវិភត្តិ ដូច្នេះ បទវិកតិកម្ម ក៏ត្រូវប្រកប ទុតិយា វិភត្តិដែរ ដូចជា :

**អហំ ធន តំ លោកិយកុដុម្ពស្សាមិនី ករិស្សាមិ** ប្រែថា **ធន** តែថា **អហំ** រីតថាគត **ករិស្សាមិ** នឹងធ្វើ **តំ ភាណំ** នូវនាង កាណានោះ **លោកិយកុដុម្ពស្សាមិនី** ឲ្យជាម្ចាស់ នៃសម្បត្តិ ជាលោកិយ៍ ។

២. បទកម្ម ក្នុង កម្មវាចក: ហេតុកម្មវាចក: ប្រកប ដោយ បឋមាវិភត្តិ ជាបទប្រធាន ព្រោះហេតុនោះ បទវិកតិកម្ម ត្រូវប្រកបដោយបឋមាវិភត្តិដែរ ដូចជា :

**អាម មហារាជ តិក្ខនញ្ញ មេ អនក្ខោសិកា កតា លោកុត្តរកុដុម្ពស្សាមិនី ច** ប្រែថា **មហារាជ** បពិត្រមហារាជ **អាម** ថ្វាយព្រះពរ **សា ភាណា** រីនាងកាណានោះ **មេ** គឺ តថាគត **កតា** ធ្វើហើយ **តិក្ខនំ អនក្ខោសិកា ច** ឲ្យជាអ្នក

មិនជេរនូវភិក្ខុទាំងឡាយ ផង **លោកុត្តរកុដុម្ពស្សាមិនី ច** ឲ្យជាម្ចាស់នៃ សម្បត្តិជាលោកុត្តរផង ។ **ភិក្ខវេ បរំ ឱវទន្តេន នាម អត្តា សុទន្តោ ភាតព្វោ** ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **អត្តា** រីខ្លួន **បុគ្គលេន** គឺបុគ្គល **បរំ** (**បុគ្គលំ**) **ឱវទន្តេន នាម** ឈ្មោះថាកាលទូន្មាននូវបុគ្គលដទៃ **ភាតព្វោ** គប្បីធ្វើ **សុទន្តោ** ឲ្យជាខ្លួនគឺគេទូន្មានល្អហើយ ។

**ធម្មំ ចរេ សុចរិតំ** ប្រែថា (**បុគ្គលោ** រីបុគ្គល) **ចរេ** គប្បីប្រព្រឹត្ត **ធម្មំ** នូវធម៌ **សុចរិតំ** ឲ្យជាធម៌គឺខ្លួនប្រព្រឹត្តល្អហើយ ។ **សោឡសកោដ្ឋាសេ កត្វា តតោ ឯកេកំ បុន សោឡសកោដ្ឋាសេ កត្វា** ... ប្រែថា **យំ ផលំ** រីផលណា **កត្វា** ធ្វើហើយ **តំផលំ** នូវផលនោះ **សោឡសកោដ្ឋាសេ** ឲ្យជាចំណែក ១៦ **កត្វា** ធ្វើ **ឯកេកំ កោដ្ឋាសំ** នូវចំណែកមួយៗ **តតោ សោឡសកោដ្ឋាសតោ** អំពីចំណែក ១៦ នោះ **សោឡសកោដ្ឋាសេ** ឲ្យជាចំណែក ១៦ **បុន** តទៅទៀត ។ **តំ ផលំ សោឡសកោដ្ឋាសេ** ជាបទវិកតិកម្ម មិនត្រូវចេញ សំនៀងថា "ទាំងឡាយ" ទេ ។

## បែបរៀនប្រែប្រយោគឧបមា

សេចក្តីដែលនាំមកប្រៀបធៀប ជាសេចក្តីដែលមានមកអំពីដើម ជារឿងពិតប្រាកដដែល លោកត្រូវនាំយកមកប្រៀបធៀបគ្នា ដើម្បីបំភ្លឺសេចក្តីឲ្យឃើញច្បាស់ តាមពិតឈ្មោះថា ប្រយោគ **ឧបមា** ។ កាលបើប្រយោគឧបមា មានហើយ ប្រយោគ ឧបមេយ្យក៏ត្រូវមានដែរ ព្រោះសេចក្តីក្នុងប្រយោគទាំងពីរនេះទាក់ទងរកគ្នាដូចកូនសោនិង មេសោ ។ សេចក្តីគួរនាំទៅប្រៀបធៀបនឹង សេចក្តីឧបមានោះ ឈ្មោះថា ប្រយោគ **ឧបមេយ្យ** ។

ប្រយោគឧបមាកំណត់ដោយនិបាត ៤ សព្ទគឺ **សេយ្យថាបិ**, **យថា** ប្រែថា "ដូចជា, យ៉ាងណា, យ៉ាងណាមិញ, មាន ឧបមាយ៉ាងណា" **ဝិយ**, **ឥវ** ប្រែថា "បីដូច **ឥវ** ដូចជា, ប្រហែល, ប្រដូច, មានឧបមាដូចជា, មានគួរនាដូចជា" ។ ប្រយោគ ឧបមេយ្យកំណត់ដោយនិបាតពីរសព្ទគឺ **តថា**, **ឯវំ** ប្រែថា "យ៉ាងនោះ, ដូច្នោះ, យ៉ាងនេះ, មានឧបមេយ្យ យ៉ាងនោះ" ។ និបាតក្នុងប្រយោគទាំងពីរនេះ ប្រែតគ្នា ដូច្នេះគឺ **សេយ្យថាបិ**, **យថា** និង **តថា**, **ឯវំ** លោកច្រើននិយមចុះក្នុង

ប្រយោគធំៗ គឺប្រយោគដែលមានកិរិយារបស់ប្រធាន... **ទិយ**, **ឥទ** ច្រើននិយមចុះក្នុងប្រយោគ ជានាមវាក្យាង្សខ្លះ ជាគុណវាក្យាង្សខ្លះ ហើយជ្រែកចូលទៅក្នុងចន្លោះកណ្តាល នៃប្រយោគឧបមេយ្យ ។

## ការប្រែប្រយោគឧបមាមាន ៣ យ៉ាងគឺ

ប្រែទទួល ១, ប្រែមិនទទួល ១, ប្រែទទួលក៏បានមិន ទទួលក៏បាន ១

១) ប្រែទទួល ត្រូវប្រែខាងប្រយោគឧបមេយ្យ ឲ្យ ទាល់តែអស់សព្ទ ទុកឲ្យ សល់នៅតែ **ឯវំ** កាលនឹងប្រែ **ឯវំ** គប្បីអានតាំងពី **យថា** ទាំងប្រយោគមករួមនឹង **ឯវំ** ប្រែចូល គ្នាតែម្តងថា "ដូចជាវី...ដូច្នោះ" ឧទាហរណ៍ : **សោ កិរ យថា គេណិយោ ជដិលោ បព្វជិតវេសេន ឯវំ គោបាលកវេសេន រាជបីឡំ បរិហរន្តោ អត្តនោ កុដុម្ពំ រក្ខតិ** ប្រែថា **កិរ** បាន ឮថា **សោ នន្ទគោបាលកោ** រីនាយនន្ទគោបាលនោះ **បរិហរន្តោ** កាលជៀសវាង **រាជបីឡំ** នូវសេចក្តីបៀតបៀន អំពីស្តេច **រក្ខតិ** រក្សា **កុដុម្ពំ** នូវទ្រព្យ **អត្តនោ** របស់ខ្លួន **គោបាលកវេសេន** ដោយភាវនៃខ្លួនជាអ្នកឃ្វាលនូវគោ **យថា គេណិយោ ជដិលោ បព្វជិតវេសេន រាជបីឡំ បរិហរន្តោ**

**អត្តនោ កុដុម្ពំ រក្ខតិ ឯវំ** ដូចជារឺ **គេណិយជដិល** កាលជៀសវាងនូវសេចក្ដីបៀតបៀនអំពីស្ដេច រក្សានូវទ្រព្យ របស់ខ្លួន ដោយភេទរបស់បព្វជិតដូច្នោះ (ធ.ប.២ ទំព័រ ២៥៩) ។

២) ប្រែមិនទទួល វិធីនេះគប្បីកំណត់យ៉ាងនេះគឺ ប្រយោគ ទាំងពីរនោះមានពាក្យវែង មានសេចក្ដីដទៃ ច្រឡូកច្រឡំជ្រែកជ្រៀតត្រង់កណ្ដាល ជាប្រយោគ **អនាទរៈ** ឬ **លក្ខណៈ** ជាដើមខ្លះ មិនមានខ្លះកាលបើប្រែរួមគ្នា រមែងធ្វើសេចក្ដីឲ្យឃ្លាតមិនជិតល្អ បើប្រែទទួលសេចក្ដីរបស់ **និបាត** នឹងបាត់ទៅ ។ វិធីមិនទទួលមាន ២ យ៉ាងគឺ : ប្រែឧបមារួចទើបប្រែឧបមេយ្យ ១, ប្រែ ឧបមារួចប្រែ **ឯវំ** បន្ទាប់បទប្រធាននៃឧបមេយ្យ ១ ។

## ក. ប្រែឧបមារួចប្រែឧបមេយ្យ

វិធីនេះត្រូវប្រែប្រយោគឧបមាមុន លុះអស់សេចក្ដីហើយ ទើបប្រែ **យថា** "យ៉ាងណា..." ទុកត្រង់ទីបំផុត ជើងប្រយោគតែម្ដង រួចទៅប្រែប្រយោគឧបមេយ្យ កាលប្រែអស់សេចក្ដីហើយ ទើបប្រែ **ឯវំ** "យ៉ាងនោះ..." ទុកត្រង់ទីបំផុតជើងប្រយោគដូចគ្នាដែរ ឧទាហរណ៍ : **យថា ឯកេន**

**បុរិសេន បដិវាតេ ខិត្តំ បហរិតុកាមតាយ ខិត្តោ សុខុមោ រជោ តមេវ បុរិសំ បច្ចេតិ.. តស្សេវ ឧបរិ បតតិ ឯវមេវ យោ បុគ្គលោ អប្បទុដ្ឋស្ស បុរិសស្ស បាណិប្បហារាទីនិ ទទន្តោ បទុស្សតិ តមេវ ពាលំ ឥធេវ ធម្មេ សម្បរាយេ វា និរយាទីសុ វិបច្ចមានំ តំ បាបំ វិបាកទុក្ខវសេន បច្ចេតិ**

ប្រែថា **រជោ** រីធូលី **សុខុមោ** ដ៏ល្អិត **ឯកេន បុរិសេន ខិត្តោ** ដែលបុរសម្នាក់បាចទៅហើយ **បដិវាតេ ខិត្តំ បហរិតុកាម-តាយ** ដោយភាវៈ នៃខ្លួនជាអ្នកប្រាថ្នាដើម្បីប្រហារនូវបុគ្គលដែលឈរហើយក្នុងទីច្រាស់ នៃខ្យល់ **បច្ចេតិ** រមែងត្រលប់មក **តំ ឯវ បុរិសំ** កាន់បុរសនោះវិញ, **តំ ឯវ បុរិសំ បច្ចេតិ** គឺថា **តស្សេវ ឧបរិ បតតិ**ៗ រមែងធ្លាក់ចុះ **ឧបរិ** ឰដ៏ខាងលើ **តស្ស ឯវ បុរិសស្ស** នៃបុរសនោះវិញ **យថា** យ៉ាងណា **បុគ្គលោ** រីបុគ្គល **យោ** ឯណា **ទទន្តោ** កាលឲ្យ **បាណិប្ប-ហារាទីនិ** នូវការប្រហារទាំងឡាយ មានការប្រហារដោយដៃជាដើម **បុរិសស្ស** ដល់បុរស **អប្បទុដ្ឋស្ស** ដែលមិនប្រទូស្តហើយ **បទុស្សតិ** ឈ្មោះថាប្រទូស្ត, **បាបំ** រីបាប **តំ** នោះ

**វិបច្ចមានំ** កាលឲ្យផល **ទិដ្ឋេវ ធម្មេ វា** ក្នុងបច្ចុប្បន្ន ឬ **សម្បរាយេ និរយាទីសុ វា** ឬក្នុងអបាយទាំងឡាយ មាននរកជាដើម ក្នុងសម្បារាយភព **តំ ឯវ ពាលំ វិបាកទុក្ខ-វសេន បច្ចេតិ** ឈ្មោះថាតាម ស្នង នូវបុគ្គលពាលនោះឯងដោយអំណាចនៃវិបាកទុក្ខ **ឯវំ ឯវ** យ៉ាង នោះឯង (ធ.ប.៥ ទំព័រ ៤៩) ។

ខ. ប្រែឧបមារួច ប្រែ **ឯវំ** បន្ទាប់បទប្រធាននៃ ឧប-មេយ្យ វិធីនេះ ត្រូវប្រែប្រយោគឧបមាមុន លុះអស់សេចក្តីហើយ ទើបប្រែ **យថា** "ដូចម្តេច មិញ" រួចប្រែបទប្រធាន ក្នុងប្រយោគឧបមេយ្យ ព្រមទាំងបទវិសេសនៈរបស់បទប្រធាន ទើបប្រែ **ឯវំ** "ក៏ដូច្នោះឯង" តទៅ ត្រូវប្រែសព្ទដទៃៗ រហូតដល់ចប់ ។

ឧទាហរណ៍ : **យថា តំ បុប្ផំ ធារេន្តស្ស សរីរេ គន្ធោ ផរតិ ឯវំ តេបិដកពុទ្ធវចនសង្ខាតា សុភាសិតា វាចាបិ សុកុព្វតោ យោ សក្កច្ចំ សវនាទីហិ តត្ថ កត្តព្វំ ករោតិ សា អស្ស បុគ្គលស្ស សផលា ហោតិ** : **សុគគន្ធធារណាគន្ធប្ប-**

**ជិបត្តិគន្ធានំ អាវហណតោ មហប្ផលា ហោតិ មហានិសំសា** ប្រែថា **គន្ធោ** រីក្លិននៃផ្កា **ផរតិ** រមែងផ្សាយទៅ **សរីរេ** ក្នុងសរីរៈ **បុគ្គលស្ស** នៃបុគ្គល **ធារេន្តស្ស** កាលទ្រទ្រង់ **បុប្ផំ** នូវផ្កា **តំ** នោះ **យថា** ដូចម្តេចមិញ **តេបិដកពុទ្ធវចនសង្ខាតា សុភាសិតា វាចាបិ** សូម្បីរីវាចាជាសុភាសិតដែលបណ្ឌិតរាប់ហើយថា ពុទ្ធវចនៈ គឺព្រះត្រៃបិដក **៦ខំ** ក៏ដូច្នោះឯង **សា សុភាសិតា វាចា** រីវាចាជាសុភាសិតនោះ **សផលា ហោតិ** ជាគុណជាតិប្រព្រឹត្តទៅមួយអន្លើដោយផល **សផលា ហោតិ** គឺថា **សុតគន្ធធារណគន្ធប្បជិបត្តិគន្ធានំ អាវហណតោ** , **មហប្ផលា មហានិសំសា ហោតិ**ៗ ឈ្មោះថាជាធម្មជាតិមានផលច្រើន មានអានិសង្សច្រើន **អាវហណតោ** ព្រោះកិរិយានាំមក **សុតគន្ធធារណគន្ធប្បជិបត្តិគន្ធានំ** នូវក្លិនគឺការស្តាប់ និង ក្លិនគឺ ការទ្រទ្រង់ទុក និង ក្លិនគឺការប្រព្រឹត្តទាំងឡាយ **សុកុព្វតោ** ដល់បុគ្គលកាលធ្វើល្អ **សុកុព្វតោ** គឺថា **យោ បុគ្គលោ សក្កច្ចំ សវនាទីហិ តត្ថ** (ពុទ្ធវចនេ) **កត្តព្វំ ករោតិ អស្ស បុគ្គលស្ស** ដល់ រីបុគ្គលណា ធ្វើនូវកិច្ចដែល ខ្លួនគប្បី

ធ្វើក្នុងពុទ្ធវចនៈនោះ ដោយកិច្ចទាំងឡាយ មានការស្តាប់ដោយគោរព ជាដើម បុគ្គលនោះ (ធ.ប.៣ ទំព័រ ៧៥) ។

៣) ប្រែទទួលក៏បាន មិនទទួលក៏បាន វិធីនេះគប្បីសង្កេតយ៉ាងនេះ សេចក្តីក្នុងប្រយោគ ទាំងពីរជាពាក្យខ្លីៗ ក៏ដោយ ជាពាក្យវែងៗ ក៏ដោយ នឹងប្រែទទួល ឬ នឹងមិនទទួល ក៏បានសេចក្តីច្បាស់លាស់ទាំងពីរយ៉ាង ។

ឧទាហរណ៍ : **យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ** ប្រែថា **គោបាលោ** រីអ្នករក្សាគោ **បាជេតិ** តែងកៀងទៅ **គាវោ** នូវគោទាំងឡាយ **គោចរំ** កាន់ទីគោចរ **ទណ្ឌេន** ដោយដំបង **យថា** យ៉ាងណា **ជរា ច** រីជរាផង **មច្ចុ ច** រីមច្ចុផង **បាជេន្តិ** តែងកៀងទៅ **អាយុំ** នូវអាយុ **បាណិនំ** របស់សត្វទាំងឡាយ **ឯវំ** យ៉ាងនោះ (នេះមិនប្រែ ទទួលទេ) ។ **ជរា ច** រីជរាផង **មច្ចុ ច** រីមច្ចុផង **បាជេន្តិ** រមែងកៀងទៅ **អាយុំ** នូវអាយុ **បាណិនំ** របស់សត្វទាំងឡាយ **យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ ឯវំ** ដូចជារីអ្នករក្សាគោ

កៀងទៅនូវគោទាំងឡាយកាន់ទីគោចរ ដោយដំបងដូច្នោះ, នេះប្រែទទួល (ធ.ប.៥ ទំព័រ ៨៥) ។

## ប្រយោគឧបមាជាវាក្យាង្គ

ប្រយោគឧបមាជាវាក្យាង្គជានាមវាក្យាង្គ និង គុណ-វាក្យាង្គ លោកប្រកប ដោយនិបាត ពីរសព្ទគឺ : **ឥវ** និង **ឥវ** ។

ប្រយោគនេះ តែងនៅក្នុងចន្លោះប្រយោគឧបមេយ្យ ដែលមិនដូចជា ប្រយោគឧបមា ដែលជាប្រយោគធំទេ តែសេចក្ដីជាសង្កាត់ៗ ផ្សេងដោយឡែក ។

## នាមវាក្យាង្គ

ឧទាហរណ៍ : **មច្ឆានំ ខីណភាវោ ឥវ ឥមេសំ ភោគានំ អភាវោ** ប្រែថា **អភាវោ** វីការមិនមាន **ភោគានំ** នូវភោគទាំងឡាយ **ឥមេសំ ពាលានំ** របស់ជនពាលទាំង-ឡាយនេះ **មច្ឆានំ ខីណភាវោ ឥវ** ដូចជាភាវៈនៃត្រីទាំងឡាយអស់ហើយ (ធ.ប.៥ ទំព័រ ១៨៦) ។

## គុណវាក្យាខ្យ

ឧទាហរណ៍ : **ឥទំ និន្ទនំ វា បសំសនំ វា អជ្ជតនំ អធុនា ឧប្បន្នំ ន ហោតិ** ប្រែថា **និន្ទនំ វា** វីការតិះដៀលក្តី **បសំសនំ វា** វីការសរសើរក្តី **ឥទំ** នេះ **អជ្ជតនំ** : **អធុនា ឧប្បន្នំ ឋិយ ន ហោតិ** មិនមែនដូចជាទើបនឹង កើតក្នុងកាលមានក្នុងថ្ងៃនេះ គឺក្នុងកាលឥឡូវនេះទេ (ធ.ប.៦ ទំព័រ ៤៧៥) ។

**ស្វេ ភវំ** ទៅជា **ស្វាតនំ** "ភត្តមានក្នុងថ្ងៃស្អែក" ។ ប្រយោគឧបមាវាក្យាង្សនេះ កាលនឹងប្រែ ត្រូវប្រែប្រយោគឧបមេយ្យរហូត អស់សេចក្តី ទើបប្រែប្រយោគឧបមាបាន ។ តាមន័យនេះបានសេចក្តីថា ប្រែបានតែវិធីប្រែ ទទួលប៉ុណ្ណោះ ។

មួយទៀត **គតិន័យ ឋិយ ឥវ** នេះប្រព្រឹត្តទៅក្នុងនាម និង គុណនាម និង គុណនៅជានាម និង គុណដដែលក៏បានក្លាយជាវិកតិកត្តាក៏បាន ។

## ឧបមាវាក្យាខ្យមាន ៣ យ៉ាងគឺ

១. ប្រែជា ឧបមាលិង្គត្ថ:

២. ប្រែជា ឧបមាវិសេសន:

៣. ប្រែជា ឧបមាវិកតិកត្តា

## ១) ឧបមាលិង្គត្ថ:

វិធីនេះ ប្រែក្រោយកិរិយាធំនៃប្រយោគឧបមេយ្យ ទើបប្រែប្រយោគឧបមាជា ខាងក្រោយ ។ វិធីនេះ ត្រូវប្រែបទកត្តាថា " រី..." ហើយប្រែឧបមាភ្ជាប់ខាងមុខថា "ដូចជា រី..." ព្រោះបទកត្តាដែល ជាលិង្គត្ថ: ក្នុងប្រយោគឧបមានេះ លោកប្រើ បឋមាវិភត្តិ ឯកវចន: ឬ ពហុវចន: មិនប្រើវិភត្តិដទៃទេ ។ មួយទៀតប្រយោគ ឧបមាលិង្គត្ថ:នេះ បើសេចក្តីបង្គាប់ដល់កិរិយា ក៏ត្រូវបន្ថែមកិរិយាចូលមក តែកិរិយានោះនិយមប្រកប **អន្ត, មាន**-បច្ច័យ ឧទាហរណ៍ : **ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។ វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។**

**មេធាវី** រីបុគ្គលមានប្រាជ្ញា **ករោតិ** រមែងធ្វើ **ចិត្តំ** នូវ

ចិត្ត **ផន្ទនំ** ដែលញាប់ញ័រ **ចបលំ** ដែលឃ្លេងឃ្លោង **ទុរក្ខំ** ដែលបុគ្គលរក្សាបានដោយលំបាក **ទុន្និវារយំ** ដែលបុគ្គលហាមបានដោយលំបាក **ឧជុំ** ឲ្យត្រង់បាន **ឧសុការោ ឥវ** ដូចជារីជាងកូនសរ **តេជនំ** កាលធ្វើ **តេជនំ** នូវកូនសរ **ឧជុំ** ឲ្យត្រង់ ។ **ចិត្តំ** រីចិត្ត **ឥទំ** នេះ **ឧព្ភតំ** ដែលបុគ្គលលើកឡើងហើយ **បញ្ចកាមគុណាលយា** ចាកអាល័យគឺ បញ្ចកាមគុណ **បហាតវេ** (**ប**-បុព្វបទ + **ហា**-ធាតុ + **តវេ**-បច្ច័យ) ដើម្បីលះបង់ **មារធេយ្យំ** នូវវដ្តជាទីតាំងនៃមារ **បរិផន្ទតិ** រមែងញាប់ញ័រ **វារិជោ ឥវ** ដូចជារីសត្វ កើតក្នុងទឹក (ត្រី) **ឧព្ភតោ** ដែលបុគ្គលលើកឡើងហើយ **ឱកមោកតោ** ចាកអាល័យគឺទឹក **ខិត្តោ** បោះទៅហើយ **ថលេ** លើគោក **បរិផន្ទន្តោ** កាលញាប់ញ័រ (ធ.ប.២ ទំព័រ ១៩៦) ។

ប្រយោគឧបមាលិង្គត្ថៈ ដែលមាននៅក្នុងចន្លោះ នៃកិរិយាកិតកៈ ក៏ត្រូវប្រែ កិរិយាសង្កាត់ឧបមេយ្យនោះ ជាមុនដែរ ដូចជា **ឯវញ្ចេ តវិស្សតិ ឯវំ ករិស្សាមីតិ វា ឥមស្មិំ កម្មេ ឯវំ កតេ ឥទន្នាម តវិស្សតីតិ វា ឯវំ និទានំ**

**សល្លកេ្ខត្វា រោគតិកិច្ឆនំ វិយ សព្វកម្មានិ និសាមេត្វា ឧបធារេត្វា ករោន្តស្ស** (**បុគ្គលស្ស** កាលបុគ្គល) **សព្វកម្មានិ និសាមេត្វា** : **ឧបធារេត្វា ករោន្តស្ស** កាលពិនិត្យហើយ គឺថា ពិចារណាហើយទើបធ្វើ នូវការងារទាំងពួងទាំងឡាយ **ឯវញ្ហេ តវិស្សតិ** ។ល។ (តមកដល់) **សល្លេកេ្ខត្វា រោគតិកិច្ឆនំ វិយ** ដូចជាវីការកំណត់នូវដើមហេតុយ៉ាងនេះថា "ប្រសិនបើផល នឹងមានយ៉ាងនេះ អញនឹងធ្វើនូវហេតុយ៉ាងនេះ" ដូច្នេះឬ ឬថា "កាលបើកម្មនេះ គឺអញធ្វើហើយយ៉ាងនេះ ផលឈ្មោះនេះនឹងមាន" ដូច្នេះមុនហើយ ទើបរក្សានូវរោគ, **រោគតិកិច្ឆនំ** (**កិត**-ធាតុ + **ឆ**-បច្ច័យ + **យុ** បច្ច័យ) (ធ. ប.២ ទំព័រ ១២៧) ។

## ២) ឧបមាវិសេសនៈ

វិធីនេះប្រែមុនកិរិយា បើបទឧបមានៅជិតបទប្រធាន គឺកាលប្រែបទប្រធាន និងបទវិសេសនៈ ឬ បទដែលនៅជិតប្រធានរួចហើយ ទើបប្រែបទឧបមា "ដូចជា... ហាក់ដូចជា... " ឧទាហរណ៍ : **រុក្ខោ ឱតរន្តោ ខានុមត្ថោវ ហុត្វា តិដ្ឋាវដ្ឋិន្តោ**

**ວາតេ បហរន្តេ អាកោដិតោ វិយ សទ្ទំ និច្ឆារេន្តោ អដ្ឋាសិ ។**

ប្រែថា **រុក្ខោ** វីដើមឈើ **ឱភគ្គោ** បាក់ចុះហើយ **ខានុមត្តោវ ឆិទ្ទាវច្ឆិទ្ទោ ហុត្វា** បែរជានៅ ត្រឹមតែដង្គត់មានប្រហោងតូច និងប្រហោងធំ **វាតេ** នាកាលខ្យល់ **បហរន្តេ** កាលបក់ត្រូវ **អាកោដិតោ វិយ** ដូចជាគឺគេគោះហើយ **និច្ឆារេន្តោ** កាលបញ្ចេញ **សទ្ទំ** នូវសម្លេង **អដ្ឋាសិ** បានឋិតនៅហើយ (ធ.ប.២ ទំព័រ ១៩២) ។

បើបទឧបមាជាវិភត្តិដទៃក្រៅអំពីបឋមាវិភត្តិ ឬ ជាកិរិយាវិសេសនៈ ប្រែបទ ឧបមាក្រោយកិរិយាវិញក៏បានគឺ : ឧបមាវិសេសនៈ ១, ឧបមាកិរិយាវិសេសនៈ ១ ។

ឧបមាវិសេសនៈ ឧទាហរណ៍ : **និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ**

ប្រែថា **បុគ្គលោ** វីបុគ្គល **បស្សេ** គប្បីឃើញ **យំ** (**បណ្ឌិតំ**) នូវបណ្ឌិតណា **មេធាវឹ** អ្នកមានប្រាជ្ញា **និគ្គយ្ហវាទឹ** អ្នកពោលសង្កត់សង្កិន **វជ្ជទស្សិនំ** អ្នកចង្អុលប្រាប់នូវទោស **និធីនំ**

**បទត្ថានំ វិយ** ដូចបុគ្គលអ្នកប្រាប់នូវកំណប់ទ្រព្យទាំងឡាយ ; **បុគ្គលោ** រីបុគ្គល **ភជេ** គប្បីគប់រក **បណ្ឌិតំ** នូវបណ្ឌិត **តាទិសំ** ប្រាកដដូច្នោះ **ហិ** ព្រោះថា **បុគ្គលស្ស** កាលបុគ្គល **ភជមានស្ស** កាលគប់រក **តាទិសំ បណ្ឌិតំ** នូវបណ្ឌិតប្រាកដ ដូច្នោះ **សេយ្យោ** រីគុណដ៏ប្រសើរ **ហោតិ** រមែងមាន **បាបិយោ** រីទោសដ៏លាមក **ន ហោតិ** នឹងមិនមាន (ធ.ប.៤ ទំព័រ ៥) ។

**ឧបមាកិរិយាវិសេសនៈ** ឧទាហរណ៍ : **ឥតិ នំ សោ មធុំ ឥវ មញ្ញតិ** ប្រែថា **សោ ពាលោ** រីមនុស្សពាលនោះ **មញ្ញតិ** រមែងសំគាល់ **នំ បាបំ** នូវបាបនោះ **មធុំ ឥវ** ដូចទឹកឃ្មុំ **ឥតិ** ដោយប្រការដូច្នេះ (ធ.ប.៣ ទំព័រ ២៣៦) ។

## ៣) ឧបមាវិភត្តិកត្តា

វិធីនេះប្រែមុនកិរិយា ឬ ក្រោយកិរិយាក៏បាន ។ ចំណែកវិធីប្រែឧបមាជា **វិភត្តិកត្តា** មាន ៣ យ៉ាងគឺ :

១. ប្រែមុនកិរិយាធំ

២. ប្រែក្រោយកិរិយាធំ

៣. ប្រែព្រមគ្នានឹងកិរិយាធំ

១/ ប្រែមុនកិរិយាធំ ឧទាហរណ៍ : **សោ តស្សា បដិពទ្ធចិត្តោ ហត្ថិក្ខន្ធតោ បតនាការប្បត្តោ វិយ ហុត្វា ខិប្បំ នគរំ បទក្ខិណំ កត្វា អន្តេបុរំ បវិសិត្វា ឯកំ វិស្សាសិកំ អមច្ចំ អាហ** ប្រែថា **សោ** រាជា រីព្រះរាជាអង្គនោះ **តស្សា បដិពទ្ធចិត្តោ** មានព្រះហឫទ័យប្រតិព័ទ្ធ ចំពោះស្រីនោះ **ហត្ថិក្ខន្ធតោ បតនាការប្បត្តោ វិយ ហុត្វា** ជាអ្នកហាក់ដូចជាដល់ហើយនូវអាការគឺការធ្លាក់ចុះអំពីខ្នងនៃដំរី **កត្វា** ទ្រង់ធ្វើហើយ **បទក្ខិណំ** នូវបទក្សិណ **នគរំ** នៃនគរ **ខិប្បំ** រួសរាន់ **បវិសិត្វា** ចូលទៅហើយ **អន្តេបុរំ** កាន់ព្រះរាជវាំង **អាហ** ទ្រង់ត្រាស់ហើយ **អមច្ចំ** នូវអាមាត្យ **វិស្សាសិកំ** អ្នកស្និទ្ធស្នាល **ឯកំ** ម្នាក់ (ធ.ប.៣ ទំព័រ ១៦៩) ។

២/ ប្រែក្រោយកិរិយាធំ បើមានកិរិយាដែលបទវិកតិកត្តាត្រូវចូលនោះ ជាកិរិយាវិសេសនៈ ត្រូវតែប្រែបទឧបមាក្រោយកិរិយាធំ ឧទាហរណ៍ : **ពាលស្ស ហិ បាបំ អកុសលកម្មំ ករោន្តស្ស តំ កម្មំ មធុ វិយ មធុររសំ វិយ ឥដ្ឋំ កន្តំ មនាបំ វិយ ហុត្វា ឧបដ្ឋាតិ** ប្រែថា **ពាលស្ស** កាលមនុស្ស

ពាល **ករោន្តស្ស** កាលធ្វើ **បាបំ** នូវបាប **បាបំ** គឺថា **អកុសល-កម្មំៗ** នូវអកុសលកម្ម, **កម្មំ** រឺកម្ម **តំ** នោះ **ឧប្បជ្ជាតិ** រមែងប្រាកដ **មធុ វិយ មធុររសំ វិយ ឥដ្ឋំ កន្តំ មនាបំ វិយ ហុត្វា** ជាធម្មជាតដូចជា ទឹកឃ្មុំ គឺថា ជាអំពើដូចរសមានជាតផ្អែម គឺថាជាកិច្ចដូចជាគួរប្រាថ្នា គួរចង់បាន គួរពេញចិត្ត (ធ.ប.៣ ទំព័រ ២៣៥) ។

៣/ ប្រែព្រមគ្នានឹងកិរិយាសំគាល់ពាក្យ ឧទាហរណ៍ : **យថា មរីចិ ទូរេ ឋិតានំ រូបគតំ វិយ គយ្ហុបគា វិយ ហោតិ** ប្រែថា **មរីចិ** រឺថ្ងៃបណ្តើរកូន **ទូរេ ឋិតានំ រូបគតំ វិយ គយ្ហុបគា វិយ ហោតិ** ជាធម្មជាតិហាក់ដូចជាដល់ហើយនូវភាពជារបស់មានរូប ហាក់ដូចជាចូលដល់នូវភាពជាធម្មជាតិ គឺបុគ្គលគប្បីកាន់យកបាន ដល់បុគ្គលទាំងឡាយអ្នកឈរហើយក្នុងទីឆ្ងាយ **យថា** យ៉ាងណាមិញ (ធ.ប.៣ ទំព័រ ៦) ។

## លំហាត់ប្រែ

**អានន្ទ មយា កបិតធម្មោ នាម សក្កច្ចំ អសុណន្តស្ស**

**អគណ្ហន្តស្ស អសជ្ឈាយន្តស្ស វណ្ណសម្បន្នំ អគន្ធកំ បុប្ផំ វិយ អផលោ ហោតិ** (ធ.ប.៣ ទំព័រ ៧៣) ប្រែថា **អានន្ទ** ម្នាលអានន្ទ **មយា កថិតធម្មោ នាម** ឈ្មោះថាវីធម៌ ដែលតថាគត សម្ដែងហើយ **សក្កច្ចំ អសុណន្តស្ស អគណ្ហន្តស្ស អសជ្ឈាយន្តស្ស អទេសេន្តស្ស បុគ្គលស្ស អផលោ ហោតិ** រមែងជាសភាវមិនមានផលដល់បុគ្គល កាលមិនស្ដាប់ កាលមិនរៀន កាលមិនស្វាធ្យាយ កាលមិនសម្ដែងដោយសេចក្ដីគោរព **វណ្ណសម្បន្នំ អគន្ធកំ បុប្ផំ វិយ** បីដូចជាផ្កាឈើដែលដល់ព្រមហើយដោយពណ៌ តែមិនមានក្លិន ។ **រញ្ញោ បុណ្ណចន្ទោ វលាហកន្តរំ បវិដ្ឋោ វិយ ឧបដ្ឋាសិ** (ធ.ប.៣ ទំព័រ ១៦៨) ប្រែថា **សា ឥត្ថី** វីស្រីនោះ **ឧបដ្ឋាសិ** ប្រាកដហើយ **រញ្ញោ** ដល់ព្រះរាជា **បុណ្ណចន្ទោ វលាហកន្តរំ បវិដ្ឋោ វិយ** បីដូចជាវីព្រះចន្ទ ពេញវង់ចូលទៅហើយកាន់ចន្លោះ នៃពពក ។ **តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ** (ធ.ប.១ ទំព័រ៣០) ប្រែថា **ទុក្ខំ** វីទុក្ខ **អន្វេតិ** តែងទៅតាម **នំ បុគ្គលំ** នូវបុគ្គលនោះ **តតោ តិវិធទុច្ចរិតតោ** ព្រោះទុច្ចរិត

មាន ៣ យ៉ាងនោះ (**ធុរំ ចហតោ ពលិពទ្ធស្ស បទំ អនុគច្ឆន្តំ**) **ចក្កំ ឥវ** បីដូចជារីកង់ កាលវិលទៅតាមនូវស្នាមជើង នៃគោបម្រើកាលនាំទៅនូវនឹម ។ **មយ្ហំ សហាយកោ ទេវកុមារោ វិយ សោភតិ** (ធ.ប.២) ប្រែថា **សហាយកោ** រីសម្លាញ់ **មយ្ហំ** របស់យើង **សោភតិ** តែងសម **ទេវកុមារោ វិយ** ដូចជាទេវកុមារ ។ **សោ បព្វតេន វិយ មហន្តេន សោកេន អវត្ថរិតោ ហុត្វា អនប្បកំ ទោមនស្សំ បដិសំវេទេសិ** (ធ.ប.២ ទំព័រ៣៨) ប្រែថា **សោ សេដ្ឋី** រីសេដ្ឋីនោះ **បព្វតេន វិយ មហន្តេន សោកេន អវត្ថរិតោ ហុត្វា** ជាបុគ្គលគឺសេចក្តីសោកដ៏ធំបីដូចជាភ្នំគ្របសង្កត់ហើយ **បដិសំវេទេសិ** សោយហើយ **ទោមនស្សំ** នូវទោមនស្ស **អនប្បកំ** មានប្រមាណមិនតិច ។ **សុរត្តទុប្បដ្ដំ និវាសេត្វា វិជ្ជុតលំ វិយ កាយពន្ធនំ ពន្ធិត្វា** (ធ.ប.២ ទំព័រ១៥២) ប្រែថា **ភគវា** រីព្រះមានព្រះភាគ **និវាសេត្វា** ទ្រង់ស្លៀកហើយ **សុរត្តទុប្បដ្ដំ** នូវសំពត់មានជាន់ពីរ គឺបុគ្គលជ្រលក់ល្អហើយ **ពន្ធិត្វា** ទ្រង់ក្រវាត់ហើយ **កាយពន្ធនំ** នូវសំពត់សម្រាប់ក្រវាត់កាយ

**ចិដ្ឋុតលំ ចិយ** បីដូចជាខ្សែនៃផ្លេកបន្ទោរ ។

**អសង្ខេយ្យំ អាយុំ គហេត្វា និព្វត្តា ចិយ អជរាមរា ចិយ និច្ចប្បមត្តា មនុស្សា** (ធ.ប.៣ ទំព័រ៩៥) ប្រែថា **មនុស្សា** រីមនុស្សទាំងឡាយ **និច្ចប្បមត្តា ហោន្តិ** ជាអ្នកប្រមាទហើយជានិច្ច **អសង្ខេយ្យំ អាយុំ គហេត្វា និព្វត្តា ចិយ** បីដូចជាកាន់យកហើយ នូវអាយុមានអសង្ខេយ្យជាប្រមាណ ហើយកើតហើយ **អជរាមរា ចិយ** បីដូចជាមិនចាស់ និងមិនស្លាប់ ។ **ឥតរោ គហេត្វា គច្ឆន្តោ ចិយ ហុត្វា គន្ត្វា តេ កុក្កុដេ បុរោហិតស្ស ឧត្វា** (ធ.ប.២ ទំព័រ៩២) ប្រែថា **ឥតរោ ចូឡុបដ្ឋាកោ** រីចូឡុបដ្ឋាកក្រៅនេះ **គហេត្វា គច្ឆន្តោ ចិយ ហុត្វា** ជាអ្នកបីដូចជាកាន់យកទៅ **គន្ត្វា** ទៅហើយ **ឧត្វា** ឲ្យហើយ **កុក្កុដេ** នូវមាន់ទាំងឡាយ **តេ** នោះ **បុរោហិតស្ស** ដល់បរោហិត ។ **មាគន្ទិយា អបរាបរំ ចិចរន្តី ចិយ ហុត្វា វីណាច្ឆិទ្ទតោ បុប្ផគុលំ អបនេសិ** (ធ.ប.២ ទំព័រ៩៤) ប្រែថា **មាគន្ទិយា** រីនាងមាគន្ទិយា **អបរាបរំ ចិចរន្តី ចិយ ហុត្វា** ជាអ្នកបីដូចជា ត្រាច់ទៅមកៗ **អបនេសិ** នាំចេញហើយ **បុប្ផ**

**គុលំ** នូវដុំនៃផ្កាឈើ **វីណាច្ឆិន្នតោ** អំពីប្រហោងនៃពិណ ។

**តេសំ វយានុរូបំ បិយវចនំ វត្វា បណ្ណាការំ បេសេន្តិ សកលនគរវាសិនោ ញាតកេ វិយ អកាសិ** (ធ.ប.៣ ទំព័រ ៩៩) ប្រែថា **សា វិសាខា** រីនាងវិសាខានោះ **វត្វា** ពោលហើយ **បិយវចនំ** នូវពាក្យជាទីស្រលាញ់ **តេសំ ជនានំ វយានុរូបំ** ដ៏សមគួរដល់វ័យ របស់ជនទាំងឡាយនោះៗ **បេសេន្តិ** តែងបញ្ជូនទៅ **បណ្ណាការំ** នូវគ្រឿងបណ្ណាការ **អកាសិ** បានធ្វើហើយ **សកលនគរវាសិនោ ជនេ** នូវជនទាំងឡាយ អ្នកនៅក្នុងនគរទាំងមូលជាប្រក្រតី **ញាតកេ វិយ** ឲ្យដូចជាញាតិ ។

## ប្រយោគបការៈ និង កិរិយាវិសេសនៈ

ប្រយោគនេះ កំណត់ដោយនិបាត ៣ សព្ទគឺ :

**យថា តថា** និង **ឯវំ** ជាប្រយោគគួរប្រែទទួល ទើបបានសេចក្តីភ្លឺច្បាស់ល្អ ។ វិធីប្រែទទួល នោះគប្បីប្រែប្រយោគ **តថា** មុន បន្សល់តែ **តថា** សព្ទ កាលប្រែអស់សេចក្តីខាង **តថា** ហើយ ត្រូវយក **យថា** ព្រមទាំងបទដទៃមករួមគ្នានឹង

**តថា** ប្រែចូលគ្នាតែម្តង ។

ប្រយោគបការៈត្រូវប្រែថា "ដោយប្រការដែល... , ដោយឧបាយដែល..., ដោយអាការ ដែល..., តាមដែល..." ។

ប្រយោគកិរិយាវិសេសនត្រូវប្រែថា : "យ៉ាងដែល..., តាមដែល..., ល្មមតែ..." ។

ប្រយោគបការៈ បើប្រែរាយ ត្រូវប្រែ **យថា** : "ដោយប្រការណា, ដោយ ឧបាយណា, ដោយអាការណា" ។ **តថា** និង **ឯវំ** ត្រូវប្រែ "ដោយប្រការនោះ, ដោយអាការនោះ" ។

ប្រយោគកិរិយាវិសេសន បើប្រែរាយ ត្រូវប្រែ **យថា** "យ៉ាងណា", **តថា** ឬ **ឯវំ** ប្រែថា "យ៉ាងនោះ" ។

ប្រែជាបការៈ ឧទាហរណ៍ **អយំ ហិ អត្តា នាម ទុទ្ទមោ ។ តស្មា យថា សោ សុទន្តោ ហោតិ តថា ទមេតព្វោ** ប្រែថា **ហិ** មែនពិត **អយំ អត្តា នាម** ឈ្មោះថារី ខ្លួននេះ **ទុទ្ទមោ ហោតិ** រមែងជាអត្តភាព គឺបុគ្គលទូន្មានបានដោយលំបាក ។ **តស្មា** ព្រោះហេតុនោះ **បរោ បុគ្គលោ** រី... **បុគ្គលេន** គឺ... **ទមេតព្វោ** គប្បីទូន្មាន **យថា សោ សុទន្តោ ហោតិ តថា** ដោយឧបាយ

ដែលរីខ្លួននោះជាអត្តភាព គឺបុគ្គលទូន្មានល្អ ហើយ (ធ.ប.៦ ទំព័រ ១៦) ។ **យថា សោ សុរក្ខិតោ ហោតិ ឯវន្តំ រក្ខេយ្យ** ប្រែថា **បុគ្គលោ** រី... **រក្ខេយ្យ** គប្បីរក្សា **តំ អត្តានំ** នូវខ្លួននោះ **យថា សោ សុរក្ខិតោ ហោតិ ឯវំ** ដោយអាការដែលរី ខ្លួននោះ ជាអត្តភាព គឺគេរក្សាទុកល្អហើយ (ធ.ប.៦ ទំព័រ ៧) ។

ប្រែជាកិរិយាវិសេសន ឧទាហរណ៍ **វិសាខា សសុរំ ទីជមានា បិតា តំ ឱស្វា សសុរស្ស អាចិក្ខិតុំ អយុត្តន្តិ យថា សោ ថេរំ បស្សតិ ឯវំ អបគន្ត្វា អដ្ឋាសិ** ប្រែថា **វិសាខា** រី... **សសុរំ ទីជមានា បិតា** កាលឈរបក់នូវឪពុកក្មេក **ឱស្វា** ឃើញហើយ **តំ ថេរំ** នូវ... **ចិន្តេត្វា** គិតហើយ **សសុរស្ស អាចិក្ខិតុំ អយុត្តំ ឥតិ** ថារីកិរិយាគឺអញប្រាប់ដល់ឪពុកក្មេក មិនគួរឡើយ ដូច្នេះ **អបគន្ត្វា** គេចចេញហើយ **អដ្ឋាសិ** បាន ឈរនៅហើយ **យថា សោ ថេរំ បស្សតិ ឯវំ** ឲ្យល្មមតែ រីឪពុកក្មេកនោះឃើញ នូវព្រះថេរ (ធ.ប.៣ ទំព័រ ១០១) ។

ឧទាហរណ៍ដែលលើកមកពោលនេះប្រែទទួលហើយ រូបផង បើប្រែទទួលតែរាយ ត្រូវប្រែ ប្រយោគ **តថា, ឯវំ** ឲ្យ

ទាល់តែអស់សេចក្តី ហើយបន្សល់ទុកតែ **តថា**, **ឯវំ** ក្នុងទីបំផុតប្រយោគ រួចទៅប្រែខាងប្រយោគ **យថា** ឲ្យទាល់តែអស់សេចក្តីទើប ប្រែ **តថា** ឬ **ឯវំ** បន្ទាប់ពី **យថា** នោះភ្លាម ។ សិក្ខាកាមគប្បីមើលឧទាហរណ៍ខាងលើនេះ ហើយហាត់ប្រែតាមសេចក្តីពន្យល់ ដោយខ្លួនឯងចុះ ។

## លំហាត់ប្រែ

១. **អថេកទិវសំ សត្ថា បច្ចូសកាលេ លោកំ វោលោកេន្តោ ។បេ។ សាយណ្ហសមយេ វិហារចារិកំ ចរន្តោ វិយ ព្រាហ្មណស្ស សន្តិកំ គន្ត្វា** ។បេ។ (ធ.ប.៤ ទំព័រ១)

ក្នុងថ្ងៃមួយ ជាខាងក្រោយវីព្រះសាស្តាទ្រង់ប្រមើលមើលនូវលោក ក្នុងកាលជាទីកម្ចាត់បង់នូវងងឹត ។ល។ ស្តេចយាងទៅហើយកាន់សំណាក់ របស់ព្រាហ្មណ៍ ដូចជា កាលទ្រង់យាង ទៅកាន់ចារិកក្នុងវិហារក្នុងសម័យជា ទីអស់ទៅនៃថ្ងៃ ។ល។

២. **ឱវាទទាយកោ បន និធិអាចិក្ខនកោ វិយ ទដ្ឋព្វោ** (ធ.ប.៤ ទំព័រ ៤) ប្រែថា ក៏រីបុគ្គលអ្នកឲ្យនូវឱវាទ

ដែលបុគ្គលគប្បីឃើញ បីដូចជា រីបុគ្គលអ្នកប្រាប់នូវកំណប់ទ្រព្យ ។

**៣. សត្ថាបិ តំ ទិវសំ បច្ចូសកាលេ លោកំ វោលោកេន្តោ ។បេ។ បុនទិវសេ ចក្កវត្តិ វិយ ខុទ្ទកគាមគោចរកំ បច្ចុគ្គច្ឆន្តោ សយមេវ បត្តចីវរំ គហេត្វា** ។ល។ (ធ.ប.៤ ទំព័រ ២២) ប្រែថា ទោះថារីព្រះសាស្តាកាលទ្រង់ប្រមើលមើលនូវលោក ក្នុងកាលជាទីកម្ចាត់បង់នូវងងឹតក្នុងថ្ងៃនោះ ។ល។ ទ្រង់កាន់យកហើយនូវបាត្រ និង ចីវរដោយព្រះអង្គឯង ស្តេចទទួលហើយ អស់ផ្លូវមានរយនៃយោជន៍ ២០ ជាប្រមាណ បីដូចជារីព្រះរាជាជាស្តេចចក្រពត្តិទ្រង់ទទួលនូវមេឃុំតូច ក្នុងថ្ងៃព្រឹកឡើង ។ល។

**៤. តេសំ អានុភាវេន ឥទំ ឧទកំ វិយ មា អហោសិ** ។បេ។ (ធ.ប.៤ ទំព័រ២៣) រីទឹកនេះកុំបាន បីដូចជាទឹកឡើយដោយអានុភាពនៃព្រះរតនៈទាំងឡាយនោះ, ក្នុងខនេះ **ឧទកំ វិយ** ជាពាក្យប្រៀប ។

**៥. សា នច្ចន្តី វិយ តុដ្ឋហដ្ឋា វិហរី គោដ្ឋេតិ ចេវ**

**ឱផុនាតិ ច** (ធ.ប.៤ ទំព័រ៣៨) ប្រែថា រីភរិយារបស់មហា-ទុគ្គតបុរសដែលដល់ហើយនូវភាពក្រីក្រនោះ ទាំងត្រេកអរ ហើយ ទាំងរីករាយហើយ បីដូចជាកំពុងរាំផង បុកផងមែន ពិត អុំផងមែនពិត នូវស្រូវទាំងឡាយ ។

៦. **មហាទុគ្គតោ តិខិណាយ សត្តិយា កុច្ឆិយំ បហាដោ ហុត្វា វិយ** (ធ.ប.៤ ទំព័រ ៤៣) ប្រែថា រីមហាទុគ្គតៈ ជាអ្នក ហាក់ដូចជាបុគ្គល គឺគេប្រហារហើយត្រង់ពោះ ដោយលំពែង ដ៏មុត ។

៧. **ឯវំ ភិក្ខវេ អតីតេបិ ភាណា ទុម្មនា អាវិលចិត្តា ហុត្វា មម វចនេន បសន្នឧទករហទោ វិយ វិប្បសន្ន-ចិត្តា អហោសិ** ។បេ។ (ធ.ប.៤ ទំព័រ៦៧) ប្រែថា ម្នាលភិក្ខុ ទាំងឡាយ រីនាងកាណា ជាស្ត្រីមានចិត្តគឺទោសប្រទូស្ត ហើយ ជាស្ត្រីមានចិត្តល្អក់ កករហើយ ជាស្ត្រីមានចិត្តផូរផង់ ហើយ តាមពាក្យរបស់តថាគត បីដូចជារីអន្លង់ ទឹកដ៏ថ្លាហើយ បានមានហើយ សូម្បីក្នុងកាលដែលកន្លងទៅហើយ ។ល។

៨. **វណោ រុក្ខតោ ឆល្លិ វិយ អបគតោ** (ធ.ប.៤)

ប្រែថា រីដំបៅទៅប្រាសហើយ បីដូចជារីក្រមរ (កាលទៅប្រាស) ចាកដើមឈើ ។

**៩. ឯតញ្ហិ បាបកម្មំ នាម ឆុរំ ខហតោ ពលិពទ្ទស្ស បទំ ចក្កំ អនុគច្ឆន្តំ វិយ អនុគច្ឆតិ** មែនពិត ឈ្មោះថារីបាបកម្មនោះតែងទៅតាម (នូវបុគ្គល) បីដូចជារីកង់ កាលវិលទៅតាមនូវស្នាមជើងនៃគោ បម្រើកំពុងនាំទៅ នូវនឹម ។

**១០. អហាមេវ កន្ទតំ ពាល្យតរោ ចន្ទំ វិយ ទារកោ រុទំ មុត្តំ កាលកតាភិបត្ថយំ** (ធ.ប.១ ទំព័រ៥២) ប្រែថា បណ្ដាយើងទាំងឡាយកំពុងកន្ទក់កន្ទេញ រីយើងហ្នឹងឯង កាលប្រាថ្នាខ្លាំងនូវបុត្តដែលមានកាលៈធ្វើហើយ (ឬ មានមរណកាលធ្វើហើយ) កំពុងយំ បីដូចជា រីទារកកាល ប្រាថ្នាខ្លាំងនូវព្រះអាទិត្យ និង ព្រះចន្ទ កំពុងយំ ជាបុគ្គលពាលជាង ។

## ប្រយោគពិសេស

ប្រយោគហៅតាមលក្ខណៈនៃការប្រែ :

១. ប្រយោគ **ភាគោលោកនៈ** មានន័យដូចជាការក្រលេកមើលនៃភ្នែក គឺសព្ទមួយ កាលបើប្រែម្ដងហើយ ទើប

ប្រែសព្ទដទៃៗ ហើយត្រូវងាកត្រលប់មកប្រែសព្ទនោះ ម្តងទៀត ដូចក្អែកកាលហើរមកទំហើយ តែងក្រលេកមើលផ្លូវដែលខ្លួនហើរមកដូច្នោះ **កាកោលោកនៈ** ដោយច្រើន តែងជាមេដែលនៅក្នុងគាថាជាគ្រឹះ ដូចជា **ចន្ទសុរិយេហិ មេ អន្តោ តេ មេ ទេហីតិ យាចិតោ** ប្រែថា **អន្តោ** រីសេចក្តីត្រូវការ **ចន្ទសុរិយេហិ** ដោយព្រះចន្ទ និង ព្រះអាទិត្យទាំងឡាយ **ហោតិ** តែងមាន **មេ** ដល់ខ្ញុំ **ត្វំ** រីលោក **មេ** គឺខ្ញុំ **យាចិតោ** សុំហើយ **ទេហិ** ចូរឲ្យ **តេចន្ទសុរិយេ** នូវព្រះចន្ទ និង ព្រះអាទិត្យទាំងឡាយនោះ **មេ** ដល់ខ្ញុំ ។ **មេ** ក្នុងទីនេះត្រូវជាតតិយាវិភត្តិម្តង ជាចតុត្ថីម្តងទៀត បានជាគេហៅថា **កាកោលោកនៈ** មានន័យដូចការក្រលេកមើល របស់ក្អែក ។ ប្រយោគនាគពាធ ពាក្យនេះជាឈ្មោះ **ឥតិ**-សព្ទ តាមធម្មតា **ឥតិ**-សព្ទ តែងភ្ជាប់សេចក្តីក្នុងទីបំផុតនៃវគ្គ តែក្នុងទីនេះលោករៀងទុកដូច្នោះមិនបានទេ ព្រោះមានហេតុ ចាំបាច់រក្សាឆន្ទជាដើម ទើបលោកដាក់ **ឥតិ**-សព្ទ ទុកត្រង់កណ្តាលសេចក្តីខុសពី **ឥតិ** ធម្មតា ដូចជាអាការរឹតរួតនៃពស់ ព្រោះ

ធម្មតាពស់ កាលដែលរឹតរួតសត្វដើម្បីស៊ី តែងប្រើដងខ្លួន ដ៏វែងរបស់វាទៅព័ទ្ធជុំវិញ យ៉ាងណាមិញ **ឥតិ**-សព្ទ ក្នុងទីនេះក៏បៀមសេចក្តីនៅជុំវិញខ្លួនដូច្នោះដែរ ព្រោះហេតុនោះ ទើបលោកហៅថា **នាគពាធ** ការបៀតបៀនរបស់នាគ ដូចជា **ចន្ទសុរិយេហិ មេ អន្តោ តេ មេ ទេហីតិ យាចិតោ** ប្រែថា **មាណវោ** រីមាណព **អាហ** ពោលហើយ **ចន្ទសូរិយេហិ** ។ល។ **យាចិតោ ឥតិ** ថាដូច្នេះ ។

ប្រយោគ **នាគសោណ្ឌិ** ប្រែថា ប្រមោយដំរី ដោយអត្ថថា មូរត្រលប់ចូលទៅរកខ្លួន ជាឈ្មោះរបស់ប្រយោគមួយប្រភេទ ពេលដែលប្រែហួសទៅហើយ ត្រូវវិលត្រលប់មកប្រែម្តងទៀត បានជាក្រុមអ្នកប្រែនិយមហៅថា**នាគសោណ្ឌិ** ដោយតាំង ជាប្រយោគថា **យស្មា តស្មា** ប្រែទទួល ហេតុផលនៃគ្នានិងគ្នា ដូចជា **អនិច្ចា វតសង្ខារា ឧប្បាទវយធម្មិនោ ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ** ប្រែថា "**សង្ខារា** រីសង្ខារធម៌ទាំងឡាយ **អនិច្ចា វត** មិនទៀងទេហ្ន៎ **ឧប្បាទវយធម្មិនោ** មានកិរិយាកើតឡើង និង វិនាសទៅ

វិញជាធម្មតា **យស្មា** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **សង្ខារា** វីសង្ខារធម៌ទាំងឡាយ **អនិច្ចា ខត** មិនទៀងទេហ្ន៎ ។ **សង្ខារា** វីសង្ខារធម៌ ទាំងឡាយ **ឧប្បជ្ជិត្វា** កើតឡើងហើយ **និរុជ្ឈន្តិ** តែងរលត់ទៅវិញ **យស្មា** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ **សង្ខារា** វីសង្ខារធម៌ទាំងឡាយ **ឧប្បាទវយ-ធម្មិនោ** មានកិរិយាកើតឡើង និង វិនាសទៅវិញ ជាធម្មតា, **វូបសមោ** វីកិរិយា ចូលទៅរម្ងាប់ **តេសំ សង្ខារានំ** នូវសង្ខារធម៌ទាំងឡាយ នោះ **សុខោ ហោតិ** ទើបជាសុខ" ។

ប្រយោគ **អដ្ឋានសម្បយុត្ត** ពាក្យនេះជាឈ្មោះរបស់ **មិ** សព្ទ ដែលដាក់នៅក្នុង កន្លែងមួយ ដល់ពេលប្រែ ត្រូវទាញទៅដាក់ក្នុងកន្លែងមួយទៀត ហើយប្រកាន់ សេចក្តីដែលសមគួរ និង ខ្លួន ចូលទៅកន្លែងណា ក៏ទាញទៅ ដាក់ចូលត្រង់កន្លែង នោះ និង រក្សាតាមកន្លែងដែលលោកដាក់ទុកពីដើមពុំបានទេ ដូចជា **វុត្តម្បិ ចេតំ** វេលាសម្ព័ន្ធ ត្រូវទាញ **មិ** ទៅរួបនឹង **ឯតំ** ជា **វុត្តំ ច ឯតំមិ** ប្រែ : **ច** ក៏ង **ឯតំមិ វចនំ** វីពាក្យសូម្បីនេះ **ភគវតា** គឺព្រះដ៏មានព្រះភាគ

**វុត្តំ** ទ្រង់ត្រាស់ហើយ, **ហិ** ក្នុងទីនេះ ត្រូវទាញទៅចូលនឹង **ឯតំ** ហៅឈ្មោះថា **អបេក្ខត្ថៈ** ។

**ប្រយោគបេយ្យាលៈ** ឈ្មោះនេះ សម្រាប់ប្រើហៅ ប្រយោគ បាលីកាត់ គឺ ប្រយោគដែលលោកកាត់បទច្រំដែល ឬ ដែលអាចដឹងបាន នាំមករៀបទុកខាងវគ្គដើម និង វគ្គចុង ឯ វគ្គកណ្តាលកាត់ចេញ និងដាក់ ។បេ។ ខ្លះ និង ។ល។ ខ្លះ ជំនួសវិញ ប្រយោគដូច្នេះហៅថា **បេយ្យាលៈ** បានន័យថា ប្រយោគដែលលោក បំប្រួញ ឬ លោក។ល។ទុក ពេលប្រែ ត្រូវដាក់ បញ្ចូលមកឲ្យពេញ ដូចជា **ថេរោ ន ខ្វាហំ ភន្តេ ឯត្ថ ភគវតោ សទ្ធាយ គច្ឆាមិ ។ សទ្ធិន្ទ្រិយំ។បេ។ អមតបរិយោសានំ យេសំ នូនេតំ ភន្តេ អញ្ញាតំ អស្សុតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ សញ្ញាយ តេ ទិដ្ឋំ បរេសំ សទ្ធាយ គច្ឆេយ្យុំ ។ សទ្ធិន្ទ្រិយំ ។បេ។ អមតបរិយោសានន្តិ ឯវន្តំ បញ្ហំ ព្យាភាសិ ។** (ធ.ប.៤ សារីបុត្តថេរវត្ថុ) ប្រយោគនេះជាប្រយោគបេយ្យាលៈ ព្រោះលោកកាត់បទដដែលៗ ត្រង់កណ្តាលចេញ ហើយដាក់ ។បេ។ ជំនួសវិញ ប្រយោគ

ពេញត្រូវមានដូច្នេះ **សទ្ធិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ ។ អមតបរិយោសានំ** ក្នុងប្រយោគនេះ បើនឹងប្រែឲ្យពេញលេញ ត្រូវដាក់ ៥ ដងតាម ឥន្ទ្រីយ៍ ៥ គឺ : **វីរិយិន្ទ្រិយំ** ។បេ។ **សតិន្ទ្រិយំ ។បេ។ សមាធិន្ទ្រិយំ ។បេ។ បញ្ញិន្ទ្រិយំ ។បេ។** ក្រៅពីនោះដូច **សទ្ធិន្ទ្រិយំ** ទាំងអស់ ។

ម្យ៉ាងទៀត ទោះជាប្រយោគដែលលោកមិនដាក់ ។បេ។ ឬ ។ល។ ទុកជា ប្រយោគធម្មតា ក៏ដោយ តែពេលប្រែត្រូវដាក់ចូលមកជារឿងជាវគ្គស្រដៀងគ្នានេះ ប៉ុន្តែមិនមែនលោកដាក់ **ឥតិ** អាទ្យត្ថៈរក្សាទុកទេ គឺដាក់ចូលមកដោយខ្លួនឯង ដូច្នេះហៅថា **បេយ្យាលៈ** បានដូចគ្នា ។

ប្រយោគកិរិយាបធានន័យ : ប្រយោគនេះមានប្រធានច្រើនបទ គឺបទប្រធាន ខាងដើម និង បទប្រធានខាងចុង ។

បទប្រធានខាងដើម ជួនជាពហុវចនៈ ជួនជាឯកវចនៈ មានកិរិយាគ្រប់គ្រង ប្រកបដោយ **ត្វាទិប្បច្ច័យ** ។ បទប្រធានខាងចុង ជួនជាពហុវចនៈ ជួនជាឯកវចនៈ ប៉ុន្តែមានកិរិយាគ្រប់គ្រង ប្រយោគពេញលក្ខណៈ មានវចនៈ ទៅតាម

បទប្រធាន របស់វា ដូចជា **តេបិ ថេរា ឯកមគ្គេនាបិ អគន្ត្វា ឯកោ ថេរោ បច្ឆិមទ្វារេន មគ្គំ គណ្ហិ ឯកោ ថេរោ បុរត្ថិមទ្វារេន គណ្ហិ** ប្រែថា **តេបិ ថេរា** សូម្បីព្រះថេរៈទាំងឡាយ **អគន្ត្វា** មិនទៅហើយ **ឯកមគ្គេន អបិ** សូម្បីតាមផ្លូវតែមួយ, **ឯកោ ថេរោ** ព្រះថេរៈ មួយអង្គ **គណ្ហិ** កាន់យកហើយ **មគ្គំ** នូវផ្លូវ **បច្ឆិមទ្វារេន** តាមទ្វារខាងលិច, **ឯកោ ថេរោ** ព្រះថេរៈមួយអង្គ **គណ្ហិ** កាន់យកហើយ **មគ្គំ** នូវផ្លូវ **បុរត្ថិមទ្វារេន** តាមទ្វារ ខាងកើត ។

## សម្ពន្ធ

**បិ** អបេកត្ថៈ ក្នុង **តេ**ៗ វិសេសន របស់ **ថេរា**ៗ សយកត្តា ក្នុង **អគន្ត្វា**ៗ កិរិយាបធានន័យ, **អបិ** អបេកត្ថៈ ក្នុង **ឯកមគ្គេន**ៗ ករណៈក្នុង **អគន្ត្វា**, **ឯកោ** វិសេសនរបស់ **ថេរោ**ៗ សយកត្តាក្នុង **គណ្ហិ**ៗ អាខ្យាតបទកត្តុវាចកៈ, **បច្ឆិមទ្វារេន** ករណៈក្នុង **គណ្ហិ**, **មគ្គំ** អវុត្តកម្ម ក្នុង **គណ្ហិ**, **ឯកោ** វិសេសនរបស់ **ថេរោ**ៗ សយកត្តា ក្នុង **គណ្ហិ**, **បុរត្ថិម-ទ្វារេន** ករណៈក្នុង **គណ្ហិ**, **មគ្គំ** អវុត្តកម្មក្នុង **គណ្ហិ**ៗ អាខ្យាត-

បទ កត្តុវាចក: ។

## លំហាត់ប្រែ

**១**. **ឯវំ ខន្ធេត្វា នគរវាសី អដ្ឋ គោជិយោ អទាសិ** (ធ.ប.៥) ប្រែថា **ទ្វេ សេដ្ឋិនោ** រីសេដ្ឋីទាំងឡាយពីរនាក់ **ធនំ** ញ៉ាំងទ្រព្យ **ខន្ធេត្វា** ឲ្យចម្រើនហើយ **ឯវំ** យ៉ាងនេះ **នគរវាសី** រីសេដ្ឋីអ្នកនៅក្នុងក្រុង **អទាសិ** បានឲ្យហើយ **គោជិយោ** នូវកោជិទាំងឡាយ **អដ្ឋ** ៨ ។

**២**. **ហេដ្ឋាគង្គាយ ច ទ្វេ ឥត្ថិយោ នហាយមានា តំ ភាជនំ ឧទកេនាហរិយមានំ ទិស្វា ឯកា ឥត្ថី មយ្ហមេតំ ភាជនន្តិ អាហ** (ធ.ប.៨) ប្រែថា **ច** ក៏ **ឥត្ថិយោ** រីស្រីទាំងឡាយ **ទ្វេ** ពីរនាក់ **នហាយមានា** កំពុងងូត **ហេដ្ឋាគង្គាយ** ក្នុងខាងក្រោមនៃ **ទន្លេគង្គា ទិស្វា** ឃើញហើយ **ភាជនំ** នូវភាជនៈ **តំ** នោះ **ឧទកេន អាហរិយមានំ** គឺទឹកកាលនាំមក ,**ឥត្ថី** រីស្ត្រី **ឯកា** ម្នាក់ **អាហ** ពោលហើយ **មយ្ហមេតំ ភាជនំ ឥតិ** ថាដូច្នេះ (**ឯតំ ភាជនំ**) រីភាជនៈនេះ **មយ្ហំ ភាជនំ ហោតិ** ជាភាជនៈរបស់ខ្ញុំ ។

**៣. ជាតិ ជរាយ សន្តិកំ បេសេត្វា, ជរា ព្យាធិនោ សន្តិកំ, ព្យាធិ មរណស្ស សន្តិកំ** (ធ.ប.៥) ប្រែថា **ជាតិ** វី កំណើត **បេសេត្វា** បញ្ជូនទៅហើយ **សន្តិកំ** កាន់សំណាក់ **ជរាយ** នៃជរា, **ជរា** វីជរា **បេសេត្វា** បញ្ជូនទៅហើយ **សន្តិកំ** កាន់សំណាក់ **ព្យាធិនោ** នៃព្យាធិ, **ព្យាធិ** វីព្យាធិ **បេសេត្វា** បញ្ជូនទៅហើយ **សន្តិកំ** កាន់សំណាក់ **មរណស្ស** នៃសេចក្តីស្លាប់ ។ល។

**៤. មម សរីរំ មជ្ឈេ ភិន្ទិត្វា ឯកោ ភាគោ ឱរិមតីរេ បតតុ** (ធ.ប.៣ ទំព័រ ៣០៩) ប្រែថា **សរីរំ** វីសរីរៈ **មម** របស់យើង **ភិន្ទិត្វា** បែកហើយ, **ភាគោ** វីចំណែក **ឯកោ** មួយចំណែក **បតតុ** ចូរធ្លាក់ចុះ **ឱរិមតីរេ** លើត្រើយខាងអាយ ។

**៥. ទារកា មយំ ឥទានិ គហេតុំ ន សក្ខិស្សាម ។ល។ ឥតិ មន្តេត្វា ឯកេកោ ឯកេកំ សាខាភង្គមុដ្ឋិមាទាយ សត្តបិ ជនា សត្តធិត្ថានិ បិទហិត្វា បក្កមឹសុ** (ធ.ប.៥) ប្រែថា **ទារកា** វីក្មេងទាំងឡាយ **មន្តេត្វា** ប្រឹក្សាគ្នាហើយ **មយំ** ។ល។ **សក្ខិស្សាម** ។ល។ **ឥតិ** ថាដូច្នេះ **ឯកេកោ ទារកោ** វីក្មេងម្នាក់ៗ **អាទាយ** កាន់យកហើយ **សាខាភង្គមុដ្ឋឹ** នូវក្តាប់នៃរំកាច់នៃ

មែកឈើ **ឯកេកំ** មួយក្តាប់ៗ **សត្តបិ ជនា ហុត្វា** ជាជនទាំង ៧នាក់ **បិទហិត្វា** បិទហើយ **ឆិទ្ទានិ** នូវប្រហោងទាំងឡាយ **សត្ត** ៧រន្ធ **បក្កមឹសុ** ជៀសចេញទៅហើយ ។ **ឥទានិ** ក្នុងកាលឥឡូវនេះ **មយំ** រីយើងទាំងឡាយ **ន សក្ខិស្សាម** នឹងមិនអាច **គហេតុំ** ដើម្បីចាប់បានទេ ។

**៦. ឯកមេកំ ភិក្ខុសតំ និសិន្នដ្ឋានេយេវ សហ បដិសម្ភិទាហិ អរហត្តំ បត្វា វិហាសំ អព្ភុគ្គន្ត្វា សព្វេបិ តេ ភិក្ខូ អាកាសេនេវ វីសយោជនសតិកំ អតិក្កមិត្វា ។ល។ បាទេ វន្ទឹសុ** (ធ.ប.៨) ប្រែថា **ភិក្ខុសតំ** រីរយនៃភិក្ខុ **ឯកេកំ** មួយរយៗ **បត្វា** ដល់ហើយ **អរហត្តំ** នូវភាពនៃព្រះអរហន្ត **សហ** មួយអន្លើ **បដិសម្ភិទាហិ** ដោយបដិសម្ភិទាទាំងឡាយ **និសិន្នដ្ឋានេ ឯវ** ក្នុងទីនៃខ្លួនអង្គុយហើយ និងអង្គុយហើយមែនពិត **អព្ភុគ្គន្ត្វា** ហោះឡើងហើយ **វេហាសំ** កាន់វេហាស៍, **ភិក្ខូ** រីភិក្ខុទាំងឡាយ **តេ** នោះ **សព្វេបិ** ទាំងអស់អង្គ **អតិក្កមិត្វា** កន្លងហើយ **កន្តារំ** នូវផ្លូវដាច់ស្រយាល **វីសយោជនសតិកំ** ប្រកបហើយដោយរយនៃយោជន៍ ២០ ។

## ប្រយោគកិរិយាបរាមាស ( **បរ** + **អា** + **មស** + **ណ** )

ការបបោសអង្អែល ការប្រកាន់យកទៅជាភាវរូប ភាវសាធនៈវិគ្គហៈថា **បរាមសនំ** ទៅជា **បរាមាសោ** ប្រែថា ការប្រកាន់យក ឬ សម្លឹងយក, សម្រាប់សម្លឹង យកសេចក្ដី ខាងមុខ បើសម្លឹងយកទាំងមូល វេលាប្រែ ត្រូវផ្លាស់ប្រយោគទាំងមូល ប្រើសព្វនាមយោគ, បើសម្លឹងយកចំពោះ តែពាក្យខ្លះ សព្ទខ្លះ ត្រូវប្រើសព្វនាម យោគយកពាក្យនោះ ឬ សព្ទនោះតែម្ដង តែសព្វនាមដែលលោករៀងទុកនោះ ជាបុំលិង្គក៏មាន ជាឥត្ថីលិង្គក៏មាន ជានបុំសកលិង្គក៏មាន ដូចតទៅនេះ :

## សព្វនាមជាបុំលិង្គ

កាលបានផ្លាស់សព្វនោះៗរួចហើយ ត្រូវនាំមកភ្ជាប់ជា បទសមាស និងភាវសព្ទ ដូចប្រយោគថា : **ធម្មោ សុចិណ្ណោ សុខមាវហាតិ**, **ឯសានិសំសោ ធម្មេ សុចិណ្ណេ** ប្រែថា **ធម្មោ** រីព្រះធម៌ **សុចិណ្ណោ** គឺបុគ្គលប្រព្រឹត្តល្អហើយ **អាវហាតិ** តែងនាំមក **សុខំ** នូវសេចក្ដីសុខ, **ឯសោ សុខស្ស អាវហនភាវោ** រីភាវនៃកិរិយានាំមកនូវសេចក្ដីសុខនេះ

**អានិសំសោ ហោតិ** ជាអានិសង្ស **ធម្មេ** ក្នុងធម៌ **សុចិណ្ណេ** ដែលបុគ្គលប្រព្រឹត្តល្អហើយ ។ **ធម្មោ** វីព្រះធម៌ **រក្ខតិ** តែងរក្សា **ធម្មចារិនំ** នូវបុគ្គលអ្នកប្រព្រឹត្តនូវធម៌ដោយប្រក្រតី **យំ** ឯណា, **ឯសា ធម្មេន រក្ខិតតា** (វីភាវនៃ បុគ្គលអ្នកប្រព្រឹត្តនូវធម៌ដោយប្រក្រតី ជាអ្នកគឺធម៌រក្សាហើយ) នេះ **ធម្មតា** ជាធម្មតា ។ **ឯសា** សម្លឹងយកអស់ មួយប្រយោគ ត្រូវផ្លាស់ **ធម្មោ ធម្មចារិនំ រក្ខតិ** ទៅជា **ធម្មេន ធម្មចារិនា រក្ខិត + តា** (ធ.ប.៨ ទំព័រ ១០១) ។

**សព្វនាម** ជា **នបុំសកលិង្គ** : បើផ្លាស់ជានាម មិនត្រូវចុះបច្ច័យក្នុងភាវតទ្ធិតទេ, បើផ្លាស់ជាគុណ ទើបចុះបច្ច័យក្នុង ភាវតទ្ធិត ក្រៅពី **តា**-បច្ច័យបាន ដូចជា **អនច្ឆរិយំ ភិក្ខវេ ឯតំ, យំ សក្កោ ទេវរាជា មយិ សិនេហំ ករោតិ** ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **ទេវរាជា** វីទេវរាជ **សក្កោ** ព្រះនាម **សក្ក ករោតិ** រមែងធ្វើ **សិនេហំ** នូវសេចក្តីស្រលាញ់ **មយិ** ក្នុងតថាគត **យំ** ឯណា, **ឯតំ សក្កស្ស ទេវរាជស្ស មយិ សិនេហស្ស ករណំ** វីកិរិយាធ្វើនូវសេចក្តី

ស្រឡាញ់ក្នុងតថាគត របស់ទេវរាជព្រះនាមសក្កនេះ **អនច្ឆរិយំ** មិនជាអស្ចារ្យទេ (ធ.ប.៦ ទំព័រ ១៩៧) ។

ចំណែកធាតុប្រព្រឹត្តទៅក្នុងអត្ថថា " មាន, កើត, ជា " បើសព្ទនាមជាបុំលិង្គ ត្រូវផ្លាស់ជា **ភាវ** ហើយប្រកបចូលនឹងបទវិសេសនៈ ឬ វិកតិកត្តា, បើសព្ទនាម ជាឥត្ថីលិង្គ ឬនបុំសកលិង្គ ត្រូវចុះបច្ច័យក្នុងភាវតទ្ធិតដូចជា **អនច្ឆរិយំ ខោ បនេតំ ភិក្ខុ, យំ ត្វំ មាទិសំ អាចរិយំ លភិត្វា អប្បិច្ឆោ អហោសិ** ប្រែថា **ភិក្ខុ** ម្នាលភិក្ខុ **បន** ក៏ **ត្វំ** រីលោក **លភិត្វា** បានហើយ **អាចរិយំ** នូវអាចារ្យ **មាទិសំ** ប្រាកដដូចតថាគត **អប្បិច្ឆោ អហោសិ** បានជាអ្នកមានសេចក្ដីប្រាថ្នាតិចហើយ **យំ** ឯណា, **ឯតំ តវ មាទិសំ អាចរិយំ លភិត្វា អប្បិច្ឆត្តំ** រីភាវនៃលោកជាអ្នកបាននូវអាចារ្យប្រាកដដូច តថាគត ហើយមានសេចក្ដីប្រាថ្នាតិចនុ៎ះ **អនច្ឆរិយំ ខោ** មិនគួរអស្ចារ្យឡើយ (ធ.ប. ២ ទំព័រ ១៩១) ។

**ឥធ ខោ តំ ភិក្ខវេ សោភេថ, យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ខមា ច ភវេយ្យាថ សោរតា ច** ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **តុម្ហេ** រីលោកទាំងឡាយ

**ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា** ជាអ្នកបួស ហើយក្នុងធម្មវិន័យដែលតថាគត ពោលល្អហើយ យ៉ាងនេះ **ខមា ច សោរតា ច ភវេយ្យាថ** គប្បីជា អ្នកចេះអត់ធន់ផង ជាអ្នកត្រេកអរក្នុងធម៌ដ៏ល្អផង **យំ** ឯណា, **តំ តុម្ហាកំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតានំ ខមសោរតត្តំ** រីភាវៈនៃលោកទាំងឡាយបួសហើយ ក្នុងធម្មវិន័យដែលតថាគតពោលល្អហើយយ៉ាងនេះ ជាអ្នកចេះអត់ធន់ និងជាអ្នក ត្រេកអរក្នុងធម៌ដ៏ល្អនុ៎ះ **សោភេថ** គប្បីល្អ **ឥធ ខោ ធម្មវិនយេ** ក្នុងធម្មវិន័យនេះឯង ។

**ឋានំ ខោ បនេតំ វិជ្ជតិ, យំ ត្វំ កុមារោ វ សមានោ កាលំ ករេយ្យាសិ** (ធ.ប.១ ទំព័រ២០៥) ប្រែថា **បន** ក៏ **ត្វំ** រីព្រះអង្គ **កុមារោ សមានោ វ** កាលជាព្រះកុមារមែនពិត **ករេយ្យាសិ** គប្បីធ្វើ **កាលំ** នូវមរណកាល **យំ** ឯណា, **ឯតំ តវ កុមារស្ស វ សមានស្ស កាលស្ស ករណំ** រីកិរិយាធ្វើនូវមរណកាលរបស់ព្រះអង្គកាលនៅជាព្រះកុមារមែនពិតនុ៎ះ **ឋានំ ខោ** ជាឋានៈមែនពិត **វិជ្ជតិ** តែងមាន ។

**ឯត្តកមេវ ភិរស្ស ឱឡារិកំ ខលិតំ អហោសិ, យំ តិក្ខនំ**

**អនាបុច្ឆា បក្កាមិ** (ធ.ប.៤ ទំព័រ១៨៨) ប្រែថា **សោ ទុគ្គតបុរិសោ** រីទុគ្គតបុរសនោះ **អនាបុច្ឆា** មិនប្រាប់ហើយ **ភិក្ខូនំ** ដល់ភិក្ខុទាំងឡាយ **បក្កាមិ** ជៀសចេញទៅហើយ **យំ** ឯណា **ឯត្តកំ ឯវ ភិក្ខូនំ អនាបុច្ឆា បក្កមនំ** រីកិរិយាមិនប្រាប់ដល់ភិក្ខុទាំងឡាយហើយ ជៀសចេញទៅមានប្រមាណប៉ុណ្ណោះឯង **អស្ស ទុគ្គតបុរិសស្ស ឱឡារិកំ ខលិតំ អហោសិ** បានជាសេចក្ដីភ្លាំងភ្លាត់ យ៉ាងក្រៃលែងរបស់ទុគ្គតបុរសនោះ ហើយ ។

**យស្មា បរស្ស អត្តនិ ឋិតេន សគ្គបរាយនេន វា មគ្គបរាយនេន វា ភវិតុំ ន សក្កា, តស្មា អត្តាវ អត្តនោ នាថោ, កឹ បរោ ករិស្សតិ** គឺបុគ្គលដែលតាំងនៅហើយ ក្នុងខ្លួនរបស់បុគ្គលដទៃ មិនអាចដើម្បីជាអ្នកមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ឬថាជាអ្នកមានមគ្គប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះហេតុណា ព្រោះហេតុនោះ រីខ្លួនហ្នឹងឯងគប្បីជាទីពឹងរបស់ខ្លួន រីបុគ្គលដទៃនឹងធ្វើដូចម្ដេចកើត ។

## ប្រយោគត្រូវបន្ថែម

ប្រយោគដែលប្រែទទួលកិរិយាបរាមាសៈចំពោះ **យំ**

មួយបទ វៀរលែង **យស្មា** និង **ហិ** ចេញ ត្រូវថែមប្រយោគមុខចូលមកដោយវិធីផ្លាស់ប្រយោគដូច្នេះ :

វិសេសនៈ អព្ភន្តរកិរិយា វិកតិកត្តា របស់បទប្រធាន ត្រូវប្រែកបជឆដ្ឋីវិភត្តិដូចជា **សុន្ទរោ ធម្មោ** ទៅជា **ធម្មស្ស សុន្ទរភាវោ តា ត្តំ, ពុទ្ធោ លោកេ ឧប្បន្នោ** ទៅជា **ពុទ្ធស្ស លោកេ ឧប្បន្នភាវោ តា ត្តំ, សង្ខារា សស្សតា នត្ថិ សង្ខារានំ សស្សតានំ នត្ថិភាវោ នត្ថិតា នត្ថិត្តំ** ។

បើកិរិយាប្រចាំប្រយោគប្រាប់បច្ចុប្បន្នកាល ឬ អនាគតកាល ត្រូវយកធាតុ នោះប្រែកបជាមួយ **យុ**-បច្ច័យ ដូចជា **ជនោ បុញ្ញំ ករោតិ** = **ជនស្ស បុញ្ញករណំ** ។

បើកិរិយាគ្រប់គ្រងប្រយោគប្រាប់អតីតកាល ត្រូវផ្សំជាមួយ **ត**-បច្ច័យ ។

បើកិរិយាប្រចាំប្រយោគជា **ភូ ហុ អស ជន** មិនបាច់ថែមផ្លាស់ជាអ្វីទេ ឲ្យប្រើ បទវិកតិកត្តា ក្នុងទីនោះ ជំនួស ដូចជា **រាជា ឥស្សរោ ហោតិ** ទៅជា **រញ្ញោ ឥស្សរភាវោ ឥស្សរតា ឥស្សរត្តំ** ។

ប្រើ **តាទិ**-សព្ទ **តា** **ត្ត**-បច្ច័យ, តភ្ជាប់ខាងក្រោយកិរិយាតាមលិង្គដែលសព្ទនាមត្រូវការហើយ ប្រកបជាមួយបឋមាវិភត្តិ ក្នុងឋានៈជាប្រធានដូច្នេះ បុំលិង្គ **ឯសោ តាទោ**, ឥត្ថីលិង្គ **ឯសា តា**, នបុំសកលិង្គ **ឯតំ ត្តំ**, បទក្រៅពីនេះ រក្សាទុកតាមរូបដើម, អាលបន មិនត្រូវយកមកបំពេញទេ ដូចជា **អនច្ឆរិយំ ខោ បនេតំ ភិក្ខុ, យំ ត្វំ មាទិសំ អាចរិយំ លភិត្វា អប្បិច្ឆោ អហោសិ** ប្រែថា **ភិក្ខុ** ម្នាលភិក្ខុ **បន** ក៏ **ត្វំ** រីលោក **លភិត្វា** បានហើយ **អាចរិយំ** នូវអាចារ្យ **មាទិសំ** ប្រាកដដូចតថាគត **អប្បិច្ឆោ អហោសិ** បានជាអ្នកមាន សេចក្តីប្រាថ្នាតិចហើយ **យំ** ឯណា, **ឯតំ តវ មាទិសំ អាចរិយំ លភិត្វា អប្បិច្ឆិត្តំ** រីភាវនៃលោកជាអ្នកបាននូវអាចារ្យប្រាកដស្មើដោយតថាគតហើយមានសេចក្តីប្រាថ្នាតិចនេះ **អនច្ឆរិយំ ខោ ហោតិ** មិនមែនជាហេតុអស្ចារ្យទេ ។

កាលសង្កេតមើលសព្ទខ្លះដែលប្រើបានពីរ ឬ បីវិភត្តិដូចជា **ទិវសេ** ក្នុងថ្ងៃ, អស់ថ្ងៃទាំងឡាយ កាលបើមានបទនៅខាងមុខជាវិសេសន ដូចជា **សត្តមេ ទិវសេ** ក្នុងថ្ងៃទី៧,

**ទេ្វ តយោ ទិវសេ** អស់ថ្ងៃទាំងឡាយពីរបី ។

**ស** ឆដ្ឋីវិភត្តិ, **ស** ចតុត្ថីវិភត្តិនៅនឹង **ភី** ដែលជាវិសេសនរបស់ **បយោជនំ** ក្តី **អត្ថោ** ក្តី ចេញសំឡេងថាដល់ ដូចជា **ភី បយោជនំ មេ ឃរាវាសេន** (ធ.ប.១ ទំព័រ៧) ។

**ភិត្តកេហិ បន តេ ភិក្ខូហិ អត្ថោ** (ធ.ប.៥) ។

**ហិ** សព្ទ ដែលមាន **តស្មា** នៅប្រយោគក្រោយ ឬ **ភឹករណា** ឲ្យប្រែថា **ហេតុ** ណា ឬ ព្រោះហេតុណា ដូចជា **ទន្ធំ កតំ កុសលំ ហិ សម្បត្តឹ ទទមានំ ទន្ធមេវ ទទាតិ តស្មា ចិត្តុប្បាទសមនន្តរមេវ កល្យាណកម្មំ កាតព្វំ** រីកុសលដែលបុគ្គលធ្វើហើយយឺតយូរ កាលនឹងឲ្យនូវសម្បត្តិរមែងឲ្យយឺតយូរមែនពិត ព្រោះហេតុណា ព្រោះហេតុនោះ រីអំពើល្អ គឺបុគ្គលគប្បីធ្វើ ក្នុងលំដាប់ស្មើនៃចិត្តុប្បាទមែនពិត (ធ.ប.៥) ។

សព្ទស្កាត់មិនចេញសំឡេងប្រែទេ តខាងចុងសព្ទដើម្បីឲ្យមានលិង្គត្រូវគ្នា ជា មួយសព្ទនាម ដូចជា

**អន្ត** ដូចជា **សុត្តន្តំ** "ព្រះសូត្រ", **កម្ម** ដូចជា **បញ្ញាកម្មំ**

ប្រែ "បញ្ញា", **គត** ដូចជា **ទិដ្ឋិគត** "ទិដ្ឋិ", **រូប** ដូចជា **អត្តរូប** ប្រែ "អត្ត, អាចិ" **ជាត** ដូចជា **សទ្ធជាតំ, ជាតិ** ដូចជា **ធម្មជាតិ** "ធមិ" ។

សព្ទដើមបទខ្លះ ប្រយោគខ្លះ ត្រូវថែមសព្ទចូល មកទើបប្រែបានដូច្នេះ

បើមិនមានរៀងទុកក្នុងប្រយោគ ឲ្យថែមតាមគោលកំណត់នេះ

**១. វិភត្តិកត្តា** នៅកណ្ដាលប្រយោគ ឬ ចុងប្រយោគ ត្រូវថែម **ភូ, ហុ, អស** ធាតុ ប្រកបជាមួយវិភត្តិ ស្របតាមបទប្រធាន និងប្រកបកាលតាមន័យដែលបញ្ជាក់ ដូចជា បច្ចុប្បន្នកាល ប្រធានជាបឋមបុរិសឯកវចន ឲ្យថែម **ហោតិ** ឧទាហរណ៍ : **ពុទ្ធោ មេ នាថោ** (**ហោតិ**) ប្រែថា ព្រះពុទ្ធជាទីពឹងរបស់ខ្ញុំ ។

**២. វិភត្តិកម្ម** បំពេញ **កត្វា** ដូចជា **ធម្មំ ចរេ សុចរិតំ**, ដូចជា **រាជបុរិសា តំ បច្ឆាពាហុំ** (**កត្វា**) **ពន្ធិត្វា កសាហិ តាលេន្តា អាឃាតនំ នយឹសុ** (ធ.ប.៣ ទំព័រ ២២០) ប្រែថា

**រាជបុរិសា** រីរាជបុរសទាំងឡាយ **ពន្ធិត្វា** ចងហើយ **តំ បុរិសំ** នូវបុរសនោះ (**ភត្វា** ធ្វើ) **បច្ឆាពាហុំ** ឲ្យមានដើមដៃទៅខាងក្រោយ **តាលេន្តា** កាលវាយ **ភសាហិ** ដោយរំពាត់ផ្ដៅទាំងឡាយ **នយីសុ** នាំទៅហើយ **អាឃាតនំ** កាន់ទីជាទីសម្លាប់ ។

៣. បើកិរិយាក្រោយវិកតិកម្មជាកម្មវាចក មិនបាច់ថែម **ភត្វា** ទេ ដូចជា **អមតំ វុច្ចតិ និព្វានំ** ប្រែថា **និព្វានំ** រីព្រះនិព្វាន **ភគវតា** គឺព្រះមានព្រះភាគ **វុច្ចតិ** ទ្រង់ត្រាស់ហៅ **អមតំ** ថាអមតៈ (ធ.ប.២ ទំព័រ១១១) ។

៤. ប្រយោគលក្ខណៈបំពេញលក្ខណកិរិយាគឺ **សមា-នេ សមានេសុ**, **សន្តេ** ឬ **សតិ** ឲ្យស្របតាមលិង្គ វចនៈ វិភត្តិរបស់ បទលក្ខណៈ ដូចជា **ឯកោ កិរ កុដុម្ពិកបុត្តោ បិតរិ កាលកតេ** (**សមានេ**) **ខេត្តេ ច ឃរេ ច សព្វកម្មានិ អត្តនាវ ករោន្តោ មាតរំ បដិជគ្គិ** (ធ.ប.១ ទំព័រ៦៤) ប្រែថា **កិរ** បានឮថា **កុដុម្ពិកបុត្តោ** រីកុដុម្ពិកបុត្រ **ឯកោ** ម្នាក់ **បិតរិ** នាកាលបិតា **កាលកតេ** ធ្វើហើយនូវមរណកាល ឬមាន

កាលធ្វើហើយ ក៏បាន (**សន្តេ** កាលមាន) **ករោន្តោ** កាលធ្វើ **សព្វកម្មានិ** នូវការងារទាំងពួងទាំងឡាយ **ខេត្តេ ច** ក្នុងស្រែផង **ឃរេ ច** ក្នុងផ្ទះផង **អត្តនា ច** ដោយខ្លួនឯង **បដិជគ្គិ** ទំនុកបម្រុងហើយ **មាតរំ** នូវមាតា ។

៥. **ប្រយោគអនាទរៈ** ត្រូវបំពេញអនាទរៈកិរិយាគឺ **សមានស្ស សមានានំ**, **សន្តស្ស** ឬ **សន្តានំ** ឲ្យស្រប តាមលិង្គ វចន វិភត្តិ របស់បទអនាទរៈ ដូចជា **តស្ស ចយប្បត្តស្ស** (**សមានស្ស**) **បិតាកាលមកាសិ** (ធ.ប.៨) ។

៦. ក្រោយ **ឥតិ** សព្ទ ត្រូវបន្ថែម **អព្ភន្តរកិរិយា** ឬ **ករណៈ** ដែលមានសេចក្ដី សម្ដែងដល់ការសន្ទនា ការនឹកគិត ការសាកសួរ ការធានា ក្ដីសង្ឃឹម ការយល់ឃើញ យ៉ាងណាមួយ បើក្រោយ **ឥតិ** សព្ទ, មិនមានកិរិយា ឬ នាមសព្ទបញ្ជាក់ ច្បាស់នូវសេចក្ដីក្នុងលេខក្នុងទេ មានរបៀបឲ្យបន្ថែមដូច្នេះ :

ក. លេខក្នុងជាប្រយោគនិយាយសន្ទនាជាមួយគ្នា ឲ្យបំពេញ **វចនេន** ក្រោយ **ឥតិ** សព្ទ ដូចជា **ភន្តេ មា ចិន្តយិត្ថ**

**មយំ ភោ បដិបជ្ជិស្សាមាតិ** (**វចនេន**) **ថេរំ អស្សាសេត្វា** ។បេ។ ឲ្យព្រះថេរ ពេញចិត្តដោយសំដីយ៉ាងនេះ (ធ.ប.១ ទំព័រ១៧) ឲ្យពេញចិត្តធ្វើព្រមជាមួយនិយាយ **ឥមំ ឈាបេហីតិ** (**វចនេន**) **ឥតិ ទត្វា និយ្យាទេត្វា បក្កមឹសុ** ឲ្យថ្លៃឈ្នួលដោយពាក្យយ៉ាងនេះ (ធ.ប.១ ទំព័រ១០០) បំពេញ **វត្វា** ក្នុងកាលដែលនិយាយនេះធ្វើមុន កិរិយាក្រោយ **ឥតិ**-សព្ទ ដូចជា **តិដ្ឋថ តាវ ភន្តេ**, **កិច្ចំ មេ អត្ថីតិ** (**វត្វា**) **តស្សា សន្តិកំ គតោ** និយាយមុនហើយទៅជាក្រោយ (ធ.ប.១ ទំព័រ២២) ។ **ភន្តេ** បពិត្រលោកម្ចាស់ ដ៏ចម្រើន **តុម្ហេ** រីលោក **តិដ្ឋថ** សូមឈប់ **តាវ** សិន **កិច្ចំ** រីកិច្ច **មេ** នៃខ្ញុំ **អត្ថិ** មាន ។

ខ. លេខក្នុងប្រយោគនឹកគិត ថែម **ចិន្តនេន** ក្នុងពេលដែលនឹកគិតនេះជាហេតុ កិរិយាក្រោយ **ឥតិ** សព្ទ ជាផលដូចជា **ពហុបការោ មេ គហបតីតិ** (**ចិន្តនេន**) **មយ្ហំ ធម្មំ ទេសេន្តោ កិលមេយ្យ** សំដែងធម៌ដល់យើងដោយគិត យ៉ាងនេះ (ធ.ប.១ ទំព័រ៦) ។ ថែម **ចិន្តេត្វា** ក្នុងពេល ដែលនឹកគិតនេះធ្វើមុនកិរិយាក្រោយ **ឥតិ**-សព្ទ ដូចជា **អយំ មហោសក្ខាយ**

**ទេវតាយ បរិគ្គហិតោ ភវិស្សតីតិ** (ចិន្តេត្វា) **តស្ស ហេដ្ឋាភាគំ សោធាបេត្វា** ។បេ។ គិតជាបុព្វកាល ត្រូវដាក់ **ត្វា**-បច្ច័យ, តែបើគិតជាហេតុ ត្រូវដាក់ **ចិន្តនេន** ឬគិតហើយធ្វើជាមួយគ្នា ដូចជា **ចិន្តនេន ភតី ឧត្វា** គិតហើយឲ្យជាមួយគ្នា ប្រើ "**ចិន្តនេន**" បើគិតរួចបានញុំាងគេឲ្យជម្រះ ទើបប្រើ **ចិន្តេត្វា** ។

គ. លេខក្នុងជាប្រយោគសួរ បំពេញ " **បុច្ឆិត្វា** " ដូចជា **កឹ ភរិយាយ មេ សន្តកំ នត្ថីតិ** (**បុច្ឆិត្វា**) **អត្ថិ សាមីតិ** (**វុត្តេ**) ។បេ។ សួរហើយទើបបានទទួលចម្លើយ ក្រោយ (ធ.ប.៥) ។ **សាមិកោ** រឺប្ដី **បុច្ឆិត្វា** សួរហើយ **កឹ ភរិយាយ មេ សន្តិកំ នត្ថិ ឥតិ** ថាដូច្នេះ **វចនេ** នាកាលពាក្យ **អត្ថិ សាមិ ឥតិ** ថាដូច្នេះ **ភរិយាយ** គឺប្រពន្ធ **វុត្តេ** ពោលហើយ **សន្តិកំ** រឺវត្ថុជារបស់ **ភរិយាយ** នៃប្រពន្ធ **មេ** របស់យើង **នត្ថិ** មិនមាន **កឹ** ទេឬ ? **សាមិ** បពិត្រលោកប្ដី **សន្តកំ** រឺវត្ថុជារបស់ **តេ** នៃលោក **អត្ថិ** មាន ។

ឃ. លេខក្នុងជាប្រយោគទទួល ធានា បំពេញ

"**សម្បដិច្ឆិត្វា**" ក្នុងពេលដែលលេខក្នុង មានបទថា "**សាធុ**" ត្រឹមមួយបទ ជួនកាលមាន **អាលបន:** នៅជាមួយក្រោយ **ឥតិ**-សព្ទ មិនមានកិរិយា អព្ភន្តរកិរិយាទេ ហៅថា **អព្ភន្តរ-កិរិយា** គឺកិរិយា ដែលប្រកបដោយ **អន្ត មាន** ជួនកាល **ត** ម្តងៗ ដែរ ប៉ុន្តែមិនមែនជាកិរិយាគ្រប់គ្រងប្រយោគទេ ដូចជា **សោ សាធូតិ** (**សម្បដិច្ឆិត្វា**) **តេសំ សំវិទហិ** គេទទួលថា ល្អ ហើយ ទើបចាត់ចែងថ្នាំ (ធ.ប.១ ទំព័រ២៩) ។

ង. លេខក្នុងជាប្រយោគកត់សំគាល់ ថែម "**មនសិការ-េន**" ក្នុងពេលដែលនឹកគិតធ្វើ ព្រមគ្នានឹងកិរិយាក្រោយ ដូចជា **យថាយំ** ។បេ។ **អយំ អត្តភាវោ បិ ឧប្បាទវយត្តេន ឯវរូបោតិ មនសិការេន មរីចិកម្មដ្ឋានំ ភាវេន្តោ** ។បេ។ ចម្រើនកម្មដ្ឋានព្រមគ្នានឹងការធ្វើទុកក្នុងចិត្តយ៉ាងនេះ (ធ.ប .៣ ទំព័រ៥) ។

ច. លេខក្នុងជាប្រយោគសំដែងសេចក្តីសង្ឃឹម, ប៉ុនប៉ង, ប្រាថ្នា ថែម "**អាសាយ**" ក្នុងពេលដែលប្រយោគលេខ-ក្នុងសំដែងសេចក្តីសង្ឃឹមដល់រឿងខាងមុខ មានកិរិយា

សព្ទ ជាភវិស្សន្តិវិភត្តិ បញ្ជាក់នូវអនាគតកាល ភាគច្រើន កិរិយាក្រោយ **ឥតិ**-សព្ទ សំដែងដល់ការធ្វើដំណើរ ដូចជា "មក, ទៅ" ចូលទៅធ្វើដើម្បីបំណងរបស់ណាមួយ ដូចជា **សត្ថារំ បស្សិស្សាមាតិ** (**អាសាយ**) **ជេតវនំ អាគន្ត្វា** ។បេ។ មកកាន់វត្តជេតពនដោយបំណងយ៉ាងនេះ (ធ.ប.១ ទំព័រ ២៧) ។

ឆ. លេខក្នុងជាប្រយោគសំដែងការយល់ឃើញ បំពេញ "**សញ្ញាយ**" ក្នុងការដែលប្រយោគលេខក្នុងសំដែង ការកាត់ស្មាន បញ្ចេញយោបល់ ឬ យល់ថានឹងត្រូវជាយ៉ាងនេះ ដូចជា **ភស្សចិ អផាសុកំ ភវិស្សតីតិ** (**សញ្ញាយ**) **សកសកដ្ឋានេហិ និក្ខមិត្វា វិហារមជ្ឈេ សន្និបតឹសុ** ចេញចាកទីអាស្រ័យរបស់ខ្លួនៗ ដោយការសំគាល់ថា ភាពមិនសុខសាន្តនឹងមានដល់នរណាមួយ (ធ.ប.២ ទំព័រ ២០១) ។

បទនាមនាមនៅជាមួយ "**ឥវ, វិយ**" ដែលប្រែក្នុងឋានៈជាប្រធាន "បីដូចជារី" ក្នុងឋានៈ វិសេសនៈ (បីដូចជា) បើមិនមានកិរិយាសព្ទរបស់បទឧបមាដាក់ជាមួយទេ ត្រូវ

ថែមកិរិយាសព្ទចូលមក ដោយប្រើធាតុក្នុងប្រយោគ ឧបមេយ្យ នោះផ្សំជា មួយ **អន្ត** ឬ **មាន**-បច្ច័យ ឲ្យមានលិង្គ វចនៈ វិភត្តិ ស្មើដោយនាមនាមបទនោះ ដូចជា **តណ្ហាយ មូលំ ខនថ ឧសីរត្ថោវ វីរណំ** (**ខនន្តោ**) លោកទាំងឡាយ ចូរជីកនូវ ឫស នៃតណ្ហាដូចជាបុគ្គលដែលត្រូវការដោយ ស្បូវ (កាលជីក) នូវស្មៅអណ្ដាស (ធ.ប.៨) ។

## **ការយោគប្រធាន, ការថែមប្រធាន, ការឡើងប្រធាន**

ការយោគប្រធានពន្យល់ពាក្យវិសេសនសព្វនាមដែល រៀងទុកជំនួសបទប្រធានដូចជាបុំលិង្គ **សោ**, ឥត្ថីលិង្គ **សា**, នបុំសកលិង្គ **តំ** ឲ្យយោគនាមនាមក្នុងប្រយោគខាងមុខមក ជាប្រធាន និងប្រកបឲ្យមានលិង្គវចនៈវិភត្តិស្មើគ្នា ដោយ វិសេសនសព្វនាម ដូចជា **សោ បុរិសោ**, **សា ឥត្ថី**, **តំ កុលំ** ។

បើនាមនាមនោះ មានលិង្គផ្សេងពីវិសេសនសព្វនាម ឲ្យប្រើសព្វស្កាត់មកបន្ត ដូចជា **តំ សទ្ធជាតំ** ។

### **ពន្យល់**

**តំ** បើកាលណាយោគ "**សទ្ធោ**" មិនត្រូវ ពីព្រោះ **សទ្ធ** ជាបុំលិង្គ បើថែម **ជាតំ** ហើយថា សព្វស្កាត់កុំឲ្យនៅ បុំលិង្គ

ដដែល ឲ្យទៅជានបុំសកលិង្គវិញ ទៅជា **សទ្ធជាតំ**, ចុះបើទៅជា **សា សទ្ធោ** កើតឬទេ ? មិនកើតទេ, **សា សទ្ធជាតិ** ហៅថាសព្ទស្អាត់ៗ នាមបុំលិង្គទៅជាឥត្ថីលិង្គ ទៅជានបុំសកលិង្គ ចុះបើសព្ទហ្នឹងជាឥត្ថីលិង្គ ចង់ទៅជាបុំលិង្គវិញ ថែម **តាច**-សព្ទ មកទៅជា **តាចោ** ។

ការថែមប្រធានក្នុងប្រយោគ ដែលមិនមានប្រធាន មានតែកិរិយាសព្ទ **ត**, **អន្ត**, **មាន**-បច្ច័យ ប្រកបជាមួយបឋមាវិភត្តិ និងមាននាមសព្ទ នៅជាមួយកិរិយា ប្រចាំប្រ-យោគ ជាបឋមបុរិស ឲ្យថែមប្រធានដោយប្រែបញ្ចូល **បុគ្គល**-សព្ទ ដូចជា **បរលោកំ គច្ឆន្តំ អនុគច្ឆន្តោ នាម នត្ថិ** ប្រែថា **អនុគច្ឆន្តោ នាម** ឈ្មោះថាវីបុគ្គលកំពុងទៅតាម (**បុគ្គលំ**) នូវបុគ្គល **គច្ឆន្តំ** កាលទៅ **បរលោកំ** កាន់បរលោក **នត្ថិ** មិនមាន ។

ការឡើងប្រធានវិភត្តិ ពួកមជ្ឈិមបុរិសៈ ឧត្តម បុរិសៈ ឡើងប្រធាន ដូច្នេះ : **សិ ហិ** ឡើង **ត្វំ**, **ថ** ឡើង **តុម្ហេ** ។

**មិ** ឡើង **អហំ**, **ម** ឡើង **មយំ** ។

១. លេខក្នុងនិយាយអំពី ដំណឹង ទះដៃ ឃោសនា វាយស្គរ ឲ្យបំពេញ "**ញាបនហេតុកំ**" ខាងក្រោយ **ឥតិ** សព្ទ របស់លេខក្នុង ដូចជា **ថេរោ** ។បេ។ **តវ បមាណំ ន ជានាសិ** **តិ** (**ញាបនហេតុកំ**) **អច្ឆរំ បហរិ** (ធ.ប.៥) ។

២. **កិមង្គំ បន បគេវ** ថែមប្រយោគមុខចូលមកតាម គោលនេះ :

ចំពោះបទនាមប្រយោគមុខ ដែលប្រកបជាមួយវិភត្តិ ដូចគ្នានឹងបទ នាមនាម ដែលមានរួចហើយខាងក្រោយ **កិមង្គំ បន** ឬ **បគេវ** មិនបាច់ថែមចូលមកទេ។

ប្រកបកិរិយាគ្រប់គ្រងប្រយោគ ឲ្យជា ភវិស្សន្តិវិភត្តិ ។ បើកិរិយាគ្រប់គ្រង ប្រយោគមុខ ពោលបដិសេធឲ្យថែមចូល មក ក្នុងរូបកិរិយាសព្ទវាយ បើកិរិយាគ្រប់គ្រងប្រយោគមុខ វាយ ឲ្យថែមចូលមកក្នុងរូប កិរិយាសព្ទបដិសេធផ្ទុយគ្នា ដូច្នេះ ជានិច្ច ដូចជា **កិមង្គំ បន** ឧទាហរណ៍ : **ន វសេ វត្តន្តិ**, **កិមង្គំ បន ញាតកា** (**វសេ វត្តិស្សន្តិ**) ។ **បគេវ** ឧទាហរណ៍

**ចតូសុ បន ទីបេសុ ចក្កវត្តិសិរឹ ទាតុំ  សមត្ថា មាតាបិតរោ នាម បុត្តានំ នត្ថិ, បគេវ ទិព្វសម្បត្តឹ វា បឋមជ្ឈានាទិ-សម្បត្តឹ វា** (**ទាតុំ សមត្ថា មាតាបិតរោ នាម បុត្តានំ តវិស្សន្តិ**) ។

ប្រយោគ **នាគសោណ្ឌិ** ជ្រើសរើសថែមបាន វិធីពីរ យ៉ាងគឺ :

ក. កាលបើប្រែប្រយោគ **នាគសោណ្ឌិ** ចប់ហើយ ឲ្យ ថែម **យស្មា តស្មា** ព្រមជាមួយប្រយោគខាងមុខ ដូចជា **សយមានោ ន គច្ឆាមិ, នត្ថិ ពាលេ សហាយតា យស្មា តស្មា** (**សយមានោ ន គច្ឆាមិ**) (ធ.ប.១ ទំព័រ២៣) ។

ខ.កាលបើមិនបានប្រែប្រយោគនាគសោណ្ឌិទេ ឲ្យ ថែម (**ហិ** ព្រោះថា) ដូចជា **សយមានោ ន គច្ឆាមិ** (**ហិ**) **នត្ថិ ពាលេ សហាយតា ។ អហំ** រីអាត្មា **សយមានោ** កាលដេក **ន គច្ឆាមិ** មិនទៅទេ **សហាយតា** រីភាពនៃសម្លាញ់ **ពាលេ** និមិត្ត បុគ្គលពាល **នត្ថិ** មិនមានទេ **យស្មា** ព្រោះហេតុណា **តស្មា** ព្រោះហេតុនេះ **អហំ** រីយើង **សយមានោ** កាលដេក (ស្លាប់ក៏

ដោយ) **ន គច្ឆាមិ** មិនទៅ (ជាមួយអ្នកទេ) ។ មួយបែបទៀត ក៏ឈ្មោះនាគសោណ្ឌិដែរ ដោយមិនបាច់បញ្ចូលច្រើនថែម តែ **ហិ** មួយមកថា **អហំ** រីយើង **សយមានោ** កាលដេក **ន គច្ឆាមិ** មិនទៅទេ (**ហិ** ព្រោះថា) **សហាយតា** រីភាពនៃខ្លួនជាសម្លាញ់ (ខ្លះប្រែថារីសហាយតាគុណ) **ពាលេ** និមិត្តបុគ្គលពាល **នត្ថិ** មិនមានទេ ។

ប្រយោគដែលមានបទថា **ខមនីយំ** ឲ្យបំពេញបទទាំងនេះចូលមក : (**សរីរយន្តំ** រីយន្តគឺសរីរៈ **ចតុចក្កំ** មានកង់ ៤ **នវទ្វារំ** មានទ្វារ៩) ដូចជា **មម បុត្តស្ស មហាកស្សបស្ស ខមនីយំ** រីយន្តគឺសរីរៈ មានកង់ ៤ មានទ្វារ ៩ ដែលព្រះមហាកស្សបៈ ជាបុត្ររបស់តថាគត គួរអត់ទ្រាំបានឬ ? (ធ.ប.៣) ។

ប្រយោគដែលមានបទថា **យថាហ** ឲ្យបំពេញ "ធម្មសង្គាហកត្ថេរោ" ដូចជា **យថាហ អហំ ខោ អាភិញ្ញោ ។បេ។ ទូបកដ្ឋោ វិហរេយ្យន្តិ** (ធ.ប.១) ។

ប្រយោគដែលមានបទថា **ឯតទគ្គំ យទិទំ** ឲ្យថែម (**ខន្ធបញ្ចកំ**) ចូលមកដូចជា **ឯតទគ្គំ** (**ខន្ធបញ្ចកំ**) **ភិក្ខវេ មម សាវិកានំ ឧបាសិកានំ ធម្មកថិកានំ, យទិទំ** (**ខន្ធបញ្ចកំ**) **ខុជ្ជុត្តរា** (ធ.ប.២) ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **ខន្ធបញ្ចកំ** រឺខន្ធបញ្ចក: **ឥទំ** នេះ **យំ** ឯណា **ខុជ្ជុត្តរា** គឺនាងខុជ្ជុ-ត្តរា **ខន្ធបញ្ចកំ** រឺខន្ធបញ្ចក: **ឯតំ** នេះ **អគ្គំ** ប្រសើរលើស **ឧបាសិកានំ** ជាងឧបាសិកាទាំងឡាយ **សាវិកានំ** ជាសាវិកា **មម** របស់តថាគត **ធម្មកថិកានំ** អ្នកសំដែងនូវធម៌។

ប្រយោគដែលមានបទថា **សាធុ** ត្រឹមមួយបទ ឬពីរបទ ឲ្យថែម **តុម្ហេហិ វុត្តវចនំ** ឬ **តយា វុត្តវចនំ** (ចូលមក) **សាធុ** ញ៉ាំងប្រយោជន៍ឲ្យសម្រេច ដូចជា **កុម្ភការោ សាធូតិ សម្បដិច្ឆិ** ទទួលព្រមហើយ **សាធុ ឥតិ** ថា **សាធុ** ដូច្នេះ (ធ.ប. ២ទំ ព័រ៣៦) ។

ប្រយោគដែលមានបទថា "**កាលោ**, វេលា" តែមិនមានប្រធានឲ្យថែម "**អយំ កាលោ, អយំ វេលា**" ចូលមក ដូចជា **កាលោ អាវុសោ** (**អយំ កាលោ**) (ធ.ប.១ ទំព័រ១៧) **អយំ**

**វេលា ខាទនស្ស ភោជនវេលា** (ធ.ប.៤) ។

**អាវុសោ** រីលោកដ៏មានអាយុទាំងឡាយ **អយំ កាលោ** រីកាលនេះ **កាលោ ហោតិ** រមែងជាកាលគួរ ។ **អយំ វេលា** រីវេលានេះ **ខាទនស្ស ភោជនវេលា ហោតិ** ជាពេលជាទីស្រាយនូវដំបៅ ។

បទសមាសដែលមានសព្ទថា វត្ថុ នៅខាងចុងបំផុតនៃរឿងនិទានឲ្យថែម **និដ្ឋិតំ** ចូលមកដូចជា **ចូឡេកសាដកវត្ថុ** រឿងរ៉ាវនៃ ចូឡេកសាដកព្រាហ្មណ៍ **និដ្ឋិតំ** ចប់ហើយ **ឥតិ** ដូច្នេះឯង (ធ.ប.៥) ។

## ការប្រែសព្ទ

ក្នុងគម្ពីរអភិធម្មត្ថវិភាវិនីដីកា និងគម្ពីរបទរូបសិទ្ធសំដែងទុកថា **អត្ថិ សក្កា លព្ភា ឥច្ចេតេ បឋមាយំ** ប្រែសព្ទទាំងឡាយនេះ គឺ **អត្ថិ សក្កា លព្ភា** ជាបឋមាវិភត្តិ សិក្ខាកាមមិនត្រូវសង្ស័យថា មកពីធាតុវិភត្តិបច្ច័យអ្វីទេ ព្រោះជា **អព្យយ**-សព្ទ អាចចូលជាបទសមាសក៏បាន ដូចជា **អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ អហោសិកម្ម** អាចជាអព្យយៈហើយ អាចផ្សំចូល

ជាមួយនឹងសមាសក៏បាន ។

## សក្កាមានលក្ខណៈ ៤ យ៉ាង គឺ

**១. សក្កា** ជាប្រធានក្នុងករណី ដែលសេចក្តីរបស់ **សក្កា** នោះ មិនមាននាមនាម ដែលអាចជាប្រធានបាន ប៉ុន្តែមានកិរិយាអាខ្យាតជាបឋមបុរិស គ្រប់គ្រងប្រយោគ ក្នុងសេចក្តីនោះ ត្រូវឡើងបទអនភិហិតកត្តាមកជួយជានិច្ច ដូចជា **តត្ថ នំ អាគតំ គហេតុំ សក្កា តថិស្សតិ** (ធ.ប.២ទំព័រ៥៩) **តត្ថ** (ឋានេ) **នំ** (រាជានំ) **អាគតំ គហេតុំ តយា សក្កា** រី កិរិយាគឺព្រះអង្គអាចដើម្បី ចាប់នូវព្រះរាជាអង្គនោះ ដែលមកហើយ ក្នុងទីនោះ នឹងមាន ។

**យត្តកេន ឱលោកេតុំ សក្កា ហោតិ** (ធ.ប.២ ទំព័រ៨៦) **យត្តកេន** (ឆិទ្ទេន) **ឱលោកេតុំ** (តុម្ហេហិ) **សក្កា** រីកិរិយាគឺនាងទាំងឡាយ អាចដើម្បីក្រលេកមើលតាម ប្រហោងមានប្រមាណប៉ុណ្ណា តែងមាន។

**២. សក្កា** ជាកិរិយាកម្មវាចកៈ ក្នុងសេចក្តីរបស់ **សក្កា** បើមាននាមនាមជាតួកម្ម ចូលនិង **តុំ**-បច្ច័យ បទនាមនាម

នោះ ប្រកបដោយបឋមាវិភត្តិ, **សក្កា** ក្នុងទីនេះចាត់ជាកិរិយាកម្មវាចកៈ ប្រែតាមលក្ខណៈរបស់កម្មវាចកៈ គ្រប់ប្រការ ដូចជា **ន សក្កា សោ អគារមជ្ឈេ ឋបេតុំ** ប្រែថា **សោ ធម្មោ** រីឯមិនោះ (**មយា** គឺអញ) **ន សក្កា** មិនអាច **អាគារមជ្ឈេ ឋបេតុំ** ដើម្បីបំពេញក្នុងកណ្តាលនៃផ្ទះបានទេ។

**៣. សក្កា** ជាកិរិយាភាវវាចកៈ ក្នុងសេចក្តីរបស់ **សក្កា** ដែលមានអកម្មធាតុ ប្រកបជាមួយ **តុំ**-បច្ច័យ ឬសកម្មធាតុ ប៉ុន្តែបទកម្មប្រកបដោយទុតិយាវិភត្តិ សេចក្តីរបស់ **សក្កា** នោះចាត់ជាភាវវាចកៈ ប្រែតាមលក្ខណៈ របស់ភាវវាចកៈ ដូចជា **ន សក្កា ឯកេន សទ្ធឹ ឯកតោ ភវិតុំ** ប្រែថា **មយា** គឺយើង **ន សក្កា** មិនអាច **ឯកេន រញ្ញា សទ្ធឹ ឯកតោ ភវិតុំ** ដើម្បីមានក្នុងទីជាមួយគ្នា មួយអន្លើដោយព្រះរាជាអង្គនេះបានទេ ។ **ន សក្កា វិហារំ កុច្ឆំ កាតុំ** (ធ.ប.៤ ទំព័រ៨៨) **មយា** គឺយើង **ន សក្កា** មិនអាច **វិហារំ កុច្ឆំ កាតុំ** ដើម្បីធ្វើនូវវិហារឲ្យទទេបានទេ ។

**៤. សក្កា** ជាវិកតិកត្តាក្នុងសេចក្តីរបស់ **សក្កា** នោះមាន

នាមនាមជាប្រធាន ប្រកបបឋមាវិភត្តិ និងមានធាតុដែលប្រែថា "កើត, មាន, ជា" នៅជាមួយ អាចជាកិរិយាតូច ឬកិរិយាធំ ក៏បាន ។ **សក្កា** ក្នុងសេចក្ដីនេះចាត់ជាវិកតិកត្តា ត្រូវឡើង បទអនភិហិតកត្តាមកផង ដូចជា **សចេ ឯតេ រូបិនោ ហុត្វា កត្ថចិ បក្ខិបិតុំ សក្កា ភវេយ្យុំ** (ធ.ប.២ ទំព័រ២៣០) ប្រែថា **សចេ** ថាបើ **ឯតេ កិលេសា** រីកិលេសទាំងឡាយ នេះ **រូបិនោ ហុត្វា** ជាសភាវៈមានរូប **កត្ថចិ បក្ខិបិតុំ កេនចិ សក្កា ភវេយ្យុំ** គប្បី ជាសភាវៈគឺនរណាមួយអាចដើម្បីដាក់ចុះក្នុងទីណាមួយ ។

## ការប្រែ អលំ

**អលំ** ជាអព្យយសព្ទរូបដើមយ៉ាងណា ក៏គង់នៅយ៉ាងនោះ ចុះក្នុងអត្ថបឋមាវិភត្តិ ក្នុងគម្ពីររូបសិទ្ធិ សំដែងទុកថា ចំណែកនិបាតបទថា **ន នោ មា អ អលំ ហលំ ឥច្ចេតេ បដិសេធនត្ថេ** ចុះក្នុងសេចក្ដីបដិសេធ ។ ចំពោះ **អលំ** ចុះក្នុងអត្ថ ៣ យ៉ាងដូច្នេះគឺ :

**១. បដិសេធនត្ថៈ** ប្រើបដិសេធជាប្រធាន ប្រែថា "រីកុំ

ឡើយ, រីល្មមហើយ" បើប្រើជាកិរិយាធំ ប្រែថា "មិនគួរ" ដូច ជា **សត្ថា អលំ ឯត្តកេន ឥមស្សាតិ បក្កាមិ** ប្រែថា **សត្ថា** រី ព្រះសាស្តា **បក្កាមិ** ស្តេចជៀសចេញទៅហើយ **ចិន្តនេន** ដោយព្រះតម្រិះ **អលំ** ។ល។ **ឥមស្ស ឥតិ** ថាដូច្នេះ **អលំ** រី ល្មមហើយ **ឥមស្ស មដ្ឋកុណ្ឌលិស្ស** ដល់ មាណពឈ្មោះមដ្ឋ-កុណ្ឌលិនេះ **ឯត្តកេន កម្មេន** ដោយកម្មមានប្រមាណ ប៉ុណ្ណេះ ។ **អលំ** ក្នុងប្រយោគនេះជាប្រធាន ប្រើក្នុងអត្ថ បដិសេធ ។ **អលំ ភិក្ខវេ មា ចិន្តយិត្ថ** (ធ.ប.៧ ទំព័រ១៩៩) ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **អលំ** រីកុំឡើយ **តុម្ហេ** រី លោកទាំងឡាយ **មា ចិន្តយិត្ថ** កុំគិតឡើយ ។ **អលំ** ក្នុងប្រ យោគនេះជាប្រធានប្រើ ក្នុងអត្ថបដិសេធ ។ **អធិវាសេត្វា ច អថ ខោ ភគវា វេរញ្ជំ ព្រាហ្មណំ អលំ យាវាសបលិពោ-ធចិន្តាយាតិ សញ្ញាបេត្វា** ។ ប្រែថា **ច** ក៏ **អថ ខោ** គ្រានោះ ឯង **ភគវា** រីព្រះមានព្រះភាគ **និមន្តនំ** ញ៉ាំងការនិមន្ត **អធិវាសេត្វា** ឲ្យនៅសង្កត់ហើយ **ព្រាហ្មណំ** ញ៉ាំងព្រាហ្មណ៍ **វេរញ្ជំ** ឈ្មោះវេរញ្ជៈ **សញ្ញាបេត្វា** ឲ្យដឹងព្រមហើយ "**អលំ**

**យាវាសមលិពោធចិន្តាយ**" **ឥតិ** ថាដូច្នេះ **តយា** គឺឯង **អលំ** មិនគួរ **យាវាសមលិពោធចិន្តាយ** ដើម្បីគិតនូវសេចក្តីខ្វល់ខ្វាយដោយការ នៅគ្រប់គ្រងនូវផ្ទះទេ ។

២. **បរិយត្ត** ប្រាប់សេចក្តីថាជារបស់សមគួរជានិបាតកិរិយាដូច **សក្កា** និង **អត្ថិ** ប្រើបានទាំងកិរិយាកម្មវាចកៈទាំងវិកតិកត្តា ប្រែថា "សមគួរ" ក្នុងអត្ថនេះថា **អលំ** ធ្វើនាទីបដិសេធក្នុង ប្រយោគដែលមាន **ន**-សព្ទ បដិសេធចូលមកផង មិនដូចបដិសេធ **នត្ថិ** ដែលមិនមាន **ន**-សព្ទទេ ដូចជា **នវហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា ច នាលំ ឧបគន្តុំ ឧបគន្ត្វា ច នាលំ ឧបនិសីទិតុំ** (ធ.ប.៣ ទំព័រ១៣) ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **កុលំ** វិត្រកូល **នវហិ អង្គេហិ សមន្នាគតំ** ដែលប្រកបព្រមហើយ ដោយអង្គទាំងឡាយ ៩ **ភិក្ខុនា** គឺភិក្ខុ **អនុបគន្ត្វា ឧបគន្តុំ ន អលំ ច** មិនទាន់ចូលទៅជិតហើយមិនគួរដើម្បីចូលទៅជិតផង **ឧបគន្ត្វា ឧបនិសីទិតុំ ន អលំ ច** លុះចូលទៅជិតហើយ មិនគួរដើម្បីអង្គុយជិតផង ។ **អលំ** ក្នុងប្រយោគនេះ ប្រើជាកិរិយាកម្ម-

វាចក: ។ **មម ធីតុ ឯត្តកា គាវោ អលំ** (ធ.ប.៣ ទំព័រ៩៤) ប្រែថា **គាវោ** រីគោទាំងឡាយ **ឯត្តកា** មាន ប្រមាណប៉ុណ្ណេះ **មម ធីតុ អលំ ហោន្តិ** ជាសត្វគួរដល់ធីតារបស់យើង ។ **អលំ** ក្នុងប្រយោគ នេះប្រើជាវិកតិកត្តា ។

**៣. ភូសនត្ថ** ចុះក្នុងអត្ថថា "ប្រដាប់តាក់តែង" បើតជាមួយនឹង **ករ**-ធាតុ ដូចជា **អលង្កតោ** "ប្រដាប់តាក់តែងហើយ", **អលង្កិត្វា** "ប្រដាប់តាក់តែងហើយ", **អលង្ករោតិ** "រមែងប្រដាប់តាក់តែង" ។ អាចារ្យខ្លះប្រែថា "ធ្វើឲ្យល្អម" ដូច្នេះ មិនត្រឹមត្រូវទេ បើប្រែថា "ធ្វើនូវការប្រដាប់តាក់តែង" ទើបសមរម្យជាង ។

## ការប្រែ លព្ភា

**លព្ភា** ប្រែថា "គប្បីបាន" ជានិបាតកិរិយាដូច **សក្កា** ចុះក្នុងអត្ថបឋមាវិភត្តិ មានពីរយ៉ាងគឺ :

**១. លព្ភា** ជានាមកិតក: សម្រេចមកពី **លភ + ណ្យ** សម្រេចរូបបុំលិង្គ **លព្ភោ**, ឥត្ថីលិង្គ **លព្ភា**, នបុំសកលិង្គ **លព្ភំ** ដូចជា **រញ្ញោ អាណា អកាតុំ ន លព្ភា** (ធ.ប.២ ទំព័រ១២២)

ប្រែថា **អាណា** វីអាជ្ញា **រញ្ញោ** របស់ព្រះរាជា **កេនចិ** គឺអ្នកណាមួយ **ន លព្ភា** មិនគប្បីបាន **អកាតុំ** ដើម្បីមិនធ្វើបានទេ ។ **លព្ភា** ក្នុងទីនេះជានាមកិតក: ត្រូវ មានលិង្គ វចន: វិភត្តិ ដូចនាមនាមជាបទប្រធានគឺ **អាណា** និង ជាកម្មវាចក: ។

**២. លព្ភា** ជានិបាតកិរិយា មិនអាចផ្លាស់ជានាមនាមដូចបទប្រធានទេ ។ សូមជ្រាបថា និបាតកិរិយាប្រើជា កិរិយាគ្រប់គ្រងប្រយោគបាន ដូចជា **បវេណិ រជ្ជំ នាម តាត ឥទំ ន លព្ភា ឯវំ កាតុំ** (ធ.ប.៣ ទំព័រ៩) ប្រែថា **តាត** នែបា **ឥទំ រជ្ជំ** វីរាជ្យនេះ **បវេណិ រជ្ជំ នាម ហោតិ** រមែងឈ្មោះថា ជាបវេណិរាជ្យ, **ឥទំ បវេណិរជ្ជំ** វី បវេណិរាជ្យនេះ **តយា** គឺឯង **ន លព្ភា** មិនគប្បីបាន **ឯវំ កាតុំ** ដើម្បីធ្វើយ៉ាងនេះទេ ។ **លព្ភា** ក្នុងសេចក្តីនេះជានិបាតកិរិយា ព្រោះគង់រូបនៅ ដូចដើម មិនផ្លាស់ តាមនាមនាមជាប្រធានគឺ **រជ្ជំ** ទេ ។ **តំ កុតោ លព្ភា** ប្រែថា **តុម្ហេហិ** គឺលោកទាំងឡាយ **លព្ភា** គប្បីបាន **តំ ទេយ្យធម្មំ** នូវទេយ្យធម៌នោះ **កុតោ ឋានតោ** អំពីទីណា, **លព្ភា** ក្នុងសេចក្តីនេះជានិបាតកិរិយា **ភាវវាចក:** ។ **តុំ**

**មាតាបិតូនំ ឯកបុត្តកោ, ន លព្ភា តយា បព្វជិតុំ** ប្រែថា **ត្វំ** រីឯង **មាតាបិតូនំ ឯកបុត្តកោ អសិ** ជាបុត្រតូចម្នាក់របស់មាតា និង បិតាទាំងឡាយ, **តយា** គឺឯង **ន លព្ភា** មិនគប្បីបាន **បព្វជិតុំ** ដើម្បីបួសបានទេ ។ ក្នុងសេចក្តីនេះ **តាត សុទិន្ន ឧត្តមំ អរិយធនំ បព្វជិតលិង្គំ បហាយ ហីនាយ គិហិភាវាយ អាវត្តិត្វា លព្ភា ភោគា ភុញ្ជិតុំ** ប្រែថា **តាត** ហៃបា **សុទិន្ន** ឈ្មោះសុទិន្ន **ភោគា** រីភោគទាំងឡាយ **តយា** គឺអ្នក **បហាយ** លះបង់ហើយ **បព្វជិតលិង្គំ** នូវភេទនៃបព្វជិត **ឧត្តមំ** ដ៏ខ្ពង់ខ្ពស់ **ឧត្តមំ** គឺថា **អរិយធនំ**ៗ ជាទ្រព្យរបស់ព្រះអរិយៈ **អាវត្តិត្វា** វិលមកហើយ **ហីនាយ** ដើម្បីភេទដ៏ថោកទាប **ហីនាយ** គឺថា **គិហិភាវាយ**ៗ ដើម្បីភាពនៃគ្រហស្ថ **លព្ភា** គប្បីបាន **ភុញ្ជិតុំ** ដើម្បីបរិភោគ ។ ក្នុង សេចក្តីនេះ បទកម្មគឺ **ភោគា** ជាបទប្រធាន ត្រូវប្រែជា កម្មវាចកៈ ។

## ការប្រែ សម្ភាវនៈ

**សម្ភាវនៈ** ប្រែថា ការលើកឡើងពោល បានដល់ការលើកយកបទពីរដែលផ្សេងគ្នាឲ្យមានសេចក្តីដូចគ្នាតែមួយ

មានពីរយ៉ាងគឺ :

១. ក្នុងប្រយោគកត្តុវាចកៈ បទកម្មប្រកបទុតិយាវិភត្តិ បទសម្ពាវនៈ ក៏ប្រកបទុតិយាវិភត្តិដែរ ដូចជា **តមហំ ព្រូមិ ព្រាហ្មណំ** (ធ.ប.៨ ទំព័រ២៦៣) ប្រែថា **អហំ** រីតថាគត **ព្រូមិ** តែងហៅ **តំ បុគ្គលំ** នូវបុគ្គលនោះ **ព្រាហ្មណំ** ថាជាព្រាហ្មណ៍ ។ **បុគ្គលំ** ជាបទកម្ម **ព្រាហ្មណំ** ជាបទ សម្ពាវនៈ ពង្រីកតួកម្មក្នុងប្រយោគកត្តុវាចកៈ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ប្រែថា **អហំ** រីខ្ញុំ **គច្ឆាមិ** សូមដល់ **ពុទ្ធំ** នូវព្រះពុទ្ធ **សរណំ** ថាជាទីរលឹក ។ **ពុទ្ធំ** ជាតួកម្មក្នុងប្រយោគកត្តុវាចកៈ ប្រកបដោយទុតិយាវិភត្តិ **សរណំ** ជាតួ **សម្ពាវនៈ** ប្រកបទុតិយាវិភត្តិដែរ បានសេចក្តីថា **អវុត្តកម្ម** ដែលប្រែថា "នូវ" គឺជាតួកម្ម ។

២. ក្នុងប្រយោគកម្មវាចកៈ បទកម្មប្រកបបឋមាវិភត្តិ ព្រោះកម្មវាចកៈត្រូវ លើកយក បទកម្មជាប្រធាន ដូច្នេះបទសម្ពាវនក៏ត្រូវប្រកបបឋមាវិភត្តិដែរ ដូចជា **អមតំ វុច្ចតិ និព្វានំ** (ធ.ប.២ ទំព័រ១១១) ប្រែថា **និព្វានំ** រីព្រះនិព្វាន

**ភគវតា** គឺព្រះមានព្រះភាគ **វុច្ចតិ** ទ្រង់ត្រាស់ហៅ **អមតំ** ថាជា អមតៈ ។

**បាបោបិ បស្សតិ ភទ្រំ យាវ បាបំ ន បច្ចតិ** (ធ.ប.៥ ទំព័រ២០) ប្រែថា **បាបំ** រីបាប **ន បច្ចតិ** មិនទាន់ឲ្យផល **យាវ** ដរាបណា **បាបោបិ** ឯរីបុគ្គលបាប **បស្សតិ** តែងឃើញ **តំ បាបំ** នូវបាបនោះ **ភទ្រំ** ថាជាកម្មដ៏ចម្រើន **តាវ** ដរាបនោះ ។ **តំ បាបំ** នេះជា បទកម្មក្នុងប្រយោគកត្តុវាចកៈ, **ភទ្រំ** ជាបទ **សម្ភាវនៈ** ប្រកបទុតិយាវិភត្តិតាមបទកម្ម ។

## ការប្រែ វិសេសលាភី

**វិសេសលាភី** គឺបទពង្រីកនាមនាមពិសេស គឺបទវិសេសនៈដែលធ្វើនាទី ពង្រីកនាមនាម ដោយច្រើនគឺប្រភេទគុណនាម ឬ ជានាមនាមដែលប្រើដូចជាបទគុណ ត្រូវមានលិង្គ វចនៈ ដូចបទនាមនាម ឬ មិនដូចគ្នាក៏បាន, មានពាក្យប្រែថា គឺ ដូចជា **យទេវ អវសិដ្ឋំ ហោតិ អង្គារោ វា បត្តំ វា តចោ វា** (ធ.ប.២ ទំព័រ១៩២) **យំ** + **ឯវ**, **យំ** ជានបុំសកលិង្គ បើដូច្នោះត្រូវបញ្ចូលបទជា នបុំសកលិង្គដែរ

ដូច្នេះ ត្រូវបញ្ចូលថា **យំ ឯវ រុក្ខជាតំ** រុក្ខជាតណាមែនពិត **អន្តោ វា** គឺបណ្ដូលឬ **មជ្ឈំ វា** ឬថាគឺស្លឹក **តចោ វា** ឬក៏គឺសម្បក **អវសិដ្ឋំ ហោតិ** ជារបស់សល់នៅហើយ ។ **រុក្ខជាតំ** ជាបទនាមនាមដែលត្រូវពង្រីក **អន្តោ មជ្ឈំ តចោ** មានលិង្គមិនដូច **រុក្ខជាតំ** តែត្រូវ ប្រកបវិភត្តិឲ្យ ដូចគ្នា គឺបឋមាវិភត្តិ ។ **ឯតេ ភិក្ខវេ ទ្វេ សហាយកា អាគច្ឆន្តិ កោលិតោ ច ឧបតិស្សោ ច** (ធ.ប.១) ប្រែថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ **សហាយកា** វិសម្លាញ់ទាំងឡាយ **ទ្វេ** ពីរនាក់ **ឯតេ** នុ៎ះ **កោលិតោ ច** គឺកោលិតៈមួយ **ឧបតិស្សោ ច** គឺឧបតិស្សៈមួយ **អាគចន្តិ** កំពុងមក ។ **សហាយកា** ជាបទនាមនាម **កោលិតោ** និង **ឧបតិស្សោ** ជាបទនាមនាមពង្រីក **សហាយកា**, **កោលិតោ** និង **ឧបតិស្សោ** មានលិង្គដូច **សហាយកា** តែវចនៈមិនដូចគ្នាទេ ។ **អហំ សោ ភន្តេតិ** (ធ.ប.២ ទំព័រ១២) **ទេវរាជា** វិទេវរាជ **អាហ** ពោលហើយ **អហំ សោ ភន្តេ ឥតិ** ថាដូច្នេះ **ភន្តេ** បពិត្រអ្នកម្ចាស់ដ៏ចម្រើន **សោ សហាយោ** វិសម្លាញ់នោះ **អហំ** គឺខ្ញុំ ។ **សហាយោ** ជាបទនាមនាម **អហំ** ជាបុរិស-

សព្វនាមវិសេសលាភី ។ **យស្ស ឯតា ធនា អត្ថិ ឥត្ថិយា វា បុរិស្ស វា** (ធ.ប.៣ ទំព័រ២១៥) ប្រែថា **ធនា** រីទ្រព្យទាំងឡាយ **ឯតា** នេះ **យស្ស** បុគ្គលស្ស របស់បុគ្គល ណា **ឥត្ថិយា វា** គឺស្ត្រីឬ **បុរិសស្ស វា** ឬថាគឺបុរស ។

## ការប្រែ ឥត្ថម្ភូត

**ឥត្ថម្ភូត** ប្រែថា "មានយ៉ាងនេះ, ជាយ៉ាងនេះ" បានដល់សេចក្តីដែលសំដែង ការមាន ការជា ជាអាកប្បកិរិយាយ៉ាងនោះ យ៉ាងនេះ របស់នាមនាម ក្នុងភាសាបាលី សេចក្តីដែលជា ឥត្ថម្ភូតប្រកបដោយតតិយាវិភត្តិមាន លក្ខណៈ ប្រែពីរប្រការគឺ :

១. ប្រែក្រោយនាមនាម ប្រែថា "មាន..." ដូចជា **តំខណញ្ញេវ រាជា ឧក្កាហិ ធារិយមានេហិ តត្ថ គន្ត្វា នារទំ វន្ទិត្វា ឯកមន្តំ និសិន្នោ អាហ** (ធ.ប.១ ទំព័រ៦០) ប្រែថា **តំ ខណំ ឯវ** ក្នុងខណៈ នោះឯង **រាជា** រីព្រះរាជា **ឧក្កាហិ** មានគប់ភ្លើងទាំងឡាយ **បុរិសេហិ ធារិយមានេហិ** គឺពាជបុរសទាំងឡាយកំពុងទ្រទ្រង់ទុក **គន្ត្វា** ស្តេចទៅហើយ **តត្ថ**

**ឋានេ** ក្នុងទីនោះ **វន្ទិត្វា** ថ្វាយបង្គំហើយ **នារទំ** នូវតាបស ព្រះនាមនារទ **និសន្នោ** គង់នៅហើយ **ឯកមន្តំ** ក្នុងទីដ៏សមគួរ **អាហ** ត្រាស់ហើយ ។

២. ប្រែក្រោយកិរិយា ប្រែថា "ដោយទាំង..." ដូចជា **អថ សោ ឥស្សរោ យថាធោតេន បត្តេនាគច្ឆន្តំ បច្ចេកពុទ្ធំ ទិស្វា វ វន្ទិត្វា អបិ ភន្តេ ភិក្ខំ លទ្ធត្ថ បុច្ឆិ** (ធ.ប.២ទំព័រ៦៦) ប្រែថា **អថ** គ្រានោះ **ឥស្សរោ ជនោ** រីជនជាអ្នកធំ **សោ** នោះ **យថាធោតេន បត្តេន អាគច្ឆន្តំ បច្ចេកពុទ្ធំ ទិស្វា វ** ឃើញហើយនូវព្រះបច្ចេកពុទ្ធ កំពុងនិមន្តមកដោយ ទាំងបាត្រគឺខ្លួនលាងហើយ យ៉ាងណាមែនពិត **វន្ទិត្វា** ថ្វាយបង្គំហើយ **បុច្ឆិ** សួរហើយ **អបិ ភន្តេ** ។ល។ **លទ្ធំ ឥតិ** ថាដូច្នេះ **ភន្តេ** បពិត្រលោក ម្ចាស់ដ៏ចម្រើន **ភិក្ខំ ភោជនំ** រីភោជនណាមួយ **តេន** គឺលោកម្ចាស់ **លទ្ធំ** បានហើយ **អបិ** ខ្លះដែរឬ ? **សា ថនេហិ ខីរំ មុញ្ចន្តេហិ ឧដ្ឋហិត្វា អល្លចីវរា គន្ត្វា ថេរំ គណ្ហិ** (ធ.ប.៦ ទំព័រ២១) ប្រែថា **សា ភិក្ខុនី** រីភិក្ខុនីនោះ **ឧដ្ឋហិត្វា** ក្រោកឡើងហើយ **ថនេហិ** ដោយទាំងដោះទាំងឡាយ **ខីរំ**

**មុញ្ចន្តេហិ** កំពុងហូរចេញនូវទឹកដោះស្រស់ **អល្លចីវរា ហុត្វា** ជាអ្នកមានចីវរទទឹក **គន្ត្វា** ទៅហើយ **គណ្ហិ** ចាប់ហើយ **ថេរំ** នូវព្រះថេរៈ ។

## ការប្រែ បគេវ

**បគេវ** មកពី **បា + ឯវ**, ចុះ **គ**-អាគម, រស្ស: **អា** របស់ **បា**, **អ** ជានិបាតប្រាប់កាល ប្រែថា "មុនមែនពិត, មុននោះឯង" ។

ប្រែតាមសព្ទ ត្រូវឡើងតួប្រធាន និង កិរិយាអាការរបស់ប្រយោគមុខមកផង ដូចជា **សាមណេរំ ហិ តស្មឹ កាលេ សិនេរុនា អវត្ថរន្តោបិ មារេតុំ សមត្ថោ នាម នត្ថិ** នេះជាប្រយោគមុខ **បគេវ អសិនា** នេះជាប្រយោគក្រោយ ប្រែថា **ហិ** ក៏ **បុគ្គលោ** រីបុគ្គល **សិនេរុនា អវត្ថរន្តោបិ** សូម្បីកាលសង្កត់ដោយភ្នំសិនេរុ **សាមណេរំ តស្មឹ កាលេ មារេតុំ សមត្ថោ នាម** ជាអ្នកឈ្មោះថាអាចដើម្បី ញ៉ាំងសាមណេរឲ្យស្លាប់ ក្នុងកាលនោះ **នត្ថិ** មិនមាន **បគេវ** នឹងបាច់ពោលទៅថ្វី **បុគ្គលោ** រីបុគ្គល **សាមណេរំ តស្មឹ កាលេ អសិនា**

**មារេតុំ សមត្ថោ នាម តវិស្សតិ** និងជាអ្នក ឈ្មោះថាអាច ដើម្បីញ៉ាំងសាមណេរឲ្យស្លាប់ ដោយដាវក្នុងកាលនោះបាន ។ **ចតូសុ បន ទីបេសុ ចក្កវត្តិសិរឹ ទាតុំ សមត្ថា មាតាបិតរោ នាម បុត្តានំ នត្ថិ** និងជាប្រយោគមុខ **បគេវ ទិព្វសម្បត្តឹ វា បឋមជ្ឈានាទិសម្បត្តឹ វា** (ធ.ប.២ ទំព័រ២៦៣) ប្រែថា **បន** ក៏ **មាតាបិតរោ នាម** ឈ្មោះថាមាតា និង បិតាទាំងឡាយ **ចតូសុ ទីបេសុ ចក្កវត្តិសិរឹ ទាតុំ សមត្ថា** ជាអ្នកអាចដើម្បីឲ្យនូវសិរីគឺភាវជាស្តេចចក្រពត្តិក្នុង ទ្វីបទាំងឡាយ ៤ **នត្ថិ** មិនមាន **បុត្តានំ** ដល់កូនទាំងឡាយ **បគេវ** នឹងបាច់ពោលថ្វីមាតាបិតរោ រីមាតា និង បិតាទាំងឡាយ **ទិព្វសម្បត្តឹ វា បឋមជ្ឈានាទិសម្បត្តឹ វា ទាតុំ សមត្ថា** ជាអ្នកអាចដើម្បី ឲ្យនូវទិព្វសម្បត្តិឬ ឬថានូវសម្បត្តិ នៃឈាន មានបឋមជ្ឈានជាដើម **នត្ថិ** តែងមិនមាន ។

## ឥតិ សព្ទ

**ឥតិ** សព្ទមានឈ្មោះ ៨ យ៉ាងតាមលក្ខណៈ ដែលចុះក្នុងអត្ថនោះៗ ដូច្នេះ :

ក. បៀមសេចក្តីដែលជាពាក្យទុកពេញទី មានសេចក្តីជាប់ជាមួយនឹងកិរិយាធំ ឬ កិរិយាតូច ប្រែថា "ដូច្នេះ" ហៅថា **អាការៈ** ។

**ឥធ វស្សំ វសិស្សាមិ, ឥធ ហេមន្តគម្ហេសុ, ឥតិ ពាលោ វិចិន្តេតិ, អន្តរាយំ ន ពុជ្ឈតិ** ប្រែថា **ពាលោ** រីជនពាល **វិចិន្តេតិ** រមែងគិតខុស **ឥធ** ។ល។ **ហេមន្តគិម្ហេសុ ឥតិ** ថាដូច្នេះ **ន ពុជ្ឈតិ** តែងមិនដឹង **អន្តរាយំ** នូវសេចក្តីអន្តរាយ ។

ខ. មានសេចក្តីជាប់ជាមួយនឹងបទនាម រួមសេចក្តីទុកខាងក្នុង ប្រែថា "គឺ" ឬ "ដូច្នេះ" ហៅថា **សរូបៈ** ខាងអាការៈគឺចូលនឹងកិរិយាតូច និង កិរិយាធំ, តែដល់ សរូបៈ គឺប្រែថា "គឺ" ឬ "ដូច្នេះ" ដែរ ប៉ុន្តែចូលជាមួយ នឹងបទនាម ។

**មនោ បុព្វង្គមាធម្មា មនោសេដ្ឋា មនោមយា មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា តតោនំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទន្តិ អយំ ធម្មទេសនា ភគ្គ ភាសិតា** ប្រែថា **ធម្មទេសនា** រីព្រះធម៌ទេសនា **អយំ** នេះ **មនោ បុព្វង្គមា**

។ល។ **ចហាតោ បទំ ឥតិ** ថាដូច្នេះ **ភគវតា** គឺព្រះមានព្រះភាគ **ភាសិតា** ទ្រង់សម្តែងហើយ **កត្ថ ឋានេ** ក្នុងទីណា ។

គ. បង្កប់សេចក្តីទុកមិនទាន់អស់ នៅមានតទៅទៀត ប្រែថា "មានបទថា ដូច្នេះជាដើម, មានដូច្នេះជាដើម" ហៅថា **អាទ្យត្ថៈ** ។

**អក្កោច្ឆិ មំ អវធិ មន្តិ ឥមំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ តិស្សត្ថេរំ អារព្ភ កថេសិ** ប្រែថា **សត្ថា** រីព្រះជាគ្រូ **វិហរន្តោ** កាលគង់នៅ **ជេតវនេ** ក្នុងវត្តជេតពន **អារព្ភ** ទ្រង់ប្រារព្ធ **តិស្សត្ថេរំ** នូវព្រះថេរៈឈ្មោះតិស្ស **កថេសិ** ទ្រង់សម្តែងហើយ **ធម្មទេសនំ** នូវធម្មទេសនា **ឥមំ** នេះ **អក្កោច្ឆិ មំ ឥតិ** មានបទថាដូច្នេះជាដើម ។

ឃ. បើរៀងទុកល្មម ឲ្យថាជាបែបធៀប ហៅថា **និទស្សនៈ** ។ **ឥតិ** សព្ទនេះ ច្រើនតែរៀង ទុកខាងដើមសព្ទដទៃតែមួយបទប៉ុណ្ណោះ វេលាប្រែ ត្រូវបញ្ចូលគ្រប់ បទទាំងអស់ ហើយសម្ពន្ធ ឥតមានចូលជាមួយនឹងបទណាឡើយ ដូចជា **ឥតិ បិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ** ប្រែថា

**ភគវា** រីព្រះមានព្រះភាគ **សោ** អង្គនោះ **អរហំ ហោតិ** ព្រះអង្គជាព្រះអរហន្ត **ឥតិបិ** ព្រោះហេតុដូច្នេះមែន, **ភគវា** រីព្រះមានព្រះភាគ **សោ** អង្គនោះ **សម្មាសម្ពុទ្ធោ ហោតិ** ព្រះអង្គទ្រង់ត្រាស់ដឹងឯងដោយប្រពៃ **ឥតិបិ** ព្រោះហេតុដូច្នេះមែន ។

ង. បើ **ឥតិ**-សព្ទដែលចុះក្នុងរូបវិគ្គហៈ ហៅថា **ហេត្វត្ថៈ** ប្រែថា "ព្រោះហេតុដូច្នោះ, ឬ ហេតុដូច្នោះ" ។ **សហ ភរិយាយ យោ វត្តតីតិ សភរិយោ** (**បុរិសោ**) ប្រែថា រីបុរសឯណាប្រព្រឹត្តទៅមួយអន្លើដោយភរិយា ព្រោះហេតុដូច្នោះ បុរសនោះឈ្មោះ **សភរិយោ** បុរសអ្នកប្រព្រឹត្តទៅ មួយអន្លើដោយភរិយា **សហ សង្គម្ម វា ភាសន្តិ ឯត្ថាតិ សភា** (**សាលា**) ប្រែថា **ជនា** រីជនទាំងឡាយ **ភាសន្តិ** តែងពោល **សហ វា** ព្រមគ្នាឬ **សង្គម្ម វា** ឬថាព្រមព្រៀងគ្នា **ឯត្ថ សាលាយំ** ក្នុងសាលាន៊ុះ **ឥតិ** ព្រោះហេតុដូច្នោះ **សា សាលា** រីសាលានោះ **សភា** ឈ្មោះថាជាទីពោលព្រមព្រៀងគ្នា ។

ច. បើជាប្រការដែល ប្រែថា "ដោយប្រការដូច្នេះ" នេះ ហៅថា **បការៈ**, **ឥតិ** សព្ទនេះ ច្រើនតែរៀងនៅខាងដើម

ប្រយោគ ហើយវេលាប្រែ ត្រូវប្រែក្រោយគេបំផុត ដូចជា **ឥតិ យន្តំ ទុត្តំ ឥទមេតំ បដិច្ច ទុត្តំ** ប្រែថា **យំ វចនំ** វីពាក្យណា **មយា** គឺ តថាគត **ទុត្តំ** ពោលហើយ **ឥតិ** ដោយប្រការដូច្នេះ **ឯតំ វចនំ** វីពាក្យនោះ **មយា** គឺតថាគត **បដិច្ច** អាស្រ័យហើយ **ឥទំ ចតុស្សតិបដ្ឋានមគ្គំ** នូវផ្លូវគឺសតិប្បដ្ឋាន ៤ នេះ **ទុត្តំ** ពោលហើយ ។

ឆ. បើចុះក្នុងទីបំផុតសេចក្តីឬ ក្នុងទីបំផុតនៃនិទាន ប្រែថា "ដូច្នេះឯង" ហៅថា **សមាបន្ន** ឬ **បរិសមាបន្ន** ដូចជា **សម្បត្តបរិសាយបិ ទេសនា សាត្ថិកា សផលា អហោសីតិ** ។ ប្រែថា **បិ** មិនតែប៉ុណ្ណោះទេ **ទេសនា** វីទេសនា **សាត្ថិកា** ជាធម្មជាតិប្រព្រឹត្តទៅមួយអន្លើដោយវាចាមានប្រយោជន៍ **សផលា** ជាធម្មជាតិប្រព្រឹត្តទៅមួយអន្លើដោយផល **អហោសិ** បានមានហើយ **សម្បត្តបរិសាយ** ដល់បរិស័ទអ្នកប្រជុំគ្នាហើយ **ឥតិ** ដូច្នេះឯង ។

ជ. បើប្រាប់ឈ្មោះ គឺប្រើជំនួសនាមសព្ទ ប្រែថា "ឈ្មោះថា" ហៅថា **សញ្ញាជោតកៈ** ដូចជា **សិន្ធវាតិ សិន្ធវ-រដ្ឋេ ជាតា អស្សា** ប្រែថា **អស្សា** វីសេះទាំងឡាយ **ជាតា** កើត

ហើយ **សិន្ធវរដ្ឋេ** ក្នុងដែនឈ្មោះសិន្ធវៈ **សិន្ធវាតិ** ឈ្មោះថាសិន្ធព ។ **តត្ថ មនោតិ កាមាវចរកុសលាទិភេទំ សព្វម្បិ ចតុភូមិកចិត្តំ** ប្រែថា **ចតុភូមិកចិត្តំ** រឺចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ **សព្វម្បិ** សូម្បីទាំងអស់ **កាមាវចរកុសលាទិភេទំ** ផ្សេងដោយចិត្តមានកុសលកាមាវចរចិត្តជាដើម **មនោ ឥតិ** ឈ្មោះថាចិត្ត **តត្ថ គាថាយំ** ក្នុងគាថានោះ ។

## គោលប្រែអដ្ឋកថា

អដ្ឋកថានៃគម្ពីរធម្មបទ មានវិធីប្រែច្រើនយ៉ាង ក្នុងទីនេះ នឹងចាត់វិធីប្រែ អដ្ឋកថានោះៗ ទុក ជាពួកៗ ដើម្បីជាគ្រឿងកំណត់ របស់សិក្ខាកាមជាន់ដំបូង ដូចតទៅនេះ :

### ពួកទី ១

បែបសម្រាប់ប្រកបប្រែជាមួយនឹង **ឥតិ**-សព្ទ ដែលតាំងនៅក្នុងទីបំផុតនៃ បទកែ និង បទតាំង ។

**អត្ថោ** រឺអត្ថ **ឥតិ** ... **បទស្ស** ឬ **បទានំ** ... **ឥតិ** ...

ឧទាហរណ៍ : **តត្ថ អប្បមាទេនាតិ អប្បមាទេ** ។បេ។ **វីតិនាមេន្តោតិ អត្ថោ, អត្ថោ រឺអត្ថ បមាទេ** ។បេ។ **វីតិនា-**

**មេន្តោ ឥតិ** ថា ... ដូច្នេះ **តត្ថបទេសុ** ជំនុំបទទាំងឡាយនោះ **បទស្ស** នៃបទ **អប្បមាទរតោ ឥតិ** ថា ... ដូច្នេះ ។

**អន្តោ** វីសេចក្តី **ឥតិ ... បទស្ស** ឬ **បទានំ ឥតិ ...**

ឧទាហរណ៍ : **បព្វតដ្ឋោ ឋ ភុម្មដ្ឋេតិ ... បព្វតមុទ្ធ-និដ្ឋិតោ ។បេ។ អភិច្ចេ ន អវេក្ខតីតិ, អន្តោ** វីសេចក្តី **បព្វតមុទ្ធនិដ្ឋិតោ** ។ល។ **អវេក្ខតិ ឥតិ** ថាដូច្នេះ **បព្វតដ្ឋោ** មួយបទ **ភុម្មដ្ឋេ** ផងឈ្មោះថា **បទទ្វយស្ស** នៃប្រជុំពីរនៃបទក៏បាន (ធ.ប.២ ទំព័រ១៥៧) ។

**អន្តោ** សេចក្តី **ឥតិ ... គាថាវចនស្ស បណ្ឌិតេន វេទិតព្វោ ។ តស្សន្តោ យានិ កម្មានិ ។ល។ បច្ឆាមុខករណំ វិយ អតិទុក្ករន្តិ** ។ **អន្តោ** វីសេចក្តី **យានិ កម្មានិ ។ល។ អតិទុក្ករំ ឥតិ** ថាដូច្នេះ **តស្ស គាថាវចនស្ស** នៃពាក្យជាគាថានោះ **បណ្ឌិតេន** គឺបណ្ឌិត **វេទិតព្វោ** គប្បីជ្រាប (ធ.ប.៦ ទំព័រ ៣២) ។

**អន្តោ** (អត្ថាធិប្បាយ) **ឥតិ** ... ក្នុង ... **ឥតិ** ...

ឧទាហរណ៍ : **បរេ ចាតិ បុព្វេ មយា ។បេ។ មេធគា**

**សម្មន្តីតិ អយមេត្ថ អត្ថោ**,។ **អត្ថោ** រីអត្ថាធិប្បាយ **មុព្វេ មយា** ។ល។ **មេធគា សម្មន្តិ ឥតិ** ថាដូច្នេះ **ឯត្ថគាថាយំ** ក្នុងគាថា នោះ **បរេ ច ឥតិ** ថាដូច្នេះជាដើម **អយំ** នេះ **បណ្ឌិតេន** គឺបណ្ឌិត **វេទិតព្វោ** គប្បីជ្រាប (ធ.ប.១ ទំព័រ៩៤) ។

**អត្ថោ** អធិប្បាយ **ឥតិ**... ។ ឧទាហរណ៍ : **បសាទំ រោចេតិយេវាតិ អត្ថោ** ។ **អត្ថោ** រីអធិប្បាយ **បសាទំ រោចេតិ ឯវ ឥតិ** ថា ... ដូច្នេះ (ធ.ប.៨ ទំព័រ១០៥) ។

**បទំ** (បទ) **ឥតិ** ... **បណ្ឌិតេន** ... **វេទិតព្វំ** ; ... **មយា វុច្ចតេ** ឧទាហរណ៍ :**ធម្មាតិ** ។បេ។ ប្រែ: **បទំ** រីបទ **ធម្មា ឥតិ** ថា ... ដូច្នេះ **បណ្ឌិតេន** គឺបណ្ឌិត **វេទិតព្វំ** គប្បីដឹង, **មយា** គឺខ្ញុំ **វុច្ចតេ** នឹងពោល (ធ.ប.១ ទំព័រ៣១) ។

## ពួកទី ២

បែបសម្រាប់ប្រកបប្រែនឹងសព្ទ ដែលចុះសត្តមីវិភត្តិ ហើយតាំងនៅតែមួយបទ ឬក៏តាំងនៅក្រោយនៃបទតាំងត្រង់ទីបំផុតនៃបទកៃ មិនមាន **ឥតិ**-សព្ទ ដូចន័យ ក្នុងពួកទីមួយទេ ។

**១**. **អត្ថោ** (សេចក្តី) ក្នុង ... **បណ្ឌិតេន** ... **វេទិតព្វោ** ... ឧទាហរណ៍ : **ទុតិយគាថាយបិ** ប្រែថា **អត្ថោ** រីសេចក្តី **ទុតិយគាថាយបិ** សូម្បីក្នុងគាថាទីពីរ **បណ្ឌិតេន** គឺបណ្ឌិត **វេទិតព្វោ** គប្បីជ្រាប ។ ន័យនេះនឹងប្រើ **វិនិច្ឆយោ** ជំនួស **អត្ថោ** ឬប្រើ **មយា ទុច្ចតេ** វិញ, **ទុច្ចតេ** ជំនួស **បណ្ឌិតេន** **វេទិតព្វោ** ក៏បាន វិធីប្រែដូចគ្នា (ធ.ប.៥ ទំព័រ២១) ។

**២**. **វិនិច្ឆយោ** វិនិច្ឆ័យក្នុង ... **ឥតិ** ... **បណ្ឌិតេន** ... **វេទិតព្វោ** ... ឧទាហរណ៍: **វនំ វនដ្ឋាតិ ឯត្ថ មហន្តា រុក្ខា នាមវិនិច្ឆយោ** រីវិនិច្ឆ័យ **ឯត្ថ** (**បទទ្វយេ**) ក្នុងពួកពីរនៃបទនុ៎ះ **វនំ វនដ្ឋា ឥតិ** ថា ... ដូច្នេះ **បណ្ឌិតេន** គឺ ... **វេទិតព្វោ** គប្បីជ្រាប (ធ.ប.៧ ទំព័រ១១៥) ។

**៣**. **វិគ្គហោ** (វិគ្គហៈ) ក្នុង ... **ឥតិ** ... **បណ្ឌិតេន** ... **វេទិតព្វោ** ... ឧទាហរណ៍ : **ធីរោ ច សុខសំវាសោតិ ឯត្ថ សុខោ សំវាសោ ឯតេនាតិ សុខសំវាសោ** ។ **វិគ្គហោ** រីវិគ្គហៈ **ឯត្ថ** (**បទទ្វយេ**) ក្នុងប្រជុំពីរនៃបទនោះ **ធីរោ ច សុខសំវាសោ ឥតិ** ថា ... ដូច្នេះ **បណ្ឌិតេន** គឺ ... **វេទិតព្វោ** ...

(ធ.ប.៦ ទំព័រ២០០) ។

## **ពួកទី ៣**

បែបប្រែ **ឥតិ**-សព្ទ ជាសញ្ញាជោតកៈភ្ជាប់នឹងបទតាំង "ឈ្មោះថា" ឧទាហរណ៍ : **អច្ចន្តទុស្សីល្យន្តិ ឯកន្តទុស្សីលភាវោ** ប្រែថា **ឯកន្តទុស្សីលភាវោ** រីភាវនៃបុគ្គលអ្នក អត់សីលដោយចំណែកមួយ **អច្ចន្តទុស្សីល្យំ ឥតិ** ឈ្មោះថាភាពនៃបុគ្គលអ្នកទ្រុស្តសីលដោយចំណែកមួយ (ធ.ប.៦ ទំព័រ ២៩) ។

## **ពួកទី ៤**

បែបសម្រាប់ប្រកបប្រែនឹងបទនាម, គុណ, កិរិយា, កិរិយានាម, កិរិយាគុណ ដែលលោករៀងតគ្នា ទាំងសេចក្តីសោតក៏ប្រដំប្រសងគ្នា គឺជាវេវចនៈនឹងគ្នា ។

១. ប្រែមុនបទកែ "គឺថា" ឧទាហរណ៍ : **បាបំ ទុម្មេធំ ... និបញ្ញំ បុគ្គលំ ចតូសុ អបាយេសុ អភិមត្ថតិ ... វិទ្ធំសេតិ** ប្រែថា **បាបំ** រីបាប **អភិមត្ថតិ** តែងញាំញី **អភិមត្ថតិ** គឺថា **វិទ្ធំសេតិ**ៗ រមែងកម្ចាត់បង់ **បុគ្គលំ** នូវបុគ្គល **ទុម្មេធំ** អ្នកឥតប្រាជ្ញា **ទុម្មេធំ** គឺថា **និបញ្ញំ**ៗ អ្នកមានប្រាជ្ញាមិនមាន

(ធ.ប.៦ ទំព័រ២៨) ។

២. ប្រែក្រោយបទកែ "ឈ្មោះថា, ឲ្យឈ្មោះថា" ឧទាហរណ៍ : **យន្តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ឯវរូបេន វីរិយេន អន្តរា អនោសក្កិត្វា និច្ចំ បវត្តេន ទឡ្ហេន បរក្កមេន សមន្នាគតា** ប្រែថា **ជនា** ពួកជនទាំងឡាយ **សមន្នាគតា** ប្រកបព្រមហើយ **វីរិយេន** ដោយសេចក្តីព្យាយាម **ឯវរូបេន** មានសភាពយ៉ាងនេះ **យន្តំ ។ល។ សណ្ឋានំ ភវិស្សតិ ឥតិ** ថា... ដូច្នេះ **បរក្កមេន** ឈ្មោះថាដោយសេចក្តីប្រឹងប្រែង **ទឡ្ហេន** ដ៏មុឹងម៉ាត់ **បវត្តេន** ដែលប្រព្រឹត្តទៅហើយ **និច្ចំ** ជានិច្ច **អនោសក្កិត្វា** ព្រោះមិនបន្ធូរ **អន្តរា** ក្នុងពាក់កណ្តាល ។ លេខក្នុង **យន្តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សន្ឋានំ** ពួកកិរិយាមិនទាន់ដល់ **តំ** នូវ ... ពួកកិច្ចណា ដែលបុគ្គលគប្បីដល់ ដោយកម្លាំងចិត្តរបស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស កិច្ចនោះទេ នឹងមិនបញ្ឈប់នូវសេចក្តីព្យាយាម **ភវិស្សតិ** នឹងមាន

(ធ.ប. ២ ទំព័រ១១៨) ។

## វិធីសង្កេតគោលប្រែអដ្ឋកថា

សិក្ខាកាមចូរសង្កេតគោលប្រែអដ្ឋកថា ដែលពោលមកហើយនោះ ដូចតទៅនេះ :

## គោលប្រែទី ១

១. អដ្ឋកថាណាដែលព្រះអដ្ឋកថាចារ្យលើកយកបទក្នុងគាថាមកតាំងត្រឹមតែមួយបទក្តី ពីរបទក្តី ច្រើនបទក្តី តាំងជាបាទក្តី តែសេចក្តីដែលកែចេញទៅមិនពិស្តារទេ លោកឲ្យកែល្មម សមគួរដល់បទ ឬ បាទនៃគាថាប៉ុណ្ណោះ ។ **អត្ថោ** ដែលយកទៅប្រើក្នុងអដ្ឋកថានោះ គប្បីប្រែថា "អត្ថ" កាលនឹងប្រែបទតាំង បើបទតាំងនោះមួយបទប្រើ **បទស្ស**, ពីរបទប្រើ **បទទ្វយស្ស**, តាំងពីបីបទឡើងទៅដែលមិនទាន់ពេញជាបាទគាថា ប្រើ **បទានំ**, បើពេញមួយបាទគាថា ប្រើ **គាថាបាទស្ស**, បើពីរបាទ ប្រើ **គាថាបាទទ្វយស្ស** ។

២. អដ្ឋកថាណាមានប្រយោគបុច្ឆានៅខាងមុខ របស់បទតាំង បទតាំងនោះឯង ក៏ជាប្រយោគវិស្សជ្ជនា របស់ប្រយោគបុច្ឆា ហើយនៅមានកែចេញទៅទៀត ដើម្បីពង្រីកសេចក្តីរបស់វិស្សជ្ជនានោះ ឲ្យច្បាស់លាស់ ។ **អត្ថោ** ដែល

យកទៅប្រើ ក្នុងអដ្ឋកថានោះ គប្បីប្រែ "សេចក្តី" ឧទាហរណ៍ **យថា កឹ ។ ចក្កំវ វហតោ បទន្តិ** ... **ធុរេ យុត្តស្ស ធុរំ វហតោ ពលិពទ្ទស្ស បទំ ចក្កំ វិយ** ប្រែថា **ពុទ្ធា** រីពុទ្ធា **យថា កឹ ឥតិ** ថា ... ដូច្នេះ, **ទុក្ខំ** រីទុក្ខ **អន្វេតិ** រមែងទៅតាម **តំ បុគ្គលំ** នូវបុគ្គលនោះ **យថា កឹ** ដូចជាអ្វី ? **វិស្សជ្ជនា** រី វិស្សជ្ជនា **ចក្កំវ វហតោ បទំ ឥតិ** ថា ... ដូច្នេះ, **ចក្កំ វហតោ បទំ អនុគច្ឆន្តំ ឥវ** ដូចជារីចក្រកាលវិលទៅតាម នូវស្នាមជើងនៃគោ **ពលិពទ្ទ** កាលនាំទៅនូវនឹម ។ តពីនេះ ទៅ បំបែកសេចក្តីវិស្សជ្ជនា **អត្ថោ** រីសេចក្តី **ធុរេ យុត្តស្ស ។ល។ ចក្កំ វិយ ឥតិ** ថា ... ដូច្នេះ ... **គាថាបាទស្ស** នៃបាទ នៃគាថា **ចក្កំវ វហតោ បទំ ឥតិ** ថា ... ដូច្នេះ, **ធុរេ យុត្តស្ស ។ល។ អនុគច្ឆន្តំ ចក្កំ វិយ** ដូចជារីចក្រកាលវិលទៅតាមនូវ ស្នាមជើងនៃគោ **ពលិពទ្ទ** ដែលគេទឹមហើយក្នុងនឹម កាល នាំទៅនូវនឹម ។

បំបែកសេចក្តីរបស់ប្រយោគវិស្សជ្ជនា ដែលជាបទតាំង បទតាំងនោះត្រូវចូលពីរលើក, លើកដំបូងចូលនឹង ប្រយោគ វិស្សជ្ជនា លើកទីពីរចូលនឹងបទ **អត្ថោ** ដែលបំបែកសេចក្តី

នៃវិស្សជ្ជនា (ធ.ប.១ ទំព័រ៣៩) ។

៣. អដ្ឋកថាណាលោកមិនមានបំណងនឹងកែសព្ទ ឬ កែសេចក្ដីនៃរឿងដទៃទេលោកប្រាថ្នានឹងកែទៅតាម សេចក្ដីរបស់គាថាដែលមានប៉ុណ្ណោះ បើទុកជា និយាយដល់ពាក្យដទៃខ្លះ ក៏ជាពាក្យដែលជាប់ទាក់ទងគ្នានឹងសេចក្ដី របស់គាថា បើមិននាំមកនិយាយផងទេ សេចក្ដីក៏មិនភ្លឺច្បាស់ ។ អដ្ឋកថានោះ លោករៀង **តស្សត្ថោ** ទុកក្នុងខាងដើម ដើម្បីជាគ្រឿងសង្កេតនៃគាថា សង្កាត់នេះ ។ **អត្ថោ** ដែលជាប់នឹង **តស្ស** នោះគប្បីប្រែថា "សេចក្ដី" ដូចទីពីរដែរ ផ្សេងគ្នាតែទីនេះ ប្រែជាកម្មវាចកៈ គឺត្រូវបញ្ចូល **បណ្ឌិតេន ... វេទិតព្វោ** ... ឬ **មយា វុច្ចតេ** ក៏បាន ។ ចូរមើល ឧទាហរណ៍ក្នុងខទី ៣ នៃគោលប្រែពួកទី ១ នោះចុះ ។

៤. អដ្ឋកថាណាលោកលើកយកបទនៃគាថាមកតាំងមួយបទៗ ឬ ច្រើនបទ ឬក៏តាំងជាបាទគាថា ហើយកែចេញទៅរៀងរហូតចប់គាថាមួយៗ កាលចប់គាថា មួយហើយ ក៏ផ្ដើមអធិប្បាយសេចក្ដីរបស់គាថានោះ ថែមមួយលើកទៀត

ដើម្បីធ្វើសេចក្តីឲ្យប្រាកដច្បាស់ឡើងជាងដើម ។ **អន្នោ** ដែល យកទៅប្រើក្នុងអដ្ឋកថានោះ គប្បីប្រែថា "អត្ថាធិប្បាយ" ។ តែវិធីប្រែបទតាំង មិនបានប្រើបទបាទ ឬ គាថាសព្វ ប្រកប ឆដ្ឋីវិភត្តិដូចន័យទី ១, ២, ៣ ទេ ត្រូវប្រកបសត្តមីវិភត្តិវិញ ។ ចូរមើល ឧទាហរណ៍ក្នុងខទី៤នៃគោល ប្រែពួកទី ១ ។ មួយ ទៀត ត្រូវបញ្ចូល **បណ្ឌិតេន ទេនិតព្វោ** ឬ **មយា ទុច្ចតេ** ដូច ពោលហើយក្នុងខទី ៣ ។

៥. អដ្ឋកថាណា លោកតាំងបទកែមកច្រើនហើយ ប៉ុន្តែមានបទខ្លះ ឬ សេចក្តីក្នុងសង្កាត់ខ្លះ ដែលកែមក ហើយនោះ នៅខ្វះខាត ឬ សេចក្តីនៅកំបាំងជ្រាលជ្រៅ លោកក៏ប្រែអធិប្បាយចំពោះបទ ឬ សេចក្តីនៃសង្កាត់នោះ ថែមទៀត ។ **អន្នោ** ដែល យកទៅប្រើក្នុងអដ្ឋកថានោះ គប្បី ប្រែថា "អធិប្បាយ" ។ ន័យនេះមិនមានបទ តាំងឡើយ ។ ឯបទ ឬ សេចក្តីដែលអធិប្បាយនោះ ប្រហែលគ្នានឹងបទ ឬ សង្កាត់ដែលខៃ ហេតុនោះសិក្ខាកាមគួរសង្កេតឲ្យធ្ងន់គំនិត ទើបដឹង ជាអធិប្បាយ ឬ ខៃ ។ ឧទាហរណ៍ : **សារម្ភោ តេ**

**ន ចិជ្ជតីតិ ... ឯវំ សន្តេ បន តេ ត្វំ ទុស្សីលោតិ តុម្ហេ ទុស្សីលាតិ ឯវមាទិកោ ឧត្តរិករណវាចាលក្ខណោ សារម្ភោបិ ន ចិជ្ជតិ, ន ភវិស្សតិ យេ វាតិ** ប្រែថា **អត្ថោ** រី អត្ថ **ឯវំ សន្តេ ។ល។ ន ចិជ្ជតិ ឥតិ** ថា ... ដូច្នេះ **គាថាបាទ-ស្ស** នៃ ... **សារម្ភោ តេ ន ចិជ្ជតិ ឥតិ** ថា ... ដូច្នេះ, **បន** ក៏ **ឯវំ ការណោ** នាកាលហេតុយ៉ាងនេះ **សន្តេ** កាលមាន **សារម្ភោបិ** សូម្បីវិវាទៈប្រព្រឹត្តទៅមួយអន្លើ ដោយការប្រណាំងប្រជែង **ឧត្តរិករណវាចាលក្ខណោ** មានវាចាជាគ្រឿងធ្វើឲ្យក្រៃលែងជាលក្ខណៈ **ត្វំ ។ល។ ឯវមាទិកោ** មានយ៉ាងនេះជាដើមថា រីភិក្ខុទាំងឡាយបានពោលហើយថា រីអ្នកទ្រុស្តសីល ចំណែកអ្នកពោលថា រីអ្នកទាំងឡាយ ក៏ទ្រុស្តសីល **ន ចិជ្ជតិ** នឹងមិនមាន **តេ** ដល់អ្នក, **អត្ថោ** រីអធិប្បាយ **ន ភវិស្សតិយេវ ឥតិ** ថា ... ដូច្នេះ, **តេ ន ភវិស្សតិ ឯវ** នឹងមិនមានដល់អ្នកឡើយ (ធ.ប.៥ ទំព័រ៨៣) ។

៦. បទ ឬ សេចក្តីក្នុងសង្កាត់នៃអដ្ឋកថាដែលលោកពណ៌នាច្រើនៗ ទៅមិនមានជើង អត្ថ តែសេចក្តីដែលពណ៌នា

នោះ ក្នុងទីបំផុតក៏សរុបចុះក្នុងបទនោះឯង, កាលបើយ៉ាងនេះ បទតាំងត្រូវប្រើ **បទំ បណ្ឌិតេន ទេឧិតព្វំ** ឬ **មយា ឧុច្ចតេ** ឧទាហរណ៍ : **និគ្គយ្ហវាទិន្តិ ឯកច្ចោ ហិ ។បេ។ អយំ និគ្គយ្ហវាទី នាម សេយ្យថាបិ សម្មាសម្ពុទ្ធោ** ប្រែថា **បទំ** រី... **និគ្គយ្ហវាទី ឥតិ** ថា ... ដូច្នេះ **បណ្ឌិតេន** គឺ... **ទេឧិតព្វំ** គប្បី ... **ហិ** ក៏ **ឯកច្ចោ អាចរិយោ** រីអាចារ្យខ្លះ ។ល។ **អយំ អាចរិយោ** រីអាចារ្យនេះ **និគ្គយ្ហវាទី នាម** ឈ្មោះថាអ្នកមានកិរិយាពោលសង្កត់សង្កិនជាប្រក្រតី **សេយ្យថាបិ សម្មាសម្ពុទ្ធោ** ដូចជារីព្រះសម្មាសម្ពុទ្ធ (ធ.ប.៤ ទំព័រ៦) ។

## គោលប្រែព្វកទី ២

១. គាថាមានច្រើន រាប់តាំងពី២គាថាឡើងទៅ, ក្នុងគាថាដើម លោកកែមក តាមលំដាប់ រហូតដល់ចប់, កាលនឹងកែគាថាតទៅ លោករៀង **ទុតិយគាថាយ** ឬ **តតិយគាថាយ** ឬ **ចតុត្ថគាថាយ** ទុកក្នុងខាងដើមទៀត, បើរៀងទុកដូច្នេះ កាលនឹងប្រែត្រូវបញ្ចូល **អត្ថោ** "សេចក្តី" **បណ្ឌិតេន**

**ទេសិតព្វោ** ឬ **មយា ទុច្ចតេ** ក៏បាន ។

២. សេចក្ដីនៃគាថាខ្លះនៅកំបាំង ដូចបទថា **ឱកមោ-កតឧព្ភតោ** ប្រែថា "លើកឡើងហើយចាកអាល័យគឺ ទឹក" ។ ពាក្យថា "ចាកអាល័យគឺទឹក" ប្រែចេញមកពីបទ **ឱកមោកត** ដែលញែកចេញជាពីរសព្ទគឺ : **ឱក** + **ឱក** ប្រែថា "ទឹក + ទឹក" ដូចគ្នា ហេតុដូចម្ដេចទើប លោកយកសព្ទ មួយថា "ទឹក" សព្ទមួយថា "អាល័យ" ? ដំណើរនេះមកពី អដ្ឋកថាចារ្យវិនិច្ឆ័យ សេចក្ដីនោះឲ្យភ្លឺត្រចះឡើង ។ ឧទាហរណ៍ : **ឱកមោកត ឧព្ភតោ ឱកបុណ្ណេហិ ចីវរេហីតិ ឯត្ថ ឧទកំ, ឱកំ, ឱកំ បហាយ អនិកេតសារីតិ ឯត្ថ អាលយោ ឥធ ឧភយំបិ លព្ភតិ** ប្រែថា **វិនិច្ឆយោ** វិនិច្ឆ័យ **ឥធ បទេ** ក្នុងបទនេះ **ឱកមោ-កតឧព្ភតោ ឥតិ** ថា ... ដូច្នេះ **បណ្ឌិតេន** ... **ទេសិតព្វោ** ... ឬ **មយា ទុច្ចតេ** ។ **ឧទកំ** វីទឹក **ឱកំ** ឈ្មោះថា **ឱក ឯត្ថ បយោគេ** ក្នុង ... **ឱកបុណ្ណេហិ ចីវរេហិ ឥតិ** ថា ... ដូច្នេះ ។ **អាលយោ** វីអាល័យ **ឱកំ** ឈ្មោះថា **ឱក ឯត្ថ បយោគេ** ក្នុង ... **ឱកំ បហាយ អនិកេតសារី ឥតិ** ថា ... ដូច្នេះ, **ឧព្ភយម្បិ**

**អាលយោទកំ** ក៏រីអាល័យ និង ទឹកទាំងពីរ **បណ្ឌិតេន** គឺ... **លព្ភតិ** រមែងបាន **ឥធ ឱកមោកតឧព្ភតោ ឥតិ បទេ** ក្នុងបទថា **ឱកមោកតឧព្ភតោ** (ធ.ប.២ ទំព័រ១៩៧) ។

៣. អដ្ឋកថាណាលោកបានកែដោយរូបវិគ្រោះ អដ្ឋ-កថានោះគប្បីប្រើ **វិគ្គហោ** ដែលប្រែថា "វិគ្រោះ" ទាំងបញ្ចូល **បណ្ឌិតេន វេទិតព្វោ** ឬ **មយា ទុច្ចតេ** ។ ឧទាហរណ៍ : **ឱហារិនន្តិ ... អាកឌ្ឍិត្វា ចតូសុ អាបាយេសុ បតនតោ អវហរតិ ... ហេដ្ឋា ហរតីតិ ឱហារិនំ** ប្រែថា **វិគ្គហោ** រី វិគ្រោះ **ឯត្ថ បទេ** ក្នុងបទនេះ **ឱហារិនំ ឥតិ** ថា ... ដូច្នេះ **បណ្ឌិតេន ... វេទិតព្វោ ... យំ កិលេសពន្ធនំ** រីចំណងគឺកិលេសណា **អវហរតិ** នាំចុះទៅ **អវហរតិ** គឺថា **ហេដ្ឋា ហរតិ**, **ហរតិ** នាំទៅ **ហេដ្ឋា** ក្នុងខាងក្រោម **អាកឌ្ឍិត្វា ចតូសុ អបាយេសុ បាតនតោ** ព្រោះជាគ្រឿងទាញទម្លាក់ ទៅក្នុងអបាយទាំងឡាយ៤ **ឥតិ** ព្រោះហេតុនោះ **កិលេសពន្ធនំ** រីចំណងគឺកិលេសនោះ **ឱហារិនំ** ឈ្មោះថា នាំទៅក្នុងខាង

ក្រោម (ធ.ប.៨ ទំព័រ២៨) ។

## គោលប្រែពួកទី ៣

អដ្ឋកថាណា លោកលើកយកបទប្រធាន មកតាំងកែ ចំពោះ តែបទប្រធាន មួយប៉ុណ្ណោះ អដ្ឋកថានោះមិនត្រូវតាំង **អត្ថ** ត្រូវប្រែតែម្តង, **ឥតិ** ដែលនៅខាង ក្រោយបទតាំងនោះ ប្រែថា "ឈ្មោះថា" ឧទាហរណ៍ : **ធម្មាតិ** ... **វេទនា-ទយោ តយោ ខន្ធា** ប្រែថា **ខន្ធា** រីខន្ធទាំងឡាយ **តយោ** បី **វេទនាទយោ** មានវេទនាជាដើម **ធម្មា ឥតិ** ឈ្មោះថាធម៌ (ធ.ប.១ ទំព័រ៥០) ។ សូម្បី វិសេសនៈរបស់ បទប្រធានខ្លះ មិនបាច់តាំងអត្ថប្រែតាមទំនងនេះក៏បាន : **កតបុញ្ញោតិ នានប្បការស្ស បុញ្ញស្ស កត្តា** ប្រែថា **កត្តា** រីបុគ្គលអ្នកធ្វើ **បុញ្ញស្ស** នូវបុណ្យ **នានប្បការស្ស** មានប្រការផ្សេងៗ **កតបុញ្ញោ ឥតិ** ឈ្មោះថាអ្នកមានបុណ្យធ្វើហើយ (ធ.ប.១ ទំព័រ១៩៤) ។

## គោលប្រែពួកទី ៤

ប្រែមុនបទកែ "គឺថា" បានដល់បទខែ គឺបទដែលយោង

សេចក្ដីជ្រាលជ្រៅឲ្យ អណ្ដែតរះឡើង មានន័យដូច តទៅនេះ :

ក. អដ្ឋកថាដែលលោកលើកបទ ក្នុងគាថាមករៀង ទុកខាងមុខ នៃបទកែ ដែលមានសេចក្ដីជ្រិះគ្នា ទាំងមាន វចនៈ វិភត្តិស្មើគ្នានឹងបទដែលមានក្នុងគាថានោះ អ្នកប្រែត្រូវ ប្រែខែបទមុខនោះ ទៅរកបទខាងក្រោយ ដូចជា **សោភតិ** : **វិរោចតិ** ។ **សោភតិ** ជាសព្ទដែលលោកលើកមកពីគាថា **វិរោចតិ** មិនមានក្នុងគាថាទេ, **សោភតិ** រមែងល្អ **សោភតិ** គឺ ថា **វិរោចតិ**ៗ រមែងរុងរឿង ។

ខ. បើបទខែនោះជាកិរិយាផ្សេងវាចកៈគ្នា តួកម្មដែល រៀងទុកនៅខាងមុខនៃ កិរិយានោះ ត្រូវទាញចូលមក ប្រែ គ្រប់កិរិយាដែលផ្សេងវាចកៈគ្នានោះ ឧទាហរណ៍ : **អត្តនា វ អត្តានំ ចោទយ សារយេ** ។ ឯ **ចោទយ** ជាកិរិយាកត្តុវាចកៈ, **សារយេ** ជាកិរិយាហេតុកត្តុវាចកៈ កាលបើប្រែ ត្រូវទាញយក **អត្តានំ** ចូលមកប្រែក្នុងកិរិយា ទាំងពីរដូច្នេះ **ត្វំ** រីអ្នក **ចោទយ** ចូរដាស់តឿន **អត្តានំ** នូវខ្លួន, **អត្តានំ ចោទយ** គឺថា **សារយេ**, **អត្តានំ** ញុំាងខ្លួន **សារយេ** ចូរឲ្យរលឹក **អត្តនា វ** ដោយ

ខ្លួនឯង (ធ.ប.៨ ទំព័រ១១៦) ។ តែបើកិរិយាជា វាចកៈដូចគ្នា ត្តកម្មត្រូវទាញមកប្រែនឹង កិរិយាខាងក្រោយតែម្តង ឧទាហរណ៍ : **អត្តានំ សំយមៈ គោបយ** ប្រែថា **ត្វំ** រីអ្នក **សំយម** ចូរសង្រួម **សំយម** គឺថា **គោបយ**ៗ ចូរឃុំគ្រង **អត្តានំ** នូវខ្លួន (ធ.ប.៨ ទំព័រ១១៧) ។

គ. វិធីប្រែខែនេះ មានពាក្យសម្រាប់ហៅតាមវិធីសម្ពន្ធ គឺបទដែលត្រូវប្រែខែ ហៅថា " **វិវរណៈ** " ឯបទដែលទទួល អំពីបទខែមក ហៅថា "**វិវរណីយៈ**" នឹងសម្ពន្ធ ឧទាហរណ៍ នេះដូច្នេះ **ត្វំ** សយកត្តាក្នុង **ចោទយៈ**, ហេតុកត្តាក្នុង **សារយ**, **ចោទយៈ វិវរណៈ** ក្នុង **សារយ**ៗ វិវរណីយៈរបស់ **ចោទយ**ៗ អាខ្យាតបទកត្តុវាចកៈរបស់ **ត្វំ**, **សារយ** អាខ្យាតបទ ហេតុ-កត្តុវាចកៈ របស់ **ត្វំ**, **អត្តនាករណៈ** ក្នុង **ចោទយ** ក្នុង **សារយ** , **វ** សព្ទ **អវធារណៈ** ក្នុង **អត្តនា**, **អត្តានំ** អវុត្តកម្មក្នុង **ចោទយ**, ការិតកម្មក្នុង **សារយ** ។ បើវាចកៈ ត្រូវគ្នាវិញត្រូវ សម្ពន្ធរួមគ្នាតែម្តង **ត្វំ** សយកត្តាក្នុង **សំយម គោបយ**, **សំយម** វិវរណៈក្នុង **គោបយ**ៗ វិវរណីយរបស់ **សំយម**, **សំយម** ក្តី

**គោបយ** ក្តី អាខ្យាតបទកត្តុវាចក:របស់ **គុំ**, **អត្ថានំ** អវុត្តកម្ម ក្នុង **សំយម គោបយ** ។

ប្រែក្រោយបទកែ "ឈ្មោះថា, ឲ្យឈ្មោះថា" បានដល់ ប្រែដកហេតុ និង ប្រែកល់ហេតុ។ វិធីនេះមានន័យដូចតទៅ

**ប្រែដកហេតុ** : បទដែលមានក្នុងគាថា លោករៀង ទុកក្នុងខាងក្រោយនៃបទកែដូចជា **ជនានំ ពាលានំ** ជាដើម ។ **ពាលានំ** មានក្នុងគាថាដែលហៅថាតួបាលី ។ **ជនានំ** មិន មានក្នុងគាថា ហៅថាបទកែ ។ បើប្រែ **ជនានំ** មុន **ពាលានំ** ប្រែក្រោយ ហៅថា ប្រែដកហេតុត្រូវបន្ថែម បទថា "ឈ្មោះ ថា" ដូចនេះ **ជនានំ** នៃជនទាំងឡាយ **ពាលានំ** ឈ្មោះថា នៃ បុគ្គលពាលទាំងឡាយ ។ បើប្រែខែត្រឡប់មក រកបទមុខ វិញក៏បាន គឺត្រូវប្រែ **ពាលានំ** មុនរួចហើយខែ **ពាលានំ** ចូល ទៅរក **ជនានំ** ដូច្នេះ **ពាលានំ** នៃបុគ្គលពាលទាំងឡាយ **ពាលានំ** គឺថា **ជនានំ**ៗ នៃជនពាលទាំងឡាយ ។ **ចាតុម្មាសំ ចសុំ** ប្រែដកហេតុ **ចាតុម្មាសំ** អស់ប្រជុំនៃខែ ៤ **ចសុំ** ឈ្មោះថា អស់រដូវភ្លៀង ។ ប្រែខែ : **ចសុំ** អស់រដូវភ្លៀង

**វស្សំ** គឺថា **ចាតុម្មាសំ**ៗ អស់ប្រជុំនៃខែ ៤ ។ ម្យ៉ាងទៀតបទកិរិយាអាខ្យាតដែលមានក្នុងគាថា កាលលោកកែច្រើនតែកែជាកិរិយាកិតក: ប្រកប **អន្ត មាន**-បច្ច័យ តួណាមួយ ហើយបទកិរិយាខាងក្រោយ ជាកិរិយាអាខ្យាត ដែលលោកលើកមកអំពីគាថាពិតៗ ត្រូវប្រែដកហេតុថា "ឈ្មោះថា" ដូចជា **សោ បិ បុរិមទុច្ចរិតានុភាវេន និព្វត្តំ ទុក្ខំ អនុភវមានោ បាបំ បស្សតិ** ប្រែថា **សោបិ ភទ្រោ** វីបុគ្គលល្អនោះ **អនុភវមានោ** កាលសោយ **ទុក្ខំ** នូវទុក្ខ **និព្វត្តំ** ដែលកើតហើយ **បុរិមទុច្ចរិតានុភាវេន** ដោយអានុភាពនៃទុច្ចរិត មានក្នុងភពមុន **បស្សតិ** ឈ្មោះថាឃើញ **បាបំ** នូវបាប ។ **អថ ទិដ្ឋធម្មេ លាភសក្ការាទិសុខំ សម្បរាយេ ច ទិព្វសម្បត្តិសុខំ អនុភវមានោ សោ ភទ្រោ ភទ្រានិយេវ បស្សតិ** ប្រែថា **អថ** ក្នុងកាលនោះ **ភទ្រោ** វីបុគ្គលល្អ **សោ** នោះ **អនុភវមានោ** កាលទទួល **ទិដ្ឋធម្មេ លាភសក្ការាទិសុខំ ច** នូវសេចក្ដីសុខមានសេចក្ដីសុខដែលកើតអំពីលាភ និងសក្ការៈជាដើមក្នុងបច្ចុប្បន្នក្ដី **សម្បរាយេ ទិព្វសម្បត្តិសុខំ ច** នូវសេចក្ដីសុខ

ដែលកើតអំពីទិព្វសម្បត្តិក្នុងបរលោកក្តី **បស្សតិ** ឈ្មោះថាឃើញ **ភទ្រានិ ឯវ** នូវសេចក្តីចម្រើនទាំងឡាយមែនពិត (ធ.ប.៥ ទំព័រ២១) ។

**ប្រែកល់ហេតុ** : សិក្ខាកាមគប្បីកំណត់គោលយ៉ាងនេះ បើបទនាម, គុណបទ ដែលលោក លើកអំពីគាថាមករៀងទុកនៅខាងក្រោយបទកៃ ឯបទកៃនោះ លោកប្រកបតតិយាវិភត្តិ ឬ បញ្ចមីវិភត្តិ ប្រែថា "ហេតុ ឬ ព្រោះ" ដើម្បីប្រាប់ហេតុផល ។ កាលបើព្រមដោយអង្គនេះ បទដែលមានក្នុងគាថា ត្រូវប្រែកល់ហេតុថា "ឈ្មោះថា" ដូចជា **ឧបដ្ឋិ-តស្សតិតាយ ហិ អប្បមត្តោ ឈាយន្តោ បុគ្គលោ** ប្រែថា **ហិ** ក៏ **បុគ្គលោ** រីបុគ្គល **ឈាយន្តោ** កាលពិនិត្យ **អប្បមត្តោ** ឈ្មោះថាអ្នកមិនប្រមាទ **ឧបដ្ឋិតស្សតិតាយ** ព្រោះភាវៈនៃគាត់ជាអ្នកមានស្មារតីតម្កល់មាំហើយ (ធ.ប.២ ទំព័រ១៥៤) ។

**តិស្សន្នំ វា អដ្ឋន្នំ វា វិជ្ជានំ បញ្ច ទសន្នញ្ច ចរណានំ សម្បត្តិយា សម្បន្នវិជ្ជាចរណា ឧបដ្ឋិតស្សតិតាយ បដិស្សតា ហុត្វា ឥទំ អនប្បកំ វដ្តទុក្ខំ បជហិស្សថ** ប្រែថា

**តុម្ហេ** រីអ្នកទាំងឡាយ **តិស្សន្នំ វា អដ្ឋន្នំ វា វិជ្ជានំ ច បញ្ច-ទសន្នំ ចរណានំ សម្បត្តិយា សម្បន្នវិជ្ជាចរណា ឧបដ្ឋិ-តស្សតិតាយ បដិស្សតា ហុត្វា** ឈ្មោះថាជាអ្នកមាន វិជ្ជា និង ចរណៈសម្រេចហើយ ព្រោះកិរិយាសម្រេចនូវវិជ្ជាទាំងឡាយ ៣ ឬ ៨ ផង នូវចរណៈទាំងឡាយ ១៥ ផង ឈ្មោះថាជាអ្នក រលឹកចំពោះ ព្រោះភាវៈនៃអ្នកទាំងឡាយ ជាអ្នកមានស្មារតី តម្កល់មាំហើយ **បជហិស្សថ** និងលះបង់ **វដ្តទុក្ខំ** នូវវដ្តទុក្ខ **អនប្បកំ** មានប្រមាណមិនតិច **ឥធំ** នេះ (ធ.ប.៥ ទំព័រ១២២) ។

វិធីប្រែដកហេតុ និងប្រែកល់ហេតុនេះមិនមានពាក្យ ហៅ ដោយផ្លូវសម្ព័ន្ធទេ ត្រូវហៅតាម សម្ព័ន្ធធម្មតាគឺ បើបទ នាមនាម ហៅតាមអត្ថរបស់វិភត្តិនាម, បើ គុណនាម ហៅថា វិសេសនៈ ឬ វិកតិកត្តា, បើជាកិរិយា ហៅថា អាខ្យាតបទ ឬ កិតបទ ដូចបទដែលលើកមកជាឧទាហរណ៍នេះ គឺត្រង់បទ ថា **អប្បមត្តោ** ហៅថា វិសេសនៈរបស់ **បុគ្គលោ**, **សម្បន្ន-វិជ្ជាចរណា** និង **បដិស្សតា** ហៅថា **វិកតិកត្តា** ក្នុង **ហុត្វា**,

**បស្សតិ** និង **បជហិស្សថ** ហៅថា អាខ្យាតបទ-កត្តុវាចកៈ ។

## វិធីប្រែអដ្ឋកថាពិសេស

វិធីនេះបំភ្លឺក្នុងការប្រែអដ្ឋកថា តែនិយាយចំពោះត្រង់សេចក្ដីដ៏សេសសល់ ដែលក្នុងវិធី គោលប្រែអដ្ឋកថាមិនបាននិយាយដល់ ។

១. បើយកនិបាតមកតាំងហើយមានពាក្យថា **និបាតោ** នៅទីបំផុតរបស់បទកែ កាលនឹងប្រែ ត្រូវបំពេញថា **បទំ** ឬ **សទ្ទោ** តភ្ជាប់នឹង **ឥតិ** ត្រង់ចុងនៃបទដែលលើកមកតាំងហើយបំពេញ **វត្តតិ** តពី **និបាតោ** ដូចជា **យាវទេវាតិ អវធិបរិច្ឆេទនត្ថេ និបាតោ** ប្រែថា **បទំ** រីបទ ឬ **សទ្ទោ** រីសព្ទ **យាវទេវ ឥតិ** ថា ... ដូច្នេះ **និបាតោ** ជានិបាត **វត្តតិ** ប្រព្រឹត្តទៅ **អវធិបរិច្ឆេទនត្ថេ** ក្នុងអត្ថថា ជាគ្រឿងកំណត់កាត់នូវខេត្តដែន (ធ.ប.៣ ទំព័រ២៧០) ។

២. តាំងអត្ថរួចហើយ បើបទកែមាននិបាតសព្ទ ប្រែនិបាតស្រេចហើយ ត្រូវប្រែតួប្រធាន តែបើមិនមាននិបាតទេ ប្រែបទកែក៏បាន ។ មាននិបាត ដូចជា **អប្បមត្តា ន**

**មីយន្តីតិ សតិយា សមន្នាគតា ហិ អប្បមត្តា** ប្រែថា **ហិ** ក៏ **ជនា** រី... **សមន្នាគតា** ប្រកបព្រមហើយ **សតិយា** ដោយ **សតិ**, **អប្បមត្តា** ឈ្មោះថា មិនប្រមាទហើយ (ធ.ប.២ ទំព័រ ១១២) ។ មិនមាននិបាត ដូចជា **សុចិកម្មស្សាតិ និទ្ទោសេហិ និរបរាធេហិ កាយកម្មាទីហិ** ដោយកម្មទាំងឡាយ មាន កាយកម្ម ជាដើម **និទ្ទោសេហិ** ដែលឥតទោស **និទ្ទោសេហិ** គឺថា **និរបរាធេហិ**ៗ ដែលឥតកំហុស ឬ មិនមានកំហុស (ធ.ប.២ ទំព័រ១២៧) ។

៣. បើលោកលើកបទក្នុងគាថាមកតាំងក្នុងទីបំផុត នៃ បទកែ មានពាក្យថា **ឥទំ**, **ឯតំ** (**អធិវចនំ**), **នាមំ**, ក្នុងទី ដូច្នេះ មិនត្រូវតាំងអត្ថទេ, **ឥទំ** ឬ **ឯតំ** ក្នុងបទកែនោះ ត្រូវ យោគ **បទំ** ឬ **វចនំ** ចូលមកដូចជា **មុទ្ធន្តិ បញ្ញាយេតំ នាមំ**, មាន **ឯតំ** ផង មាន **នាមំ** ផង មិនត្រូវតាំងអត្ថទេ ប្រែ : **ឯតំ បទំ** រីបទនេះ **មុទ្ធំ ឥតិ** ថាក្បាល ដូច្នេះ **នាមំ** ជាឈ្មោះ **បញ្ញាយ** នៃប្រាជ្ញា (ធ.ប.៣ ទំព័រ២៧០) ។ **បោសស្សាតិ ឥទម្បិ អបរេនាការេន សត្តាធិវចនមេវ** ប្រែថា **ឥទំ បិ**

**បទំ** ក៏រីបទនេះ **ឃោសស្ស ឥតិ** ថា **ឃោសស្ស** ដូច្នេះ **អបរេន អាការេន សត្តាធិវចនំ ឯទ** ជាឈ្មោះរបស់សត្វដោយអាការៈដទៃមែនពិត (ធ.ប.១ទំព័រ៤៩) ។

៤. អដ្ឋកថាណា លោកលើកបទក្នុងគាថាមកតាំងត្រឹមតែមួយបទ ឬ ពីរបទដល់លោកកែចេញទៅ កែដោយទាំងបទដែលមិនបានលើកមកតាំងដូច្នេះ : **តត្ថ មូលេតិ យស្ស រុក្ខស្ស ចតូសុ ទិសាសុ ។បេ។ និព្វត្តតិ យេវាតិ អត្ថោ** អដ្ឋកថានេះ លោកលើកតែ **មូលេ** មួយបទមកតាំង កាលបើដូច្នេះ **ឥតិ**-សព្ទ ដែលរៀងទុកក្នុងទីបំផុតក្នុងបទតាំង ត្រូវប្រែជា **អាទ្យត្ថៈ** ថា **អត្ថោ** រីអត្ថ **យស្សរុក្ខស្ស ។បេ។ និព្វត្តតិ យេវ ឥតិ** ថាដូច្នេះ **តត្ថ បទេសុ** ជំនុំបទទាំងឡាយនោះ **បទស្ស** នៃបទ **មូលេតិ** ថាដូច្នេះជាដើម (ធ.ប.៨ទំព័រ១៥) ។

៥. បើអដ្ឋកថាដែលលោករៀង **ឥទំ វុត្តំ ហោតិ** នៅខាងដើមនៃបទដែលលោកអធិប្បាយក្នុងវេលាប្រែ បទថា **ឥទំ** នោះត្រូវយោគ **អត្ថរូបំ** រូបនៃសេចក្ដី ឬ **វចនំ** ពាក្យ ដូចជា **ឥទំ វុត្តំ ហោតិ យថា មហាទ្ធនោ** ។បេ។ **បាបានិ**

**បរិវជ្ជេយ្យាតិ** ប្រែថា **ឥទំ អត្ថរូបំ** រីរូបនៃសេចក្តីនេះ **យថា មហាទ្ធនោ ។បេ។ បរិវជ្ជេយ្យ ឥតិ** ថា ... ដូច្នេះ **វុត្តំ ហោតិ** ជាពាក្យអធិប្បាយ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ (ធ.ប.៥ ទំព័រ៣៣) ។

ការប្រែតាមអត្ថ គឺការប្រែបាលីយកសេចក្តី ដើម្បីឲ្យប្រជាជនខ្មែរស្តាប់បានដោយងាយ ព្រោះការប្រែភាសាបាលីតាមសព្ទ គឺការប្រែលោតប្រយោគតាមក្បួន វេយ្យាករណ៍មានប្រយោគ **កត្តុ**, **កម្ម**, **ភាព** ជាដើម ដូចជា **សូទេន ឱទនោ ភុញ្ជិយតេ** "រីបាយគឺអ្នកគ្រួកំពុងបរិភោគ" **កម្មវាចកៈ**; ឬ "គឺអ្នកគ្រួកំពុងបរិភោគនូវបាយ" **ភាវវាចកៈ** យ៉ាងនេះខ្មែរមិនធ្លាប់ប្រើទេ គេច្រើនតែនិយាយថា "អ្នកគ្រួពិសាបាយ" **កត្តុវាចកៈ** ។ "ម្តាយឲ្យកូនញ៉ាំបាយ" **ហេតុកត្តុវាចកៈ** ។ រឿងនេះយើង សង្កេតឃើញថា ខ្មែរចូលចិត្តនិយាយគ្នាជាប្រយោគ **កត្តុវាចកៈ** និង **ហេតុកត្តុវាចកៈ** ទាំងពាក្យអាយតនិបាតខ្លះ ដូចជា "រី..., នូវ..., ញុំាង..." ជាដើម ក៏មិន

ប្រើដែរ ហេតុនេះការប្រែភាសាបាលី គប្បីសម្រួលសេចក្ដីឲ្យខ្មែរស្ដាប់បានងាយដោយវិធីផ្លាស់ ប្រយោគ **កម្មវាចកៈ** មកជា **កត្តុវាចកៈ** ជាដើម និង លុបពាក្យអាយតនិបាតខ្លះតម្រូវតាមសំនួនវោហារខ្មែរនិយម ។

## ការប្រែដោយអត្ថ គួរមានគោលដូច្នេះ

១. លំដាប់ការប្រែ គឺប្រែ **អាលបនៈ**, **និបាត**, **កាលសត្តមី**, **បទប្រធាន** និង **បទតុល្យ** ជាដើមតទៅ ដូចជា :

**អថស្ស នចិរស្សេវ ភរិយាយ គព្ភោ បតិដ្ឋាសិ ។ សា គព្ភស្ស បតិដ្ឋិតភាវំ ញត្វា តស្ស អារោចេសិ ។**

**ប្រែតាមសព្ទ** : គ្រានោះវិសត្វដែលកើតហើយក្នុងគភ៌តាំងនៅស៊ប់ហើយក្នុងផ្ទៃនៃភរិយា របស់កុដុម្ពីក៏នោះចំពោះកាលមិនយូរមែនពិត ។ វីភរិយានៃកុដុម្ពីក៏ នោះដឹងហើយនូវភាវៈនៃសត្វ ដែលកើតហើយក្នុងគភ៌ ជាអ្នកតាំងនៅស៊ប់ហើយ ប្រាប់ដល់កុដុម្ពីក៏នោះ ។

**ប្រែតាមអត្ថ** : គ្រានោះ មិនយូរប៉ុន្មាន ភរិយារបស់កុដុម្ពីក៏នោះ ក៏មានគភ៌តាំងនៅស៊ប់ហើយ ។ នាងដឹងថា

មានគភ៌ហើយ ទើបប្រាប់ដល់កុដុម្ពិក៍នោះ ។

តាមឧទាហរណ៍នេះ យើងឃើញបានថា លំដាប់ការប្រែតាមអត្ថ ត្រូវប្រែសព្ទ ដែលទាក់ទងនឹងពេលវេលា គេតែងនិយមប្រែមុនជានិច្ចដើម្បីឲ្យជាសំនួនភាសាខ្មែរ ។

២. ការប្រែដោយអត្ថត្រូវឲ្យខ្លី ការប្រែតាមអត្ថ នឹងត្រូវព្យាយាមមិនឲ្យវែងឆ្ងាយ ដូចប្រែតាមសព្ទទេ ដោយសម្រួលសំនួនភាសាឲ្យសមតាមរឿងនោះៗ ប្រៀបធៀបការប្រែទាំងពីរ យ៉ាងដូចតទៅនេះ :

**១) សាវត្ថិយំ កិរ ឯកោ មហាសុវណ្ណោ នាម កុដុម្ពិកោ អហោសិ អឌ្ឍោ មហទ្ធនោ មហាភោគោ អបុត្តកោ ។**

**ប្រែតាមសព្ទ** : បានឮថា រីកុដុម្ពីក៍ម្នាក់ឈ្មោះថាមហាសុវណ្ណៈជាមនុស្សស្ដុកស្ដម្ភ ជាមនុស្សមានទ្រព្យច្រើន ជាអ្នកមានភោគច្រើន ជាអ្នកមានកូនមិនមាន បានមានហើយក្នុងក្រុងសាវត្ថី ។

**ប្រែតាមអត្ថ** : បានឮថា ក្នុងក្រុងសាវត្ថី មានកុដុម្ពិក៍ម្នាក់ឈ្មោះមហាសុវណ្ណៈ ជាអ្នក ស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគច្រើន តែមិនមានកូន ។

**២) អនាថបិណ្ឌិកោបិ វិសាខាបិ មហាឧបាសិកា និច្ចំ ទ្វេ វារេ តថាគតស្ស ឧបដ្ឋានំ គច្ឆន្តិ ។**

**ប្រែតាមសព្ទ** : រីសេដ្ឋីឈ្មោះអនាថបិណ្ឌិកក្តី រីមហាឧបាសិកាឈ្មោះវិសាខាក្តី តែងទៅកាន់ទីបម្រើរបស់ព្រះតថាគត អស់វារៈទាំងឡាយពីរដងនៃថ្ងៃជានិច្ច ។

**ប្រែតាមអត្ថ** : អនាថបិណ្ឌិកសេដ្ឋីក្តី មហាឧបាសិកាវិសាខាក្តី តែងទៅគាល់ ព្រះតថាគត មួយថ្ងៃពីរដងជានិច្ច ។

**៣) មនុស្សា តេសំ ភិក្ខូនំ បដិញ្ញំ គហេត្វា វិហារំ បដិជគ្គិត្វា រត្តិដ្ឋានទិវាឋានានិ សម្បាទេត្វា អទំសុ ។**

**ប្រែតាមសព្ទ** : រីមនុស្សទាំងឡាយកាន់យកហើយនូវការប្តេជ្ញានៃភិក្ខុទាំងឡាយនោះ ទំនុកបម្រុងហើយនូវវិហារ ញុំាងទីជាទីសម្រាកក្នុងវេលាយប់ និងទីជាទីសម្រាកក្នុងវេលាថ្ងៃទាំងឡាយឲ្យដល់ព្រមហើយ បានប្រគេនហើយ ។

**ប្រែតាមអត្ថ** : មនុស្សទាំងឡាយទទួលពាក្យប្តេជ្ញារបស់ភិក្ខុទាំងនោះហើយ បានតាក់តែងវិហារ ចាត់ចែងទីស្នាក់ពេលយប់ និងទីស្នាក់នៅពេលថ្ងៃប្រគេនហើយ ។

**៤) មយំ ហិ ធរមានស្ស ពុទ្ធស្ស សន្តិកេ កម្មដ្ឋានំ**

**គហេត្វា អាគតា ។ ពុទ្ធា ច នាម ន សក្កា សចេន អារាធេតុំ ។ កល្យាណជ្ឈាសយេន ហោតេ អារាធេតព្វា ។ ចមត្តស្ស ច នាម ចត្តារោ អបាយា សកគេហសទិសា អប្បមត្តា ហោថាវុសោ ។**

**ប្រែតាមសព្ទ** : ព្រោះថាវីយើងទាំងឡាយ រៀនហើយ នូវកម្មដ្ឋានក្នុងសំណាក់ នៃព្រះពុទ្ធទ្រង់ព្រះជន្មនៅឡើយ ជាអ្នកមកហើយ ក៏ឈ្មោះថា វីព្រះពុទ្ធទាំងឡាយ គឺបុគ្គល អ្នកអួតអាង មិនអាចដើម្បីញុំាំងព្រះអង្គឲ្យប្រោសប្រាណ បានទេ ដោយហេតុថា វីព្រះពុទ្ធទាំងឡាយនោះ គឺបុគ្គលមានអធ្យាស្រ័យល្អ គប្បីញុំាំងព្រះអង្គឲ្យប្រោសប្រាណបានម្យ៉ាងទៀត វីអបាយទាំងឡាយ ៤ ប្រាកដដូចជាផ្ទះរបស់ខ្លួនឈ្មោះថានៃបុគ្គលប្រមាទហើយ ម្នាលលោកអ្នកមានអាយុទាំងឡាយ វីលោក ទាំងឡាយចូរជាអ្នកមិនប្រមាទហើយ ។

**ប្រែតាមអត្ថ** : ព្រោះថា ពួកយើងរៀនកម្មដ្ឋានក្នុងសំណាក់ព្រះពុទ្ធ ដែលទ្រង់មានព្រះជន្មនៅឡើយ ទើបនាំគ្នាមក ក៏ធម្មតាព្រះពុទ្ធទាំងឡាយគឺអ្នកអួតអាង មិនអាច

ញ៉ាំងព្រះអង្គឲ្យប្រោសប្រាណបានទេ ដោយហេតុថា ព្រះពុទ្ធទាំងឡាយនោះ អ្នកមានអធ្យាស្រ័យល្អទើបធ្វើឲ្យ ព្រះអង្គប្រោសប្រាណបាន ម្យ៉ាងទៀត ធម្មតាអ្នកដែលប្រមាទតែងមានអបាយ៤កើតដូចជាផ្ទះរបស់ខ្លួន ចូរអ្នកទាំងឡាយជាអ្នកមិនប្រមាទចុះ ។

**៥) ភិក្ខវេ តទា មម បុត្តេន កតកម្មំ បច្ឆតោ បច្ឆតោ អនុពន្ធិ ។ បាបកម្មំ ហិ នាមេតំ ធុរំ វហតោ ពលិពទ្ទស្ស បទំ ចក្កំ វិយ អនុគច្ឆតិ ។**

**ប្រែតាមសព្ទ** : ម្នាលភិក្ខុទាំងឡាយ រីកម្មគឺបុត្ររបស់យើងធ្វើហើយក្នុងកាលនោះ ជាប់ហើយតាមក្រោយៗ ព្រោះថា ឈ្មោះថារីបាបកម្មនេះតែងជាប់តាមទៅ ដូចជារីកង់កំពុងជាប់តាមនូវស្នាមជើងនៃគោដែលមានកម្លាំង កំពុងនាំទៅនូវនឹម ។

**ប្រែតាមអត្ថ** : ម្នាលភិក្ខុទាំងឡាយ កម្មគឺបុត្ររបស់យើងធ្វើទុកក្នុងពេលនោះ បានជាប់តាមមកខាងក្រោយៗ ព្រោះធម្មតា បាបកម្មនេះតែងជាប់តាមបុគ្គល ដូចកង់រិល

ទៅតាម ស្នាមជើងគោដែលអូសនឹមទៅដូច្នោះ ។

**៦)អយំ ព្រាហ្មណោ ធនច្ឆេទភយេន មម គេហំ អកាវេត្វា ឥទានិ អាឡាហនំ គន្ត្វា រោទតិ, ទិព្វភាវប្បត្តំ នំ ករិស្សាមិ ។**

**ប្រែតាមសព្ទ** : រីព្រាហ្មណ៍នោះ មិនញុំាងបុគ្គលឲ្យធ្វើហើយ នូវថ្នាំដល់យើង ព្រោះការខ្លាច អំពីកិរិយាអស់ទៅនៃទ្រព្យ ពេលនេះទៅហើយកាន់ព្រៃស្មសាន តែងយំ, រីយើងនឹងធ្វើនូវព្រាហ្មណ៍នោះឲ្យជាអ្នកដល់ហើយនូវប្រការដ៏ចំឡែក ។

**ប្រែតាមអត្ថ** : ព្រាហ្មណ៍នោះមិនឲ្យថ្នាំដល់យើង ព្រោះខ្លាចអស់ទ្រព្យ ឥឡូវនេះទៅប៉ាឆា ហើយយំ យើងនឹងធ្វើឲ្យគាត់ដល់ប្រការចំឡែក ។

**៧) អច្ឆរិយា ខត ភោ ពុទ្ធគុណា, អទិន្នបុព្វកព្រាហ្មណស្ស នាម បុត្តោ អញ្ញំ កិញ្ចិ បុញ្ញំ អកត្វា សត្ថរិ មនំ បសាទេត្វា ឯវរូបំ សម្បត្តឹ បដិលភតិ ។**

**ប្រែតាមសព្ទ** : ម្នាលអ្នកដ៏ចម្រើន រីព្រះពុទ្ធគុណ

ទាំងឡាយជាគុណគួរអស្ចារ្យ ណាស់ហ្ន៎ រីបុត្ររបស់ អទិន្ន-បុព្វកព្រាហ្មណ៍ មិនធ្វើហើយនូវបុណ្យអ្វីៗ ដទៃ ញុំាងចិត្តឲ្យជ្រះថ្លាហើយ ក្នុងព្រះសាស្តាបានចំពោះហើយ នូវសម្បត្តិមានសភាពយ៉ាងនេះ ។

**ប្រែតាមអត្ថ** : អ្នកដ៏ចម្រើនទាំងឡាយ ព្រះពុទ្ធគុណគួរអស្ចារ្យមែនហ្ន៎ បុត្ររបស់អទិន្នបុព្វកព្រាហ្មណ៍ មិនបានធ្វើបុណ្យអ្វីដទៃឡើយ បានធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះសាស្តាប៉ុណ្ណោះ ក៏បានសម្បត្តិយ៉ាងនេះ ។

ឧទាហរណ៍ទាំង ៧ នេះ កាលបើប្រៀបធៀបសំនួនប្រែតាមអត្ថ នឹងឃើញថា សំនួនប្រែតាមអត្ថមានភាពខ្លី និងមានលក្ខណៈជាភាសាខ្មែរ ដែលងាយយល់បាន ។

៣. ការប្រែបទសមាស ត្រូវសម្រួលវោហារ ហើយបទសមាសខ្លះ បើប្រែតាមលក្ខណៈវេយ្យាករណ៍ នឹងក្លាយទៅជាភាសាខ្មែរដែលពិបាកយល់ ។ អ្នកដែលមិនបានរៀនវេយ្យាករណ៍បាលី រឹតតែងឿងឆ្ងល់ខ្លាំង កាលបើប្រែតាមអត្ថទើបចាំបាច់ត្រូវចេះសម្រួលវោហារ ឬពាក្យឲ្យទៅជា

ភាសាខ្មែរដែលសមគួរដល់រឿងនោះៗ ដូចតទៅនេះ :

**១) សោ មហាបាលោ សត្ថុ សន្តិកំ គន្ត្វា បព្វជ្ជំ យាចិត្វា លទ្ធប្បព្វជ្ជូបសម្បទោ អាចរិយុបជ្ឈាយានំ សន្តិកេ បញ្ច វស្សានិ វសិត្វា វុដ្ឋវស្សោ បវារេត្វា សត្ថារំ ឧបសង្កមិត្វា វន្ទិត្វា បុច្ឆិ ។**

**ប្រែតាមសព្ទ** : រីមហាបាលនោះ ទៅហើយកាន់សំណាក់ របស់ព្រះសាស្តា ទូលសូមហើយ នូវបព្វជ្ជា មានបព្វជ្ជា និងឧបសម្បទាបានហើយ នៅហើយក្នុងសំណាក់នៃអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយ អស់វស្សាទាំងឡាយ ៥ មានវស្សានៅរួចហើយ បវារណាហើយ ចូលទៅគាល់ហើយនូវព្រះសាស្តា ថ្វាយបង្គំហើយ ទូលសួរហើយ ។

**ប្រែតាមអត្ថ** : មហាបាលនោះទៅកាន់សំណាក់ព្រះសាស្តាហើយទូលសូមផ្នួស បានទទួលនូវបព្វជ្ជា និងឧបសម្បទា ហើយនៅក្នុងសំណាក់អាចារ្យ និង ឧបជ្ឈាយ៍ អស់ ៥ វស្សា កាលបើចេញវស្សាបវារណារួចហើយ បានទៅគាល់ព្រះសាស្តា ក្រាបបង្គំទូលសួរហើយ ។

**២) អថ ព្រាហ្មណោ ភគវតោ ភិច្ចំ តថាគតំ**

**ឧបសង្កមិត្វា នីចាសនេ និសិន្នោ បញ្ហំ បុច្ឆិ ។**

**ប្រែតាមសព្ទ** : គ្រានោះ វិព្រាហ្មណ៍ចូលទៅរក ហើយនូវព្រះតថាគត អ្នកមានភត្តកិច្ចធ្វើហើយ អង្គុយហើយ លើអាសនៈទាប ទូលសួរហើយនូវបញ្ហា ។

**ប្រែតាមអត្ថ** : គ្រានោះ ព្រាហ្មណ៍បានចូលទៅរក ព្រះតថាគតដែលសោយភត្តាហាររួចហើយ បានអង្គុយលើ អាសនៈទាប ហើយទូលសួរបញ្ហា ។

៣) **តាទិសេន បាបេន មម យដ្ឋិកោដិគ្គហនកិច្ចំ នត្ថិ ។**

**ប្រែតាមសព្ទ** : វិកិច្ចគឺកិរិយាកាន់យកនូវចុងនៃ ឈើច្រត់របស់យើង ដោយបុគ្គលអ្នកមានបាបដូចជាអ្នក មិនមានទេ ។

**ប្រែតាមអត្ថ** : មនុស្សបាបដូចជាអ្នកមិនបាច់កាន់ ចុងឈើច្រត់របស់យើងទេ ។

៤) **កោសម្ពិយំ ហិ ឃោសិតារាមេ បញ្ចសតបញ្ច-សតបរិវារា ទ្វេ ភិក្ខូ វិហរឹសុ វិនយធរោ ច ធម្មធរោ ច ។**

**ប្រែតាមសព្ទ** : ដូចនឹងពោលដោយពិស្តារ វីភិក្ខុ

ទាំងឡាយពីរអង្គគឺ វីព្រះវិន័យធរ ១ វីព្រះធម្មធរ ១ ជាអ្នកមានបរិវារមានរយប្រាំ និង រយប្រាំជាប្រមាណ នៅហើយក្នុងឃោសិតារាមជិតក្រុងកោសម្ពី ។

**ប្រែតាមអត្ថ** : ដោយសេចក្តីថា ភិក្ខុពីររូបគឺ ព្រះ-វិន័យធរ និង ធម្មធរ មានបរិវារប្រាំរយៗ បាននៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។

៥) **ថេរោ ចក្កវត្តិរញ្ញោ សន្តិកា បដិលទ្ធមហាលាភោ មហាយោធោ វិយ តុដ្ឋមានសោ សាវកបារមិញាណេ ឋត្វា បុច្ឆាសនានុមោទនំ អារភិ ។**

**ប្រែតាមសព្ទ** : វីព្រះថេរៈជាអ្នកមានចិត្តត្រេកអរហើយដូចជាវីទាហានជាន់ខ្ពស់ដែលមានលាភច្រើនបានចំពោះហើយពីសំណាក់នៃស្តេចចក្រពត្តិ តាំងនៅហើយក្នុងសាវកបារមីញាណ ផ្តើមហើយនូវបុប្ផាសនានុមោទនា ។

**ប្រែតាមអត្ថ** : ព្រះថេរៈមានចិត្តត្រេកអរ ដូចនាយទាហានធំ ដែលបានទទួលព្រះរាជទាន លាភដ៏ច្រើនអំពីសំណាក់ស្តេចចក្រពត្តិ បានតាំងនៅក្នុងសាវកបារមីញាណ ហើយប្រារព្ធបុប្ផាសនានុមោទនា ។

៦) **សត្ថា ... សហម្បតិព្រហ្មុនា អាយាចិតធម្មទេសនោ**

**ពុទ្ធចក្ខុនា លោកំ ឱលោកេត្វា ព្រហ្មុនោ អជ្ឈេសនំ អធិវាសេសិ ។**

**ប្រែតាមសព្ទ** : រីព្រះសាស្តា ... មានធម៌ទេសនាដែលសហម្បតីព្រហ្មទូលសូមហើយ ទ្រង់ប្រមើលមើលនូវសត្វដោយពុទ្ធចក្ខុហើយ ទ្រង់ញ៉ាំងពាក្យអារាធនានៃព្រហ្មឲ្យតាំងនៅហើយ ។

**ប្រែតាមអត្ថ** : ព្រះសាស្តា ... បើស្តេចសហម្បតីព្រហ្មក្រាបបង្គំសូមព្រះធម៌ទេសនា ទូលសូមឲ្យទ្រង់សម្តែងធម៌ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ហើយទ្រង់ទទួលអារាធនា របស់ព្រហ្ម ។

៧) **ទ្វេបិ ជនា បញ្ចបញ្ចមាណវកសតបរិវារា ហោន្តិ ។**

**ប្រែតាមសព្ទ** : រីជនទាំងឡាយទាំងពីរនាក់ ជាអ្នកមានរយនៃមាណពប្រាំ និង ប្រាំជាបរិវារ តែងមាន ។

**ប្រែតាមអត្ថ** : ទោះបីអ្នកទាំងពីរមានមាណពជាបរិវារប្រាំរយៗ ។ ឧទាហរណ៍ទាំងអស់នេះ នឹងឃើញបាន

ថាបទ សមាសខ្លះ កាលប្រែតាមអត្ថ ត្រូវចេះប្រែដកយកសេចក្ដីឲ្យច្បាស់លាស់ ដោយការសម្រួលវោហារឲ្យជាភាសាខ្មែរដែលសមគួរ ទើបនឹងបានសេចក្ដីល្អ ។

៤. **ការប្រែតាមសព្ទ** ដែលចូលជាបទសមាសនឹងភាវតទ្ធិត, ភាវសព្ទដែលចូលបទសមាស ចូលនឹងសព្ទនាម ឬ នាមកិតកៈខ្លះ, កិរិយាកិតកៈខ្លះ, អាខ្យាតខ្លះ និង សព្ទភាវ-តទ្ធិត **តា**-បច្ច័យ កាលនឹងប្រែតាមអត្ថ ត្រូវសម្រួលពាក្យឲ្យខ្លី ឲ្យជាសំនួន ភាសាខ្មែរគួរយល់បានងាយ អាចប្រែកម្មវាចកៈជាកត្តុវាចកៈខ្លះ កាត់ក្បួនវេយ្យាករណ៍ខ្លះ មិនគួរឲ្យមានសេចក្ដី វែងឆ្ងាយទេ ឲ្យសង្កេតតួយ៉ាងតទៅ នេះ :

**ក. នាមកិតកៈ នាមនាម គុណនាម តាមសព្ទ**

**១) អថស្ស សត្ថា អត្តនោ អបស្សនភាវំ ញត្វា ឯកំ រំសឹ វិស្សជ្ជេសិ ។**

**ប្រែតាមសព្ទ** : គ្រានោះ រីព្រះសាស្ដាទ្រង់ជ្រាបហើយនូវភាវៈ គឺកិរិយាមិនឃើញនូវព្រះអង្គ នៃមដ្ឋកុណ្ឌលីនោះទ្រង់ផ្សាយទៅហើយនូវរស្មីមួយខ្សែ ។

**ប្រែតាមអត្ថ** : គ្រានោះ ព្រះសាស្ដាទ្រង់ជ្រាបថា

មដ្ឋកុណ្ឌលីនោះ មិនឃើញព្រះអង្គ ទើបទ្រង់ផ្សាយរស្មីមួយខ្សែ ។

នឹងប្រែ **តាទ**-សព្ទ ដែលនៅជាមួយសកម្មកិរិយាថា "ថា..." ក៏រឹតតែធ្វើឲ្យបានសេចក្តីច្បាស់ ប្រយោគយ៉ាងនេះគួរប្រែថា : គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបថា មដ្ឋកុណ្ឌលីនោះនឹងមិនឃើញព្រះអង្គ ។

២) **តថាគតស្ស តត្ថ ហត្ថិនាគេន ឧបដ្ឋិយមានស្ស វសនភាវោ សកលជម្ពូទីបេ បាកដោ អហោសិ ។**

**ប្រែតាមសព្ទ** : រីភាវៈគឺកិរិយាប្រថាប់នៅនៃព្រះតថាគត ដែលដំរីដ៏ប្រសើរ កាលបម្រើក្នុងទីនោះ ជាអាការប្រាកដហើយក្នុងជម្ពូទ្វីបទាំងមូល បានមានហើយ ។

**ប្រែតាមអត្ថ** : ការដែលព្រះតថាគត មានដំរីដ៏ប្រសើរ កំពុងបម្រើទ្រង់ប្រថាប់នៅហើយក្នុងទីនោះ បានជាដំណឹងល្បីល្បាញពាសពេញជម្ពូទ្វីប ។

៣) **អយំ តាបសោ ពុទ្ធភាវំ មេ ជានាតុ ។**

**ប្រែតាមសព្ទ** : រីតាបសនេះ ចូរដឹងនូវភាវៈនៃយើងជាព្រះពុទ្ធ ។

**ប្រែតាមអត្ថ** : តាបសនេះ ចូរដឹងនូវភាពនៃយើងជា

ព្រះពុទ្ធ ឬ តាបសនេះ ចូរដឹងថា យើងជាព្រះពុទ្ធ ។

៤) **ព្រាហ្មណោ តស្ស ទុព្វលភាវំ ញត្វា ឯកំ វេជ្ជំ បក្កោសិ ។**

**ប្រែតាមសព្ទ** : រីព្រាហ្មណ៍ដឹងហើយនូវភាវៈនៃបុត្រនោះជាអ្នកមានកម្លាំងគឺរោគប្រទូសហើយ ហៅមកហើយនូវគ្រូពេទ្យម្នាក់ ។

**ប្រែតាមអត្ថ** : ព្រាហ្មណ៍ដឹងថា កូននោះ មានកម្លាំងខ្សោយ ទើបហៅ ពេទ្យម្នាក់មក ។

៥) **តំ ករោន្តស្សេវស្ស រោគោ ពលវា អហោសិ ។ អតេកិច្ឆភាវំ ឧបាគមិ ។**

**ប្រែតាមសព្ទ** : កាលបើព្រាហ្មណ៍កំពុងធ្វើនូវថ្នាំនោះឯង រីរោគជាសភាវៈមានកម្លាំងបានកើតហើយ ចូលដល់ហើយ នូវភាពជារោគ ដែលនរណាៗ មិនគួររក្សាបាន ។

**ប្រែតាមអត្ថ** : កាលព្រាហ្មណ៍កំពុងធ្វើថ្នាំនោះឯងរោគដ៏ខ្លាំងកើតឡើងដល់ថ្នាក់គឺពេទ្យរក្សាមិនបាន ។

**ខ. កិរិយាកិតកៈ ភាវ**-សព្ទ : **ភាវ**-សព្ទដែលចូលជាបទសមាសជាមួយកិរិយាសព្ទនោះ កាលបើប្រែតាមអត្ថ នឹង

ត្រូវសម្រួលពាក្យឲ្យខ្លីជាភាសាខ្មែរ ដែលងាយយល់ដូចតទៅ :

**១) អថស្ស មម ចក្ខូនំ បរិហីនតាវំ អារោចេយ្យាថ ។**

**ប្រែតាមសព្ទ** : គ្រានោះ រីអ្នកទាំងឡាយ ចូរប្រាប់នូវភាពនៃចក្ខុទាំងឡាយរបស់យើងជាអវយវៈសាបសូន្យអស់ហើយ ដល់ប្អូនប្រុសរបស់យើងនោះ ។

**ប្រែតាមអត្ថ** : ពេលនោះ ពួកអ្នកចូរប្រាប់ថា ដែលភ្នែករបស់យើងខ្វាក់ហើយ ដល់ប្អូនប្រុសរបស់យើង នោះ ឬ ពួកអ្នកចូរប្រាប់ប្អូនប្រុសរបស់យើងថា ភ្នែករបស់យើងខ្វាក់ហើយ ។

**២) អាចរិយ តុម្ហាកំ ឥធ និបន្នភាវំ ន ជានាមិ ។**

**ប្រែតាមសព្ទ** : បពិត្រលោកអាចារ្យ រីខ្ញុំតែងមិនដឹងនូវភាវៈនៃលោកជាអ្នក សឹងហើយក្នុងទីនេះទេ ។

**ប្រែតាមអត្ថ** : លោកអាចារ្យ ខ្ញុំមិនដឹងថាលោកម្ចាស់សឹងកន្លែងនេះទេ ឬ លោកអាចារ្យ ខ្ញុំមិនដឹងថាលោកសឹងទីនេះទេ ។

**៣) ថេរស្ស អាគតភាវំ ជានាសិ ។**

**ប្រែតាមសព្ទ** : រីលោកតែងដឹងនូវភាពនៃព្រះថេរៈជាអ្នកមកហើយឬ ?

**ប្រែតាមអត្ថ** : លោកជ្រាបថា ព្រះថេរៈមកហើយឬ ?

**៤) សត្ថា តំ ទិស្វា តស្ស អន្តោគេហា នីហរិត្វា តត្ថ បិតរា និបន្នភាវំ ញត្វា ... ។**

**ប្រែតាមសព្ទ** : រីព្រះសាស្តា ទ្រង់ឃើញហើយនូវមដ្ឋកុណ្ឌលីនោះ ទ្រង់ជ្រាបហើយ នូវភាវៈនៃមដ្ឋកុណ្ឌលីនោះ ជាអ្នកគឺព្រាហ្មណ៍ជាបិតានាំចេញអំពីខាងក្នុង នៃផ្ទះឲ្យដេកហើយក្នុងទីនោះ ... ។

**ប្រែតាមអត្ថ** : ព្រះសាស្តាទ្រង់ទតឃើញមដ្ឋកុណ្ឌលីនោះ ហើយទ្រង់ជ្រាបថា គេត្រូវព្រាហ្មណ៍ជាបិតានាំចេញពីខាងក្នុងផ្ទះ ហើយឲ្យដេកនៅក្នុងទីនោះ ។

**៥) អថស្សា មាតាបិតរោ គព្ភស្ស បតិដ្ឋិតភាវំ ញត្វា គព្ភបរិហារំ អទំសុ ។**

**ប្រែតាមសព្ទ** : គ្រានោះ រីមាតានិងបិតាទាំងឡាយ

របស់ស្រីនោះដឹងហើយនូវភាវៈនៃគភ៌តាំងនៅស៊ប់ហើយ បានឲ្យហើយនូវថ្នាំជាគ្រឿងថែរក្សានូវគភ៌ ។

**ប្រែតាមអត្ថ** : គ្រានោះ មាតានិងបិតារបស់ស្រី នោះ ដឹងថា ស្រីនោះមានគភ៌ហើយទើបឲ្យ ថ្នាំសម្រាប់រក្សាគភ៌ ។

**គ. កិរិយាអាខ្យាត នាម**-សព្ទ : កិរិយាអាខ្យាត ដែលប្រើចូលជាបទសមាស ជាមួយនឹង **នាម**-សព្ទ មានពីរសព្ទគឺ **អត្ថិ** និង **នត្ថិ** ដូចជា **នត្ថិ** តែចូលជាបទសមាស មិនមែនជាកិរិយាអាខ្យាតទេ គឺជានិបាតសព្ទ ហើយជា **អព្យយ**-សព្ទទៀត មិនផ្លាស់ប្តូរ ទោះបីជាចូលជាមួយអ្នកណាក៏ដោយនៅតែ **អត្ថិ នត្ថិ សក្កា លព្ភា** ហៅថាចូលជា **អព្យយ**-សព្ទ ប៉ុន្តែឥឡូវគេនិយាយថាអាខ្យាត អាខ្យាតហ្នឹងជា **អស**-ធាតុ + **អ**-បច្ច័យ + **តិ** ផ្លាស់ជា **អត្ថិ** ពហុវចនៈ **សន្តិ** ដូច្នេះ **អត្ថិ នត្ថិ** នេះប្រើ ជាពហុវចនៈ ពីព្រោះក្នុងនិបាតសព្ទអត់មានវចនៈទេ ប៉ុន្តែសាច់ការប្រែច្រើន ។

**១) នាយ សញ្ញាយ អត្ថិនាមំ ជានិស្សាម ។**

**ប្រែតាមសព្ទ** : រីយើងទាំងឡាយ នឹងដឹងនូវភាវៈ នៃ

យើងទាំងឡាយមាននៅ ដោយសញ្ញានោះ ។

**ប្រែតាមអត្ថ** : ពួកយើងនឹងដឹងនូវការមាននៅ របស់ពួកយើងដោយសញ្ញានោះ ។

**២) តេនហិ ភន្តេ គច្ឆ ។ វិហារេ ភិក្ខូនំ អត្ថិភាវំ វា នត្ថិភាវំ វា ជានាហិ ។**

**ប្រែតាមសព្ទ** : ម្នាលនាយ បើដូច្នោះ រីអ្នកចូរទៅ រីអ្នកចូរដឹងនូវភាវៈនៃភិក្ខុទាំងឡាយ មាននៅឬ ឬថាមិនមាននៅក្នុងវិហារ ។

**ប្រែតាមអត្ថ** : នែអ្នក បើដូច្នោះ ចូរអ្នកទៅ ចូរដឹងថាក្នុងវិហារមានភិក្ខុឬ ឬថាមិនមានទេ ។

ឃ. **នាមសព្ទ ភាវតទ្ធិត** : ការប្រែសព្ទ ភាវតទ្ធិតដោយចំពោះ **ភា**-បច្ច័យ ឲ្យប្រព្រឹត្តទៅ ដូចជាការប្រែ **ភាវ**-សព្ទ ...

**១) សោ ថេរំ លទ្ធបិណ្ឌបាតំ អញ្ញតរំ ឱកាសំ គច្ឆន្តំ ទិស្វា និសីទិតុកាមតញ្ចស្ស ញត្វា ។**

**ប្រែតាមសព្ទ** : រីបរិព្វាជកនោះឃើញហើយ នូវព្រះ

ថេរៈ អ្នកមានបិណ្ឌបាតបានហើយ កំពុងទៅកាន់ឱកាសមួយកន្លែង ជ្រាបហើយនូវភាវៈនៃព្រះថេរៈនោះជា អ្នកប្រាថ្នាដើម្បីអង្គុយ ។

**ប្រែតាមអត្ថ** : បរិព្វាជកនោះបានឃើញព្រះថេរៈបានទទួលបិណ្ឌបាតហើយ និមន្តទៅកាន់ឱកាសមួយកន្លែង និង ដឹងថាលោកប្រាថ្នានឹងគង់ ។

២) **ឥមេ បរិព្វាជកា នាម សាសនស្ស បដិបក្ខភូតា ឥមស្ស សាសនេ គម្ភីរតំ ទស្សិស្សាមិ ។**

**ប្រែតាមសព្ទ** : ឈ្មោះថា រីបរិព្វាជកទាំងឡាយនេះជាអ្នកបដិបក្ខចំពោះ សាសនាតែងមាន រីយើងនឹងសំដែងនូវភាពជារបស់ជ្រាលជ្រៅ ក្នុងព្រះសាសនា តែងមានដល់បរិព្វាជកនេះ ។

**ប្រែតាមអត្ថ** : ធម្មតាបរិព្វាជក ទាំងនេះជាសត្រូវចំ-ពោះព្រះសាសនា យើងនឹងសំដែង ភាពជ្រាលជ្រៅក្នុងសាសនាដល់បរិព្វាជកនេះ ។

៣) **តស្សេវ ឱរកស្ស បន្ថេ ជាតត្តា បន្ថភោតិ នាមំ**

**ករិស្សុ** ។

**ប្រែតាមសព្ទ** : រីមាតានិងបិតាទាំងឡាយ បានធ្វើហើយនូវពាក្យថា រីបន្ថក: ដូច្នេះឲ្យជា ឈ្មោះនៃទារក នោះឯង ព្រោះភាវៈនៃទារកនោះជាអ្នកកើតហើយត្រង់ផ្លូវ ។

**ប្រែតាមអត្ថ** : មាតាបិតាបានតាំងឈ្មោះទារកនោះថា បន្ថក: ព្រោះជាអ្នកកើតហើយក្នុងផ្លូវ ។

៤) **កាយោ អបវិទ្ធោ អបគតវិញ្ញាណកាយ តុច្ឆោ ហុត្វា សេស្សតិ**

**ប្រែតាមសព្ទ** : រីរាងកាយដែលបុគ្គលបោះបង់ចោលហើយ ជាសភាវៈសោះសូន្យ ព្រោះ ភាវៈនៃកាយនោះជាសភាវៈមានវិញ្ញាណទៅប្រាសហើយ និងដេកស្ដូក ។

**ប្រែតាមអត្ថ** : រាងកាយដែលត្រូវគេបោះបង់ចោលហើយ នឹងជារបស់ដេកនៅទទេ ព្រោះប្រាសចាកវិញ្ញាណ ។

៥) **នន្ទោ ភន្តេ គោបាលកោ តុម្ហាកំ ឥធាគតត្តា មហាទានំ ទត្វា ។**

**ប្រែតាមសព្ទ** : បពិត្រព្រះអង្គដ៏ចម្រើន វីនាយគោបាល ឈ្មោះនន្ទឲ្យហើយនូវមហាទាន ព្រោះភាវៈនៃព្រះអង្គទ្រង់យាងមកហើយក្នុងទីនេះ ។

**ប្រែតាមអត្ថ** : បពិត្រព្រះអង្គ នាយគោបាល ឈ្មោះនន្ទ បានថ្វាយមហាទាន ព្រោះព្រះអង្គស្តេចយាងមកទីនេះ ។

**៦) សោឯវ អនុបុព្វេន បុញ្ញកម្មស្ស កតត្តា អនុបុព្វសេដ្ឋីបុត្តោ នាម ជាតោ ។**

**ប្រែតាមសព្ទ** : វីសេដ្ឋីនោះឯង ជាអ្នកឈ្មោះថា អនុបុព្វសេដ្ឋីបុត្រ កើតហើយ ព្រោះភាវៈនៃ បុញ្ញកម្ម ជាកម្មដែលសេដ្ឋីធ្វើហើយដោយលំដាប់ ។

**ប្រែតាមអត្ថ** : សេដ្ឋីនោះឯងបានឈ្មោះថា អនុបុព្វសេដ្ឋីបុត្រ ព្រោះបានធ្វើបុញ្ញកម្មទុកដោយលំដាប់ ។

**៥. ប្រយោគ** និង សព្ទពិសេស : សំនួនភាសាមគធៈ ប្រយោគខ្លះ និងសព្ទខ្លះ ប្រសិនបើប្រែតាមលក្ខណៈវេយ្យាករណ៍នឹងពាក្យមូលសព្ទ មិនបានសេចក្តីទេ កាលបើ

ប្រែដោយអត្ថ ត្រូវដកយកសេចក្តីឲ្យសមតាមរឿង ។ សូមមើលតួយ៉ាង ដូច្នេះ :

**១. សា ទសមាសច្ចយេន បុត្តំ វិជាយិ ។**

**ប្រែតាមសព្ទ** : រីភរិយានោះប្រសូតហើយនូវបុត្រដោយការដែលប្រព្រឹត្តកន្លងទៅនៃខែដប់ ។

**ប្រែតាមអត្ថ** : ភរិយានោះ កាលកន្លងទៅគ្រប់ដប់ខែហើយ ក៏បានប្រសូតបុត្រមក ។

**២. សេដ្ឋី ... តស្ស បាលោតិ នាមំ អកាសិ ។**

**ប្រែតាមសព្ទ** : រីសេដ្ឋីបានធ្វើហើយនូវពាក្យថា បាលៈដូច្នេះ... ឲ្យជាឈ្មោះ នៃបុត្រនោះ ។

**ប្រែតាមអត្ថ** : សេដ្ឋី ... បានតាំងឈ្មោះបុត្រនោះថា បាលៈ ។

**៣. អថខោ មយិ មនំ បសាទេត្វា សគ្គេ និព្វត្តានំ គណនា នាម នត្ថិ ។**

**ប្រែតាមសព្ទ** : ឈ្មោះថារីកិរិយារាប់នូវសត្វទាំងឡាយអ្នកញ៉ាំងចិត្តឲ្យជ្រះថ្លាហើយ ក្នុងតថាគតកើតហើយក្នុង

ឋានសួគ៌ តែងមិនមានដោយពិត ។

**ប្រែតាមអត្ថ** : តាមពិត សត្វដែលធ្វើចិត្តឲ្យជ្រះថ្លាចំពោះតថាគត ហើយទៅកើតក្នុងឋានសួគ៌នោះ រាប់មិនអស់ទេ ។

**៤. អតីតេ ពារាណសិយំ ពារាណសីរញ្ញោ រជ្ជំ ការេន្តេ ឯកោ ទេវិលោ នាម តាបសោ អដ្ឋ មាសេ ហិមវន្តេ វសិត្វា** ... ។

**ប្រែតាមសព្ទ** : ក្នុងកាលដែលកន្លងទៅហើយ នាកាលព្រះបាទពារាណសី សោយរាជ្យក្នុងក្រុងពារាណសី រីតាបសមួយរូបព្រះនាមថា ទេវិល នៅហើយក្នុងព្រៃហេមពាន្ត អស់ខែទាំងឡាយ ៨ ។

**ប្រែតាមអត្ថ**: ក្នុងអតីតកាល កាលដែលព្រះបាទពារាណសីសោយរាជ្យក្នុង ក្រុងពារាណសី តាបសមួយអង្គព្រះនាមទេវិល នៅហើយក្នុងព្រៃហេមពាន្តអស់ ៨ ខែ ។

**៥. តំ ខណញ្ញេវ រាជា ឧគ្គាហិ ឆារិយមានាហិ តត្ថ គន្ធា** ...

**ប្រែតាមសព្ទ** : រីព្រះរាជាស្តេចទៅហើយក្នុងទីនោះ ព្រមទាំងគប់ភ្លើងទាំងឡាយ ដែលរាជបុរសទ្រទ្រង់ទុកក្នុង

ខណៈនោះឯង ។

**ប្រែតាមអត្ថ** : ក្នុងខណៈនោះឯង ព្រះរាជាបានយាង ទៅក្នុងទីនោះ ដោយ មានរាជបុរស កាន់គប់ភ្លើងថ្វាយ ។

**៦. សោ កុដុម្ពិកបុត្តោ ឥទានិ អញ្ញំ វិជាយិនំ ឥត្ថឹ អានេត្វា មំ ទាសិភោគេន ភុញ្ជិស្សតិ ។**

**ប្រែតាមសព្ទ** : រីបុត្រនៃកុដុម្ពីក៍នោះ នឹងនាំមកហើយ នូវស្រីអ្នកប្រសូតបុត្រជាប្រក្រតីដទៃទៀត នឹងប្រើប្រាស់ នូវ យើងដោយការប្រើប្រាស់ដូចជាទាសីក្នុងកាលឥឡូវនេះ ។

**ប្រែតាមអត្ថ** : ឥឡូវនេះ បុត្រកុដុម្ពីក៍នោះនឹងនាំស្រី អ្នកប្រសូតបុត្រដទៃទៀតមក នឹងប្រើយើងដូចជាទាសី ។

**៧. តេ ភិក្ខូ អាគតាគតេហិ អង្គុលិយា ទស្សិយមានា លជ្ជាយ សីសំ ឧក្ខិបិតុំ អសក្កោន្តា** ...

**ប្រែតាមសព្ទ** : រីភិក្ខុទាំងឡាយនោះ ដែលមនុស្ស ទាំងឡាយមកហើយនឹងមកហើយ កំពុងចង្អុលដោយម្រាម ដៃ មិនអាចដើម្បីងើបឡើងនូវក្បាលព្រោះអៀនខ្មាស ។

**ប្រែតាមអត្ថ** : ពួកភិក្ខុទាំងនោះត្រូវអ្នកមកហើយ ចង្អុលដោយម្រាមដៃ មិនអាចងើបក្បាលឡើងបានព្រោះ

ការរៀនខ្មាស ។

**៨. ចុល្លកាលោ ឧដ្ឋាយ សមុដ្ឋាយ សុភារម្មណេន ពហុលោ វិហរតិ ។**

**ប្រែតាមសព្ទ** : រីព្រះចុល្លកាលក្រោកឡើងហើយ ក្រោកឡើងព្រមហើយ ជាអ្នកច្រើនដោយអារម្មណ៍ថាល្អ តែងមាន ។

**ប្រែតាមអត្ថ** : ព្រះចុល្លកាលម្តងងើបម្តងអង្គុយនៅច្របូកច្របល់នឹងអារម្មណ៍ថាស្អាត ។

**៩. អថ ភិក្ខូ ធម្មសភាយំ កថំ សមុដ្ឋាបេសុំ ។**

**ប្រែតាមសព្ទ** : គ្រានោះ រីភិក្ខុទាំងឡាយញ៉ាំងវាចាជាគ្រឿងពោលឲ្យតាំងឡើងព្រមហើយ ក្នុងសាលាជាទីពោល និងជាទីសំដែងនូវធម៌ ។

**ប្រែតាមអត្ថ** : គ្រានោះពួកភិក្ខុទើបសន្ទនាគ្នាក្នុងធម្មសភា ។

**១០. ភាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា ។**

**ប្រែតាមសព្ទ** : ម្នាលភិក្ខុទាំងឡាយ រីលោក

ទាំងឡាយជាអ្នកប្រជុំគ្នាហើយ ដោយវាចាជាគ្រឿងពោល អ្វីហ្ន៎ តែងមានក្នុងកាលឥឡូវនេះ ។

**ប្រែតាមអត្ថ** : ម្នាលពួកភិក្ខុ ឥឡូវនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ទៅ ។

**១១. ទ្វេបិ ជនា បញ្ចបញ្ចមាណវកសតបរិវារា ហោន្តិ ។**

**ប្រែតាមសព្ទ** : វីជនទាំងឡាយសូម្បីពីរនាក់ ជាអ្នកមានរយនៃមាណពប្រាំនិង ប្រាំជាបរិវារតែងមាន ។

**ប្រែតាមអត្ថ** : សូម្បីជនទាំងពីរនាក់មានមាណពជាបរិវារម្នាក់ប្រាំរយៗ ។

**១២. តេសុ ឯកេកស្ស បញ្ច បញ្ច ឧបាសកសតានិ បរិវារា ។**

**ប្រែតាមសព្ទ** : វីរយនៃឧបាសកទាំងឡាយប្រាំៗ ជាបរិវារនៃឧបាសកនោះណា ឧបាសកម្នាក់ៗ តែងមាន ។

**ប្រែតាមអត្ថ** : បណ្ដាឧបាសកទាំងឡាយ នោះ ឧបាសកម្នាក់ៗ មានឧបាសកជាបរិវារ ម្នាក់ប្រាំរយៗ ។

**១៣. ចតុរាសីតិយា បាណសហស្សានំ ធម្មាភិសមយោ ជាតោ ។**

**ប្រែតាមសព្ទ** : វីកិរិយាសម្រេចធម៌កើតហើយ ដល់ពាន់នៃសត្វទាំងឡាយ ៨៤ ។

**ប្រែតាមអត្ថ** : សត្វចំនួន ៨៤០០០ បានសម្រេចធម៌ហើយ ។

**១៤. ឋានំ ខោ បនេតំ យំ ត្វំ កុមារោ វ សមានោ កាលំ ករេយ្យ ។**

**ប្រែតាមសព្ទ** : ក៏វីព្រះអង្គជាកុមារហ្នឹងឯង រស់នៅគួរធ្វើនូវកាលៈ ឯណា វីហេតុនោះ ជាឋានៈហ្នឹងឯងតែងមាន ។

**ប្រែតាមអត្ថ** : ក៏ដែលព្រះអង្គនឹងអស់ព្រះជន្ម កាលទ្រង់នៅក្មេងនៅឡើយ ជាឋានៈគឺនឹងមាន ។

**១៥. កោកាលិកោបិ ខោ ... ជន្នុកេន ហទយមជ្ឈេ បហរិ ។**

**ប្រែតាមសព្ទ** : សូម្បីវីព្រះកោកាលិក ... ប្រហារហើយនូវភិក្ខុទេវទត្តដោយ ជង្គង់ត្រង់កណ្តាលនៃបេះដូង ។

**ប្រែតាមអត្ថ** : សូម្បីព្រះកោកាលិក ក៏បានយកជង្គង់

បុកកណ្ដាលបេះដូង ភិក្ខុទេវទត្ត ។

**១៦. តំ សុត្វា ភុម្មទេវេ អាទឹ កត្វា យាវ ព្រហ្មលោកា សព្វា ទេវតា ចេវ នាគសុបណ្ណា ច សាធុការំ អទឹសុ ។**

**ប្រែតាមសព្ទ** : រីទេវតាទាំងឡាយទាំងពួង ធ្វើនូវភូមិទេវតាទាំងឡាយឲ្យជាដើមដ៏រាបដល់ព្រហ្មលោកផងមែនពិត រីនាគនិងគ្រុឌទាំងឡាយផងស្ដាប់ហើយ នូវសាធុការនោះ បានឲ្យហើយ នូវសាធុការ ។

**ប្រែតាមអត្ថ** : ទេវតាទាំងពួងរាប់តាំងពីភូមិទេវតារហូតដល់ព្រហ្មលោក ទាំងនាគ និងគ្រុឌទាំងឡាយបានស្ដាប់សំឡេងសាធុការនោះ ហើយបានឲ្យសាធុការ ។

**១៧. ឧទេនោ ... ចម្មបសិព្វកេ ហិរញ្ញសុវណ្ណស្ស បូរេត្វា ការេណុកបិដ្ឋេ ឋបេត្វា ... ។**

**ប្រែតាមសព្ទ** : រីព្រះបាទឧទេន ... ញុំាងបាវដែលបុគ្គលធ្វើហើយដោយស្បែកទាំងឡាយ ឲ្យពេញដោយប្រាក់និងមាសឲ្យដាក់ទុកហើយលើខ្នងនៃដំរីញ្ញីឈ្មោល ។

**ប្រែតាមអត្ថ** : ព្រះបាទឧទេន .... ទ្រង់យកបាវ

ស្បែកដាក់មាសប្រាក់ឲ្យពេញ ហើយទ្រង់ដាក់លើខ្នងដំរីឈ្មោល ។

**១៨. សចស្ស សមណស្ស មយា អត្ថោ នត្ថិ នត្ថិកភាវោ វ វត្តព្វោ ។**

**ប្រែតាមសព្ទ** : ថាបើវីសេចក្តីត្រូវការដោយយើង នៃព្រះសមណៈ នេះតែងមិនមានទេនោះ វីការកើតឡើងបុគ្គលអ្នកមិនមានសេចក្តីត្រូវការនោះ ដល់ព្រះសមណៈ នេះគួរពោលថា ... ។

**ប្រែតាមអត្ថ** : ថាបើព្រះសមណៈនេះ មិនត្រូវការដោយយើងព្រះសមណៈនេះ គួរប្រាប់ថា មិនត្រូវការទេ ។

**១៩. ការ ច បន វោ អន្តរា កថា វិប្បកតា ។**

**ប្រែតាមសព្ទ** : ក៏ឯវីវាចាជាគ្រឿងពោលអ្វី គឺអ្នកទាំងឡាយ ធ្វើទុកហើយក្នុងចន្លោះ ។

**ប្រែតាមអត្ថ** : ក៏រឿងអ្វីទៅដែលពួកអ្នកសន្ទនាគ្នាឈប់កណ្តាលរឿង ។

**២០. មាតិសម្បិ នាមេតេ បញ្ញាសម្បន្នំ បុរិសាជានេយ្យំ អាលោលេន្តិ ។ អថសេសេសុ កា កថា ។**

**ប្រែតាមសព្ទ** : រីកិលេសទាំងឡាយនោះ ញុាំងបុរសអាជានេយ្យដែលដល់ព្រមហើយដោយបញ្ញា ឈ្មោះថាសូម្បីដូចជាយើងតែងឲ្យរឹករវ ។ រីវាចាជាគ្រឿងពោល ដូចម្តេចក្នុងបុគ្គលទាំងឡាយដ៏សេស ។

**ប្រែតាមអត្ថ** : កិលេសទាំងនេះ តែងធ្វើបុរសអាជានេយ្យដែលបរិបូណ៌ដោយប្រាជ្ញា ដូចជាយើងឲ្យរឹករវបាន ។ ចំពោះបុគ្គលដ៏សេសនឹងនិយាយធ្វើអ្វី ។

**២១. ចតូសុ បន ទីបេសុ ចក្កវត្តិសិរឹ ទាតុំ សមត្ថា មាតាបិតរោ នាម បុត្តានំ នត្ថិ ។ បគេ្គវ ទិព្វសម្បត្តឹ វា បឋមជ្ឈានាទិសម្បត្តឹ វា ។ លោកុត្តរសម្បត្តិទានេ កថា វ នត្ថិ ។**

**ប្រែតាមសព្ទ** : ក៏ឈ្មោះថារីមាតា និង បិតាទាំងឡាយដែលអាចដើម្បីឲ្យនូវ សិរីគឺ ការកើតឡើងនៃស្តេចចក្រពត្តិក្នុងទ្វីបទាំងឡាយ ៤ តែងមិនមានដល់បុត្រទាំងឡាយ ។ រីមាតា និងបិតា ទាំងឡាយដែលអាចដើម្បីឲ្យនូវទិព្វសម្បត្តិ

ឬថានូវ សម្បត្តិមានបឋមជ្ឈានជាដើម និងមានបាននោះឯង ។ រីវាចាជាគ្រឿងពោល ក្នុងការឲ្យនូវលោកុត្តរសម្បត្តិនោះ តែងមិនមាន ។

**ប្រែតាមអត្ថ** : ក៏បានឈ្មោះថា រីមាតាបិតាដែលនឹងអាចឲ្យសិរីគឺការកើតជាស្តេចចក្រពត្តិក្នុងទ្វីប ៤ ដល់ បុត្រ តែងមិនមាន នឹងពោលទៅថ្វីដល់អ្នកដែលអាចឲ្យនូវទិព្វសម្បត្តិ ឬ សម្បត្តិមានបឋមជ្ឈានជាដើមនោះ ចំពោះការឲ្យលោកុត្តរសម្បត្តិមិនបាច់និយាយដល់ឡើយ ។

**២២. មហល្លកស្ស ហិ អត្តនោ ហត្ថបាទាបិ អនស្សវា ហោន្តិ ន វសេ វត្តន្តិ កិមង្គំ បន ញាតកា (វសេ វត្តិស្សន្តិ) ។**

**ប្រែតាមសព្ទ** : ព្រោះថាសូម្បីរីដៃ និងជើងទាំងឡាយ របស់ខ្លួននៃមនុស្សចាស់ ជាអវយវៈមិនស្តាប់បង្គាប់តែងមាន មិនប្រព្រឹត្តទៅក្នុងអំណាច ក៏នឹងបាច់ពោលទៅថ្វី រីញាតិទាំងឡាយនឹង ប្រព្រឹត្តទៅក្នុងអំណាចនោះ ។

**ប្រែតាមអត្ថ** : ព្រោះសូម្បីតែដៃជើងរបស់ខ្លួននៃ

មនុស្សចាស់ ក៏មិនប្រព្រឹត្តទៅក្នុងអំណាច នឹងពោលទៅថ្វីដល់ ពួកញាតិនោះ ។

**៦. ការប្រែអដ្ឋកថា តែអត្ថ** : ការប្រែអដ្ឋកថានោះ ជាដំបូងឲ្យពិនិត្យមើលថា បទឬប្រយោគដែលលោក នាំមកតាំងទុកដើម្បីអធិប្បាយនោះ ជាសព្ទ ឬ សេចក្តី ឬ ការវិនិច្ឆ័យ ក៏ប្រែបែបវិនិច្ឆ័យ ឲ្យមើលតួយ៉ាង ដូចតទៅ :

១) **តត្ថ មនោតិ កាមាវចរកុសលាទិភេទំ សព្វម្បិ ចតុភូមិកចិត្តំ ។**

**ប្រែតាមអត្ថ** : បទថា "**មនោ**" ក្នុងគាថានោះបានដល់ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីទាំងអស់មាន កាមាវចរ-កុសលចិត្តជាដើមជាប្រភេទ ។

២) **បុព្វង្គមាតិ តេន បឋមគាមិនា ហុត្វា សមន្នាគតា** ... បទថា **បុព្វង្គមា** សេចក្តីថាប្រកបដោយចិត្តនោះ ដែលមានកិរិយាទៅមុនជាប្រក្រតី ។

៣) **តត្ថ អក្កោច្ឆីតិ អក្កោសិ ។ អវធីតិ បហរិ** ប្រែតាមអត្ថ បទថា **អក្កោច្ឆិ** ក្នុងគាថានោះ ប្រែថា បានជេរហើយ

បទថា **អវធិ** ប្រែថា បានប្រហារហើយ ។ វិធីប្រែអដ្ឋកថានោះ ជាទូទៅតាមដំណើរដែលប្រែតាមសព្ទ ដូចពោលមកហើយក្នុងបទមុន និងដើម្បីឲ្យសិក្ខាកាមយល់ ការប្រែតាមអត្ថឲ្យច្បាស់ ទាំងប្រែ យកសេចក្តីទូទៅនឹង អដ្ឋកថា ទើបនាំបញ្ហា និងចម្លើយជាផ្លូវការផ្នែកបាលីមកទុក ដូចតទៅ សូមយកធម្មបទភាគ ៣ បើកទៅ ទំព័រ ១៨៣ រាប់ពីក្រោមឡើងលើ បន្ទាត់ទី ៣ ខាងចុងត្រង់បាលីថា **សោបិ បុរិសោ តត្ថេវ និសិន្នោ តំ កថំ សុត្វា លទ្ធោ មេ ពលវប្បច្ចយោតិ សត្ថារំ អាហ ភន្តេ រញ្ញោ តាវ អជ្ជ រត្តិយា ទីឃតាវោ ញាតោ អហំ បន ហិយ្យោ សយមេវ យោជនស្ស ទីឃភាវំ អញ្ញាសិន្តិ ។ សត្ថា ត្វិន្នំបិ កថំ សំសន្ទេត្វា ឯកច្ចស្ស រត្តិ ទីឃា ហោតិ ឯកច្ចស្ស យោជនំ ទីឃំ ហោតិ ពាលស្ស បន សំសារោ ទីឃោតិ វត្វា ធម្មំ ទេសេន្តោ ឥមំ គាថមាហ ។**

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតន្តិ ។**

សូម្បីបុរសនោះ អង្គុយនៅត្រង់នោះ ស្តាប់សម្តីនោះ ហើយគិតថា យើងបានបច្ច័យសំខាន់ហើយ ទើបក្រាបទូល

ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះព្រះរាជា ទ្រង់ជ្រាបថា រាត្រីវែងឆ្ងាយជាងមុន ឯខ្ញុំព្រះអង្គបានដឹងថា យោជន៍វែងឆ្ងាយវិញទេ កាលពីម្សិលមិញ ។ ព្រះសាស្តាទ្រង់ប្រៀបធៀបសម្តីអ្នកទាំងពីរហើយ ទើបត្រាស់ថា រាត្រីជាវេលាវែងឆ្ងាយដល់បុគ្គលពួកខ្លះ យោជន៍ជារយៈវែងឆ្ងាយដល់បុគ្គលពួកខ្លះ ឯសង្សារជាសភាវៈវែងឆ្ងាយដល់បុគ្គលពាល កាលទ្រង់សម្តែងធម៌ ទើបទ្រង់ត្រាស់ព្រះគាថានេះថា រាត្រីយូរអង្វែងដល់អ្នកភ្ញាក់រលឹក យោជន៍វែង ដល់អ្នកនឿយហត់ សង្សារវែងឆ្ងាយដល់ជនពាលអ្នកមិនដឹងច្បាស់ នូវព្រះសទ្ធម្ម ។ **តត្ថ ទីឃាតិ រត្តិ នាមេសា តិយាមមត្តាវ ជាគរន្តស្ស បន ទីឃា ហោតិ ទ្វិគុណតិគុណា វិយ ហុត្វា ខាយតិ តស្សា ទីឃភាវំ អត្តានំ មំកុណសង្ឃស្ស ភត្តំ កត្វា យាវ សុរិយុគ្គមនា សម្បរិវត្តកំ សេមានោ មហាកុសិតោបិ សុភោជនំ ភុញ្ជិត្វា សិរីសយនេ សយមានោ កាមភោគីបិ ន ជានាតិ សព្វរត្តឹ បន បធានំ បទហន្តោ យោគាវចរោ ច ធម្មកថំ កថេន្តោ ធម្មកថិកោ ច អាសនសមីបេ និសីទិត្វា ធម្មំ សុណន្តោ ច សីសរោគាទីហិ ផុដ្ឋោ វា ហត្ថបា-**

**ទច្ឆេទាទិនិ បត្តោ វា វេទនាភិភូតោ ច រត្តឹ មគ្គបដិបន្នោ អទ្ធិកោ ច ជានាតិ ។ យោជនន្តិ យោជនម្បិ ចតុគាវុតមត្តមេវ សន្តស្ស បន កិលន្តស្ស ទីឃំ ហោតិ ទ្វិគុណំ តិគុណំ វិយ ខាយតិ ។ សកលទិវសំ ហិ មគ្គំ គន្ត្វា កិលន្តោ បដិបថំ អាគច្ឆន្តំ ទិស្វា បុរតោ គាមោ កីវទូរោតិ បុច្ឆិត្វា យោជនន្តិ វុត្តេ ថោកំ គន្ត្វា អបរម្បិ បុច្ឆិត្វា តេនាបិ យោជនន្តិ វុត្តេ បុន ថោកំ គន្ត្វា អបរម្បិ បុច្ឆតិ សោបិ យោជនន្តិ វទតិ តេ បុច្ឆិតបុច្ឆិតា យោជនន្តិ វទន្តិ ទីឃំ វតិទំ យោជនន្តិ ឯកំ យោជនំ ទ្វេ តីណិ យោជនានិ វិយ មញ្ញតិ ។ ពាលានន្តិ ឥធលោកបរលោកត្ថំ បន អជានន្តានំ ពាលានំ សំសារវដ្តស្ស បរិយន្តំ កាតុំ អសក្កោន្តានំ យំ សត្តតឹសពោធិបក្ខិកាទិភេទំ សទ្ធម្មំ ញត្វា សំសារស្ស អន្តំ ករោន្តិ តំ សទ្ធម្មំ អវិជានតំ សំសារោ ទីឃោ នាម ហោតិ ។ សោ ហិ អត្តនោ ធម្មតាយ ឯវ ទីឃោ នាម ។ វុត្តម្បិចេតំ អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតីតិ ពាលានំ បន បរិយន្តំ កាតុំ អសក្កោន្តានំ អតិទីឃោយេវាតិ ។** បណ្តាបទទាំងនោះ បទថា **ទីឃា** ជាដើមសេចក្តីថា ធម្មតារាត្រីនេះមានត្រឹមតែបីយាម ប៉ុណ្ណោះ

ចំណែកបុគ្គលអ្នកដេកមិនលក់ រាត្រីជាពេលវេលាយូរអង្វែង គឺប្រាកដដូចជាពីរដង បីដងអ្នកជា **មហាភុសិតោ** គឺអ្នកខ្ជិលច្រើនដែលដេកបម្រះននៀលទៅមកៗ ធ្វើខ្លួនឲ្យជាចំណីរបស់ពួកសង្អើចតាំងពីព្រលប់ដល់ថ្ងៃរះក្តី អ្នកដែលល្មោភបរិភោគកាម បរិភោគភោជនយ៉ាងឆ្ងាញ់ ហើយដេកលើគ្រែដ៏មានសិរីក្តី តែងមិនដឹងថារាត្រីនោះវែងឆ្ងាយឡើយ ចំណែកព្រះយោគាវចរ ដែលតាំងសេចក្តីព្យាយាមយ៉ាងម៉ឺងម៉ាត់តាំងពីព្រលប់ដល់ថ្ងៃរះក្តី ព្រះធម្មកថិកសម្តែងធម្មីកថាតាំងពីព្រលប់ដល់ថ្ងៃរះក្តី អ្នកដែលអង្គុយស្តាប់ធម៌នៅជិតធម្មាសនៈ តាំងពីព្រលប់ដល់ព្រលឹមក្តី អ្នកដែលត្រូវវេទនាគ្របសង្កត់ គឺអ្នកដែលត្រូវរោគ មានរោគឈឺក្បាលជាដើមប៉ះពាល់ហើយ ឬអ្នកត្រូវគេកាត់ដៃនិងជើងជាដើមក្តី ឈ្មោះថាជាអ្នកត្រូវវេទនាគ្របសង្កត់ក្តី អ្នកដើរផ្លូវឆ្ងាយ ធ្វើដំណើរពេញមួយយប់ក្តី តែងដឹងថារាត្រីនោះ ជាវេលាវែងឆ្ងាយ ។ បទថា យោជន៍ ជាដើម សេចក្តីថា ទោះបីយោជន៍ ក៏មានត្រឹមតែបួនគាវុតប៉ុណ្ណោះ សម្រាប់អ្នកនឿយហត់ គឺ អ្នកអស់

កម្លាំង ហើយថាជារយៈវែងឆ្ងាយ គឺប្រាកដដូចជា ពីរដង ឬ បីដង ។ មែនពិត អ្នកធ្វើ ដំណើរអស់មួយថ្ងៃ នឿយហត់ ហើយ ឃើញអ្នកធ្វើដំណើរដើរមកផ្លូវជួបគ្នាក៏សួរថា ភូមិ ខាងមុខចំងាយប៉ុណ្ណាទៅ ? កាលបើគេប្រាប់ថាចំងាយមួយ យោជន៍ ក៏ដើរទៅបានបន្តិចសួរអ្នកផ្សេងទៀត ទោះជា អ្នក ដែលត្រូវសួរនោះប្រាប់ថានៅមួយយោជន៍ទៀត អ្នក ដើរដែលត្រូវសួរគេហើយទាំងនោះ ម្នាក់ៗ ក៏ប្រាប់ថាមួយ យោជន៍ៗ អ្នកដែលនឿយហត់ហើយនោះ គិតថា យោជន៍ នេះវែងឆ្ងាយមែន តែងសំគាល់ យោជន៍មួយដូចជាពីរ ឬបី យោជន៍ដូច្នោះ ។ បទថា **ពាលានំ** ជាដើមសេចក្ដីថា ពួក បុគ្គលពាលអ្នកមិនស្គាល់ប្រយោជន៍ ក្នុងលោកនេះ និង ប្រយោជន៍ក្នុងបរលោក គឺអ្នកមិនអាចធ្វើទីបំផុតនៃសង្សារវដ្ដ បានឈ្មោះថា អ្នកមិនស្គាល់ព្រះសទ្ធម្ម ដែលផ្សេងដោយធម៌ មានពោធិបក្ខិយធម៌ ៣៧ ប្រការជាដើម ដែលព្រះអរិយៈ ជាម្ចាស់ទាំងឡាយដឹងហើយ ធ្វើទីបំផុតនៃសង្សារបាន ។ សង្សារឈ្មោះថាជាសភាពវែងឆ្ងាយ ។ ពិតមែនសង្សារនោះ

ឈ្មោះថាវែងឆ្ងាយតាមធម្មតារបស់ខ្លួនឯង សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើម គ្មាននរណាទៅតាមដឹងបានទេ ទីបំផុតដែលជាខាងដើមតែងមិនប្រាកដដូច្នេះ ។ តែសម្រាប់ ពួកជនពាលរឹងរឹតតែមិនអាចធ្វើទីបំផុតនៃសង្សារបាន ជាសភាពវែងឆ្ងាយខ្លាំងណាស់ទៅទៀត ។

សូមនិមន្តយកធម្មបទភាគ ១ រឿងចុល្លកាលមហាកាល ត្រង់គាថា **បសហតីតិ អភិភវតិ អជ្ឈោត្ថរតិ ។ វាតោ រុក្ខំវ ទុព្វលន្តិ ពលវវាតោ ឆិន្នតដេ ជាតំ ទុព្វលរុក្ខំ វិយ យថា ហិ សោ វាតោ តស្ស រុក្ខស្ស បុប្ផផលាទីនិបិ បាតេតិ ខុទ្ទកសាខាបិ ភញ្ជតិ សម្ភូលំបិ តំ រុក្ខំ ឧព្វត្តេត្វា ឧទ្ធំមូលំ អធោសាខំ កត្វា គច្ឆតិ ឯវមេវ ឯវរូបំ បុគ្គលំ អន្តោឧប្បន្នោ កិលេសមារោ បសហតិ ពលវវាតោ ទុព្វលរុក្ខស្ស បុប្ផផលបណ្ណបលាសាទិបាតនំ វិយ ខុទ្ទានុខុទ្ទកាបត្តិអាបជ្ជនំបិ ករោតិ ខុទ្ទកសាខាភញ្ជនំ វិយ និស្សគ្គិយាទិអាបត្តិ-**

អាបជ្ជនំបិ ករោតិ មហាសាខាភញ្ជនំ វិយ តេរសសង្ឃាទិសេសាបជ្ជនំបិ ករោតិ ឧប្បាដេត្វា ឧទ្ធំមូលំ ហេដ្ឋា សាខំ កត្វា បាតនំ វិយ បារាជិកាបត្តិអាបជ្ជនំបិ ករោតិ ស្វាក្ខាតសាសនា នីហរិត្វា កតិបាហេនេវ គិហិភាវំ បាបេតិ ឯវរូបំ បុគ្គលំ កិលេសមារោ អត្តនោ វសេ វត្តេតីតិ អត្ថោ ។ អសុភានុបស្សិន្តិ ទសសុ អសុភេសុ អញ្ញតរំ អសុភំ បស្សន្តំ បដិកូលមនសិការេ យុត្តំ កេសេ អសុភតោ បស្សន្តំ លោមេ នខេ ទន្តេ តចំ វណ្ណំ សណ្ឋានំ អសុភតោ បស្សន្តំ ។ ឥន្ទ្រិយេសូតិ ឆសុ ឥន្ទ្រិយេសុ ។ សុសំវុតន្តិ និមិត្តគ្គាហាទិវិរហិតំ បិហិតទ្វារំ ។ អមត្តញ្ញុតាបដិបក្ខេន ភោជនម្ហិ ច មត្តញ្ញុំ ។ សទ្ធន្តិ កម្មស្ស ច ឯវ ផលស្ស ច សទ្ទហនលក្ខណាយ លោកិយសទ្ធាយ ចេវ តីសុ វត្ថូសុ អវេច្ចប្បសាទសង្ខាតាយ លោកុត្តរសទ្ធាយ ច សមន្នាគតំ ។ បគ្គហិតវីរិយំ បរិបុណ្ណវីរិយំ ។ តំ វេតិ តំ ឯវរូបំ បុគ្គលំ ។ យថា ទុព្វលវាតោ សណិកំ បហរន្តោ ឯកឃនំ សេលំ ចាលេតុំ ន សក្កោតិ តថា អព្ភន្តរេ ឧប្បជ្ជមានោបិ ទុព្វលកិលេសមារោ នប្បសហតិ ខោភេតុំ កម្បេតុំ ចាលេតុំ ន សក្កោតីតិ អត្ថោ ។ បទថា **បសហតិ** សេចក្ដីថា គ្របសង្កត់ គឺញាំញី បាទព្រះគាថាថា

**ဝါတော ရုက္ခံဝ ဒုဗ္ဗလံ** សេចក្តីថា ដូចខ្យល់ដ៏មានកម្លាំងខ្លាំង ប្រហារដើមឈើដែលមានកម្លាំងទន់ខ្សោយ ដែលដុះហើយជិតមាត់ជ្រោះ អធិប្បាយថា បីដូចជាខ្យល់នោះៗ គឺខ្យល់មានកម្លាំងខ្លាំង ញ៉ាំផ្កា ផ្លែ និងស្លឹកជាដើមនៃឈើនោះឲ្យរលើងឡើង ហើយឲ្យរលំចុះខ្លះ កាច់បំបាក់មែកតូចៗ ខ្លះបំបាក់មែកធំៗខ្លះ ញ៉ាំងឈើនោះព្រមទាំងឫសឲ្យរលើងឡើង ហើយឲ្យមានឫសឡើងលើ ឲ្យមានមែកចុះក្រោម ហើយរលំទៅខ្លះ យ៉ាងណាមិញ កិលេសមារដែលកើតឡើងក្នុង សន្តានខាងក្នុងនៃបុគ្គលនោះក៏ដូចគ្នាដែរ គឺធ្វើឲ្យត្រូវអាបត្តិតូច ដូចខ្យល់ដែលមានកម្លាំងខ្លាំង ញ៉ាំងផ្កា ផ្លែ និងស្លឹក ជាដើមនៃឈើដែលមានកម្លាំងខ្សោយឲ្យជ្រុះចុះខ្លះធ្វើឲ្យ ត្រូវអាបត្តិនិស្សគ្គីយជាដើម ដូចជាខ្យល់មានកម្លាំងខ្លាំង ញ៉ាំងឈើតូចៗ ឲ្យបាក់ទៅខ្លះ ធ្វើឲ្យត្រូវអាបត្តិសង្ឃាទិសេស ១៣ ដូច ជាខ្យល់មានកម្លាំងខ្លាំង ញ៉ាំងឈើធំៗ ឲ្យរលំទៅខ្លះ ធ្វើឲ្យត្រូវអាបត្តិបារាជិកនាំភិក្ខុនោះចេញចាកព្រះសាសនា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកល្អហើយ

ធ្វើឲ្យដល់នូវភាពជាគ្រហស្ថដោយថ្ងៃពីរបីប៉ុណ្ណោះ ដូចជាខ្យល់ដ៏មានកម្លាំងញ៉ាំងដើមឈើនោះឲ្យរលើងឡើងហើយឲ្យមានឫសទៅខាងលើ ឲ្យមានមែកទៅខាងក្រោម ហើយរលំទៅខ្លះ កិលេសមារញ៉ាំងបុគ្គលដែលឃើញយ៉ាង នោះឲ្យប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួនដូច្នេះ ។ បទថា **អសុភានុបស្សឹ** អ្នកឃើញអារម្មណ៍ថាមិនល្អ យ៉ាងណាមួយ បណ្ដាអារម្មណ៍មិនល្អ ១០ យ៉ាងគឺប្រកបក្នុងការធ្វើទុកក្នុងចិត្ត ដោយភាពជារបស់គួរខ្ពើម បានដល់ឃើញសក់ដោយសភាពថា ជារបស់មិនស្អាត ជាដើម ក្រចក ធ្មេញ ស្បែក ពណ៌សម្បុរ រាងរៅ ដោយភាពថាជារបស់មិនល្អ ។ បទថា **ឥន្ទ្រិយេសុ** បានដល់ក្នុងឥន្ទ្រិយ ៦ ។ បទថា **សុសំវុតំ** បានដល់អ្នកវៀរចាក ការកាន់យកដោយនិមិត្តជាដើមគឺ មានទ្វារបិទហើយ និងស្គាល់ប្រមាណ ក្នុងភោជន៍ ដោយផ្ទុយពីភាពជាអ្នកមិនស្គាល់ប្រមាណ ។ បទថា **សទ្ធំ** សេចក្ដីថា អ្នកប្រកបដោយ **លោកិយសទ្ធា** មានការជឿកម្ម និងផលរបស់កម្មជាលក្ខណៈ និងដោយលោកុត្តរសទ្ធាពោលគឺ សេចក្ដីជ្រះថ្លាមិន

កម្រើកក្នុងព្រះរតនត្រៃ ។ បទថា **អារទ្ធវីរិយំ** បានដល់អ្នកមានសេចក្ដីព្យាយាម គឺអ្នកមានសេចក្ដីព្យាយាមពេញទី ។ បទថា **តំ វេ** បានដល់បុគ្គលនោះ គឺបុគ្គលអ្នកឃើញយ៉ាងដូច្នោះ ។ អធិប្បាយថា ខ្យល់មានកម្លាំងខ្សោយបក់តិចៗ តែងមិនអាច នឹងញុំាងភ្នំថ្មតាន់ដ៏ធំមាំឲ្យរង្គោះរង្គើ បានយ៉ាងណា កិលេសមារដែលមានកម្លាំងខ្សោយ ទោះបីកើតឡើងក្នុងខាងក្នុង តែងរារាំងបុគ្គលនោះមិនបាន គឺមិនអាចធ្វើបុគ្គលនោះ ឲ្យញាប់ញ័ររង្គោះរង្គើបាន ដូច្នោះឯង ។ សូមសិក្ខាកាម កុលបុត្រទាំងឡាយ ដែលមានប្រាថ្នាដើម្បីរៀនប្រែយកសេចក្ដីបានល្អ សូមពិនិត្យតាមសៀវភៅអនុមោទនវិធី ជាដើម ឧទាហរណ៍ដូចជា **ភវតុ សព្វមង្គលំ** តើប្រែលោតប្រយោគរបៀបណា បទប្រធាននៅឯណា លោកប្រែរៀងសេចក្ដីបែបយ៉ាងម៉េច ឬក៏ **សព្វីតិយោ វិវជ្ជន្តុ សព្វរោគោ វិនស្សតុ** យកមករៀនប្រែលោតប្រយោគ ហើយសម្ពន្ធសាកមើល ទើបមើលសេចក្ដីថា តើលោកអ្នកប្រាជ្ញជាន់ចាស់នោះ លោកប្រែយកសេចក្ដីដោយកាច់ កម្មវាចកៈ

ហេតុកម្មវាចកៈ ទៅជាកត្តុវាចកៈ ហេតុកត្តុវាចកៈ ជាដើម ព្រមទាំងពាក្យអាយតនិបាតខ្លះ ក៏លោកបំបាត់ចោលដើម្បីសម្រួលសេចក្តីឲ្យខ្មែរស្តាប់បាន ។ ពុំនោះសោតព្រះអង្គអាចពិនិត្យ មើលនូវធម៌សូត្រផ្សេងៗដូចជា **យថាបច្ចយំ បវត្តមានំ ឆាតុមត្តមេវេតំ យនិទំ, សព្វោ បនាយំ** ... ប្រែលោតប្រយោគហើយយើងដឹងថា លោករៀបសេចក្តីរួចស្រេច តើប្រយោគដើមដូចម្តេច ជាមួយនឹងសេចក្តីនោះ យើងអាចយកជាមេរៀនបាន ឬក៏ប្រែរឿងរ៉ាវ ខ្លះក្នុងព្រះត្រៃបិដកខាងព្រះសូត្រ គឺយើងពិនិត្យមើល រឿងរ៉ាវតាមបាលីផង ប្រែជាសេចក្តីនេះផង អាចនឹងចេះបាន ។

ការប្រែរៀបរៀងសេចក្តី ខ្ញុំព្រះករុណាបានទុកដាក់តែប៉ុណ្ណេះ សូមព្រះអង្គ រៀបរៀងសេចក្តីតាមសៀវភៅនានាដែលអ្នកប្រាជ្ញបុរាណ បានរៀបចំទុកហើយ ស្រេចនោះសិក្ខាកាមកុលបុត្រទាំងអស់ សូមបានសម្រេចនូវប្រាជ្ញាចេះពិចារណា ប្រែភាសាបាលីដោយអង្គឯង សូមបានសម្រេចនូវព្រះនិព្វាន នៅអវសានជាតិ កុំបីឃ្លៀងឃ្លាតឡើយហោង ។

ការរៀបរៀងបែបរៀនប្រែភាសាបាលីមកជាខ្មែរប្រែតាមសព្ទ និងប្រែយកសេចក្តី សន្មតថាចប់តែប៉ុណ្ណោះ ឯង ។ សូមអភ័យទោស អំពីលោកអ្នកប្រាជ្ញទាំងឡាយ បើឃើញមានកំហុសខុសឆ្គងកន្លែងណា សូមមេត្តាជួយកែតម្រូវដើម្បីទុកជាបទពិសោធន៍ យ៉ាងត្រឹមត្រូវសម្រាប់កុលបុត្រ ជាសិក្ខាកាមទាំងឡាយ សិក្សារៀនសូត្របាន វែងឆ្ងាយតទៅ ។

ខ្ញុំសូមផ្សព្វផ្សាយនូវចំណេះវិជ្ជាទាំងនេះ ទុកជាធម្មទាន ដើម្បីឲ្យបានប្រយោជន៍ទូលំទូលាយ ឥតមានរក្សាសិទ្ធិទុកទេ ដូច្នេះសូមសប្បុរសទាំងអស់ទទួលអនុមោទនាយកបុណ្យធម្មទានរបស់ខ្ញុំ ដែលបានកសាង ទាំងប៉ុន្មាននេះឲ្យបានរួចចាកទុក្ខដល់នូវព្រះនិព្វានគ្រប់ព្រះអង្គគ្រប់គ្នាទៅហោង ៕

# ចប់បែបរៀនភាសាបាលី

# ភាគទី ៥